សៀវភៅនេះជាការវាយបញ្ចូលរបស់ខ្ញុំបាទ ថៃ ប៊ុនឆាយ សម្រាប់ជាធម្មទានៗ

# អច្ឆរិយបុគ្គល



# **វាចាខ្ញុំអ្នកវាយអត្ថបទ**

ខ្ញុំព្រះករុណាខ្ញុំបាទសូមថ្វាយបង្គំព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងខ្ពង់ខ្ពស់បំផុតលើលោក និងបងប្អូនមិត្តភ័ក្តិទាំងអស់ ដោយហេតុចង់ចេះដឹងរឿងចិត្តវិទ្យាខ្លាំងពេក ក៏ចិត្តនោះបញ្ជាឲ្យមានកម្លាំងខ្លាំង នឹងមានព្យាយាម អត់ធន់ក្នុងវាយបញ្ចូលក្នុងកុំព្យូទ័រដើម្បីជាធម្មទាន និងដើម្បីងាយស្រួលក្នុងអានផងដែរ។

ដោយអំណាចនៃបុណ្យកុសលនេះ ក៏សូមឧទិសបុណ្យកុសលទាំងអស់ជូនដល់អ្នកនិពន្ធសៀវភៅ **អ.ធីរាវុធ** សូមឲ្យលោកបានរួចផុតចាកទុក្ខទាំងពួង និងបាននូវព្រះនិព្វានជាទីបំផុតទុក្ខ។ និងសូមឧទិសបុណ្យដល់អ្នកមានគុណទាំងពីរ ឪពុក **ថៃ គឹមឈាត** និង មាតា **ផាត់ ឡេង** និងបងប្អូន មិត្តភ័ក្តិទាំងអស់ទទួលនៅបុណ្យកុសលដែលជាធម្មទានេះគ្រប់គ្នា សូមអនុមោទនាបុណ្យ។

ពីខ្ញុំបាទ **ថៃ ប៊ុនឆាយ**

ភ្នំពេញថ្ងៃ ទី ១៥ ខែ កុម្ភៈ គ.ស ២០១៣។

†††

# បទទី១

# មនុស្ស និង សមិទ្ធិ

## ១) សេចក្តីសម្រេចរបស់មនុស្សនៅទីណា?

ក្នុងយុគបច្ចុប្បន្ននេះ មនុស្សគ្រប់រូបនាំគ្នាយកចិត្តទុកដាក់តែក្នុងការសម្រេចផលផ្សេងៗដែលឧប្បត្តិការណ៍ឡើងនឹងមនុស្សទូទៅ។ ក្នុងទស្សនៈផ្លូវហោរាសាស្ត្រ មនុស្សពួកនេះមានការចូលចិត្តថាសេចក្តីចំរើនរុងរឿង និង សេចក្តីវិនាសទ្រុឌទ្រោមរបស់មនុស្សនីមួយៗរហូតដល់វាសនារបស់ប្រទេសផង តែងតែនៅក្រោមអំណាច អាណាចក្រនៃដួងតារា ឬ ក៏ព្រហ្មលិខិត។ ជីវិតរបស់មនុស្សនឹងខ្ពស់ឬទាប ល្អ ឬអាក្រក់ លិច ឬអណ្តែត ចំរើនឬអន់ថយក៏ស្រេចតែអាណត្តិនៃព្រហ្មលិខិត ឬ ជោគជាតានឹងកំណត់ផ្លូវអោយ។ ជោគជាតារបស់មនុស្សរមែងឋិតនៅលើស្នាមនៃបាត ដៃ ឬ ដួង។ កាលណាដួងមិនល្អស្នាម លើបាតដៃក៏មិនល្អ។ មនុស្សនោះនឹងល្អទៅមិនបានជាដាច់ខាត។ នេះជាទស្សនៈរបស់ពួកហោរាសាស្ត្រដែលតែងតែយល់ថា ក្រោមមេឃលើដីនេះគ្រប់យ៉ាងតែងឋិតនៅក្រោមអាណត្តិនៃព្រហ្មលិខិត គឺព្រហ្មលិខិតបានកំណត់វិថីជីវិតរបស់មនុស្ស និងពិភពលោក ស្រេចសព្វគ្រប់ទាំងអស់។ តាមការពិតទ្រឹស្តីរបស់ហោរាសាស្ត្រនឹងមានការពិតយ៉ាងណា-បែបណា-ត្រឹមណា-ក៏ដោយតែបើយើងពិនិត្យពិចារណាមើលអោយត្រឹមត្រូវហើយ ក៏នឹងរកការពិតមិនបានពិសោធន៍មិនឃើញ។ ហេតុដូចម្តេចជីវិតមនុស្សយើង ទើបធ្លាក់នូវក្រោមអាណត្តិនៃព្រហ្មលិខិត។ ហើយក៏ព្រហ្មលិខិតនៃជីវិតនោះ តើនៅឯណា? មានកំលាំង និង ឥទ្ធិពលយ៉ាងណា? ដែលអាចបណ្តាលជីវិតមនុស្សអោយមានការប្រែប្រួលផ្លាស់ប្តូរទៅបានផ្សេងៗដូច្នោះ។

ចំណែកទស្សនៈនៃចិត្តវិទ្យាវិញនោះ។ អ្នកប្រាជ្ញចិត្តវិទ្យា បានមូលមតិយល់ស្របគ្នាថាអាណាចក្រនៃពិភពលោក។

គ្មានឥទ្ធិពលយ៉ាងណាទេ ដែលអាចនឹងបណ្តាលអោយជីវិតមនុស្សប្រែប្រួលផ្លាស់ប្តូរទៅបានទោះបីក្នុងផ្លូវល្អ ឬអាក្រក់យ៉ាងណាក៏ដោយ។ ការប្រែប្រួលផ្លាស់ប្តូរ របស់មនុស្សលោកនេះទោះបីសេចក្តីប្រែប្រួលនោះ នឹងប្រព្រឹត្តទៅក្នុងធម៌ ឬ នាមធម៌ក៏ដោយ។ សេចក្តីប្រែប្រួលតែងតែឧប្បត្តិការណ៍ឡើង ដោយអាណាចក្រនៃកម្លាំង សេចក្តីគិតនេះមួយដោយអាណាចក្រនៃធម្មជាតិនេះមួយ។ មានសច្ចៈសូត្រមួយពោលទុកថា ក្រោមដួងព្រះអាទិត្យនេះ មិនមានអ្វីដែលមិនប្រែប្រួលទេ (កលវិធីរំដោះទុក្ខដោយ អ.ធីរាវុធ) ប្រាកដការណ៍នៃ

ការផ្លាស់ប្តូរត្រូវប្រព្រឹត្តទៅតាមធម្មជាតិជានិច្ច។ ខ្ញុំបាទបានកំណត់សំដៅយកវត្ថុគ្រប់យ៉ាងដែលត្រូវតែមានការប្រែប្រួលទៅតាមសភាពលក្ខណ៍ធម្មជាតិ។ ដូចសេចក្តីប្រែប្រួលរបស់សង្ខាររាងកាយ សេចក្តីរលត់បាត់ទៅនៃជីវិត សេចក្តីអន់ថយ សេចក្តីចំរើន សេចក្តីវិនាស ។ល។ វត្ថុទាំងនោះធម្មជាតិ ទេតើដែលទ្រទ្រង់នូវឥទ្ធិពល ធម្មជាតិទេតើ ដែលអាចបណ្តាលអោយមនុស្ស និង សត្វរួមទាំងព្រឹក្សាជាតិនានា ប្រព្រឹត្តទៅតាមសភាពរបស់វា។ ទាំងនេះបានសេចក្តីថា យើងនឹងទទឹងរឹងរូសនូវធម្មជាតមិនបានជាដាច់ខាត។ ដូចសេចក្តីចាស់ជរាសេចក្តីស្លាប់ជាដើមយើងនឹងរឹងទទឹងមិនព្រមចាស់ជរាមិនព្រមស្លាប់យ៉ាងម្តេចបាន។ វាតែងតែប្រព្រឹត្តទៅតាមលក្ខណៈនៃធម្មជាតិ។ ម្យ៉ាងទៀតគឺ "អាណាចក្រនៃសេចក្តីគិត" ។ ពាក្យថា អាណាចក្រនៃសេចក្តីគិតនេះ ខ្ញុំបាទសំដៅយកសេចក្តីគិតរបស់មនុស្សនានាទាំងដែលជាប្រយោជន៍ដល់លោកទាំងដែលជាទោសដល់ពួកមនុស្ស។

សេចក្តីគិតដែលជាប្រយោជន៍ គឺបានដល់សេចក្តគិតរបស់អ្នកប្រាជ្ញ អ្នកបញ្ញាវន្ត អ្នកនយោបាយ អ្នកសាសនា អ្នកនិពន្ធ អ្នកប្រិតស្ន ។ល។ ជាគំនិតផ្នែកកុសលកម្មឬសេចក្តីគិតរបស់អច្ឆរិយៈ ក្នុងផ្លូវបណ្តុះបណ្តាលជាគុណប្រយោជន៍ដ៏សំខាន់។ ចំណែកសេចក្តីគិតដល់ជាទោស គឺការក្បត់ ការចលាចល ការបោះបោរ ការរដ្ឋប្រហារ ការបដិវត្តន៍ ការសង្គ្រាម ការទំលាយ ការកាប់សម្លាប់គ្នា កាជិះជាន់ទារុណកម្ម ជាគំនិតផ្នែកអកុសលកម្មឬសេចក្តីគិតរបស់អច្ឆរិយៈក្នុងផ្លូវអំលាយ ជាសេចក្តីគិតដែលជាទោស។ អាណាចក្រនៃសេចក្តីគិតទាំងពីរប្រការនេះ អាចបណ្តាលអោយស្រុកប្រទេសតូចធំក្តៅក្រហាយ ឬ ត្រជាក់ត្រជុំរមនា ក៏ស្រេចតែសភាពរបស់សេចក្តីគិតដូចពោលមកនេះ។

សេចក្តីគិតរបស់មនុស្ស ជាផ្នែកមួយនៃបញ្ហាផ្លូវចិត្តវិទ្យា (Psychology) ។ ចំណែកចិត្តវិទ្យានោះ ខ្ញុំបាទបាន កំណត់សំដៅយកចិត្តវិទ្យា ដែលបានកំណត់ផែនការទុកជាមុន ឬ ចិត្តវិទ្យារបៀបថ្មីនោះឯង។ មុនដែលយើងនឹងត្រូវ ដឹងដល់គោលចិត្តវិទ្យារបៀបថ្មីនោះ។ យើងគួរតែដឹងដល់ ចិត្តវិទ្យាក្នុងយុគអាណាចក្រនៃធម្មជាតិជាមុនសិន។ មានសេចក្តីពិតម្យ៉ាងគឺ "អច្ឆរិយៈ" "អច្ឆរិយៈ" រមែងមិនបានសំដៅយកពាក្យថា "ធម្មជាតិ" ទេ ។ ធម្មជាតិ ក៏មិនអាចបណ្តុះបណ្តាលស្និតស្នាងអោយនរណាជា "អច្ឆរិយៈ" ឡើងមកបានឯងៗនោះឡើយ។ តែធម្មជាតិតែងតែគាំទ្រ ឬ ទ្រទ្រង់នូវ ភាពជាអច្ឆរិយៈបានខ្លះ ដូចមនុស្សមានអវៈយវៈពិការគឺ ៖ ខ្វាក់ ខ្វិន គ ។ល។ មកពីកំណើត។ ធម្មជាតិក៏បានទ្រទ្រង់ ឬ គាំទ្របំពេញតម្លៃព្រលឹងអោយ ឬ ដូចបណ្តាលអោយមានដួងអាទិត្យ ដួងតារា ដួងច័ន្ទ បណ្តាលអោយមានសេចក្តីក្តៅ សេចក្តីត្រជាក់បណ្តាលអោយមានសេចក្តីគិត សេចក្តីសង្កេត មានសេចក្តីចាំ មានសេចក្តីក្រោធ។ ព្រមទាំងបណ្តាល អោយមនុស្សបានប្រើសតិបញ្ញាការពារខ្លួនឯង។

ក្រៅអំពីនេះ ធម្មជាតិក៏បានប្រសិទ្ធិប្រសាទអោយមនុស្សមានសញ្ញាតិញ្ញាណ នៃសេចក្តីស្រវាស្រទេញសញ្ញាតិញ្ញាណនៃសេចក្តីមេត្តា សញ្ញាតិញ្ញាណនៃសេចក្តីតស៊ូ សញ្ញាតិញ្ញាណនៃការសន្សំរួបរួម សញ្ញាតិញ្ញាណនៃកាមារណ៍ សញ្ញាតិញ្ញាណនៃសេចក្តីក្លាហ៊ាន នេះគឺធម្មជាតិបានស្និតស្នាង បណ្តុះផ្សាំមកអោយមនុស្សតែគ្រប់ៗ រូបដូចៗគ្នា

អាណាចក្រនៃចិត្តវិទ្យានេះហើយ ដែលធម្មជាតិបានស្និតស្នាងហុចឲ្យមនុស្សគ្រប់រូប។ ទោះបីមនុស្សនោះជាស្មូម យាចក វនិព្វក ឬ ចក្រពត្រាមហារាជអ្វីក៏ដោយ។ ធម្មជាតិបានសាងមនុស្សអោយមាន "អាណាចក្រនៃចិត្តគំនិត" ដូចគ្នាទាំងអស់ដោយមិនរើសមុខ។ កាលបើយើងដឹង នៅសភាពធម្មតារបស់មនុស្សតាមគោលការនៃធម្មជាតិ ដូច្នេះហើយ ពាក្យថា "អច្ឆរិយៈ" ដោយធម្មជាតិក៏រមែងមិនមាន។ អច្ឆរិយៈនឹងកើតឡើងមកបាន ក៏ដោយប្រាកដការណ៍នៃវត្ថុព័ទ្ធឡោម។ ហើយក៏តោងមានគោលដៅសម្រាប់បណ្តុះផ្សាំសាងវាឲ្យកើតមានឡើង។ វត្ថុដែលយើងបណ្តុះផ្សាំសាងឲ្យកើតមានឡើងនោះក៏គឺ "ចិត្តវិទ្យារបៀបថ្មី" នោះឯង។ ចិត្តវិទ្យារបៀបថ្មីនោះ គឺចិត្តវិទ្យាកំណត់សំដៅយកសេចក្តីត្រូវការ សេចក្តីសង្កេត សេចក្តីចាំ សេចក្តីខ្នះខ្នែង សេចក្តីស្រវាស្រទេញ សេចក្តីក្លាហ៊ាន សេចក្តីស្មោះត្រង់ មនោភាព សមាធិ ចិត្តានុភាព នោះឯង ឬ មិនដូច្នោះទេ "ចិត្តគំនិតនៃភាពជាអច្ឆរិយៈ" អាចនឹងកើតឡើងដោយហេតុការណ៍ផ្សេងៗក៏បាន។ ព្រោះតាមធម្មតា អច្ឆរិយៈរបស់មនុស្សម្នាក់ៗតែងតែមានទៅនឹងខ្លួនឯងស្រេចទៅហើយដោយធម្មជាតិ។

បើសិនយើង មិនបានបណ្តុះផ្សាំអំណាចបែបនេះឲ្យកើតឡើង (សមាធិ ចិត្តានុភាព មនោភាព ។ល។) អំណាចដូចពោលមកហើយនេះ ក៏មិនអាចស្មើស្មងឲ្យដល់នរណាបានឡើយ។ ឬបុគ្គលដែលចេះប្រើអំណាចដ៏ពិសេសអស្ចារ្យនេះក៏អាច ឬ ក្លាយទៅជាអ្នកធំសម្បើមក្នុងផ្លូវនយោបាយ ក្នុងផ្លូវពាណិជ្ជកម្ម និងក្នុងផ្លូវផលិកម្មក៏បានយើងហៅថា "អច្ឆរិយបុគ្គល"។ ចំណែកបុគ្គលដែលខុសបំណង ឬ ក៏អស់សង្ឃឹមក្នុងឆាកជីវិតក្នុងអនាគតនោះមានតែសេចក្តីងងឹតងងុល អន្ទការ អស់សេចក្តីព្យាយាម ខូចកម្លាំងចិត្ត មានតែសេចក្តីធុញ

ទ្រាន់ ទុក្ខ ទោមនស្ស។ល។ ក៏គឺបុគ្គលដែលមិនចេះប្រើកម្លាំងអំណាចដ៏ពិសេសអស្ចារ្យ ដែលធម្មជាតិបានប្រសិទ្ធិប្រសាទឲ្យមកគ្រប់ៗគ្នាហើយនោះ។ សូម្បីតែមនុស្សយើងមិនអាចបណ្តុះផ្សាំអំណាចបែបនេះ ឲ្យកើតឡើងមកបានក៏ដោយ តែគាប់ជួនអំណាចអច្ឆរិយៈដ៏ពិសេសអស្ចារ្យនេះ ក៏រមែងតែងតែកើតឡើងបានក៏មានដែរ ដូច្នេះសេចក្តីខ្លាច យ៉ាងខ្លាំងហួសពេក? សេចក្តីជឿយ៉ាងមុតមាំ ឧបាទាន ឬ សេចក្តីមេត្តាករុណារឹងប៉ឹងបំផុត ទាល់តែធ្វើឲ្យចក្រព័ត្តកម្លោះនៃ "សិទ្ធត្ថកុមារ" មិនអាចនឹងអត់ទ្រាំគ្រប់គ្រងអំណាច "ចក្រព្រាធិរាជ" នៅតទៅបាន។ តោងលះបង់ចោលទ្រព្យសម្បត្តិដ៏មហាសាល រួមទាំងប្រពន្ធកូន និងបរិវារជាទីស្នេហា ដើម្បីស្វែងរកគោលសច្ចធម៌ប្រោសសត្វលោក។ ចំណែកសេចក្តីក្លាហាន ក៏អាចសាងភាពជា "អច្ឆរិយៈ" ឲ្យដល់ចិត្តគំនិតបានដូចគ្នាដែរ ដូចសេចក្តីក្លាហានរបស់ហ្សានដាក វីរស្ត្រីជាតិបារាំងសេសជាដើម។ តែសូមឲ្យចូលចិត្តជាមុនថា "អច្ឆរិយៈ" មិនចាំបាច់តោងជា "អច្ឆរិយៈ" ក្នុងផ្លូវសាងជាដរាបទៅទេ អាចជា "អច្ឆរិយៈ" ក្នុងផ្លូវទំលាយក៏បានដែរ។ តែក្នុងទីនេះ ខ្ញុំបានកំណត់សំដៅយកតែ "អច្ឆរិយៈ" ក្នុងផ្នែកចំពោះផលល្អនៃអានុភាព របស់ចិត្តគំនិតដែលមានកម្លាំង និង អំណាចលើដួងចិត្ត នៃធម្មជាតិតែមួយយ៉ាងប៉ុណ្ណោះ។

សូមលើកតួយ៉ាង ការពិតក្នុងរឿងសេចក្តីខ្លាចមួយ ដើម្បីបញ្ជាក់ឲ្យឃើញជាក់ច្បាស់ទាំងដើម្បីជាគោលការណ៍ក្នុងការប្រៀបធៀបពិចារណា ។ យូរអង្វែងណាស់មកហើយក្នុងជនបទនៃប្រទេសអង់គ្លេស (ទស្សនាវដ្ដីឈ្មោះ Evening Post) បានកើតភ្លើងឆេះយ៉ាងទ្រលោមក្នុងផ្ទះមួយ ។ ហើយភ្លើងក៏បានឆាបឆេះរាលដាលតៗ ទៅដល់ជិតខាងយ៉ាងកំណាចសាហាវ។ អ្នកផ្ទះទាំងនោះ បាននាំគ្នាជញ្ជូនទ្រព្យសម្បត្តិនានា ចេញពីផ្ទះយ៉ាងតោក្រហលជ្រួលជ្រើមតែរៀងរាល់ខ្លួនជាទីបំផុត។ នៅផ្ទះខ្នងចុងគេបំផុតនោះ មានកំលោះម្នាក់ដេកឈឺយ៉ាងទំងន់ ដោយសន្លាក់ដៃ និង ជើងហើមឈឺចាប់ជាខ្លាំងប្រើការមិនបាន ក្រោកដើរទៅណាមកណាពុំរួចជាយូរឆ្នាំណាស់មកហើយ សូម្បីតែទៅបន្ទោរឧច្ចារបស្សាវៈក៏តោតមានគេជួយគ្រាទៅទើបទៅរួច។ ហើយជាការគាប់

ជូនពិត។ ក្នុងថ្ងៃដែលភ្លើងឆេះផ្ទះនោះ ញាតិសន្តានបងប្អូនមិននៅត្រូវមានកិច្ចធុរៈទៅក្រៅផ្ទះនោះអស់។ គង់ឲ្យគេដេកចាំផ្ទះតែម្នាក់ឯងប៉ុណ្ណោះ នៅទីបំផុតភ្លើងក៏ឆាបឆេះ រាលដាលចូលមកដល់ផ្ទះដែលអ្នកកំលោះដេកឈឺនោះ។ ក្នុងវេលានេះអ្នកកំលោះកំពុងតែក្រវ៉ល់ក្រវ៉ាយ អន្ទះសាររកអ្វីប្រៀបផ្ទឹមពុំបាន ។ ព្រោះតែសេចក្តីខ្លាចគេបានស្រែកយ៉ាងអឺងកងរំពង ដើម្បីអង្វររកឲ្យអ្នកជិតខាងមកជួយ តែមិនមាននរណាអាចមកជួយគេបានឡើយ។ ក្នុងទីបំផុតភ្លើងក៏បានឆាបឆេះរាលដាលចូលមកដល់ក្នុងផ្ទះដោយសេចក្តីនឹកខ្លាចថា ភ្លើងនឹងឆេះឆាបដល់រាងកាយរបស់គេ បានបង្កើតឡើយយ៉ាងខ្លាំងបំផុត។ អ្នកកំលោះពិការ នោះក៏រួមកម្លាំងខ្លាំងក្លា (Will Power) ក្រោករត់ចេញមកក្រៅផ្ទះដោយឆាប់រហ័សដូចខ្យល់ព្យុះ ។ អាការឈឺចាប់ និងអាការខ្វិនដើរមិនរួចសោះជាយូរឆ្នាំនោះក៏វិនាសអន្តរធានបាត់ទៅយ៉ាងគួរអស្ចារ្យ។ ហើយជាពិសេសជាងនេះទៅទៀត បុគ្គលនេះក៏បានប្រើអំណាចយ៉ាងអាថ៌កំបាំងក្នុងខ្លួន ដែលធម្មជាតិបានប្រសិទ្ធិប្រសាទទុកឲ្យមក ដើម្បីតស៊ូក្នុងឆាកជីវិតយ៉ាងក្លាហានទាល់តែឥឡូវនេះ គេក៏ក្លាយទៅជាអ្នកមានរាងកាយរឹងប៉ឹងមាំមួនមានអំណាចកំលាំងចិត្តក្លាហាន ដែលអាចធ្វើឲ្យប្រជាជនរាប់អានគេ យ៉ាងច្រើនជាអតិបរមា។

លោកអ្នកអានជាទីគោរព លោកនឹងថាខ្ញុំបាទយ៉ាងណាក៏ដោយ ខ្ញុំបាទយល់ឃើញថាក្រោមមេឃលើដីនេះមិនមានអំណាចអ្វីដែលមានឥទ្ធិពលធំជាង "អំណាចដួងចិត្ត" ឬក៏ "ចិត្តវិទ្យារបៀបថ្មី" នេះទេ។ ការសាងបុគ្គលិកលក្ខណៈរបស់ខ្លួនដើម្បីសេចក្តីសម្រេចផលរមែងឋិតនៅក្រោមអាណាចក្រនៃ ចិត្តវិទ្យារបៀបថ្មីនេះច្រើនជាងអំណាចនៃដួងតារា អំណាចនៃជោគជាតា ឬ ឥទ្ធិពលនៃព្រហ្មលិខិត។ សេចក្តីសម្រេចផលទាំងក្នុងផ្លូវលោក និងផ្លូវធម៌រមែងឋិតនៅក្រោមតណ្ហាចិត្តវិទ្យាទាំងអស់។ ទោះបីសេចក្តីសំរេចរបស់ព្រះសម្មាសព្ទុទ្ធជាម្ចាស់ ឬ សេចក្តីសំរេចព្រះយេស៊ូ ព្រះមហាមាត់ ណាប៉ូលេអុង លិនខល័ន ។ល។ ក៏រមែងរួមចូលក្នុងចិត្តវិទ្យាទាំងអស់។ លោកចង់បានសេចក្តីសម្រេចនូវចិត្តវិទ្យារបៀបថ្មីនេះទេ? លោកចង់មានកិត្តិសព្ទល្បីល្បាញដូចមហាត្មះគន្ធីទេ? លោកចង់បានកេរ្តិ៍ឈ្មោះដូចអិដិស័ន ទេ? លោកចង់មានទ្រព្យសម្បត្តិ

យ៉ាងស្អុកស្កម្ភជាសេដ្ឋីដូចអែនដ្រូហ្គានេគីយ៍ទេ? បើលោកចង់បានជាមនុស្ស មានកេរ្តិ៍ឈ្មោះល្បីល្បាញដូចយូលីអុសហ្សីហ្សារ វិហ្សីរល្មឺរ ដិស្សរាអេលី ក្លែត ស្តោនហ្គារ៍ អ្នកស្រីពួងការរេយ៍ ។ល។ លោកត្រូវតែសាកសួរខ្លួនលោកសិន ថា លោកមានមនោគតិ (Idea) អ្វីខ្លះឬទេ? លោកមានឧត្តមគតិ (Ideology) អ្វីខ្លះឬទេ? លោកមានសេចក្តីស្រវាំស្រទាញ (Ambition) ខ្លាំងក្លាត្រឹមណា ហើយឬទេ? លោកមានចិត្តានុភាព (Will power) ទៀងទាត់មាំមួនឬទេ? លោកមានសមាធិចត្តិ (Concentration) ហ្មឹងហ្មឹតថេរឬទេ? លោកតក់ស្លុត ចំពោះឧបសគ្គផ្សេងៗឬទេ? លោកបង្ក្រាបបញ្ហាខ្លួនលោកបានហើយឬទេ?

លោកអ្នកអានជាទីគោរព គុណសម្បត្តិដែលបានពោលយ៉ាងសង្ខេប ខាងលើនេះ មាននៅក្នុងខ្លួនលោកគ្រប់គ្រាន់ហើយឬទេ? បើសិនគុណសម្បត្តិ ទាំងនោះមាននៅក្នុងខ្លួនរបស់លោកគ្រប់គ្រាន់ហើយ។ ខ្ញុំបាទអាចធានារ៉ាប់រង បានថា លោកត្រូវតែជាបុគ្គលសំខាន់យ៉ាងពិតប្រាកដទោះបីដួងជាតា និង វាសនារបស់លោកដុនដាប អាក្រក់សែនអាក្រក់យ៉ាងក៏ដោយ។

ខ្ញុំបាទបានពោលពីរឿងអាថ៌កំបាំងនៃការសាងភាពជា "អច្ឆរិយៈ" ជូន លោកអ្នកអាន ជាទីគោរពមកហើយ ដូច្នេះសូមឲ្យលោកចូលចិត្តថា អាថ៌ កំបាំងក្នុងការសាងភាពជា "អច្ឆរិយៈ" នោះ មានសេចក្តីសំខាន់ក្នុងបញ្ហានៃការ កសាងជីវិតយ៉ាងណា? ការស្ថាបនាស្និតស្នាងខ្លួនឯងដើម្បីសេចក្តីរុងរឿងថ្កុំ ថ្កើនក្នុងបច្ចុប្បន្ន និង អនាគតនោះ។ បញ្ហាសំខាន់បំផុតរមែងឋិតនៅនឹង "ចិត្ត វិទ្យា" ឬ "អាណាចក្រនៃសេចក្តីគិត" ។ ជាការពិតណាស់ទៅហើយដែលជា បុគ្គលណាបើប្រាសចាកបុគ្គលិកលក្ខណៈ ឬ នៅពុំទាន់ស្គាល់ខ្លួនរបស់ខ្លួនឯង ទេ។ ចិត្តានុភាព សមាធិ មនោភាព និងឧត្តមគតិ ក៏នៅមិនអាចចូលដល់ចិត្ត ឬ មិនអាចយល់លក្ខណៈដ៏សំខាន់ដែលកើតមានឡើងដល់ខ្លួនឯងបានឡើយ ។ ខ្ញុំបាទអាចពោលថា "បុគ្គលនោះ ឬ អ្នកណាក៏ដោយក៏មិនអាចនឹងមានជីវិត រស់នៅដោយផាសុកបានក្រោមមេឃលើដីដែលមានតែការតស៊ូ និងប្រណាំង ប្រជែងគ្នាស្ទើរតែគ្រប់ច្រកល្ហក នៃជីវិត។ ហើយក៏ពុំមានប្រយោជន៍អ្វីឡើយ ដែលយើងនឹងត្អូញត្អែរ អន្ទក់អន្ទេញ សោកសៅនូវការខុសបំណងក្នុងឆាកជីវិត

ក្នុងសេចក្តីអភ័ព្វអប្បជោគ រួមទាំងសេចក្តីច្រណែន និទ្ទា ដែលឃើញអ្នកដទៃគេរុងរឿងថ្កុំថ្កើនជាង។ យើងនឹងតូចចិត្តទៅធ្វើអ្វី? កាលបើធម្មជាតិក៏បានបណ្តុះផ្សាំវត្ថុទាំងនោះមកឲ្យយើងស្មើៗគ្នា ដោយមិនរើសមុខ។ តែយើងទេតើដែលមិនចេះប្រើវត្ថុដែលធម្មជាតិបានស្អិតស្អាងទុកឲ្យដល់ខ្លួនឯង អ្នកណាដែលមិនអាចឈានឡើងកាន់ឋានៈខ្ពស់ត្រដែតបាន ក៏ព្រោះគេទៅមិនទាន់ចូលជិត ឬស្គាល់ខ្លួនឯងយ៉ាងពិតប្រាកដ នៅពុំទាន់មានជំនឿខ្ជាប់ខ្លួនក្នុងខ្លួនឯង នៅបង្គាប់បញ្ជាខ្លួនឯងពុំបាន ព្រមទាំងនៅពុំទាន់យល់ច្បាស់នូវ សភាពការប្រព្រឹត្តិទៅរបស់មនុស្សលោកដូច "មហាត្មៈគន្ធី" ដែលមានការតស៊ូក្នុងឆាកជីវិតយ៉ាងជោគជាំមុននឹងសំរេចផលដ៏គួរស្ញប់ស្ញែងអស្ចារ្យ។ បុគ្គលសំខាន់ៗ ដូចព្រះសម្មាសម្ពុទ្ធម្ចាស់ ព្រះយេស៊ូ ព្រះយេស៊ូ ព្រះមហាម៉ាត់ លិនខល័ន ហ្សឺហ្សារ អាឡិកសាន់ដឺរ អ៊ិដិស័ន ហេនរីហ្វដ។ល។ ក៏បានតស៊ូក្នុងវិថីជីវិតដ៏កំសត់ទុរគិត។ ជួនកាលលោកទាំងនោះខ្លះក៏បានទទួលសេចក្តីពិបាកសែនទារុណ ដោយត្រូវជាប់គុកជាប់ច្រវាក់ត្រូវនិរទេស ជាហេតុឲ្យព្រាត់ប្រាស់ប្រពន្ធកូន យ៉ាងហិនហោចខ្លោចផ្សាជាទីបំផុត។ សូមឲ្យលោកពិនិត្យពិចារណាមើលនូវការតស៊ូរបស់លោក "មហាត្មៈគន្ធី" ដែលជារដ្ឋបុរសដ៏ធំ ឆ្នើម ក្នុងរដ្ឋឥណ្ឌា។ លោកនេះ មានការតស៊ូរហូតទាល់តែជីវិតត្រូវវិនាសយ៉ាងគួរឲ្យអាណោចអាធម៍ជាទីបំផុត។ តែកេរ្តិ៍ឈ្មោះរបស់លោកក្រអូបឈ្ងុយឈ្ងប់សោយសុះយ៉ាងក្រៃលែងជាងរដ្ឋបុរសណាៗទៅទៀតក្នុងសាកលលោក។ សូមលោកសាកល្បងធិសោធន៍មើលថាតើមានឥទ្ធិពលយ៉ាងហ្ន៎ ដែលជួយជំរុញលោកនេះឲ្យទៅដល់គោលដៅចុងចប់ដ៏គួរឲ្យប្រាថ្នាបាន។ កម្លាំងជំរុញចិត្តរបស់លោកនោះ ក៏គ្មានសភាពផ្សេងគ្នានឹងបុគ្គលសាមញ្ញណាមួយក៏ទេដែរ។ ធម្មជាតិនិងព្រះអទិទេព (បើសិនមាន) ក៏មិនបានជួយស្អិតស្អាងឲ្យលោកមហាត្មៈគន្ធី ជាមហាបុរសបានទេ។ តែដោយសារតែខ្លួនរបស់លោកទេតើ (កម្លាំងនៃមេត្តាធម៌) ដែលចេះប្រើអំណាចធម្មជាតិ សឹងមាននៅក្នុងខ្លួនរបស់លោកហើយ។ លោកនាំវាយកប្រើឲ្យកើតជាប្រយោជន៍ គឺមិនព្រមបណ្តោយឲ្យវាបាត់បង់ទៅព្រមនឹងពេលវេលា ដែលកំពុងតែកន្លងទៅគ្រប់វិនាទីនោះ។

## ២. បុគ្គល ៣ ជំពូកក្នុងទស្សនៈលោក ប៉ាប្លូហ្វ

លោក "រ៉ូស្សូ" អ្នកទស្សនៈវិទូដ៏កំសត់ទុរគត៌ នៃជាតិបារាំងសេសបាន ពោលថា "សេចក្ដីផ្សេងគ្នា ក្នុងភាពរបស់មនុស្សនោះ មិនមាននៅក្នុងសង្គម មនុស្សទេ"។

លោក ប៉ាប្លូហ្វ សាស្រ្ដាចារ្យជាតិរុស្សី បានពោលទុកថា "មនុស្សដែល ចេះគ្រប់គ្រងខ្លួនឯងប៉ុណ្ណោះ ចាត់ជាអ្នកតស៊ូក្នុងឆាកជីវិត ឲ្យសម្រេចប្រយោ ជន៍ដល់ខ្លួនឯងបាន" លោកនេះបានបែងចែកបុគ្គលទុកជា ៣ពួក។ ខ្ញុំបាទ នឹង នាំមកពោលចំពោះតែពួកទី១ ប៉ុណ្ណោះ។ ចំណែក ២ពួកទៀតឃើញថា មិន សូវសំខាន់ណាស់ទេ ទើបមិនគួរនឹងនាំមក ពោលក្នុងទីនេះ។ ពួកដែលល្អផ្ដាច់ ឬពួកទី១ នោះលោកប៉ាល្លូហ្វពោលថា "មហាបុគ្គលិកលក្ខណៈ" គឺ លក្ខណៈដ៏ ធំ សម្បើម របស់បុគ្គលនោះឯង។ លក្ខណៈរបស់បុគ្គលដូចពោលមកនេះជា លក្ខណៈរបស់ចិត្តគំនិត ដែលអាចគ្រប់គ្រងខ្លួនឯងបានដោយពិតប្រាកដ ហើយទាំងអាចគ្រប់គ្រងសម្បជញ្ញៈចិត្ត (Conscious mind) រួមទាំងបរិវារចិត្ត (Subconscious mind) ឲ្យដំណើរទៅបានដោយត្រឹមត្រូវ តាមទ្រឹស្ដីនៃតក្ក វិទ្យា។ បុគ្គលក្នុងរូបលក្ខណៈដូចពោលមកនេះ រាប់ថាជាអ្នកមានចិត្តានុភាពរឹង ប៉ឹងបំផុត មានគោលបំណងមិន ចេះប្រែប្រួលមានសេចក្ដីអត់ធ្មត់យ៉ាងកំពូល ជាងមនុស្សធម្មតាសាមញ្ញ មានសេចក្ដីស្រវាំស្រទាញ មិនចេះអស់មិនចេះ ហើយមានឧត្ដមគតិ ឬមធ្យោបាយវិសេសវិសាល មានសេចក្ដីតស៊ូពុះពារ មិន ចេះធុញទ្រាន់ជាមនុស្សមិនខ្លាចស្លាប់ ឬរួញរាក្នុងការតស៊ូនូវឧបសគ្គរាំងគ្រប់ យ៉ាង ជាអ្នកមានមនោភាពមើលឃើញ និង ដោយហេតុការណ៍វែងឆ្ងាយនៃ ពិភពលោកបានដោយត្រឹមត្រូវជាអ្នកមានផែនការណ៍ ល្អិតសុខុមរៀបរយ ទាំង ព្យាយាមធ្វើជាកម្មករក្នុងផែនការណ៍របស់ខ្លួននោះ ដោយមិនចេះស្គាល់នឿយ ហត់ និង ធុញទ្រាន់សោះឡើយ។ បុគ្គលទាំងនេះហើយដែលលោកសាស្រ្ដា ចារ្យ "ប៉ាល្លូហ្វ" លើកតំកើតថា ជាមនុស្សសំខាន់របស់ពិភពលោកជាអ្នកមាន អំណាចធំសម្បើម ជាប្រមុខក្នុងផ្លូវការរដ្ឋ ជាអ្នកប្រតិស្ន ដែលលោកពុំអាច បំភ្លេចបានជាអ្នកនិពន្ធ ដែលមានឈ្មោះល្បីល្បាញជាប់នូវនឹងបបូរមាត់មនុស្ស

អ្នកអានទូទៅនរណាក៏បានដែរបើសិនមានមហាបុគ្គលិក លក្ខណៈក្នុងផ្លូវចិត្តវិទ្យាដូចពោលមកហើយនេះក៏អាចនឹងជំរុញ រុញច្រានជីវិតរបស់ខ្លួនឯង ឲ្យជួបប្រទះនូវសេចក្តីសម្រេចដ៏គួរសប្បាយរីករាយជាទីបំផុត។ ព្រះសម្មាសម្ពុទ្ធម្ចាស់ជាបុគ្គលដំបូងបង្អស់ដែលនឹងត្រូវលើកមកពោលគឺព្រះសម្ពុទ្ធព្រះអង្គនេះ ជាប្រជាពលលោក រមែងជ្រាបក្នុងពាក្យប្រៀនប្រដៅរបស់ព្រះអង្គ។ ព្រោះអ្នកណាក៏ដោយក៏តែងតែធានារាប់រងដោយទូទៅថា សាសនាព្រះពុទ្ធជាសាសនាដែលមានអត្ថរស-អត្ថន័យ។ល។ ល្អិតសុខុមវិសេសវិសាលជាងសាសនាណាៗទាំងអស់ ក្នុងពិភពលោក។ ការដែលព្រះសម្មាសម្ពុទ្ធម្ចាស់បានកន្លងផុតវិស័យ បុថុជ្ជនក្លាយទៅជាអច្ឆរិយបុរសដូច្នេះក៏អាចនឹងពោលបានថា ព្រះអង្គជាអ្នកមាន "មហាបុគ្គលិកលក្ខណៈ" ខ្ពស់ជាងនរណាទាំងអស់។ តែមិនបានសំដៅថា ព្រះពុទ្ធជាមនុស្សវិសេសវិសាលជាងមនុស្សធម្មតាក៏ទេដែរ (ព្រោះថាព្រះពុទ្ធម្ចាស់ក៏មានសញ្ជាតិ ញាណជាមនុស្សដែរ)។ ព្រោះខ្ញុំបាទបានពោលមកហើយថា "ធម្មជាតិ" មិនបានស្អិតស្អាងនរណាឲ្យជា "អច្ឆរិយៈ" នោះទេ។ បុគ្គលតែម្នាក់ៗប៉ុណ្ណោះទេតើ ដែលបានស្អិតស្អាងអច្ឆរិយៈរបស់ខ្លួនឯងឡើយមក។ ហើយប្រការមួយទៀត អច្ឆរិយៈអាចនឹងកើតពីសភាពព័ទ្ធឡោមរបស់សង្គមមនុស្សក៏បាន។ ព្រោះថាសង្គមមនុស្សលោក ក្នុងយុគបច្ចុប្បន្ននេះតែងឋិតនៅក្នុងរបបសង្គមប្រជាធិបតេយ្យ (Individualism) ។ របបគ្រប់គ្រងបែបនេះ រមែងពេញទៅដោយការប្រណាំងប្រជែងការឈ្វេងយល់តែប្រយោជន៍ផ្ទាល់ខ្លួន (អត្តទត្ថបុគ្គល) ការរំលោភ ការបៀតបៀនគ្នាដោយគ្មានសីលធម៌ ការកោសរូសដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ការប្រមែប្រមូលដើម្បីប្រយោជន៍ខ្លួនឯង ដោយមិនបានគិតដល់សេចក្តីទុក្ខវេទនារបស់អ្នកដទៃ? ការដណ្តើមប្រណាំងប្រជែងគ្នាក្នុងផ្លូវនយោបាយ ការតំកើងខ្លួនជាធំ និង សញ្ជាតិញាណនៃការសម្លុត។ ព្រឹត្តិការណ៍បែបនេះតែងពោរពេញទៅដោយ មនុស្សច្រើនជំពូក ពោលគឺមានទាំងសេដ្ឋី កម្មករ អ្នកស្មូម ជាដើម។ ការរិបជាន់គ្នាក្នុងផ្លូវសេដ្ឋកិច្ច ធ្វើឲ្យវត្ថុព័ទ្ធឡោមទាំងនេះជួយឲ្យ កើតអំណាចផ្ទុងផ្តើមនៃចិត្តគំនិតស្ទាប់ ស្ទង់ទៅក្នុងរង្វង់នៃអច្ឆរិយៈលក្ខណៈ។ សេចក្តីទីទ័លក្រនិងការត្រូវ

ជិះជាន់នេះឯងជាមន្តមួយ ដ៏វិសេសដែលអាចបណ្តុះផ្សាំបុគ្គលសំខាន់ៗក្នុងលោកឲ្យកើតប្រាកដមកនាសព្វថ្ងៃនេះ។ ក្រៅពីសេចក្តីទីទ័លក្រហើយ? សេចក្តីប្រាថ្នានៃកេរ្តិ៍ឈ្មោះរបស់មនុស្សក៏ជាកម្លាំងមួយដ៏សំខាន់ ជួយរុញច្រានឲ្យមនុស្សទាំងនោះ ក្លាយទៅជាមនុស្សធំដុំ ឬ សំរេចផលក្នុងកិច្ចការងារបានដូចគ្នា។

បើសិនយើងបានសិក្សាជីវប្រវត្តិនៃសេចក្តីចុំច្រើន រុងរឿងរបស់រដ្ឋបុរសល្បីឈ្មោះ អ្នកនយោបាយនាមឧត្បែសន៍ អ្នកវិទ្យាសាស្ត្រ អ្នកប្រតិស្ឋ រហូតអ្នកសាសនា ដែលមានគេគោរពពេលទាំងផ្ទៃនៃសាកលលោក។ ខ្ញុំបាទមានជំនឿយ៉ាងមុតមាំថា បុគ្គលសំខាន់ៗ ក្នុងពិភពលោកដូចជាព្រះសម្មាសម្ពុទ្ធម្ចាស់ ព្រះយេស៊ូ ព្រះមហាម៉ាត់ ណាប៉ូឡេអុងប៉ូ ណាប៉ារត៍ ហ្សាលម៉ាន់ ព្រះចៅ ពិទីរមហារាជ្យ ហ្សីហ្សារ អាឡិកហ្សនដឺរ អិដិស័ន វ៉ូលទែរ រ៉ូស្សូ វិល្លិយ៉ាំភិត (បុត្រ) ឱស្រាអិល្លី មហាត្មៈគន្ធី។ល។ បុគ្គលដូចពោលមកនេះ បានឈានឡើងកាន់ជីវិតក៏ធំដុំ ឬបានឈានឡើងកាន់លោកីយសម្បត្តិ ឬលោកុត្តរសម្បត្តិបានក៏គួរតែមានអ្វីម្យ៉ាង ឬច្រើនយ៉ាងរួមគ្នាជាថាមពលដ៏វិសេស ជួយរុញច្រានឲ្យលោកទាំងនោះ ត្រូវជួបប្រទះនូវសេចក្តីសម្រេចបាន។

ម្យ៉ាងទៀតការដែលបុគ្គលទាំងនេះ បានសម្រេចតាមគោលដៅ នៃជីវិតរបស់ខ្លួននោះក៏តោងអាស្រ័យថាមពល នៃអំណាចយ៉ាងណាមួយ ដូចនឹងបានជំរាបដោយខ្លីៗតទៅក្នុងសៀវភៅនេះ។

## ៣. អំណាចនៃមេត្តាធម៌

ពាក្យថា "ថាមពលនៃមេត្តាធម៌" ខ្ញុំបាទបានកំណត់សំដៅរកសេចក្តីថាកម្លាំង ឬអំណាចរបស់សេចក្តីប្រាថ្នាដ៏ខ្លាំងក្លា ដែលអាចជួយឲ្យអ្នកដទៃបានសេចក្តីសុខ។ សេចក្តីសុខដែលពោលមកនេះ អាចជាសេចក្តីសុខដែលកើតពីផ្លូវការរដ្ឋ ផ្លូវសាសនា ផ្លូវវិទ្យាសាស្ត្រ ផ្លូវការពេទ្យ ឬ ក៏សេចក្តីមេត្តារវាងបិតានិងបុត្រ រវាងបុត្រ និមាតា ឬ ដែលកើតឡើងដោយករណីណាមួយក៏ដោយក៏រាប់ថាជាមេត្តាធម៌ តាមន័យដូចពោលមកនេះទាំងអស់។

តទៅនេះ ខ្ញុំបាទនឹងពោលពីអំណាចរបស់មេត្តាធម៌ខ្លះថា "តើមេត្តាមានអំណាចឥទ្ធិពលយ៉ាងណាដែល អាចនឹងជម្រុញច្រានបណ្ដាលឲ្យកើតអំណាចចិត្ត មានប្រសិទ្ធិភាពខ្លាំងក្លាឡើងបាន?"។

មេត្តាធម៌ ជាសញ្ញាតិញាណនៃមនុស្ស ដែលធម្មជាតិបានបណ្ដុះផ្សាំឲ្យដល់មនុស្ស និងសត្វលោកទូទៅ។ សេចក្ដីមេត្តាប្រណី ទើបជាតួអង្គជួយជំរុញបណ្ដាលឲ្យចិត្តមនុស្សមានសេចក្ដីអន្ទើង ស្ទុះស្ទារ ចង់ជួយសង្គ្រោះ ពពួកមនុស្ស ឲ្យមានសេចក្ដីសុខដូចសម្ដេចឪរបស់យើងសព្វថ្ងៃនេះ ព្រះអង្គតែងមានព្រះទ័យមេត្តាដល់កូនចៅ ដោយមិនមានរើសមុខជាដើម។ សេចក្ដីមេត្តាមានឥទ្ធិពលយ៉ាងខ្លាំងណាស់ ដែលធ្វើឲ្យមនុស្សត្រូវលំបាកលំបិន ធ្វើការដោយសេចក្ដីក្លាហានអង់អាច និងដាច់ខាត។ ព្រោះអំណាចនៃមេត្តាធម៌ដល់ពពួកមនុស្សនេះ ទោះបីសេកថ្ដីមេត្តារវាងបុគ្គល និងបុគ្គល បក្សពួក និងបក្សពួកឬក៏ក្នុងផ្ទៃប្រទេស ក្រៅប្រទេសក៏ដោយ ។ មេត្តានុភាព ដូចពោលមកនេះត្រូវធ្វើឲ្យមនុស្សកើតសេចក្ដីអាណិតអាសូរ យ៉ាងជាប់ចិត្តដិតថ្លើម ចង់តែជួយសង្គ្រោះបុគ្គល ឬប្រជាជនទូទៅឲ្យមានផាសុខភាព។ មេត្តាធម៌ ទើបជាឈ្នួនអុជឋាមពលនៃអំណាចចិត្ត ឲ្យបង្កើតភាពជា "អច្ឆរិយៈ" ឡើង។ បុគ្គលដែលមានមេត្តាធម៌ប្រចាំចិត្ត តែងតែប្រកបទៅដោយការប្រើគំនិតយ៉ាងធ្ងន់ ហើយអាចកំណត់ផែនគ្រោងការណ៍ ដែលអាចជួយស្រោចស្រង់អ្នកដទៃដោយមិនរំភើបញាប់ញ័រខ្លាចក្រែងឥទ្ធិពលយ៉ាងណាទាំងអស់។ បុគ្គលដែលមាន មេត្តាធម៌នេះបើសិនជាគ្រូពេទ្យ គេក៏ត្រូវប្រិតប្រៀង ពិនិត្យពិចារណា ស្រាវជ្រាវនូវការរក្សារោគដើម្បីទំលុះទំលាយ បំផ្លិចបំផ្លាញអំណាចមេរោគ (ពាចតរិ) ឲ្យសាបសូន្យវិនាសអស់ទៅដូចហ្លួយប៉ាស្ទ័រ ខ្លរេនណៃទិងគឹលជាដើម។ បើសិនជាអ្នកនយោបាយវិញ គេក៏ត្រូវធ្វើគ្រប់មធ្យោបាយដើម្បីប្រជាជាតិរបស់គេទាំងស្រុង ដោយមិនខ្លាចក្រែងសេចក្ដីស្លាប់ដូច សម្ដេចឪរបស់យើង លិនខល័នមហាត្មៈគន្ធី ជាដើម។ បើគេជាអ្នកសាសនា គេក៏តោធ្វើការស្រាវជ្រាវរកទ្រឹស្ដីដ៏ត្រឹមត្រូវបរិបូរណ៍ មកអប់រំប្រៀនប្រដៅមនុស្សទូទៅដោយមិនរើសមុខឲ្យផុតពីសេចក្ដីទុក្ខ ហើយឲ្យកើតសន្តិសុខ ដូចការស្រាវជ្រាវរកគោលចារិកនៃធម៌

ខ្ពង់ខ្ពស់របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះយេស៊ូ ខុងជឺ និងព្រះមហាហ្មាត់ជាដើម ។ ខ្ញុំបាទមានទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំថា៖ ឋាមពលនៃសេចក្ដីមេត្តា ធ្វើឲ្យលោកដូចពោល មកហើយខាងលើនោះក្លាយភាពជា "អច្ឆរិយៈបុគ្គល" បានដោយពិតប្រាកដ។ ការដែលរុស្ស៊ីមានការបដិវត្តន៍កាល គ.ស ១៩០៧ ១៩០៨ ១៩១៧ ខ្ញុំគិតថា ក៏ដោយសារមេត្តាធម៌ អាណិតអាសូរ ក្នុងសភាពការរស់នៅរបស់មនុស្សដែល ពោរពេញទៅដោយសេចក្ដីអត់ឃ្លានសែនវេទនាដែលឧប្បត្តិការណ៍ឡើងក្នុងប្រទេសរុស្ស៊ី ។ អំពីទារុណកម្មនៃព្រះចៅ ហ្សារ និង រាជបរិពារដែលកោសរូស ជិះជាន់សង្កត់សង្កិនរាស្ត្រទូទៅ ដោយប្រាសចាកមនុស្សធម៌នោះឯង ជាមូលហេតុកើតការបដិវត្តន៍ក្នុងប្រទេសករុស្ស៊ីយ៉ាងទារុណកបំផុតក្នុង គ.ស ១៩១៧ ។ បើសិនជាជនជាតិរុស្ស៊ីភាគច្រើនមិនបានកុម្មុនីស្តដូចសព្វថ្ងៃនេះ ក៏បាន។

លោក វូតរ៉ូ វីលស័ន ប្រធានាធិបតីនៃសហរដ្ឋអាមេរិច ដែលបានសាងសន្និបាតជាតិក្រោយសង្គ្រាមលោក គ.ស ១៩១៤ ក៏ព្រោះតែមានចេតនាដើម្បីសន្តិភាព និង សន្តិធម៌នៃមនុស្សលោក ។ ទាំងនេះរមែងកើតដោយកម្លាំង និង អំណាចនៃមេត្តាធម៌ទាំងអស់។

## ៤) អំណាចស្នេហា និង កាមារម្មណ៍

ស្ត្រីដែលយើងស្រឡាញ់គាប់ចិត្ត ប្រៀបធៀបនាងថាដូចជាបុប្ផាជាតិដ៏ល្អស្រស់ ទាំងមានក្លិនក្រអូបគួរឲ្យអភិរម្មណ៍ មានសម្រស់គួរឲ្យថ្នាក់ថ្នមបបោសអង្អែល ជាទីនិយមរាប់រកនៃពលលោក ជាដួងព្រលឹងនៃជីវិត ជាកំពូលនៃសេចក្ដីស្នេហា ជាទេពធិតានៃដួងវិញ្ញាណ ឬ និងប្រៀបស្ត្រីដែលយើងស្រឡាញ់គាប់ចិត្តថា ជាអ្វីក្នុសេចក្ដីអភិរម្មណ៍ក៏ដោយ។ តែបើពោលតាមសេចក្ដីពិត ហើយកាមារម្មណ៍ ឬសេចក្ដីស្នេហា នេះហើយដែលជាកម្លាំងដ៏សំខាន់ក្នុងការបណ្ដុះបណ្ដាលជម្រុញឲ្យមនុស្សក្លាយទៅជា "អច្ឆរិយៈ" បាន។ ព្រោះថាមនុស្សនឹងមានសមិទ្ធិយ៉ាងជោគជាំក្នុងកាមារម្មណ៍ ឬ សេចក្ដីស្នេហា បានត្រូវតែជាអ្នកមានអំណាចវាសនាធំដុំក្នុងសង្គមមនុស្សជាមុនសិន។ កាល

ណាបានគ្រប់គ្រងភាពជាឥស្សរៈជនហើយ។ កាមារម្មណ៍ ឬ សេចក្ដីស្នេហា ក៏ជាគ្រឿងបំណាច់វង្វាន់ផ្ដល់ឲ្យគេយ៉ាងជោគជ័យសម ប្រាថ្នាគ្រប់បែបយ៉ាង។

យើងអាចយល់បានថា ស្ត្រីក៏ជាកម្លាំងដ៏សំខាន់ដែលនឹងជម្រុញឲ្យបុរសក្លាយទៅជាបុគ្គលមានអំណាចវាសនាធំដុំបាន។ តាមការពិត អ្នកនាងចូលចិត្តតែបុរសដែលមានចិត្តគំនិតជាហីរ៉ូ (Hero) អ្នកនាងចូលចិត្តតែបុរសដែលមានអំណាច ឬ មានកិត្តិយស។ បើសិនជាអ្នកនយោបាយ ក៏តោងជាអ្នកនយោបាយថ្នាក់ ហិត្លែរ ឬ លិនខល័ន ។ល។ បើសិនជាអ្នកប្រដាល់ក៏ត្រូវជាអ្នកប្រដាល់ថ្នាក់ ចូហ្លុយ យ៉ែកដេមហ្សេ យីនត័ន្នី។ល។ បើសិនជាអ្នកនិពន្ធក៏តោងជាអ្នកនិពន្ធថ្នាក់ សេវ៉ាន់តេសនៃប្រទេស អេស្បាញ ធិកស្តារ ឬ អិតចិវ៉េលនៃប្រទេសអង់គ្លេស វ៉ូលទែរនៃប្រទេសបារាំងសែស បើសិនជាសេដ្ឋីក៏តោង ជាសេដ្ឋីថ្នាក់ រ៉ក់ គីហ្វេលឡឺរ ឬ ហេនរិហ្វរ៍ដ ។ល។ បើសិននរណាអាចសាងខ្លួនឯងឲ្យ មានវាសនាជាអ្នកធំដុំ ឬ អ្នកមានទ្រព្យដ៏ស្តុកស្តម្ភ ដូច្នោះហើយ ក៏មិនជាក្រអ្វីទេ ដែលសេចក្ដីស្នេហា ឬ កាមារម្មណ៍ត្រូវតែជាគ្រឿងបណ្ណាការតបស្នងក្នុងសេចក្ដីឧស្សាហ៍ព្យាយាមរបស់គេ ។ បុគ្គលសំខាន់ៗ ក្នុងលោកដូចណាប៉ូ ឡេអុង-ប៉ូណាបារ៍ត។ល។ ក៏បានអាស្រ័យសេចក្ដីស្នេហា ឬ កាមារម្ម-ណ៍ជាគ្រឿងផ្ទុងផ្ដើមសមត្ថភាព និង ព្រសិទ្ធិភាព នៃសេចក្ដីសម្រេចរបស់គេមិនមែនតិចតួចឡើយ។ កាលបើកាមារម្មណ៍ ឬ សេចក្ដីស្នេហា មានអំណាច និងថាមពលដ៏គួរអស្ចារ្យដូច្នេះ។ ក៏ជាការធម្មតាដែលកាមារម្មណ៍ ឬ សេចក្ដីស្នេហា ជាជំនួយក្នុងការផ្ទុងផ្ដើម ឲ្យសសម្រេចផលដ៏អស្ចារ្យដល់មនុស្សលោក។

ដោយហេតុនេះ ខ្ញុំបាទទើបពោលបានថា កាមារម្មណ៍ ឬ សេចក្ដីស្នេហា ក៏ជាគ្រឿងឧបករណ៍ ផ្ទុងផ្ដើមឲ្យមនុស្សមានអំណាចវាសនាជាអ្នកធំដុំ ហើយក៏ក្លាយទៅជា "អច្ឆរិយៈបុគ្គល" ក្នុងផ្លូវលោកីយសម្បត្តិបាន។

កាមារម្មណ៍ ឬ សេចក្ដីស្នេហាទើបជាឥទ្ធិពលមួយដ៏អស្ចារ្យ ដែលជាជំនួសឲ្យមនុស្សក្លាយទៅជាបុគ្គលសំខាន់ៗ ឬ ជាអច្ឆរិយបុគ្គល ដូចអត្ថន័យដែលបានរៀបរាប់ជំរាបមកហើយនេះ។

## ៥) ចង់ឲ្យជីវិតមានសេចក្តីសុខ

ការដែលមនុស្សធ្វើការយ៉ាងយ៉ាប់យ៉ឺន ត្រូវតស៊ូនឹងសេចក្តីលំបាក ទីទ័លក្រដ៏សែនវេទនា សាច់ឈាមស្ទើរខ្ទាយ ភ្នែកស្ទើរលៀន ក៏មានសេចក្តីប្រាថ្នាតែមួយ គឺសេចក្តីសុខរបស់ជីវិត។ មិនដែលមានរណាម្នាក់សោះក្នុងលោកនេះ ដែលមិនប្រាថ្នានូវសេចក្តីសុខកាយសប្បាយចិត្តនោះទេ។ បើសិនគ្រប់ៗ គ្នាត្រូវការសេចក្តីសុខសប្បាយដូច្នេះ ក៏ជាធម្មតាដែលគេទាំងនោះត្រូវតែព្យាយាមខ្វល់ខ្វាយ និងខ្នះខ្នែងស្វែងរកសេចក្តីសុខសប្បាយ ឲ្យដល់ខ្លួនឯងតាមសមត្ថភាពរបស់ខ្លួន ឬ តាមដែលខ្លួនអាចនឹងធ្វើបាន។ បើយើងគ្រប់គ្នាចង់បានសេចក្តីសុខ សេចក្តីសប្បាយដូច្នេះ យើងក៏ត្រូវតែព្យាយាមធ្វើ ព្យាយាមអត់ធន់គ្រប់កម្មវិធីគ្រប់មធ្យោបាយ ដើម្បីសេចក្តីចំរើនរុងរឿងឲ្យដល់ខ្លួនឯងក្នុងបច្ចុប្បន្ននឹងអនាគត។ ចាប់តាំងពីកម្មករ រកព្រឹកស៊ីល្ងាច រកល្ងាចស៊ីព្រឹកដរាបដល់រដ្ឋបុរសដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងពិភពលោក។ បុគ្គលទាំងនេះ សុទ្ធតែបានព្យាយាមខ្វល់ខ្វាយស្វែងរកសេចក្តីសុខ? សេចក្តីសប្បាយ? ឲ្យដល់ ខ្លួនឯងដោយប្តូរផ្តាច់នឹងដោយពេញសមត្ថភាព។ នរណាអង្គុយឱបដៃ ឬ រង់ចាំតែជោគវាសនា និង ភព្វសំណាង ឬ នរណាចាំតែបន់ស្រន់សូមឲ្យទេវតា ឥន្ទព្រហ្ម ឬ ព្រះអាទិទេព ព្រះជាម្ចាស់ជួយនោះ ជារឿងត្លុកកំប្លែងគួរឲ្យអស់សំណើចពន់ពេកណាស់។

ខ្ញុំបាទ អាចហ៊ានពោលថា មនុស្សដែលបានក្លាយទៅជាអ្នកធំ ជាអ្នកសម្បើម ឬ ក្លាយទៅជាមនុស្សសំខាន់ៗ មានកេរ្តិ៍ឈ្មោះល្បីល្បាញពេញក្នុងសាកលលោកដូច អឡិកហ្សាន់ដឺរមហារាជចក្រពត្តិណាប៉ូឡេអុង-ប៉ូណាបារត៍ យ៉ជ ស៊ីវេនស័ន បេនហ្សាមិន ហ្វ្រែងក្លិន។ល។ ក៏ព្រោះគេទាំងនោះអាស្រ័យកម្លាំងជំរុញនៃចិត្ត ដែលកើតមានមកពីសេចក្តី ប្រាថ្នានូវសេចក្តីសុខសេចក្តីសប្បាយដើម្បីខ្លួនឯងមែន ឬទេ? ។ ក្រោមឧត្តមគតិរបស់មនុស្ស ក្នុងរបបសេរីនិយម (Liberalism) មនុស្សគ្រប់រូបត្រូវជួយខ្លួនឯងធ្វើទៅដើម្បីខ្លួនឯង រកសេចក្តីសុខក្សេមក្សាន្តឲ្យដល់ខ្លួនឯង។ អ្នកណាដំអត់ទំរន់ អ្នកណាខ្វះសមត្ថភាព អ្នកណាមិនអត់ធន់ឲ្យមុះមុតអ្នកណាខ្ជិលច្រអូស អ្នកណាមិនតស៊ូ ក៏ត្រូវ

បានទទួលសេចក្តីលំបាកវេទនារហូតជីវិត។

កាលបើសេចក្តីសុខ ជាសេចក្តីប្រាថ្នា ជាសេចក្តីត្រូវការរបស់មនុស្ស ទូទៅដូច្នេះហើយ។ ទស្សនៈនៃជីវិតក៏គឺ "ត្រូវធ្វើគ្រប់កម្មវិធី និង គ្រប់មធ្យោបាយ ដើម្បីស្នេហាភាពដល់ជីវិតខ្លួនឯង"។

សេចក្តីប្រាថ្នានៅសេចក្តីសុខ ទើបជាឥទ្ធិពលមួយជួយច្រានឲ្យ មនុស្ស ឧស្សាហ៍វិរិយភាពខ្លាំងក្លាបំផុត ក្នុងការធ្វើការងារ។ ដោយហេតុនេះហើយ ទើបខ្ញុំបានហ៊ានពោលថា "សេចក្តីប្រាថ្នានូវសេចក្តីសុខក្នុងឆាកជីវិត "ក៏ជាមន្តឱសថមួយ ជួយជម្រុញរុញច្រានឲ្យមនុស្សបោះជំហានទៅមុខបាន ឬ ន័យមួយទៀតថា "សេចក្តីប្រាថ្នានូវសេចក្តី សុខនៃឆាកជីវិតនេះហើយ ចាត់ជាថាមពលជួយជម្រុញឲ្យកើតភាពជា "អច្ឆរិយបាន" ។

## ៦) ត្រូវការមានអំណាច

សង្គមនៃមនុស្សសម័យបុរាណ កុំថានឹងក្រឡេកមើលក្នុងប្រភេទសត្វដ៏ប្រសើរគឺ ពពួកមនុស្ស ឬ សត្វដែល ថោកទាបជាងមនុស្ស ចុះទៅទៀតដូចសត្វតិរច្ឆាន។ ចំណែកសត្វតិរច្ឆានដោយសញ្ជាតិញាណវាក៏ស្វែងរកអំណាចឲ្យដល់ខ្លួនឯងទាំងអស់ ដូចសុនខខ្លះវាសំដែងអំណាចរបស់វាដោយលក្ខណៈនៃការសង្កត់សង្កិនគ្នាវាក្នុងពេលវាដែលដណ្តើម អាហារគ្នាស៊ី។ ចំណែកមនុស្សយើង ក្នុងសម័យបូរាណវិញ ការស្វែងរកអំណាច ក៏មិនផ្សេងគ្នាដោយឡែកពីមនុស្សក្នុងសម័យបច្ចុប្បន្ននេះប៉ុន្មានដែរ។

កាលបើសង្គមមនុស្សមានវិវឌ្ឍនាការដោយអារ្យធម៌ វប្បធម៌ ដូចសព្វថ្ងៃនេះ ការដែលមនុស្សនឹងដណ្តើមអំណាចគ្នាតាមអំពើចិត្ត ដូចសម័យបូរាណនោះ រមែងប្រព្រឹត្តទៅមិនបាន។ ព្រោះថាសង្គមមនុស្សយើងមានវិវឌ្ឍនាការជឿនលឿនទៅមុខមកទល់សព្វថ្ងៃនេះហើយ។ ការប្រើអំណាច ក៏តោងប្រព្រឹត្តទៅតាមគោលវិវឌ្ឍនាការ នៃអារ្យធម៌ វប្បធម៌ដ៏ល្អរបស់សង្គមមនុស្ស។ មនុស្សសព្វថ្ងៃនេះ ត្រូវការណាស់នូវអំណាចទាំងនោះ ក៏ព្រោះអំណាច ជាគ្រឿងក្មេងក្មាងក្នុងសង្គមមនុស្សនាបច្ចុប្បន្ននេះ។ អំណាចជាឧបករណ៍ដ៏

សំខាន់បំផុតក្នុងការមានកេរ្តិ៍ឈ្មោះ អំណាច ជាឧបករណ៍ដ៏ឆើតឆាយបំផុត ដែលអាចធ្វើឲ្យសង្គមមនុស្សគោរពកោតក្រែង។

កាលបើអំណាចជាភាគមួយ ដែលអាចធ្វើឲ្យមនុស្សក្លាយទៅ ជាមនុស្សអ្នកធំអ្នកមានកេរ្តិ៍ឈ្មោះ អ្នកមានវេសនា អ្នកសម្បើមឡើងដូច្នេះ។ ក៏មិនជាការប្លែកអស្ចារ្យអ្វីសោះដែលមនុស្សសព្វថ្ងៃនេះ កំពុងតែដណ្ដើមយក ភាពជាអ្នកធំ ជាអ្នកសម្បើម ដោយចង់គ្រប់គ្រងលោកទាំងមូល ដោយគ្មានមនុស្សធម៌។ ការដែលមនុស្សគ្រប់រូបស្វែងរកអំណាចព្រមទាំងសំដែងប្រតិកិរិយាផ្សេងៗ ក្នុងការប្រើឥទ្ធិពលនានា ក៏ព្រោះសញ្ជាតិញាណ នៃការអំនួតនេះ។

សូមឲ្យលោកអ្នកអានជាទីគោរព ងាកនៅមើលសហរដ្ឋអាមេរិច រុស្ស៊ី ឬមហាប្រទេស ដទៃៗ ដែលកំពុង តែដណ្ដើមគ្នាសាកល្បងបរមាណូក្នុងដី ក្នុងទឹក លើគោក លើអាកាស ដែលមិនខ្វីវល់ឈឺក្បាលនឹងសម្រែកត្អូញត្អែរ របស់មនុស្សនិងប្រទេសដែលត្រូវទទួលគ្រោះថ្នាក់នោះៗ តើមិនព្រោះតែអំនួតនៃអំណាចរបស់ខ្លួនទេឬ?

## ៧) ចង់មានកេរ្តិ៍ឈ្មោះ

ពាក្យថា "កេរ្តិ៍ឈ្មោះ" នោះគឺអ្វី? ខ្ញុំបាទយល់ថា លោកអ្នកអានជាទីគោរព អាចជ្រាបបានដោយងាយ។ កេរ្តិ៍ឈ្មោះ ទើបជាអំណាចចំឡែកអស្ចារ្យមួយ ដែលមនុស្សគ្រប់រូបត្រូវការពុំចេះឆ្អែតឆ្អន់សោះ។ សូម្បីយាចក វនិព្វករហូតដល់អ្នកធំសម្បើមៗ ក្នុងលោកនេះក៏តែងតែព្យាយាមយ៉ាងអស់សមត្ថភាព ដើម្បីស្ថិតស្អាងបណ្ដុះបណ្ដាលកេរ្តិ៍ឈ្មោះឲ្យដល់ខ្លួនឯង។ ទោះបីការសាងកេរ្តិ៍ឈ្មោះនោះ នឹងពោរពេញទៅដោយឧបសគ្គនានា ឃាត់ឃាំង រារាំង ឬភយន្តរាយយ៉ាងណាក៏ដោយ។ តែបុគ្គលដែលចង់មានកេរ្តិ៍ឈ្មោះទាំងនោះ ក៏រមែងមិនមានសេចក្ដីរួញរាធុញទ្រាន់យ៉ាងណាសោះឡើយ។ រឿងនេះយើងអាចសង្កេតបានថាអ្នកនយោបាយដែលព្យាយាមសាងខ្លួនឯងដោយសេចក្ដីតស៊ូ ពុះពារ តាមឧត្ដមគតិរបស់គេយ៉ាងក្រៀមមាត់ស្ងួតក្រពះ ដូចអាប់រ៉ាហ័ម លិនខល័ន មហាត្មះគន្ធីជាដើម។ ការដែលបុគ្គលដូចពោលមកហើយទាំងនេះ

គេធ្វើទៅដូច្នេះ តើគេចង់បានអ្វី? មិនមែនចង់បាន "កេរ្តិ៍ឈ្មោះទេឬ?"។ ក្នុងការតស៊ូដែលពោរពេញទៅដោយ ការផ្សងភ័យរបស់គេគ្រប់បែបយ៉ាងនោះ។ គេមានគោលបំណងតែនឹងសាងអនុស្សាវរីយ៍នៃកេរ្តិ៍ឈ្មោះ ទុកក្នុងការកត់ចាំនៃប្រជាពលលោក។ គេត្រូវការឲ្យពិភពលោកកត់សំគាល់គុណសម្បត្តិ សេចក្តីល្អរបស់គេចុះ ក្នុងប្រវត្តិសាស្រ្តនៃជាតិ និង ពិភពលោក។ ទាំងនេះដើម្បីកេរ្តិ៍ឈ្មោះតែម្យ៉ាងប៉ុណ្ណោះ។ មហាត្មៈគន្ធី ទើបបានត្រូវបញ្ចប់ជីវិតរបស់ខ្លួនទៅដោយទារុណបំផុតក្នុងប្រវត្តិសាស្រ្តនៃប្រទេសឥណ្ឌា។ តែសេចក្តីល្អរបស់លោក មហា ត្មៈគន្ធី នោះត្រូវធ្វើឲ្យប្រជាជាតិឥណ្ឌាទាំងមូល តោងសោកសង្រេង និង ស្រោចសម្រក់ទឹកភ្នែក បូជាសេចក្តីល្អ របស់លោក ពេលទាំងផ្ទៃប្រទេស។ កេរ្តិ៍ឈ្មោះទើបជាសារៈសំខាន់មួយ ដែលមនុស្សគ្រប់រូបតែងតែត្រូវការ។ អ្នកណាក៏ដោយ បើត្រូវការកេរ្តិ៍ឈ្មោះត្រូវការឲ្យគេកោតសរសើរ ត្រូវការឲ្យគេលើកតំកើងក៏តោងសាងសេចក្តីល្អគ្រប់យ៉ាងឲ្យមានឡើងយ៉ាង ច្រើនបំផុត ដែលអាចនឹងធ្វើទៅបាន។ ចង់សាងកេរ្តិ៍ឈ្មោះជាអ្នកនយោបាយបែបមហាត្មៈគន្ធី នៃឥណ្ឌា ឬបែប ម៉-ពួងការរេយ៍នៃបារាំងសេស បែបអាប់រ៉ាហ័មលិនខល័ននៃសហរដ្ឋអាមេរិក ឬ វិលិយ៉ាំមភិត (បុត្រ) នៃអង់គ្លេសក៏បាន ចង់សាងកេរ្តិ៍ឈ្មោះបែប ហ្លួយប៉ាស្ទ័រ នៃបារាំងសេស ឬ ធោម័សអិដិស័ន នៃអាមេរិកក៏បាន ឬ ចង់សាងកេរ្តិ៍ឈ្មោះជាអ្នកនិពន្ធបែប ហ្សេវ៉ាន់តេស នៃអេស្ប៉ាញ ឬវ៉ូលទែរនៃបារាំងសេសក៏បាន ជាអ្នកកងទ័ពបែប ណេលស៊ន ឬ ជាអ្នកតន្រ្តីមានឈ្មោះល្បីល្បាញបែប ប៊ីធោហ្វិនក៏ស្រេចតែសេចក្តីប្រាថ្នា និង ការយល់ឃើញរបស់លោកអ្នក ព្រោះថាកេរ្តិ៍ឈ្មោះជាតួនិមិត្តរូបដ៏ប្រសើរ ដែលអាចជួយឲ្យមនុស្សបំពេញករណីយកិច្ចដល់សង្គមមនុស្សបាន។ ការដែលអ្នកនយោបាយត្រូវប្រហារជីវិត? ត្រូវលបលួចធ្វើឃាដ? ត្រូវជាប់គុក? ជាប់ច្រវាក់? ត្រូវនិរទេស? ក៏ព្រោះសេចក្តីប្រាថ្នា ចង់មានកេរ្តិ៍ឈ្មោះ បោះសម្លេងក្នុងសង្គមមនុស្សលោកជាបច្ច័យ ដ៏សំខាន់បំផុត។

បុគ្គលសំខាន់ៗ ក្នុងលោកទាំងជាអ្នកបដិវត្តន៍ អ្នកទស្សនៈវិទូ អ្នកវិទ្យាសាស្រ្ត អ្នកនយោបាយ ជាអាទិ៍ ដូចជា មហាត្មៈគន្ធី វ៉ូលទែរ អាប់រ៉ាហ័ម-លិន

ខល៍ន ណាប៉ូឡេអុង-ប៉ុណាបារត៍។ល។ បុគ្គលទាំងនេះ សុទ្ធតែប្រកដោយចេតនារម្មណ៍របស់ខ្លួនយ៉ាងខ្លាំងក្លា អត់ធ្មត់បំផុត តស៊ូបំផុត នោះ មិនមែនព្រោះប្រាថ្នា សេចក្តីត្រូវការ នូវកេរ្តិ៍ឈ្មោះនោះទេឬ។ កេរ្តិ៍ឈ្មោះនេះហើយទើបជាឈ្នួនអុចឲ្យថាមពលនៃភាពជា អច្ឆរិយបុគ្គលផ្ទុះឧប្បត្តិឡើង។

## ៨) ចង់ធ្វើខ្លួនត្រដែតក្នុងសង្គម

ការសង្គម ត្រូវចាត់បានថា ជាសញ្ញាតិញ្ញាណមួយចំណែករបស់មនុស្ស។ លោក អែហ្សែកនិវត័ន អ្នកវិទ្យាសាស្ត្រ ឈ្មោះល្បីពោលទុកថា "សត្វតិរច្ឆាននៅចេះសមាគមគ្នា ឬ រួបរួមគ្នាជាពួកជាក្រុម ទាំងការសង្គមរបស់សត្វពួកខ្លះកាល បើវាបានរួមគ្នាជាក្រុមហើយ វាក៏ព្យាយាមលើកតំកើងខ្លួនរបស់វាខ្ពស់ឲ្យជាងសត្វដទៃ។ នេះជាការគូសបញ្ជាក់ឲ្យឃើញច្បាស់ថា ក្នុងការសម្តែងរបស់សត្វតិរច្ឆាន វាចេះព្យាយាមលើកខ្លួនវា ឲ្យថ្កុំថ្កើងលេចឡើងដែរ។

ចំណែកមនុស្សយើង ក៏មានទំនងប្រហែលគ្នានឹងសត្វ។ តែក្នុងសម័យបច្ចុប្បន្ននេះមិនមែនអនារ្យយុគឬ យុគថ្មទេ។ ការលើកខ្លួនឲ្យថ្កើនក្នុងសង្គមក៏តោងមិនមែនដូចសត្វ។ ការដែលមនុស្សយើង អាចសាងខ្លួនឲ្យថ្កុំថ្កើង រុងរឿងបាននោះ ត្រូវតែបណ្តុះផ្សាំរុញច្រានខ្លួនឯងឡើងមកក្នុងផ្លូវល្អ ឬ ក្នុងផ្លូវណាមួយ ដែលជាប្រយោជន៍សាធារណៈដើម្បីឲ្យគេនិយមសេចក្តីអង់អាចក្លាហាន និងសេចក្តីល្អផ្សេងៗរបស់ខ្លួន។ បុគ្គលណាក៏ដោយនឹងមានឈ្មោះសម្លេងត្រដែតឡើងក្នុងសង្គមមនុស្សបាននោះ ក៏ព្រោះសេចក្តីស្រវាស្រទេញ (Ambition) ក្នុងការចង់ថ្កើង ចង់មានកេរ្តិ៍ឈ្មោះល្អ។ បើសិនមនុស្សយើងគ្រប់រូបមានសេចក្តីស្ទុះស្ទាស្រវាស្រទេញក្នុងដួងចិត្តហើយ គេទាំងនោះក៏អាចបង្វិលរុញច្រានចិត្តឲ្យកើតអំណាចខ្លាំងក្លា (Will power) ឡើងដូចជំនឿខ្ជាប់ មនោភាព សមាធិ ចិត្តានុភាព។ល។ កាលបើគេបានសាងបុគ្គលិកលក្ខណៈរបស់ខ្លួន ឲ្យថ្កុំថ្កើងរុងរឿង មានកេរ្តិ៍ឈ្មោះដូច្នេះហើយខ្ញុំបាទយល់ថា សេចក្តីត្រូវការចង់ផ្តើមឲ្យមនុស្សនោះក្លាយទៅជា "អច្ឆរិយៈបុគ្គល" បានដោយមិនបាច់សង្ស័យឡើយ។

## ៩) ឧត្តមគតិនៃនយោបាយ

បញ្ហានយោបាយជាបញ្ហាសំខាន់ មានមនុស្សភាគច្រើន ឬ សឹងតែទាំងអស់យល់ថាជាទស្សនៈតែមួយប៉ុណ្ណោះ ក្នុងការដែលនឹងបោះជំហានឡើងទៅកាន់ភាពជាអ្នកធំដុំ ជាអ្នកមានអំណាចវាសនា។ល។ នយោបាយទើប ជារឿងរបស់មហាជន ជារឿងរបស់អ្នកនយោបាយជារឿងរបស់អ្នកស្វែងរកអំណាច ជារឿងរបស់អ្នករកកេរ្តិ៍ឈ្មោះ ជារឿងរបស់អ្នកស្វែងរកទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ ជារឿងរបស់ប្រយោជន៍សាធារណៈ។ ដូច្នោះ ការនយោបាយទើបជាទីយកចិត្តទុកដាក់របស់មនុស្សទូទៅក្នុងសាកលលោក ដែលនឹងស្វែងរកសេចក្តីសុខ ហើយនឹងអំណាចរបស់ខ្លួន។ ដោយហេតុតែនយោបាយជារឿងរបស់ការស្វែងរកសេចក្តីសុខ ហើយនឹងអំណាចរបស់ខ្លួន។ ដោយហេតុតែនយោបាយជារឿងរបស់ការស្វែងរកអំណាច និងសេចក្តីស្តុកស្តម្ភនៃព្រទ្យសម្បត្តិទើបជាហេតុមួយធ្វើឲ្យ មនុស្សទូទៅទាំងសាកលលោកមានសេចក្តីស្ទុះស្ទារស្រវាស្រទេញ (Ambition) ដោយគោលគំនិតដ៏ខ្លាំងក្លាបំផុត (Will power) ចង់លេងនយោបាយ។ ហើយគេទាំងនោះ ក៏ព្យាយាមប្រឹងប្រែងបាចសាចប្រាក់មាសដើម្បីប្រណាំងប្រជែង ជ្រើសរើសការបោះឆ្នោត ដោយពុំបានគិតដល់ហាយនៈភាពដែលអាចនឹងឧប្បត្តិការណ៍ឡើង។ មនុស្សខ្លះមិនអាចនាំខ្លួនឯងឡើងកាន់ភាពជាអ្នកនយោបាយបាន ទោះបីនឹងដោយបុព្វហេតុយ៉ាងណាក៏ដោយ ក៏ព្យាយាមធ្វើគ្រប់វិធីដូចការបដិវត្តន៍ ឬ រដ្ឋប្រហារ។ល។ ដើម្បីដណ្តើមយកភាពជាអ្នកធំក្នុងនយោបាយ។ ទាំងនេះព្រោះ ភាពជាអ្នកនយោបាយគេតែងប្រកាន់ថា "ជាកិត្តិយស ជាការបំពេញប្រយោជន៍ដើម្បីប្រទេសជាតិដើម្បីសាធារណៈប្រយោជន៍"។ អ្នកណាក៏ដោយ ដែលបំពេញខ្លួនជាអ្នកនយោបាយរមែងរកកេរ្តិ៍ឈ្មោះបានដោយរួសរាន់ជាងវិធីដទៃទាំងអស់។ ក្រៅអំពីជាអ្នកមានកេរ្តិ៍ឈ្មោះហើយមនុស្សនៅកោតសរសើរទូទៅពេលទាំងផ្ទៃប្រទេស ព្រមទាំងសម្បូណ៍ហូរហៀរទៅដោយអំណាចវាសនាផ្សេងៗទៀតផង។

ខ្ញុំបាទបានធ្លាប់ពោលមកហើយថា "បំណាច់រង្វាន់របស់អ្នកមានកេរ្តិ៍ឈ្មោះ និងអំណាចក៏គឺកាមារម្មណ៍ និងសេចក្តីសុខសប្បាយនៃជីវិត។ ព្រោះ

បុគ្គលទាំងនោះរមែងរាប់បានថាតែងតែ ស្គប់ស្គល់ដោយលោកីយវិស័យយ៉ាងជោគជាំហើយទាំងពោរពេញទៅដោយកិត្តិយសយ៉ាងខ្ពង់។ សូម្បីតែលោកទាំងនេះ នឹងចាស់ជិណយ៉ាងណាក៏ដោយក៏អាចមានសេចក្តីសុខសម្បូណ៍ហូរហៀរដោយផលនៃកិត្តិយសដែលខ្លួនបានបំពេញមកអំពីអតីតកាល។ ឧត្តមគតិនៃនយោបាយ ទើបជាឋាមពលមួយដ៏សំខាន់ ជួយរុញច្រានឲ្យលោកទាំងនោះក្លាយភាពជា "អច្ឆរិយៈ" បានដូចជំរាបសព្វគ្រប់ មកហើយខាងលើនេះ។

## ១០) ឧត្តមគតិនៃសេចក្តីខ្សត់

សេចក្តីទីទ័លក្រ និងសេចក្តីក្រខ្សត់ ខ្ញុំអាចហ៊ានពោលដោយមិនខ្លាចខុសថា "សេចក្តីទីទ័លក្រជាឧត្តមគតិមួយដ៏សំខាន់ ដែលអាចធ្វើឲ្យមនុស្សរួចផុតពីសេចក្តីស្រេកឃ្លាន និងសេចក្តីខ្វះខាតបានយ៉ាងគួរឲ្យស្ងើច ណាស់ "សេចក្តីទីទ័លក្រ ជាអំណាចមួយដ៏មហស្ចារ្យដែលធម្មជាតិបានស្នើស្នង ឲ្យដល់បុគ្គលក្នុងការស្ទុះស្ទាខ្នះខ្នែងដល់ដំណើរនៃជីវិត។ សេចក្តីទីទ័លក្រ នោះជាឥទ្ធិពលដ៏ចំឡែក ដែលស្និតស្នាងឲ្យមនុស្សត្រូវមានសេចក្តីព្យាយាមពុះពារ និង ខ្នះខ្នែងយ៉ាងខ្លាំក្លាបំផុត ក្នុងការតស៊ូនៃជីវិត ក្នុងការមានជីវិតរស់នៅក្នុងពិភពលោក។ ព្រោះសេចក្តីទីទ័លក្រខ្វះខាតជា មន្តជួយផ្ទុតផ្តើមសមត្ថភាព និងប្រសិទ្ធិភាពរបស់មនុស្សទោះបីក្នុងផ្លូវតក្កវិទ្យា ឬផ្លូវចិត្តវិទ្យា ពោលគឺឧត្តមគតិ សមាធិ មនោភាព ចិត្តានុភាព និង ជំនឿខ្ជាប់ខ្ជួន ។ សេចក្តីទីទ័លក្រ ទើបអាចស្និតស្នាងបណ្តុះបណ្តាលភាពជា "អច្ឆរិយៈ" ឲ្យដល់មនុស្សយ៉ាងគួរអស្ចារ្យណាស់។ អាទិទេពនៃសេចក្តីទីទ័លក្រ អាទិទេពនៃសេចក្តីជិះជាន់មើលងាយអាទិទេពនៃ សេចក្តីខ្វះខាត អាចបណ្តុះបណ្តាលឲ្យស្ថាប័ននៃចិត្តគំនិតមានប្រសិទ្ធិជាពខ្ពង់ខ្ពស់ឡើង រួមទាំងបណ្តុះបណ្តាលឲ្យមនុស្សបង្កើតបុគ្គលិកលក្ខណៈគួរឲ្យឆ្ងល់ណាស់។ បើសិនយើងព្យាយាមសង្កេតពិនិត្យមើលបុគ្គលសំខាន់ៗក្នុងពិភពលោកហើយយើងក៏អាចនឹងឃើញបានភ្លាមភ្លាមថា មនុស្សទីទ័លក្រ មានឱកាសសាងសេចក្តី រុងរឿងថ្កុំថ្កើង ឲ្យពិភពលោកមិនមែនតិចតួចឡើយ ។ ព្រោះសេចក្តីទីទ័លក្របានធ្វើឲ្យឋាមពលនៃភាពជា "អច្ឆរិយៈ"

បដិសន្ធិឡើង។ សេចក្ដីទីទ័លក្រ ទើបជាមន្ដដ៏វិសេស ជាឱសថដ៏សក្ដិសិទ្ធិជា អាវុធសំខាន់ដែលអាចនឹងសាងភាពជា "អច្ឆរិយៈ" ឲ្យដល់មនុស្សបាន។ ខ្ញុំទើបហ៊ានពោលបានថា អាទិទេព នៃសេចក្ដីទីទ័លក្រនោះឯងបានសាង ណាប៉ុឡេងអុង អាប់រ៉ាហ័មលិនខល័ន ចេហ្វីស័ន មុស្សូលិនី ហិត្លែរ អិដិស័ន។ល។ ឲ្យក្លាយទៅជាមនុស្សធំដុំ ជាមនុស្សមានកេរ្តិ៍ឈ្មោះល្បីល្បាញ ពេញទាំងផ្ទៃនៃសាកលលោក យើងហៅថាជា អច្ឆរិយបុគ្គលដូចពោលមកហើយ។

# អាយុជីវិតនៃខេមរជន
# គឺ ជាតិ សាសនា រាជបល្ល័ង្ក

# បទទី២
# ចូរសាងគោលដៅនៃជីវិត

## ១. គោលដៅនៃជីវិតគឺអ្វី?

បើយើងបានសិក្សានូវជីវប្រវត្តិរបស់មនុស្សសំខាន់ៗ ក្នុងលោកហើយ យើងអាចជ្រាបបានថាបុគ្គលសំខាន់ៗ ទាំងនោះមាន Aim ឬ គោលដៅនៃជីវិតយ៉ាងម្តេចខ្លះ។ ពាក្យថា "គោលដៅនៃជីវិត" ខ្ញុំបានសំដៅយកការតាំងមនោបណិធាន ឬ សេចក្តីប៉ុនប៉ងប្រាថ្នាដ៏ទៀងទាត់ពិតប្រាកដក្នុងឆាកជីវិត។ គឺមានសេចក្តីប្រាថ្នាជាអ្នកប្រតិស្ឋ ដ៏មានកេរ្តិ៍ឈ្មោះល្បីល្បាញប្រាថ្នា ជាសិល្បករតួឯងក្នុងលោក ប្រាថ្នាជាអ្នកនិពន្ធដ៏មានកេរ្តិ៍ឈ្មោះក្នុងលោកនៃការនិពន្ធ ដូចហ្សេវ៉ាន់តេស វ៉ូលទែរ។ល។ ឬប្រាថ្នាយ៉ាងណាមួយក្នុងឆាកជីវិត ដូចសេចក្តីប្រាថ្នារបស់ អាប់រ៉ាហ័ម លិនខល័ន នៃសហរដ្ឋអាមេរិកដែលតាំងចិត្តប្រាថ្នាឲ្យបានធ្វើជាប្រធានាធិបតី ហ្គារ៉ៃនៃអ៊ីតាលី មានសេចក្តីប្រាថ្នា ចង់រួបរួមអាណាចក្រនៃអ៊ីតាលីឲ្យទៅជាឯកភាពតែមួយ។ ណាប៉ូឡេអុង-ប៉ូណាបារត៍ មានសេចក្តីប្រាថ្នាជា មហាចក្រព័ត្តគ្រងទាំងពិភពលោក។ ឱស្សា្យរ៉ាអេលី នៃអង់គ្លេសមានសេចក្តីប្រាថ្នាជាអគ្គមហាសេនាបតីទាំងដែលប្រជាជាតិ អង់គ្លេសស្អប់ខ្ពើមគេជាទីបំផុត។ តែ ឱស្សា្យរ៉ាអេលីព្យាយាមជាអគ្គមហាសេនាបតីទាល់តែបាន។

## ២. គោលដៅនៃបុគ្គលសំខាន់ៗ

ចាកទស្សនៈ និងឧទាហរណ៍ដូចពោលមកហើយនោះ បានគូសបញ្ជាក់ឲ្យឃើញច្បាស់ថា "មនុស្សដែលឈាន ឡើងទៅកាន់ភាពរុងរឿងក្នុងឆាកជីវិតបាននោះ សុទ្ធតែជាអ្នកមាន "Aim" ឬគោលដៅនៃឆាកជីវិតដូចគ្នាទាំងអស់។ បានសេចក្តីថា បើសិនជាគេបានតាំងគោលដៅយ៉ាងណាមួយក្នុងឆាកជីវិត

ហើយ គេក៏ត្រូវតែព្យាយាម ពុះពារ ទំលុះទំលាយនូវឧបសគ្គគ្រប់បែបយ៉ាង តទៅ ដោយសេចក្តីមានៈ តស៊ូ អត់ធន់ ជាទីបំផុត។ ទោះបីគោលបំណងនៃឆាកជីវិត របស់គេនឹងពោរពេញទៅដោយឧបសគ្គ និង មហន្តរាយស្ពាត់មុខស្នាក់ក្រោយច្រើនយ៉ាងណាក៏ដោយ។ បុគ្គសំខាន់ៗ ទាំងនោះក៏ព្យាយាមធ្វើតទៅដោយមិនព្រមផ្លាស់ប្តូរប្រែប្រួលគោលដៅនៃជីវិត ដែលខ្លួនបានតាំងសេចក្តីប្រាថ្នាទុក ហើយនោះជាដាច់ខាត។ ក្នុងសច្ចៈសូត្រនៃទស្សនៈរបស់ចិត្តវិទ្យា មានពោលទុកថា "ជំហានទៅមុខរបស់បុគ្គលទាំងនោះទៅនឹងការសាងគោលដៅ នៃជីវិតឲ្យទៀងទាត់ ពិតប្រាថ្នាតែប៉ុណ្ណោះ" (សូមអានជំហានជីវិតដោយអ.ធីរាវុធ) ។ លោកត្រូវការយកកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងផ្លូវណាគឺលោកត្រូវការជាអ្នកនយោបាយ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ដូចលិនខល័ន ម៉ុ-ពួងការេយ៍ មូស្សូលីនី វិន ស្តុនឈឺរ៍ឈិល ។ល។ ឬ លោកត្រូវការ ជាអ្នកនិពន្ធដែលមានកេរ្តិ៍ឈ្មោះកក្រើកក្នុងលោកនៃការនិពន្ធដូច វ៉ុលទែរ ហេរ្វ៉ាន់តេស។ ឬ លោកត្រូវការជាអ្នកប្រតិស្នដែលមាននាមឧត្តោស ដូចហេនរីហ្វរត អិដិស័ន ។ល។ ឬ លោកនឹងមានចំណងនៃឆាកជីវិតយ៉ាងណាក៏ដោយ។ គឺគោលបំណងក្នុងឆាកជីវិតរបស់លោកនេះហើយ ដែលជាឱសថដ៏សក្តិសិទ្ធិមន្តដ៏វិសេស អាវុធដ៏សំខាន់ អាចជំរុញកម្លាំងចិត្តរបស់លោកឲ្យកើតឋាមពលខ្លាំងក្លាឡើងបាន ព្រមទាំងស្អិតស្អាងជីវិតចិត្តថ្លើមរបស់លោក ឲ្យកើតស្វាហាប់ជាពិសេស។ ហើយទាំងអាចបណ្តុះបណ្តាលឲ្យ កើតសមត្ថភាព និងប្រសិទ្ធភាពក្នុងការប្រកបការងារដែលពោរពេញទៅដោយសេចក្តីតស៊ូ អត់អន់ និង រឹងប៉ឹងបំផុត។ ការសាងគោលដៅនៃជីវិតអាចធ្វើឲ្យឋាមពលនៃខួរក្បាលរបស់លោកកើតប្រតិកិរិយា ជាពិសេសរឹតតែខ្លាំងក្លាឡើង។ នេះហើយគឺសមិទ្ធភាពរបស់លោក ដែលអាចនឹងបោះជំហានទៅមុខរបស់មនុស្សឋិតនៅនឹងការសាងគោលដៅ នៃជីវិតឲ្យទៀងទាត់ពិតប្រាកដថា "តើលោកនឹងយកកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងផ្លូវណា"។ គោលដៅនៃជីវិតនេះហើយ អាចជាអាវុធដ៏វិសេសអាចជាមន្តដ៏អស្ចារ្យ អាចជាឱសថដ៏សក្តិសិទ្ធិ ដែលនឹងបណ្តុះបណ្តាលចិត្តគំនិតរបស់លោក ឲ្យមានកម្លាំងនៃការតាំងផ្តើមក្នុងការប្រកបកិច្ចការងារនា

បច្ចុប្បន្ននិងអនាគត។ ទាំងអាចបណ្តុះបណ្តាលសមត្ថភាពនិងប្រសិទ្ធិភាពក្នុងការ ធ្វើការងាររបស់លោកឲ្យ ពោរពេញទៅដោយភាពរឹងប៉ឹងមុះមុត។ ចូរសាងគោលដៅ នៃជីវិតឲ្យពិតប្រាកដទៀងទាត់ ទើបអាចធ្វើឲ្យចិត្តគំនិតរបស់លោកកើតសមាធិ កើតចិត្តានុភាព កើតមនោភាព រួមទាំងកើតសេចក្តីស្រស់បសប្រិមប្រិយគ្រប់យ៉ាង។ បុគ្គលដែលមិនមានគោលដៅនៃជីវិត ភាគច្រើនៗតែជាបុគ្គលរវើរវាយ ច្រិមច្រុំ ទាល់ច្រក សំឡឹងឃើញជីវិតរបស់ខ្លួនឯង ដែលពោរពេញទៅដោយ សេចក្តីល្វិតល្វង់ និងដោយការអស់សង្ឃឹម។ ហើយគេក៏បណ្តែត បណ្តោយជីវិតរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមតែយថាកម្មតាមតែជោគវាសនា។ វាជានាទីនៃសេចក្តីងងឹតងងុល អន្ធការបំផុតរបស់គេ។ គេក្រឡេកឃើញសេចក្តីចំរើន រុងរឿងថ្កុំថ្កើងរបស់អ្នកដទៃរឹងប៉ឹងជាង ថ្លៃថ្នូរជាង ដោយសេចក្តីច្រណែន ឬស្យា និងធុញទ្រាន់។ គេអស់សេចក្តីរាប់អានទុកចិត្តខ្លួនឯងគេអស់សេចក្តីជឿមាំក្នុងខ្លួនឯង គេដាក់ទោស ទៅលើជោគជាតាវាសនានៃជីវិតរបស់គេ ដោយអាងព្រហ្មលិខិតនិង ព្រះអាទិទេព។ គេមិនបានគិតថាបុគ្គលទាំងនោះគេក៏មានសភាពជាមនុស្សដូចគ្នា នឹងមនុស្សគ្រប់ៗរូបបើនឹងមានផ្សេងគ្នាខ្លះ ក៏គឺសេចក្តីឆ្លៀវឆ្លាតក្នុងកលឧបាយនៃជីវិតតែប៉ុណ្ណោះ។ ការមិនមានគោលដៅនៃជីវិត ក៏ជាការគូសបញ្ជាក់ឲ្យយើងឃើញច្បាស់ថា បុគ្គលទាំងនោះដូចនាវាអត់ចង្កូត ឬដូចត្រីស្លាប់អណ្តែតទៅតាមទឹក។ ជីវិតរបស់គេហាក់ដូចជារកសេចក្តីសម្រេចអ្វីគ្មានសោះ ។ ជាងនេះទៅទៀត បុគ្គលទាំងនេះនឹងមិនមានសង្ឃឹម អាចនាំជីវិតឲ្យរុងរឿងថ្កុំថ្កើងទៅមុខ ទាំងក្នុងបច្ចុប្បន្ននិងអនាគត បានជាដាច់ខាត់។

ធេន្និស័ន អ្នកទស្សនៈវិទូបានពោលទុកថា "គ្រាន់តែមានសេចក្តីប៉ុនប៉ងដ៏មុតមាំត្រឹមតែមួយប៉ុណ្ណោះ ក៏អាចធ្វើ ឲ្យមនុស្សជាមនុស្សបាន "។ លោករូបឺតខស្ស៊ែន អ្នកទស្សនៈវិទូនៃអង់គ្លេស បានពោលទុកក្នុងអត្ថបទរបស់លោកថា "អ្នកអស់សង្ឃឹម គឺអ្នកគ្មានបច្ចុប្បន្ន នឹងអានគតសោះឡើយ"។

អាថ៌កំបាំងនៃសេចក្តីចំរើនទៅមុខ អាថ៌កំបាំងនៃការតស៊ូក្នុងឆាកជីវិតក៏គឺចូរសាង "គោលដៅនៃជីវិត" ឲ្យម៉ឺងមាត់ទៀងទាត់ប្រាកដ។ គោលដៅនៃ

ជីវិតត្រូវតែសាងចូលក្នុងផែនគ្រោងការណ៍ ត្រូវតែមានកម្មវិធីនឹងមធ្យោបាយ។ ហើយព្រមជាមួយគ្នានោះលោកត្រូវតែបដិរូបចិត្តគំនិតរបស់លោកឲ្យ គួរគាប់នឹងសង្គមមនុស្ស ឲ្យគួរគាប់នឹងគោលបំណងនៃជីវិតរបស់លោក។ លោកត្រូវតែកំចាត់លក្ខណៈដែលទំនាស់ដល់សេចក្តីចំរើនដូចជាសេចក្តីខ្លាច សេចក្តីអៀនខ្មាស ការមានទិដ្ឋិមានៈ ការភ្លេចភ្លាំង ការស្ទើរស្ទាក់ ការសង្ស័យ ការរើរវាយ។ល។ ឲ្យអស់ពីដួងចិត្ត។ គង់ឲ្យនៅសល់ តែប្រតិកិរិយាដែលអាចនឹងធ្វើឲ្យគោលដៅនៃជីវិតរបស់លោក ជួបប្រសព្វតែជោគល្អ ទាំងប្រទះតែការទទួលបដិសណ្ឋារៈដ៏ថ្លៃថ្នូរ។ ហើយក្នុវេលាជាមួយគ្នានោះទៀត លោកត្រូវតែមានការបដិរូបសមត្ថភាពក្នុងខ្លួនរបស់លោក ឲ្យមានប្រសិទ្ធិភាព ខ្លាំងក្លាឡើង។ គ្រាន់តែមានគោលដៅនៃជីវិតក៏មិនអាចកើតប្រយោជន៍អ្វីក្នុងការបោះបង់ ជំហានឈានទៅមុខទេ។ កុំអាលភ្លេចគោលការណ៍ថា "មនុស្សជាសត្វរដ្ឋ" តាមដែលទស្សនៈវិទូ អរិស្សតូតឹល បានពោលទុកមកនោះ។ មនុស្សត្រូវតែនៅរួមជាមួយគ្នាជាពួក ជាក្រុម តាមសេចក្តីចំរើនរបស់វត្ថុព័ទ្ធឡោម ការសិក្សាលទ្ធិសាសនា។ល។ ដូច្នេះជាដើម។ តែមួយពួកៗនោះក៏មានសេចក្តីចេះគិត សេចក្តីឈ្វេងយល់ឧត្តមគតិ ចរិកប្រពៃណី និង ពិធីការ ផ្សេងៗមិនដូចគ្នា។

សេចក្តីគិតឃើញ និងការឈ្វេងយល់របស់មនុស្សម្នាក់ៗ ក៏រមែងតែងប្រព្រឹត្តទៅតាមឧត្តមគតិរបស់គេ។ កាលបើគោលដៅនៃជីវិតរបស់យើង មានសម្ព័ន្ធភាពទាក់ទង និង មហាជនទូទៅដូច្នេះហើយ យើងត្រូវតែព្យាយាមផ្ទុងផ្តើមកិរិយាមារយាទឲ្យទន់ភ្លន់ (តែមិនទន់ខ្សោយ) សមរម្យព្រមទាំង ឱភាប្រាស្រ័យឲ្យគួរគាប់ តាមសេចក្តីប៉ុងប៉ងរបស់យើង។ សូមជ្រាបថាមិនមាននរណាអបអរសាទរជួយទំនុកបម្រុងយើងទេ កាលបើយើងសំដែងខ្លួនជាបដិប័ក្សនឹងគេជិះជាន់គេ ទំនាស់នឹងគេ សំដែងកិរិយាមិនសុភាពរាបសានឹងគេ ឬ មើលងាយលទ្ធិដែលជាទីគោរពរាប់អានរបស់គេ។ យើងត្រូវតែមានការសង្រួមទុកជានិច្ច យើងមិនត្រូវបណ្តោយខ្លួនឲ្យប្រព្រឹត្តទៅតាមតែអារម្មណ៍ ឬនឹងពោលតាមន័យម៉្យាងទៀត ក៏គឺយើងនឹងធ្វើអ្វីក៏ដោយត្រូវតែប្រើសម្បជញ្ញៈចិត្តជានិច្ចកុំធ្វើទៅដោយប្រាសចាកសតិសម្បជញ្ញៈជាដាច់ខាត។ បុគ្គលដែលបានសំរេច

ក្នុងកិច្ចការផ្សេងៗរាប់ថា ជាបុគ្គលមានចេតនារម្មណ៍យ៉ាងខ្លាំងក្លាបំផុតរាប់ថាបុគ្គល នោះជាអ្នកមានសេចក្ដីប្រាថ្នាខ្ជាប់ខ្ជួន ស្ថាពរក្នុងគោលដៅនៃជីវិតរបស់ខ្លួន។ ទោះបីខ្លួនគេនឹងធ្លាក់ទៅក្នុងភាពដ៏ធ្ងន់ធ្ង ឬ ហេតុការណ៍ដ៏អាក្រក់យ៉ាងណាក៏ដោយ ឬ នឹងត្រូវនិរទេស ត្រូវជាប់គុក ឬ នឹងខុសបំណងភ្លាំងភ្លាត់ប៉ុន្មានដង ប៉ុន្មាន គ្រាក៏ដោយ។ តែគោលដៅនៃជីវិតរបស់គេ ពុំមានថ្ងៃនឹងទ្រុឌទ្រោមឱនថយទៅបានជាដាច់ខាត។ ហេតុផលទាំងនេះ ហើយដែលធ្វើឲ្យមនុស្សក្នុងសាកលលោក បានពើបប្រទះនូវសេចក្ដីចំរើនរុងរឿងថ្កុំថ្កើង រហូតមកទល់សព្វថ្ងៃនេះ។

## ៣. គោលដៅរបស់លិនខល័ន

មានថ្ងៃមួយ លោក អាប់រ៉ាហ័ម លិនខល័ន បានមានប្រសាសន៍នឹងលេខាធិការិនីរបស់លោកថា "ខ្ញុំធ្លាប់បាន ប្រាស្រ័យទាក់ទងនឹងអ្នកធំៗមកជាច្រើន តែខ្ញុំមិនដែលឃើញថាមនុស្សទាំងនោះ "នឹងផ្សេងគ្នាពីមនុស្សធម្មតាសាមញ្ញ យ៉ាងណាបន្តិចបន្តួចសោះ"។

ការពិនិត្យពិចារណារបស់ លិនខល័ន ក្នុងទស្សនៈដែលទាក់ទងនឹងវឌ្ឍនភាព របស់មនុស្សថា សេចក្ដីផ្សេងគ្នារវាងមនុស្ស មិនបាននៅនឹងការគ្រប់គ្រងជីវភាពដែលខ្ពស់ ឬ ទាបជាងគ្នានោះទេ។ តែតាមការពិត វាឋិតនៅនឹងការគ្រប់គ្រងជីវភាពដែលខ្ពស់ ឬ ទាបជាងគ្នានោះទេ។ តែតាមការពិត វាឋិតនៅនឹងការកសាងសេចក្ដីចំរើនវិវឌ្ឍនាការឲ្យដល់ខ្លួនឯងច្រើន ឬ តិចដោយឡែកទេតើ។ លោក លិនខល័ន ជាអ្នកមានគោលដៅ នៃជីវិតយ៉ាងដាច់ខាតពិតប្រាកដ សូម្បីតែជីវិតរបស់លោក នឹងពោរពេញទៅដោយសេចក្ដីទីទ័លក្រតោកយាកសែនវេទនាយ៉ាងណាក៏ដោយ។ តែគោលដៅនៃជីវិត ដែលគេមានចេតនារម្មណ៍ជិតនៅយ៉ាងខ្លាំងក្លានោះ មិនមានការផ្លាស់ប្ដូរសោះឡើយ។ គេប្រើពេលទំនេរទាំងអស់ ស្រាវជ្រាវនិងស្វែងរកចំណេះវិជ្ជា ដោយការអានសៀវភៅពីព្រលឹមទល់ប្រលប់រាល់ៗថ្ងៃ។ ពេលណាដែល លិនខល័ន សំរាកពីការងារ គេត្រូវតែចាប់សៀវភៅអានភ្លាម ពេលមិនធ្វើការ គេអាចមានសៀវភៅ

ជាប់ដៃជានិច្ច។ ពេលឈប់សំរាកធ្វើការ ដែលដំណក់ញើសនៅជោកទាំងរាងកាយគេក៏អានសៀវភៅដោយសេចក្តីពេញចិត្តជាទីបំផុត។ ការអានរបស់គេជាការអានដូចអ្នកសិក្សាគឺអានយកសេចក្តីចូលចិត្តជាគោល ឃើញមានអ្វីសំខាន់ៗ គេក៏ទន្ទេញចងចាំទុកដ៏រាបដល់ជក់ចិត្ត។ ជួនកាល លិនខល័ន តោងធ្វើដំណើរពីទីលំនៅរបស់ខ្លួនទៅផ្លូវឆ្ងាយដើម្បីសុំខ្ចីសៀវភៅគេមកអាន។ ទោះបីជីវិតលិនខល័ន នឹងត្រូវជុនដាបទៅដោយសេចក្តីទីទ័លក្រ ខ្វះខាតយ៉ាងណាក៏ដោយ ទោះបីខ្លួនឯងនឹងមានការក្រខ្សត់ខ្សោយ ដោយប្រាក់កាសយ៉ាងណាក៏ដោយក៏គេនៅតែពុះពារកសាងគោលដៅនៃជីវិតរបស់គេជានិច្ច គេចង់គ្រប់គ្រងតំណែងជាប្រធានាធិបតេយ្យដូច យ៉ជវ៉សស៊្សិងត័ន នៃសហរដ្ឋអាមេរិក។

មានគ្រាមួយ លិនខល័ន បានទៅសុំខ្ចីសៀវភៅរឿង "ជីវិតវ៉ស្សិងត័ន" មកអាន។ លោកលិនខល័ន បានអានរួចក៏បញ្ចេញគោលដៅនៃជីវិតរបស់លោក ដោយចេតនារម្មណ៍ដ៏ខ្លាំងក្លាថាខ្ញុំត្រូវតែជាប្រធានាធិបតីដូច "វ៉ស្សិងត័ន" ឲ្យបាន។ នាង គ្រហ្វ៍រត ស្រ្តីដែលធ្លាប់តែមានសេចក្តីមេត្តាប្រណីដល់ លិនខល័ន ក្នុងការខ្វះខាតជានិច្ចទើបចំអន់លេងថាអ្នកអាចជាប្រធានាធិបតីដែលល្អល្អះ ទៅដោយឧបាយកល និង ត្លុកកំប្លែងគួរឲ្យអស់សំណើចណាស់។ លិនខល័ន បានឆ្លើយតបទៅដោយសេចក្តីទុកចិត្តយ៉ាងមាំក្នុងខ្លួនឯងថា "បានខ្ញុំបានប្រុងប្រៀបស្រេច ហើយរង់ចាំតែឱកាសនឹងមកដល់តែប៉ុណ្ណោះ"។

លិនខល័ន បានសាង និងជម្រុញខ្លួនឯងឡើងមកដោយគោលដៅនៃជីវិតយ៉ាងមុះមុតបំផុតគេមានសេចក្តីប្រាថ្នាប៉ុនប៉ងនូវតំណែងជាប្រធានាធិបតិដូចលោក វ៉ស្សិងត័ន។ គេក៏មានសមត្ថភាពអាចធ្វើទៅបានយ៉ាងពិតប្រាកដគេមានគោលបំណង និង លើកលែងនូវទាសភាពដ៏ទារុណ អាក្រក់ ប្រាសចាកមនុស្សធម៌ ។ គេក៏អាចលើកលែងទាសភាព នោះទាល់តែបានទោះបីអាមេរិកកាំងទាំងប្រទេស នឹងកើតចម្បាំងកាប់សម្លាប់គ្នាឯង ព្រោះតែហេតុនេះអស់វេលាដល់ ទៅ៤ឆ្នាំ ក៏ដោយ។

លោកអ្នកអានជាទីគោរព មនុស្សយើងគ្រប់ៗរូបត្រូវតែសាងគោល ដៅ

នៃជីវិតឲ្យទៀងទាត់ពិតប្រាកដ។ កាលបើមានគោលដៅនៃជីវិតឧប្បត្តិឡើងមក ហើយអំណាចម្យ៉ាងប្លែកពិសេសក៏នឹងបដិសន្ធិឡើងគឺ "អំណាចផ្តួចផ្តើម" ឬ ឋាមពលនៃគារផ្តួចផ្តើម។ អំណាចទាំងនេះជាឋាមពលដ៏អស្ចារ្យដែលនឹងស្ថិតស្ថាងបណ្តុះបណ្តាលឲ្យមនុស្សនោះ ក្លាយទៅជាមនុស្សសំខាន់ឡើងមកបាន។ អំណាចនៃចំពូកនេះ នឹងមានឋាមពលរឹតតែខ្លាំងក្លាឡើងជានិច្ចក្នុងគ្រាដែល គោលដៅនៃជីវិតគោលដៅដ៏ទៀងទាត់ពិតប្រាកដ ព្រមទាំងមានស្ថេរភាពជាស្ថាពរទៅដូច្នេះ។

ត្រកូល រ៉ៃធ៍ ពីរនាក់បងប្អូន គឺ អររិល និង វិលបឺរ៉ៃធ៍ ដែលជាអ្នកឲ្យកំណើតអាកាសយានដំបូងបង្អស់ក្នុងលោក។ គេមានគោលដៅនៃជីវិតក្នុងការសាងអាកាសយានឲ្យសំរេចបាន។ ដោយគោលដៅយ៉ាងខ្លាំងក្លាទៀងទាត់ ដូច្នេះគេក៏បានព្យាយាមមានះតស៊ូទាល់តែសាងអាកាសយានគ្រឿង ដំបូងបង្អស់ឲ្យមានឡើងក្នុងលោកបាន។

ចនវ៉ែនណាមេគ្គឺរ នាយពាណិជ្ជសំខាន់បំផុតក្នុងលោក គេមានគោលដៅនៃជីវិតដើម្បីស្ថាបនាក្រុមហ៊ុនពាណិជ្ជកម្មមួយឲ្យធំបំផុតក្នុងលោក គេក៏អាចពុះពារស្ថាបនាទាល់តែសម្រេចបានពិតប្រាកដ។

## ៤. គោលដៅរបស់យោល័ម្ប៊ែស

លោក គ្រិស្តូហ្វឺរ យោល័ម្ប៊ែស ជាជនមួយរូបទៀតនៅក្រុងហ្សេនូ ដែលមានគោលដៅនៃជីវិតទៀងទាត់ មិនព្រមប្រែប្រួល តាមសេចក្តីយល់ឃើញរបស់ យោល័ម្ប៊ែស គេយល់ថាលោកដ៏មានវិសាលភាពទូលំទូលាយ ដែលយើងអាស្រ័យនៅសព្វថ្ងៃនេះគឺ មានសណ្ឋាននិងលក្ខណៈមូល ជាសេចក្តីយល់ឃើញទំនាស់គ្នាក្នុងសម័យនោះយ៉ាងខ្លាំង ព្រោះអ្នកដទៃគេយល់ឃើញថា លោកដែលយើងអាស្រ័យនៅនេះ មានសណ្ឋានសំប៉ែត។ តែលោក គ្រិស្តូរ យោល័ម្ប៊ែស មានសេចក្តីយល់ឃើញផ្ទាល់ខ្លួនថា ការធ្វើដំណើរពីអឺរ៉ុបសូម្បីនឹងចាប់ផ្តើមពីចំណុចណាមួយក៏ដោយ ដោយបែរមុខទៅកាន់ទិសខាងកើតតែម្យ៉ាង ហើយក៏ត្រឡប់មកកាន់ទីដើមវិញពិទិសបស្ចិម។ ហើយក្នុងទំនងដូចគ្នា

បើបំណងធ្វើដំណើរឆ្ពោះ ទៅកាន់ទិសបស្ចិមតែម្យ៉ាងហើយ នៅទីបំផុតក៏នឹងត្រឡប់មកកាន់ទីដើមវិញបាន ដោយទិសខាងកើត។ នេះជាទ្រឹស្តីរបស់លោក យោល័ម្ប៊ែស ដែលមានសេចក្តីយ៉ាងមាំក្នុងចិត្តថា ត្រូវតែប្រព្រឹត្តទៅតាមទ្រឹស្តីរបស់ខ្លួន។ ទោះបី យោល័ម្ប៊ែស នឹងមានគោលដៅដ៏ពិតប្រាកដប៉ុន្មានក៏ដោយ តែលោក យោល័ម្ប៊ែស ក៏មិនអាចធ្វើដំណើរដោយមូលធនផ្ទាល់ខ្លួនឯងបានឡើយ។ ព្រោះការធ្វើដំណើរតាមគ្រោងការណ៍ យោល័ម្ប៊ែស ត្រូវតែមាននាវាយ៉ាងធំ រួមទាំងកម្មករវានាចំនួនច្រើន ហើយទាំងត្រូវមានស្បៀងអាហារបង្ការទៅផងយ៉ាងគ្រប់គ្រាន់។ តែលោក យោល័ម្ប៊ែស មិនមែនជាអ្នកមានធនធានស្តុកស្តម្ភឡើយ ទើបព្យាយាមត្រិះរិះរកមធ្យោបាយដែលនឹងធ្វើដំណើរតាមផែនការណ៍របស់ ខ្លួនឲ្យបាន។ នៅទីបំផុត លោកគ្រិស្តូរ យោល័ម្ប៊ែស ក៏បានខំប្រឹងសរសេរទ្រឹស្តីនៃការធ្វើដំណើរតាមសមុទ្រ ដោយសព្វគ្រប់ល្អិតល្អន់ឡើង។ ទាំងនេះ ដើម្បីជាការអង្វររកសុំសេចក្តីអនុគ្រោះ ពីបុគ្គលអ្នកទ្រទ្រង់អំណាចធនធានអ្នកធំៗក្នុងរាជរដ្ឋាភិបាល ។ ដំបូងលោក គ្រិស្តូ យោល័ម្ប៊ែស បានសុំជំនួយពីបុគ្គលសំខាន់ៗក្នុងប្រទេសរបស់លោកសិន ហើយតមកទើបចុតហ្មាយស្នើដល់សការរដ្ឋប័រទុយក័លអេស្បាញ និង អង់គ្លេស។ តែសេចក្តីគិតឃើញរបស់លោក យោល័ម្ប៊ែស បានត្រូវចំអកឡកឡឺយឆ្កោះផ្គងមើលងាយទូទៅយ៉ាងខ្លាំង។ ហើយបុគ្គលទាំងនោះ បាននាំគ្នានិយាយតិះដៀល យោល័ម្ប៊ែស ថាជមនុស្សឆ្កួត ជាមនុស្សលីលាមិនបានការ គ្រោងការណ៍របស់គេនោះរមែងជាសេចក្តីពិតទៅមិនបាន។ ដោយហេតុនេះហើយ ទើបគេមិនបានទទួលនូវឧបការៈទំនុកបំរុងសូម្បីតែបន្តិចបន្តួចឡើយ។ ដូច្នោះ យោល័ម្ប៊ែស ទើបមានសេចក្តីសៅហ្មងចិត្តសម្បើមណាស់ដែលត្រូវបានទទួលការផ្តន្ទានឹងមើលងាយយ៉ាងគួរឲ្យខ្លោចផ្សាបំផុត។ សូម្បីតែដូច្នោះក៏ដោយ គេក៏នៅតែពុំទាន់អស់សង្ឃឹមក្នុងគោលដៅចុងចប់របស់ខ្លួន។ នៅទីបំផុតគេបានទៅរកមិត្តរបស់គេម្នាក់ដែលជាបុគ្គលសំខាន់មានកេរ្តិ៍ឈ្មោះ ក្នុងសភាទីប្រឹក្សារាជការអេស្បាញជាទីប្រោសប្រណីរបស់ព្រះចៅ ហ្វឺឌិ ណាន្ទ នៃប្រទេសអេស្បាញ នឹងថាជាជោគវាសនា ឬនឹងថាដោយការមិនព្រមធុញថយក្នុងគោលដៅនៃ

ជីវិត ឬ យ៉ាងណាក៏ដោយ។ គ្រោងការណ៍របស់ឃោល័ម្ប៊ស ជាទីសព្វព្រះរាជហឫទ័យនៃព្រះនាង អេលីហ្សាបេលឡា ដោយទ្រង់ព្រះមហាករុណាមេត្តាប្រោសព្រះរាជទានឲ្យគ្រប់សព្វ។ នាវាដើរសមុទ្រ៣គ្រឿងរួមទាំងកម្មករនាវា ១២០០នាក់ ហើយនឹងគ្រឿងសម្ភារៈដែលចាំបាច់ផ្សេងៗទើបបានរៀបចំធ្វើដំណើរតទៅ។

ដោយសេចក្ដីប៉ុនប៉ង និង ជំនឿខ្ជាប់ក្នុងគោលគំនិតរបស់ខ្លួណ លោក គ្រិស្តូ ឃោល័ម្ប៊ស ក៏បានធ្វើដំណើរចេញ កាលពីថ្ងៃ ៣ សីហា ១៤៩២ ឬ ព.ស ២០៣៥ គេបើកតម្រង់ក្បាលនាវាឆ្ពោះទៅកាន់កោះ គ្មានារីយ៉ាងប្រុងប្រយ័ត្ន។ នាវាបានល្បឿនទៅឆ្ងាយជាលំដាប់រួមវេលាជាងមួយខែប្លាយក៏នៅពុំទាន់មានជ្រុងជ្រោយថានឹងជួបប្រទះកោះ ឬ ភូមិ ឬក៏ផ្ទៃប្រទេសណាមួយឡើយ។ នាវិករទាំងឡាយក៏កើតជ្រួលជ្រើមព្រោះត្រូវពិបាកនឿយហត់ដោយប្រាសចាកសេចក្ដីសង្ឃឹមអ្វីៗទាំងអស់។ ពួកកម្មករនាវា ទាំងនោះចូលចិត្តថាឃោល័ម្ប៊សបានបោកបញ្ឆោតពួកខ្លួនឲ្យទៅស្លាប់។

ពួកនាវិករក៏គិតព្យាយាមរកឧបាយនឹងចាប់ឃោល័ម្ប៊សទម្លាក់ទឹក កាលបើមានព្រឹត្តិការណ៍ដូច្នេះកើតឡើង ឃោល័ម្ប៊ស ក៏ដឹងទាន់នូវប្រតិកិរិយារបស់ពួកនោះជាមុន ទើបបានលួងលោមបង្ហាញហេតុផលឲ្យឃើញជាក់ច្បាស់ដោយប្រការផ្សេងៗទាល់តែនាវិករទាំងនោះទន់ចិត្ត ហើយមានសេចក្ដីយល់ឃើញថា គួរនឹងបង្អង់ទៅសិន។ នៅទីបំផុត គ្រិស្តូ ឃោល័ម្ប៊ស ក៏បានជ័យជំនះ ដោយបានជួបប្រទះនូវលោកថ្មីគឺ ទ្វីបអាមេរិចសព្វថ្ងៃនេះ។

មាន ខគួរឲ្យសង្កេតនូវសេចក្ដីសម្រេចរបស់ឃោល័ម្ប៊ស ជាច្រើនប្រការ គឺ ៖

១. លោកឃោល័ម្ប៊ស មានគោលដៅនៃជីវិតទៀងទាត់ដោយមិនផ្លាស់ប្ដូរ សូម្បីតែត្រូវគេប្រមាថមើលងាយ ឬ ចំអកឡកឡឺយ ផ្ដោះផ្ដងយ៉ាងណាក៏ដោយ ។

២. ឧត្តមគតិរបស់លោក ឃោល័ម្ប៊ស រាប់ថាជាឧត្តមគតិថ្មីបំផុតក្នុងយុគនោះ ទើបជាទីសព្វព្រះរាជហឫទ័យ នៃព្រះនាងអេល្លីហ្សាបេលឡា ដោយ

ទ្រង់ទទួលព្រះរាជឧបត្ថម្ភយ៉ាងរួសរាន់។

៣. ការដែលឃោល័ម្ប៊ែស បានព្យាយាមសរសេរទ្រឹស្តី ការធ្វើដំណើរតាមនាវានោះ រាប់ថាជារបស់ត្រឹមត្រូវណាស់។ ព្រោះមុននឹងឲ្យនរណាជឿជាក់ក្នុងគោលគំនិតរបស់ខ្លួននោះ ត្រូវតែបង្ហាញប្រយោជន៍ឲ្យគេឃើញជាមុនសិនថា នឹងមានប្រយោជន៍យ៉ាងណាខ្លះ តាមក្រោយការណ៍នោះ ។

៤. ឃោល័ម្ប៊ែស ជាបុគ្គលដែលមានចិត្តានុភាពខ្លាំងក្លា (Will power) មុះមុតសំខាន់ណាស់។ ក្នុងពេលដែលនាវិករទាំងឡាយ បានព្យាយាមនឹងចាប់គេបោះទំលាក់ទឹកនោះគេក៏មិនមានសេចក្តីតក់ស្លុតភិតភ័យ តែយ៉ាងណាសោះឡើយ។ ទោះបីតែអន្តរាយផ្សេងៗនឹងមកពីទិសណាក៏ដោយ ឃោល័ម្ប៊ែស ក៏ដាច់ចិត្តផ្សងជីវិតដើម្បីឲ្យសម្រេចតាមគោលដៅនៃជីវិតរបស់ខ្លួនគ្រប់យ៉ាង។

៥. ឃោល័ម្ប៊ែស មានសេចក្តីស្រវាស្រទាញឧបសគ្គយ៉ាងខ្លាំងបំផុត។ ដោយសេចក្តីស្រវាស្រទាញនេះឯង ទើបធ្វើឲ្យឃោល័ម្ប៊ែស មិនព្រមលះបង់គោលដៅរបស់ខ្លួនដរាបដល់ជួបប្រទះនូវសេចក្តីសម្រេច។

៦. សេចក្តីសម្រេចរបស់ ឃោល័ម្ប៊ែស ក្រៅពីខ ១-៥ ដូចពោលមកហើយនេះ គេនៅមានមួយប្រការទៀត ដែលជាប្រការសំខាន់បំផុតគឺ ឃោល័ម្ប៊ែស មានមិត្តម្នាក់ដែលជាអ្នកមានឥទ្ធិពល ជួយទំនុកបំរុងគ្រោងការណ៍របស់គេ។ សេចក្តីសម្រេចរបស់មនុស្សយើង នោះមានខ្លះដែលត្រូវតែអាស្រ័យមិត្តភ័ក្ត ឬ អ្នកជួយទំនុកបំរុងឧបត្ថម្ភផងទើបបានលទ្ធផល ដូច្នេះជាដើម។

## ៥. គោលដៅនៃជីវិតរបស់យ៉ែកឡុនដន

យ៉ែកឡុនដន ជាជនម្នាក់ទៀត ដែលមានកេរ្តិ៍ឈ្មោះដ៏ឆើតឆាយក្នុងលោកនៃការ និពន្ធអាមេរិកកាំង។ គេមានគោលដៅនៃជីវិត ក្នុងភាពជាអ្នកនិពន្ធឯករបស់លោក។ ដើមឡើយ យ៉ែកឡុនដន ជាក្មេងកំសត់ទុកគ័ត រស់នៅ

តាមចិញ្ចើមថ្នល់។ ជីវិតរបស់គេពោរពេញទៅដោយការក្រខ្សត់ រហេមរហាម គ្មានទីលំនៅរសាត់អណ្តែតទៅក្នុងទីផ្សេងៗ។ ជួនកាលគេអែបជ្រកទៅក្នុងរទេះភ្លើង ជួនកាលត្រូវសុំទានគេស៊ីតាមផ្លូវរទេះភ្លើង ជួនកាលត្រូវគេចាប់ហើយក៏ត្រូវពិភាក្សាឲ្យជាប់គុក ក្នុងឋានៈជាមនុស្សគ្មានទីលំនៅពិតប្រាកដ ជួនកាលគេត្រូវទ្រាំស៊ីនំប៉័ងផ្អូម និង ទឹកទទេ ដល់ទៅ៣០ថ្ងៃក្នុងពន្ធនាគារក៏មាន។

ក្រោយពីនោះ មកប្រមាណ៥ឆ្នាំ ក្មេងគម្រក់នេះ ក៏បានក្លាយទៅជាដួងតារាមួយដ៏ត្រចះត្រចង់បញ្ចាំងរស្មី ក្នុងលោកនៃការនិពន្ធរបស់ជាតិអាមេរិកកាំង។ សមាគមអ្នកនិពន្ធរបស់អាមេរិកកាំង បានធ្វើបដិសណ្ឋារៈចំពោះគេដោយឲ្យកិត្តិយសយ៉ាងខ្ពស់។ ទស្សនៈនៃពត៌មានភាគច្រើនបានលើកដំកើងគេថា ជាអ្នកនិពន្ធ ដែលពោរពេញទៅដោយឧត្តមគតិនិងសារៈប្រយោជន៍។ គេមានឈ្មោះល្បីល្បាញយ៉ាងមហោឡារិកពេញទាំងផ្ទៃប្រទេស។

ឋាមពលនៃភាពជា "អច្ឆរិយៈ" ដែលអាចនឹងបណ្តុះបណ្តាល ឲ្យក្មេងអនាថានេះបានល្បីល្បាញឡើងមកនោះគឺ គាប់ជួនថ្ងៃមួយ គេបានដើររសាត់ចូលទៅក្នុងបណ្ណាល័យសាធារណៈមួយកន្លែង។ ដោយមិនតាំងចិត្តមកជាមុន ហើយគេក៏ជ្រើសរើសយកសៀវភៅដែលពោលដល់ប្រវត្តិ "រ៉ូបិស័នគ្រូស" មួយក្បាលមកអាន តែគេមិនមានសេចក្តីប្រាថ្នាចង់ដឹងថាក្នុងការនិពន្ធនោះ តើនឹងមានសារៈសំខាន់អ្វីល្អៗបង្កប់នៅខ្លះ។ ដោយហេតុតែ យ៉ែកឡុនដននេះជាក្មេងដែលធាត់ធំឡើងមកពីជាយទន្លេឆ្នេរសមុទ្រ គេទើបចូលចិត្តរលករំជួយវាលខ្សាច់ដ៏សត្រសុះ កោះដែលលិចឡើងពីផ្ទៃ ទឹកដ៏គួរអភិរម្យ សម្រស់ព្រឹក្សាដ៏ខៀវ ស្រងាត់ខ្ពស់ក្រែងវែងឆ្ងាយ រស្មីព្រះសូរិយាពេញបែកបំផុសស្រោងៗ និងពន្លឺព្រះច័ន្ទដែលកំពុងគ្របដណ្តប់លើផ្ទៃពសុធា បណ្តែតខ្លួនលើផ្ទៃវេហាស៍ចោល ពន្លឺដ៏សែនឆើតឆាយពេលខែភ្លឺ។ គេអានទៅៗរឹតអានរឹតតែជក់ចិត្តជិតថ្លើម បណ្តែតអារម្មណ៍ខ្លាំងឡើងៗ។ ចិត្តក៏ភ្លើតភ្លើននឹងសៀវភៅនោះទាល់តែដល់ថ្នាក់វង្វេង វង្វាន់សឹងឆ្កួតទៅតែម្តង។ គេភ្លេចមិត្ត ភ្លេចស្រែកឃ្លាន ភ្លេចដើរលេងភ្លេចសេចក្តីអាក្រក់អប្បមង្គលផ្សេងៗដោយប្រការទាំងពួង។ ចិត្តា

អារម្មណ៍របស់គេក្នុងពេលនេះពោរពេញទៅដោយសេចក្ដីប៉ងប្រាថ្នា ឬក៏សន្សឹមៗ មានគោលដៅចុងចប់នៃជីវិតកើតឡើងគ្រប់ខណៈ។

លុះព្រឹកឡើងតែព្រលឹម គេក៏តម្រង់ចូលទៅក្នុងបណ្ណាល័យនោះតែម្ដង ហើយជ្រើសយកសៀវភៅដែលគេពេញចិត្តមកអាន។ គេអានចម្រុះមិនថាសៀវភៅអ្វីជាអ្វី លុះអានច្រើនឡើងៗសម្បជញ្ញៈចិត្តរបស់គេ ក៏បែកប្រាជ្ញាព្រោងព្រាតខ្លាំងឡើង។

នៅទីបំផុត គេក៏សម្រេចចិត្តប្ដេជ្ញាដាច់ខាតក្នុងការជាអ្នកនិពន្ធ។ គេអាចសរសេររឿងបានយ៉ាងឆាប់រហ័ស ជាពិសេសគឺក្នុងមួយថ្ងៃ១ គេអាសរសេរបាន ៤-៥ បុង (១៦ទំព័រជា ១បុង)។ តែក៏ខុសបំណង ព្រោះរឿងរបស់គេនៅប្រើការមិនទាន់បានពេញលេញ សម្បជញ្ញៈចិត្តរបស់គេ នៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់។

ទោះបីត្រូវបណ្ណាធិការនៃសារពត៌មាន បញ្ជូនអត្ថបទត្រឡប់មកវិញ ក៏ដោយ តែយ៉ែឡុនដន ក៏មិនរួញរាធុញទ្រាន់ ឬ អស់កំលាំងចិត្តឡើយ។ គេខំប្រឹងសរសេរឲ្យរឹតតែល្អឡើង និងច្រើនឡើងទៅទៀត ដរាបទាល់តែការសរសេររបស់គេបានសំរេចលទ្ធផលដ៏គួររីករាយជាទីបំផុត។

គេបានបញ្ជូនរឿងរបស់គេទៅប្រកួតក្នុងសារពត៌មានមួយច្បាប់ ហើយគេក៏បានទទួលរង្វាន់ជ័យលាភីជាន់ខ្ពស់ តែសភាពសេចក្ដីខ្វះខាតទីទាល់ក្ររបស់គេ ក៏នៅតែមានដូចដើមទោះជាដូច្នេះក៏ដោយ ចេតនារម្មណ៍ក្នុងការនិពន្ធរបស់គេក៏នៅតែខ្លាំងក្លាបំផុត។ នៅទីបំផុតយ៉ែកឡុនដន ក៏ក្លាយទៅជាអ្នកនិពន្ធដែលមានកេរ្ដិ៍ឈ្មោះល្បីល្បាញក្នុងសហរដ្ឋអាមេរិក ដរាបដល់សព្វថ្ងៃនេះ។ សេចក្ដីសំរេចរបស់ យ៉ែឡុនដនដែលប្រព្រឹត្តទៅបានដូចពោលមកហើយនេះក៏ព្រោះ គេមានគោលដៅនៃជីវិតមិនចេះកែប្រែ មិនចេះផ្លាស់ប្ដូរនោះឯង។

លោកអ្នកអានជាទីគោរព ខ្ញុំបាទអាចដឹងបានថា លោកអ្នកអានគ្រប់រូបចង់មានវិវឌ្ឍនភាពនៃជីវិតដូចៗគ្នាទាំងអស់ ខ្ញុំបាទអាចដឹងបានថា លោកមានគោលដៅនៃជីវិតហើយឬនៅ?។ បើសិនលោកនៅមិនទាន់មានគោលដៅ នៃ

ជីវិតទេ លោកគួរតែផ្ដើមសាងគោលដៅនៃជីវិតរបស់លោកបានហើយ។ វិវឌ្ឍនាការផ្សេងៗក៏ជារបស់លោក សេចក្ដីសុខសិរិមង្គលក៏ជារបស់លោក សមិទ្ធិភាពគ្រប់យ៉ាងក៏ជារបស់លោក ទាំងនេះក៏ព្រោះតែលោកមិនបណ្ដែតបណ្ដោយឲ្យជីវិតរបស់លោកប្រាសចាកគោលដៅនៃជីវិត។ គោលដៅនៃជីវិតរបស់លោកក៏នឹងរួបរួមគ្នាជាឋាមពលមួយដ៏វិសេសវិសាល ប្រគល់ឲ្យលោក លោកក៏អាចនឹងតស៊ូក្នុងបញ្ហាជីវិតបានយ៉ាងវិសេសវិសាលបំផុត។ គោលដៅនៃជីវិតរបស់លោកអាចជួយឲ្យលោកផ្លាស់កិរិយា និង គំនិតថ្មីយ៉ាងគួរឲ្យអស្ចារ្យណាស់។ គោលដៅនៃជីវិតធ្វើឲ្យសេចក្ដី ប្រព្រឹត្តថោកទាបរបស់មនុស្សគ្រប់ជាន់ថ្នាក់ ត្រឡប់ក្លាយ ជាមនុស្សល្អក្លាយជាអ្នកយកចិត្តទុកដាក់ក្នុង ការងាររឹតតែខ្លាំងក្លាឡើង។ សេចក្ដីខ្ជិលច្រអូស និងសភាពទន់ខ្សោយនៃចិត្តគំនិតអាចនឹងកើតមានឡើង ក៏ចំពោះតែមនុស្សដែលគ្មានគោលដៅនៃជីវិតទៀងទាត់ប៉ុណ្ណោះ។ មនុស្សដែលគ្មានគោលដៅនៃជីវិត ប្រៀបបាននឹងទូកដែលប្រាសចាកចង្កូតដូចបានពោលមកហើយខាងដើម។ លោកត្រូវតែសម្រេចចិត្ត ប្ដេជ្ញានឹងខ្លួនលោកឥឡូវនេះថាខ្ញុំនឹងធ្វើគ្រប់កម្មវិធីគ្រប់មធ្យោបាយ ព្រទាំងហ៊ានតស៊ូចំពោះឧបសគ្គ និងស៊ូទ្រាំក្នុងការពិបាកផ្សេងៗ ដើម្បីសេចក្ដីសំរេចក្នុង "គោលដៅនៃជីវិតដែលខ្ញុំប៉ុនប៉ងទុក" មុននេះលោកត្រូវទន្ទេញឲ្យជាប់មាត់ជក់ចិត្តតែរៀងរាល់ថ្ងៃ។

គោលដៅនៃជីវិតជាសារៈដ៏សំខាន់បំផុត ជាឱសថមហាសក្ដិសិទ្ធិជាអាវុធដ៏វិសេសវិសាលសំរាប់អ្នកត្រូវការមានជំហានទៅមុខ អ្នកត្រូវការមានវិវឌ្ឍនាការដល់ ខ្លួនឯង (ជំហានជីវិតដោយ អ.ធីរាវុធ)។ មនុស្សដែលចំរើនរុងរោចន៍ក្នុងឆាកជីវិត ក្នុងសង្គមមនុស្សទូទៅ នោះលោកទាំងនោះសុទ្ធតែមានគោលដៅនៃជីវិតទៀងទាត់ពិតប្រាកដជាគោលដៅចុងចប់ទាំងអស់។

ថ្វីបើគោលដៅចុងចប់នៃជីវិតអាចជាទស្សនៈ ឬ ដួងប្រទីបដ៏រុងរោចន៍ក៏ដោយ តែយើងក៏ត្រូវតែមានគុណសម្បត្តិដទៃៗជាច្រើនទៀតប្រកបផង ដូចសេចក្ដីវាងវៃខ្ជាប់ខ្លួនរបស់ខួរក្បាល ការធ្វើអ្វីក៏ឲ្យគាប់គួរនឹងឱកាស ការសេពគប់មិត្តយ៉ាងទូលំទូលាយ ដោយមិនរើសជាន់វណ្ណៈត្រូវតែមានសេចក្ដីក្លាហាន

នឹងតស៊ូចំពោះឧត្តមការណ៍របស់ខ្លួន ព្រមទាំងមានសេចក្ដីស្រវាំស្រទេញចង់រុងរឿងថ្កុំថ្កើងរហូតអស់កាលជានិច្ច។

## ៦. គោលដៅរបស់ប៊ុវលិជ្ជឺរ

ប៊ុវលិជ្ជឺរ ជាជនជាតិហូឡង់ម្នាក់ទៀត ដែលបានអាស្រ័យទូកក្ដោងធ្វើការផ្សងជោគវាសនាទៅក្នុងផែនដី សហរដ្ឋអាមេរិក ដោយគោលដៅនៃជីវិតចង់ជាអ្នកសារពត៌មាន។ ប៊ុវលិជ្ជឺរ ចូលជាន់ដែលដីអាមេរិកដោយហោប៉ៅទទេស្អាត តែចិត្តគំនិតរបស់ ប៊ុវលិជ្ជឺរ ពោរពេញទៅដោយកំលាំងចិត្តខ្លាំងក្លាបំផុត (Will power) ។ សេចក្ដីក្លាហានដែលនឹងត្រូវតស៊ូនូវឧបសគ្គ សេចក្ដីមានះតស៊ូទ្រាំធ្វើការ សេចក្ដីសំរេចចិត្តដោយដាច់ខាត សេចក្ដីស្រវាំស្រទេញប្រាថ្នានូវឈ្មោះសម្លេងដ៏រុងរោចន៍ក្នុងភាពជាអ្នកសារពត៌មាន។ ដោយសេចក្ដីប្រាថ្នាដ៏ខ្លាំងក្លារបស់គេនេះឯង ទើបគេបានធ្វើការជាអ្នកឲ្យពត៌មានប្រចាំក្នុងតំបន់មួយ ហើយអំណើះតមក គេទើបបានទិញកម្មសិទ្ធិ ទិនានុប្បវត្តិ (សារពត៌មាន) មួយដែលមានភាពដុនដាបស្ទើរតែរលុំទៅហើយនោះ។

ប៊ុវលិជ្ជឺរ បានព្យាយាមរកកម្មវិធីនឹងមធ្យោបាយ ដើម្បីកែប្រែសារពត៌មានរបស់គេច្បាប់នេះឲ្យមានប្រសិទ្ធិភាព និង ឥទ្ធិពលជាទីនិយមយកចិត្តទុកដាក់របស់អ្នកអានទូទៅពេញទាំងផ្ទៃនៃប្រទេសអាមេរិក។ ឧត្តមការណ៍ របស់គេក៏បានសមិទ្ធិផលដូចសេចក្ដីប្រាថ្នាគ្រប់យ៉ាង។

ឥឡូវនេះ ប៊ុវលិជ្ជឺរ ក៏បានក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិ ដ៏ស្ដុកស្ដម្ភមហាសាលទៅហើយ។ គេបានសាងគ្រឹះស្ថានមួយខ្នងយ៉ាងខ្ពស់ស្កិមស្កៃទុកជាការិយាល័យសារពត៌មានរបស់គេ ជាគ្រឹះស្ថានដែលខ្ពស់ជាងគ្រឹះស្ថានដទៃទៀតទាំងអស់ ដែលអាមេរិកបានសាងឡើងក្នុងសម័យនេះ ជាមន្ទីរធ្វើការនៃក្រុមបណ្ណាធិការរបស់គេដំបូលរូប ដោម (Dome) ខាងក្នុងដោមក្រាលដោយមាសផែនក្រាស។ ថ្នាក់ក្រោមនៃដោមនេះ ជាមន្ទីរធ្វើការនៃចាងហ្វាងសារពត៌មាន។

នេះគឺគោលដៅនៃជីវិតដែល ប៊ិវលិជ្ជីរ បានតាំងមនោបណិធានទុក ដើម្បីស្ថាបនាខ្លួនគេឲ្យបានជួបប្រទះនូវជោគជ័យក្នុងទីបំផុត។ គោលដៅនៃជីវិត នឹងរុងរោចន៍ហើយអាចឈានទៅកាន់វត្ថុបំណង នឹងសមិទ្ធិគ្រប់យ៉ាងបានដោយរួសរាន នោះតោងតែប្រកបដោយកំលាំងចិត្ត សេចក្តីមានៈ សេចក្តីតស៊ូអត់ធន់ ការធ្វើការយ៉ាងក្តៅក្រហាយ ការសំរេចចិត្តយ៉ាងពិតប្រាកដ ការអប់រំសម្បជញ្ញៈចិត្តឲ្យមានប្រាជ្ញាញាណ ការចេះបង្គាប់ខ្លួនឯងការសេពគប់មិត្ត នឹងការបដិរូបផ្លូវចិត្ត ដែលជាឧបសគ្គដល់គោលដៅនៃជីវិត គោលដៅនៃជីវិតនឹងកើតផលល្អឡើងមកបាន ក៏តោអាស្រ័យគុណសម្បត្តិច្រើនប្រការរួមគ្នាដូចជំរាបមកនេះ។ ប៊ិវលិជ្ជីរ ជារាជានៃសារពត៌មានឡើងមកបានក៏ព្រោះគេលេងចត្រង្គបារាំង នឹងមិត្តម្នាក់ដែលជាម្ចាស់សារពត៌មាននោះ ហើយគេទាំងពីរនោះមានចិត្តគំនិតត្រូវគ្នា ស្និទ្ធស្នាលជាមិត្តភ័ក្តនឹងគ្នា ទើបគេឲ្យ ប៊ិវលិជ្ជីរ បានជាអ្នកឲ្យពត៌មានប្រចាំតំបន់តូចៗរបស់ទិនានុប្បវត្តិច្បាប់ដែលគេបានទិញជាកម្មសិទ្ធិនេះ ។ ក្រៅអំពីត្រូវសាងគោលដៅនៃជីវិតដែលត្រូវតែផ្ទុងផ្តើមខ្លួនឯងដើម្បីឲ្យមានសមិទ្ធិភាពគ្រប់យ៉ាងហើយ គេត្រូវតែមានការបដិរូបទាំងកាយនឹងចិត្តគំនិតឲ្យគាប់គួរដល់គោលដៅនៃជីវិតទៀតផង។ ពាក្យថា "ចិត្តគំនិត" នេះខ្ញុំបាទសំដៅយកការកំចាត់ចំណុតខ្សោយឲ្យចេញផុត ចាកចិត្តគំនិតឲ្យអស់ ដូចសេចក្តីខ្លាច សេចក្តីអៀនខ្មាស សេចក្តីរវើរវាយ សេចក្តីអណ្តែតអណ្តូងនៃចិត្ត សេចក្តីដំអក់ទំរន់ សេចក្តីខ្ជិលច្រអូស សេចក្តីស្ទើរស្ទាក់។ ចំណែករាងកាយនោះក៏ត្រូវតែព្យាយាមថ្នាក់ថ្នមផ្ទុងផ្តើមប្រតិបត្តិឲ្យមាន សុខភាពអានម័យបរិបូណ៌ មាំទាំ ល្មមនឹងតស៊ូនូវបញ្ហា និង ឧបសគ្គនៃជីវិតផ្សេងៗឲ្យកន្លងផុតទៅបាន។ ថ្វីបើលោកនឹងមានគោលដៅនៃជីវិតដ៏មាំទាំងពិតប្រាកដត្រឹមណាក៏ដោយ។ គោលដៅនៃជីវិតរបស់លោកនោះ នឹងមានសមិទ្ធិផលដ៏រុងរោចន៍ក្នុងឆាកជីវិតមិនបានជាដាច់ខាត កាលបើលោកមាននិស្ស័យបណ្តែតបណ្តោយខ្លួនទៅតាមអារម្មណ៍ មិនអាចនឹងបង្គាប់បញ្ជាខ្លួនឯងបាន។ ក្នុងការដែលលោកមានចិត្តគំនិតពោរពេញទៅដោយសេចក្តីកោតខ្លាច ញាប់ញ័រ ភិតភ័យ តក់ស្លុត ក្នុងអន្តរាយផ្សេងៗ ឬក៏លោកមានលក្ខណៈឫកពារ

កិរិយាជាអ្នកប្រកាន់ខ្លួន ការលើកតំកើងខ្លួន ការសង្កត់សង្កិនជិះជាន់អ្នកដទៃ រួមទាំងមិនមានការសមាគមសេពគប់រកអ្នកណាទាំងអស់។ គោលស្និទអ្នកទស្សនៈវិទូល្បីឈ្មោះបានពោលទុកថា "បើមនុស្សកើត មកថាមនុស្សហើយ មិនសមាគមនឹងមនុស្ស តើនឹងហៅថាជាមនុស្សពេញលេញយ៉ាងម៉េចបាន?"។ គោលដៅនៃជីវិតរបស់លោក នឹងបោះជំហានទៅមុខយ៉ាងគួរឲ្យចាប់អារម្មណ៍បាន (ជំហានជីវិតដោយ អ.ធីរាវុធ) ក៏ត្រូវតែបង្ហាញខ្លួន ជាអ្នកមានចិត្តថ្លើមសុភាពរាបសារ ជាអ្នកប្រកបដោយសេចក្តីមេត្តាករុណាដល់ពពួកមនុស្សដូចគ្នា ត្រូវតែចេះចរចាប្រាស្រ័យទាក់ទងដល់មហាជន ដោយសេចក្តីគោរពនូវភាពជាមនុស្សរបស់គេ ដូចគ្នានឹងភាពនៃមនុស្សរបស់ខ្លួន។ សូមជ្រាបថា គោលដៅនៃជីវិតជាអ្នកនិពន្ធ ខ្លះមានគោលដៅនៃជីវិតជាអ្នកនយោបាយខ្លះមានគោលដៅនៃជីវិតជាអ្នកសិល្បករដ៏ល្បីល្បាញ។ល។ គោលដៅនៃជីវិតរបស់តែម្នាក់ៗ ទើបមិនដូចគ្នានឹងគោលដៅដែលខ្លួននឹងឈានឡើងទៅ ។ អ្នកខ្លះមានគោលដៅនៃជីវិតយ៉ាងខ្លាំងក្លាមានសេចក្តីស្រវាស្រទាញយ៉ាងមុតមាំ មានចិត្តានុភាពរឹងប៉ឹងខែងរែងបំផុត មានសេចក្តីមានះអត់ធន់យ៉ាងលើសលុប មានខួរក្បាលដ៏វាងវៃ និងឆ្លៀវឆ្លាតជាពិសេស។ តែគេមាននិស្ស័យមិនល្អអែបជាប់ជិតនៅជាអាទិ៍ ដូចខ្វះសេចក្តីសុភាពរាបសារ មិនចូលចិត្តការសមាគមនឹងអ្នកដ៏ទៃទូទៅ ចូលចិត្តលើកខ្លួនសង្កត់គេ ចូលចិត្តសម្លុតជិះជាន់លើគេ ដោយប្រាសចាកសេចក្តីមេត្តាករុណាដល់ពពួកមនុស្ស មានទិដ្ឋិមានះខ្លាំងក្លា ចូលសង្គមនឹងគេមិនបាន។ មនុស្សទាំងនេះហើយដែលរាប់ថា ជាអ្នកមាននិស្ស័យ និង ចិត្តថ្លើមថាឧបសគ្គដល់គោលដៅនៃជីវិតរបស់ខ្លួន។ លោកអ្នកអានជាទីគោរពនរណាក៏ដោយ ដែលអាចសាងគោលដៅនៃជីវិត ឬព្យាយាមឲ្យព្យាយាមឲ្យសំរេចនូវគោលដៅនៃជីវិតបាននោះ គេត្រូវតែបង្កាប់បញ្ហាខ្លួនរបស់គេឲ្យបានជាមុនសិន។ គេត្រូវតែផ្លាស់ប្តូរកិរិយាដ៏អាក្រក់ ដែលអាចបង្កឲ្យកើតចំណុចខ្សោយនោះឲ្យផុតរលត់ទៅឲ្យសល់តែវត្ថុធាតុដែលជាសារៈប្រយោជន៍ដល់ខ្លួនឯងតែប៉ុណ្ណោះ។ ដូច្នេះមនុស្សទាំងនោះទើបរាប់បានថាជា មនុស្ស

បានស្គាល់ច្បាស់នូវអាថ៌កំបាំងនៃសេចក្តីចំរើនរុងរឿង ទៅមុខរបស់ខ្លួនដោយពេញបរិបូណ៌។

## ៧. គោលដៅរបស់ហ្លូយ ប៉ាស្ទ័រ

រហ្លួយ ប៉ាស្ទ័រ អ្នកគីមីជាតិបារាំងសេស ជាអ្នកមានគោលដៅនៃជីវិតយ៉ាងរឹងប៉ឹងមុតមាំបំផុត គេបានស្រាវជ្រាវ ជួបមេរោគ (Bacteria) មុខគេទាំងអស់ក្នុងលោក។ គេបានពោលឧត្តមគតិដែលគួរយកចិត្តទុកដាក់ថាគួរយកចិត្តទុកដាក់ថាដំបូងបង្អស់ អ្នកចូរសួរខ្លួនឯងសិនថា "វេលានេះខ្ញុំបានខំប្រឹងសិក្សារឿងអ្វីរបស់ខ្ញុំខ្លះ "ហើយកាលបើធំឡើងតទៅខាងមុខ ត្រូវតែសួរខ្លួនឯងដូច្នេះជាដរាបទៅហើយ ក្នុងថ្ងៃណាមួយខាងមុខ លោកអ្នកនឹងបានជួបប្រទះនូវសុភមង្គលយ៉ាងកំពូល ក្នុងការដែលចេះរួបរួមគ្នា ដើម្បីសាងវិវឌ្ឍនភាព និងសុវត្ថិភាពនៃមនុស្សជាតិឲ្យមានជំហានទៅមុខបាន។ ហ្លួយ ប៉ាស្ទ័រ អ្នកគីមីជាតិបារាំងសេស ជាអ្នកមានគោលដៅនៃជីវិតយ៉ាងរឹងប៉ឹងមុតមាំបំផុត គេបានស្រាវជ្រាវ ជួបមេរោគ (Bacteria) មុនគេទាំងអស់ក្នុងលោក។ គេបានពោលឧត្តមគតិដែលគួរយកចិត្តទុកដាក់ថា ដំបូងបង្អស់ អ្នកចូលសួរខ្លួនឯងសិនថា "វេលានេះ ខ្ញុំបានខំប្រឹងសិក្សារឿងអ្វីរបស់ខ្ញុំខ្លះ" ហើយកាលបើធំឡើងទៅខាងមុខត្រូវតែសួរខ្លួនឯងទៀតថា "ខ្ញុំបានធ្វើប្រយោជន៍អ្វីឲ្យដល់ប្រទេសជាតិរបស់ខ្ញុំខ្លះ" កាលបើបានសួរខ្លួនឯងដូច្នេះជាដរាបទៅហើយ ក្នុងថ្ងៃណាមួយខាងមុខ លោកអ្នកនឹងបានជួបប្រទះនូវសុភង្គលយ៉ាងកំពូល ក្នុងការដែលចេះរួបរួមគ្នា ដើម្បីសាងវិវឌ្ឍនភាព និង សុវត្ថិភាពនៃមនុស្សជាតិ ឲ្យមានជំហានទៅមុខបាន។ ឧត្តគតិរបស់ប្រាជ្ញ ប៉ាស្ទ័រ ដែលបានពោលដូចនេះបានគូសបញ្ជាក់ឲ្យយើងគ្រប់គ្នាឃើញថា លោក ប៉ាស្ទ័រ មានគោលដៅនៃជីវិតក៏ពោពេញទៅដោយប្រយោជន៍សាធារណៈជាអតិបរមា។ លោក ប៉ាស្ទ័រ បានប្រើពេលវេលាទាំងអស់ក្នុងឆាកជីវិតរបស់លោក ដើម្បីកិច្ចការស្រាវជ្រាវមេរោគ(Bacteria) ដែលមនុស្សឲ្យទោសដល់មនុស្សយ៉ាងណា? លោកបានស្រាវជ្រាវពិសោធន៍ជួបមេរោគ អែនទ្រេក្ស៍ និងរោគពិសឆ្កែឆ្កួតខាំ ហើយរួម

ទាំងស្រាវជ្រាវជួបតួមេរោគ ដែលអាចធ្វើឲ្យអាហារត្រូវផ្អូមជូរផ្សេងៗទៀត ជាអនេកប្រការ។ ការស្រាវជ្រាវជួបនូវវត្ថុទាំងនេះរបស់លោក ប៉ាស្ទ័រ រមែងកើតប្រយោជន៍ជាអតិបរមាដល់មនុស្សទូទៅក្នុងពិភពលោក។ ហួយ ប៉ាស្ទ័រ មានគោលដៅនៃជីវិតមួយយ៉ាងទៀត គឺការស្រាវជ្រាវឲ្យដឹងច្បាស់ថា "តើ Bacteria អាចមានទោសដល់មនុស្សយ៉ាងណាខ្លះ?" ទាំងនេះដើម្បីជាប្រយោជន៍ ដល់មនុស្សជាតិទូទៅក្នុងសាកលលោក។ ដោយគោលដៅដ៏ទៀងទាត់ពិតប្រាកដរបស់លោក ដូច្នេះ ទើបធ្វើឲ្យលោកមានសមិទ្ធិភាពនិងប្រសិទ្ធភាពក្នុងការស្រាវជ្រាវយ៉ាងមហោឡារិក ព្រមទាំងបានទទួលការទះដៃអបអរសាទរចាកប្រជាជាតិបារាំងសេស គួរឲ្យរំភើបញាប់ញ័រពេញទាំងផ្ទៃប្រទេស ទំនងដូចគ្នានឹងលោក អិដិ ស័ន ដែលបានទទួលការទះដៃសរសើរពីប្រជាជាតិអាមេរិកទាំងមូលយ៉ាងនោះដែរ។

សេចក្តីសំរេចរបស់លោក ប៉ាស្ទ័រ ទាំងនេះ ក៏ព្រោះលោកមានគោលដៅនៃជីវិតមិនព្រមប្រែប្រួលផ្លាស់ប្តូរសោះនោះឯង។ លោកខំព្យាយាមស្រាវជ្រាវមិនចេះរាថយ មិនចេះធុញទ្រាន់សមិទ្ធិភាពដ៏រុងរោចន៍ ទើបឧប្បត្តិឡើងដល់លោកយ៉ាងគាប់ប្រសើរបំផុតដូច្នេះ។

លោកអ្នកអានជាទីគោរព លោកនឹងមានចិត្តានុភាពខ្លាំងក្លាប៉ុណ្ណា លោកនឹងមានសមាធិហ្មឹងហ្មា រឹងប៉ឹងត្រឹមណា លោកនឹងមានសេចក្តីក្លាហាយ៉ាងណាដ៏ដោយ តែបើលោកប្រាសចាកគោលដៅក្នុងឆាកនៃជីវិតក្នុងការឈានទៅមុខ ហើយថាមពល (Will power) ដែលមាននៅក្នុងលោករបស់លោក ក៏មិនអាចមានជំហាន់ទៅកាន់សារៈប្រយោជន៍ ដ៏សំខាន់ដូចប្រាថ្នាបាននៅក្នុងខ្លួនរបស់លោក ក៏មិនអាចមានជំហានទៅកាន់សារៈប្រយោជន៍ ដ៏សំខាន់ដូចប្រាថ្នាបានឡើយ បើសិនជាលោក មិននាំយកចិត្តកម្លាំងកាយ កម្លាំងគំនិត នឹងមធ្យោបាយ គ្រប់បែបយ៉ាងមកបណ្តុះផ្សាំស្អិតស្អាងជាមួយគ្នាផង។

ដូច្នេះ មនុស្សសំខាន់ៗក្នុងពិភពលោកគ្រប់ៗគ្នា គេតែងមានគោលដៅនៃជីវិតរបស់គេទាំងអស់។ ហើយគោលដៅនៃជីវិត ដែលនឹងប្រព្រឹត្តទៅបាន ឬមិនបាននោះ ក៏ត្រូវតែអាស្រ័យកម្លាំងចិត្ត កម្លាំងកាយ និង កម្លាំងគំនិត ទាំង៣

ប្រការនេះជាគ្រឿងជ្រោមជ្រែងផ្ទុងផ្តើម។ ព្រោះគោលដៅនៃជីវិត គ្រាន់តែជាសេចក្តីប្រាថ្នា សេចក្តីបំណង ម្យ៉ាងប៉ុណ្ណោះ និងមានឥទ្ធិពលជំរុញបណ្តុះបណ្តាល សេចក្តីសំរេចឲ្យដល់មនុស្សក៏ទេដែរ។ គោលដៅនៃជីវិត រមែងបិតនៅលើអនុភាពនៃកម្លាំងចិត្ត និងអនុភាពនៃកម្លាំងកាយ។ ទាំងពីរយ៉ាងនេះត្រូវតែមានយ៉ាងគ្រប់គ្រាន់ ព្រមទាំងមានប្រសិទ្ធិភាពផងទើបអាចធ្វើឲ្យគោលដៅនៃជីវិត កើតប្រយោជន៍បានយ៉ាងបូរីបូរណ៍ គោលដៅនៃជីវិត ទើបត្រូវផ្ទុងផ្តើមក្នុងផ្នែកអានុភាព នៃកំលាំងចិត្ត ឲ្យមានប្រសិទ្ធិភាព ផ្ទុងផ្តើមកំលាំងកាយឲ្យមាំទាំធន់ធាន ដើម្បីតស៊ូឧបសគ្គនានា ប្រការដែលអាចនឹងជ្រៀតជ្រែកចូលមកទំនាស់នូវចង្វាក់នៃអភិវឌ្ឍនភាព របស់លោក។ សូម្បីអ្នកដែលមានចំណេះវិជ្ជាជ្រៅជ្រះ មានសមាគមយ៉ាងទូលំទូលាយ មានសេចក្តីអង់អាចក្លាហាន ក៏មិនអាចធ្វើការឲ្យសំរេចបានជាដុំជាកំភួនបានឡើយ។ ទាំងនេះក៏ព្រោះគេមិនបានសាងគោលដៅនៃជីវិតរបស់ខ្លួន ឲ្យកើតមានឡើងដោយពិត ប្រាកដសេចក្តីពេញចិត្ត (ឆន្ទៈ) និងសេចក្តីព្យាយាម (វិរិយៈ) ទាំងនោះមិនបានប្រើឲ្យត្រូវចំតាមគោលដៅ សេចក្តីសំរេចផ្សេងៗ ទើបកើតឡើងដោយឥតខ្លឹមសារ។

បើលោកចង់បានអភិវឌ្ឍនភាព និង សុភមង្គល លោកត្រូវកសាងគោលដៅនៃជីវិតរបស់លោកឲ្យមានសមិទ្ធិភាពឡើងពិត។ អនាគតនៃអភិវឌ្ឍនភាព និង សុភមង្គលកំពុងតែរង់ចាំបម្រើលោកអ្នកហើយ មនុស្សដែលជាអច្ឆរិយបុគ្គលត្រូវតែមានគោលដៅនៃជីវិតយ៉ាងទៀងទាត់ពិតប្រាកដគ្រប់ៗគ្នា។

## ៨. គោលដៅរបស់ម៉ែកដូណល់ដ៍

បុគ្គលដែលគួរនាំមកជាគំរូ ក្នុងរឿងការសាងគោលដៅនៃជីវិត ទាល់តែបានសំរេចដូចបំណងនោះ គឺ លោក វ៉ៃម=រ៉េម ហ្សេយ៍ម៉ែកដូណ៍លដ៍។ បុគ្គលនេះ ជាមនុស្សម្នាក់ទៀតដែលមានសេចក្តីស្រវាស្រទេញ (Ambition) យ៉ាងខ្ពស់ មានសេចក្តីមានះយ៉ាងកំពូលហើយប្រការសំខាន់បំផុតក៏គឺលោកនេះគោលដៅនៃជីវិត ដែលមិនចេះរាថយមាន សេចក្តីប្រាថ្នាមិនចេះផ្លាស់ប្តូរ ព្រមទាំងមានឧត្តមគតិមិនចេះប្រែប្រួលសោះ។ ដោយហេតុនេះឯងយើងគួរតែ

សិក្សា នូវជីវប្រវត្តិរបស់លោកនេះ ឲ្យល្អិតល្អន់បន្តិច ដើម្បីជាគំរូក្នុងបញ្ហាជីវិត ដូចតទៅនេះ។ លោក ម៉ែក ដូណ៍លដ៍ កើតនូវថ្ងៃទី ១៦ តុលា ១៨៦៦ ក្នុង ឡេសហ្ស៊ម័ត ជាតំបន់មួយតូចលើត្រើយម៉ឺរវ៉េយ៍។ ក្នុងគ្រួសាររបស់គេជាគ្រួសារទីទាល់ក្រ បិតាតោងខ្វះខាតត្រូវតែដើរទៅស៊ីឈ្នួលជាកម្មករ អស់រយៈផ្លូវឆ្ងាយជានិច្ច ចំណែកឯមាតា ក៏តោទៅធ្វើជាមេដោះ តែគេបានទទួលការឧបត្ថម្ភ គាំទ្រពីសាច់ញាតិឆ្ងាញៗ ខាងមាតារបស់គេរហូតមក។ ទើបគេបានចូលសិក្សាអក្សរសាស្ត្រក្នុងសាលារៀនមួយ ក្នុងតំបន់នោះ ព្រោះតែគេមានសេចក្តីឈ្លាសវៃ និងមានសេចក្តីអង់អាចជាពិសេសរហូតដល់ មានសេចក្តីព្យាយាមយ៉ាងខ្លាំងបំផុតមិនយូរប៉ុន្មាន ទើបគេបានទទួលជ្រើសតាំងឲ្យធ្វើជាគ្រូបង្រៀន ព្រមទាំងខ្លួនគេក៏បានយកចិត្តទុកដាក់ ស្វះស្វែងរកតំរិះវិជ្ជាតទៅទៀតជានិច្ច ដោយមិនចេះឆ្អែតឆ្អន់សោះ។

វាអាចជាសញ្ញាល័ក្ខណ៍នៃសេចក្តីចំរើន និង ជំហានទៅមុខរបស់លោក ម៉ែកដូណ៍លដ៍ ក៏បានប្រត្យក្សថា លោកនេះមានសេចក្តីជាប់ចិត្ត ដិតថ្លើម ក្នុងធម្មជាតិវិទ្យា សេដ្ឋវិទ្យា តក្កវិទ្យា ទស្សនៈវិទ្យា រហូតដល់រដ្ឋសាស្ត្រផង។ ដោយហេតុតែការយកចិត្តទុកដាក់ក្នុងគោលវិជ្ជាដ៏សំខាន់។ ទាំងនេះ ទើបធ្វើឲ្យលោក ម៉ែដូណ៍លដ៍ កើតមានសេចក្តីប្រាថ្នាខ្លាំងក្លាបំផុតក្នុងភាពជាអ្នកនយោបាយ ដើម្បីបំពេញប្រយោជន៍ដល់សាធារណៈជន និង ប្រទេសជាតិ។ ដើម្បីឲ្យបានសំរេចនូវគោលដៅទាំងនេះ គេទើបបានធ្វើដំណើរទៅកាន់ក្រុងឡុនដុន ដោយចេតនារម្មណ៍ដ៏ពោរពេញទៅដោយ សេចក្តីសង្ឃឹម និង គ្រោងការណ៍នយោបាយ ដោយសេចក្តីប្រាថ្នាដ៏ខ្លាំងក្លា ដោយសេចក្តីស្រវាស្រទេញយ៉ាងរឹងប៉ឹង ដោយគោលបំណងដ៏មុតមាំដូចពោលមកហើយនេះ លោក ម៉ែក ដូណ៍លដ៍ ក៏បានចូលធ្វើការក្នុងដំណែងជាស្មៀនរបស់ក្រុមហ៊ុនដឹកនាំព័ស្ទុផ្សេងៗ ក្នុងឃ្លាំងពាណិជ្ជកម្មមួយ។ ក្នុងវេលាជាមួយគ្នានោះមានពេលទំនេរខ្លះ គេក៏បានព្យាយាម សិក្សាចំណេះវិជ្ជាផ្សេងៗ ដើម្បីប្រលងប្រជែងយកអាហាររូបករណ៍វិទ្យាសាស្ត្រនិយម ដែលជាមូលនិធិរបស់ សៅថ៍ខេន ហែមត៍ន។ ការធ្វើយ៉ាងធ្ងន់ពីរយ៉ាងក្នុងពេលជាមួយគ្នានោះ ជាហេតុធ្វើឲ្យសុខភាពរបស់គេ

ទ្រុឌទ្រោមជា ច្រើន។ តែទោះជាដូច្នេះក៏ដោយ គេក៏បានព្យាយាមយ៉ាងអស់សមត្ថភាព ដើម្បីប្តូរផ្តាច់សមិទ្ធិតែមួយ គឺសេចក្តីសម្រេច តាមគោលដៅនៃជីវិតរបស់គេទាល់តែបាន។ ដោយមកពីសេចក្តីជាប់ចិត្ត ជិតថ្លើមក្នុងទស្សនៈជាអ្នកនយោបាយរបស់ គេនោះឯង គេទើប ចូលទទួលដំណែងជា លេខានុការរបស់លោក ធោម៍សឡូ ដែលជាគូបដិបក្សរបស់គណៈ សៅធ៍អិស លិងតន៍ ក្នុង គ.ស ១៨៨៦។ គេបានធ្វើការក្នុងដំណែងថ្មីនេះរហូតវេលា ៤ឆ្នាំ។ គេបានទទួលនូវចំណេះវិជ្ជាយ៉ាងជ្រៅជ្រះក្នុងផ្លូវនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ហើយនិងកិច្ចការដទៃៗទៀតជាច្រើន។ ដើម្បីទ្រទ្រង់ខ្លួនឯងឲ្យមានប្រសិទ្ធិភាព និង សមត្ថភាពឲ្យបានគួរគាប់នឹង ភាពជាអ្នកនយោបាយរឹតតែច្រើនឡើង លោក ម៉ែកដូណ័លដ៍ ក៏បានព្យាយាមសិក្សាលទ្ធិនោយបាយ លទ្ធិសេដ្ឋកិច្ច លទ្ធិទស្សនៈវិជ្ជា លទ្ធិសង្គមកិច្ច។ល។ បន្ថែមឲ្យជ្រៅជ្រះតទៅទៀត។ ក្នុងពេលនេះគេក៏បានសរសេរអត្ថបទមួយ ស្តែងពីទស្សនៈរបស់គេទាំងក្នុងផ្លូវនយោបាយ និង ផ្លូវសេដ្ឋកិច្ចចុះផ្សាយក្នុងទិនានុប្បវត្តិអង់គ្លេសមួយ ទាល់តែកេរ្តិ៍ឈ្មោះរបស់គេ ខ្ចរខ្ចាទៅពេញទាំងផ្ទៃនៃប្រទេសអង់គ្លេសដោយរួសរាន់។ តែវិធីការសរសេររបស់លោកនេះ អាចធូន់ទៅក្នុងផ្លូវកម្មការច្រើនជាងទស្សនៈវិធីក្នុងបក្សសេរីនិយម។

ក្នុងឆ្នាំ ១៨៩៤ គេមិនអាចស៊ូទ្រាំនៅនឹងឧត្តមគតិ ដែលមិនស្របនឹងនិស្ស័យរបស់គេ។ គេត្រូវតែដោះម្ជួក សុំលាពីបក្សសេរីនិយម ចូលកាន់បក្សកម្មករឥស្សរៈដែលមាន លោកហ្កែន៍ហារ៍ឌី ជាមេដឹកនាំ។ ក្រោយដែលគេបានចូល សង្កាត់បក្សកម្មករឥស្សរៈបានមួយឆ្នាំគេក៏ចូលស្មគ្រ័ជ្រើសតាំងជាសមាជិករដ្ឋសភាពប្រចាំខេត្ត សៅធ៍ហែមតន៍ ក្នុងនាមនៃបក្សសង្គមនិយម ហើយគេក៏ត្រូវបរាជ័យយ៉ាងខ្លោចផ្សារ។ តែការបរាជ័យក្នុងពេលនេះ មិនបានធ្វើឲ្យគោលដៅ នៃជីវិតរបស់គេត្រូវផ្លាស់ប្តូរ ប្រែប្រួលទៅ សូម្បីតែបន្តិចបន្តួចសោះឡើយ។

តមកក្នុង គ.ស ១៨៩៩ គេបានទទួលតែងតាំជាលេខាធិការនៃបក្សកម្មករឥស្សរៈហើយក្នុង គ.ស ១៩០០ ក៏បានស្ម័គ្រចូលប្រណាំងប្រជែងជ្រើស

តាំងជាសមាជិករដ្ឋសភាពនៅ ឡៃសេស្ទ័រ តែក៏ត្រឡប់បរាជ័យម្តងទៀតជាគំរប់ពីរដង។

សូម្បីគេបានភ្លាត់ពីដំណែងសមាជិករដ្ឋសភាក៏ដោយ តែគេក៏បានទទួលការតែងតាំងឲ្យធ្វើជា គណៈទេសមន្ត្រីនាក្រុង ឡុនដុន ក្នុង គ.ស ១៩០១ - ១៩០៤។ លុះដល់ក្នុងឆ្នាំ ១៩០៦ គេបានស្នើរខ្លួនឯង ចូលស្ម័គ្រជ្រើសតាំងជាសមាជិករដ្ឋសភាពម្តងទៀត គេក៏ត្រូវបរាជ័យទៀតក្នុង ឡៃសេស្ទ័រ ដដែលហើយក៏ក្នុង គ.ស ដដែលនោះឯងគេក៏បាន ទទួលការតែតាំងឲ្យធ្វើជាប្រធានគណៈបក្សកម្មករឥស្សរៈ។ ក្នុង គ.ស ១៩១១ គេត្រូវបាត់បង់បុត្រប្រុសមួយរហូតដល់មាតា និង ភរិយាគេមានសេចក្តីខូចចិត្ត និង ទុក្ខទោមនស្សយ៉ាងក្រៃលែង ទើបលាចេញពីប្រធានគណៈបក្សកម្មករ ឥស្សរៈ ហើយក៏នាំគ្រួសារទៅនៅឯ ហែមស្ទេត។

ទោះបីតែគេនឹងពោរពេញទៅដោយការសៅសោក ទុក្ខទោមនស្ស ក្នុងការដែលម្តាយភរិយានិងកូនជាទីស្នេហា បានឃ្លាតចាកចោលទៅដោយមិនមានថ្ងៃនឹងត្រឡប់មកវិញទៀតក៏ដោយ តែដោយភាពជាអ្នកមានចិត្តរឹងប៉ឹងមុតមាំ ព្រមទាំងមានគោលដៅនៃជីវិតទៀងទាត់ពិតប្រាកដដែលគេនឹងត្រូវជាអ្នកដឹកនាំ និង ការគ្រប់គ្រងប្រទេសអង់គ្លេស ឲ្យបាននោះឯងទើបធ្វើឲ្យគេ ត្រូវតែចូលកាន់របបនយោបាយម្តងទៀត។ គ្រានេះ គេបានជាអ្នកដឹកនាំគណៈបក្សក្នុងសភាសាមញ្ញ កិច្ចការដែលគេបានដំណើរមកនេះ បានបង្កើតផលវិសេសវិសាលធំឡើងយ៉ាងមហស្ចារ្យ ទាល់តែសាកលលោកយល់ឃើញថា គេត្រូវតែជាមនុស្សសំខាន់ម្នាក់ក្នុងឋានៈជាអ្នកនយោបាយរបស់អង់គ្លេស។ លុះមកក្នុង គ.ស ១៩១៤ អង់គ្លេស ក៏បានចូលរួមធ្វើសង្គ្រាម តទល់នឹងអាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទី១ តែ ម៉ែក ដូណ៉ាលដ៍ មិនយល់ស្របសោះនឹងគំនិតរបស់រដ្ឋាភិបាលគណៈបក្សសេរីនិយម។ តែរដ្ឋភិបាលគណៈបក្សសេរីនិយមក៏បានយល់ ឃើញនូវការចាំបាច់ ឬ សេចក្តីសំខាន់របស់ ម៉ែក ដូណ៉ាលដ៍ ណាស់ដែរ ទើបបានព្យាយាមអង្វរករ សុំអញ្ជើញឲ្យគេទទួលតំណែងរដ្ឋមន្ត្រីមួយរូបតែវាមិនស្របនឹងឧត្តមគតិរបស់គេ។ ព្រោះថា ឧត្តមគតិរបស់គេនោះ គេត្រូវ

ការឲ្យ សាកលលោកមានតែសន្តិភាព និង សន្តិសុខជានិច្ច គេមិនត្រូវការឲ្យមានសង្គ្រាមទេ គេមានសេចក្តីប្រាថ្នាតែគ្រោងគារពង្រីកចំរើននូវសន្តិភាព និង សន្តិសុខក្នុងលោក រួមទាំងការលូតលាស់ចំរើននូវសេដ្ឋកិច្ច សង្គមកិច្ចដល់សង្គមមនុស្សទូទៅតែប៉ុណ្ណោះ។ ដោយហេតុនេះហើយ ទើបគេលាចេញពីអ្នកដឹកនាំគណៈបក្សជាបន្ទាន់ ហើយគេក៏បានចាប់ផ្តើមសាងទស្សនៈរបស់គេរួមនឹងមិត្តភក្តិដែលមានទស្សនៈ និង ឧត្តមការណ៍ដូចគ្នា ពោលគឺ គេបានចាត់តាំង "យូនៀន អហ្វដេមូគ្រេទិច ខន់ទ្រោល (Union of democratic control)។ ឧត្តមការណ៍របស់គេនេះមានអ្នកឃាត់ឃាំងទំនាស់ច្រើនណាស់ តែភាពជា "អច្ឆរិយៈ" របស់ ម៉ែក ដូណ៉ាលដ៍ មានប្រចាំចិត្តតែមួយគឺ បើតាំងចិត្តនឹងធ្វើអ្វីហើយ ត្រូវតែធ្វើឲ្យទាល់តែបាន មិនព្រមថយក្រោយជាដាច់ខាត។ ក្នុងគ្រប់ៗមជ្ឈដ្ឋាននៃការទំនាស់នានា ប្រការនោះគេក៏នៅតែមានសមត្ថភាពធ្វើទៅតាមទស្សនៈរបស់គេដោយមិនរួញរា ទាំងពោរពេញទៅដោយសេចក្តីដាច់ខាតក្លាហានអស់រយៈកាល ៨ឆ្នាំ។ ក្នុងឋានៈដែលគេស្តែងខ្លួន ឲ្យប្រជាជាតិអង់គ្លេសយល់ឃើញថា ជាអ្នកយកចិត្តទុកដាក់នូវគោលការណ៍នៃសន្តិភាពនេះឯងបានជាហេតុមួយយ៉ាងធំដែលធ្វើឲ្យប្រជាជនអង់គ្លេសស្អប់ខ្ពើមលោកណាស់។ ព្រោះប្រជាជនអង់គ្លេស ក្នុងសម័យនោះ គ.ស ១៩១៤ យល់ឃើញថាសង្គ្រាមជាបច្ច័យមួយដ៏សំខាន់សំរាប់ការពង្រីកទឹកដីរបស់អង់គ្លេស រួមទាំងបញ្ហាសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ឧស្សាហកម្មទៀតផង។ ដោយទស្សនៈរបស់លោក ម៉ែក ដូណ៉ាលដ៍ គឺចង់ឲ្យពិភពលោកមានតែសុខ និង សន្តិភាពពិតប្រាកដនេះឯង។ លោកតាំងចិត្ត នឹងទៅប្រជុំមេគណៈបក្សសង្គមនិយម នៅ ស្តុក់ហោម ក្នុងប្រទេស ស្វិដែន។ តែលោកត្រូវទទួលការទំនាស់ដោយដាច់ខាត ពីអ្នកកាន់អំណាចកប៉ាល់ដើរសមុទ្រ មិនព្រមឲ្យលោកធ្វើដំណើរទៅតាមកប៉ាល់ជាបន្ទាន់ទេ ហើយអ្នកកាន់កាប់កប៉ាល់ទាំងនោះក៏បាន មូលមតិគ្នា មិនព្រមឲ្យលោកទៅតាមចេតនារម្មណ៍របសលោកជាដាច់ខាត។

ក្រោយដែលសង្គ្រាមលោក ១៩១៤ បានអវសានហើយ ប្រត្យក្សថាប្រជាជនអង់គ្លេសបានអស់សេចក្តីជ្រះថ្លា ក្នុងទស្សនៈរបស់លោកយ៉ាងច្រើន

ជាអតិបរមា។ តែទោះជាយ៉ាងណាក៏ដោយ គេក៏នៅតែជឿយ៉ាងខ្ជាប់ខ្ជួន ទាំងប្រាថ្នា យ៉ាងខ្លាំងក្លាតាមគោលដៅរបស់ខ្លួនដោយមិនចេះប្រែប្រួល និងរាថយសោះឡើយ។ ក្នុងឆ្នាំ ១៩១៨ គេបានស្ម័គ្រចូលប្រណាំងប្រជែងជ្រើសតាំងជាសមាជិករដ្ឋសភាម្តងទៀត តែគេក៏នៅតែចាញ់ការជ្រើសតាំងទៀតទាំងនោះជាការគូសបញ្ជាក់ឲ្យឃើញច្បាស់ថា ទស្សនៈ និង ឧត្តមគតិរបស់គេនោះ ប្រជាជាតិអង់គ្លេសទាំងមូលមិនមានជំនឿ និង ជ្រះថ្លា សោះឡើយ។

សូម្បីតែដូច្នេះក៏ដោយ គេក៏នៅតែជឿយ៉ាងមុតមាំថាឧត្តមគតិរបស់គេជាឧត្តមគតិដែលជនជាតិអង់គ្លេសទាំងមូល ត្រូវតែនិយមក្នុងឱកាសតទៅ។

អំណើះតមកទៀត គេក៏បានចាញ់ការបោះឆ្នោតម្តងទៀតនៅ វុលវិជ (Wool Vich) យ៉ាងក្រៀមក្រំបំផុត។ តែគេនៅតែមានឧត្តមការណ៍ដ៏ពិតប្រាកដ ទាំងមានគោលដៅនៃជីវិតក្នុងភាពជាអ្នកនយោបាយយ៉ាងមុតមាំព្រមទាំង មានសេចក្តីប្រាថ្នាយ៉ាងជ្រាលជ្រៅបំផុត ក្នុងចំនុចសន្តិភាព ។ ដោយបុគ្គលិកភាពដូចនេះឯង ទើបធ្វើឲ្យបរិកាសនៃនយោបាយរបស់គេសន្សឹមៗបញ្ចាំងរស្មើឡើងម្តងបន្តិចៗទាល់តែប្រជាជនអង់គ្លេសបានមើលឃើញ សេចក្តីសំខាន់នៃឧស្សាហ៍វិរិយៈ ក្នុងការចាត់របបសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ជាតិឲ្យត្រឹមត្រូវ ទាំងពង្រីកសើររើប្រែប្រួលស្ថេរភាព នៃកម្មករឲ្យមានសេចក្តីសុខសេចក្តីចំរើន រឹតតែច្រើនឡើង។

មានសេចក្តីតាំងចិត្តនៅទីណា ក៏តោងមានសេចក្តីសម្រេចនៅទីនោះ មានគោលដៅនៃជីវិតយ៉ាងណា ក៏តោងបានសំរេច យ៉ាងនោះជាដរាប។

អំណើះតមកទៀត ក្នុងគ.ស ១៩២២ រ៉ែមសេយ៍ ម៉ែកដូណ័លដ៍ បុរសដែលមិនព្រមថយក្រោយ បុរសដែល មិនចេះស្គាល់ការចាញ់ បុរសដែលមិនព្រមលុតជង្គង់ចុះចាញ់នូវឧបសគ្គនានាគ្រប់ប្រការ ក៏ចូលស្ម័គ្រប្រណាំងប្រជែងជ្រើសតាំងជាសមាជិករដ្ឋសភាម្តងទៀត។ តែម្តងនេះគេបានសម្រេចសមដូចសេចក្តីប្រាថ្នារបស់គេ គឺគេបានជាប់ឆ្នោត ជាសមាជិករដ្ឋសភានៅក្នុងខេត្ត អាប៊ីរ៉ាវ៉ន (Aberavon) ដោយបានបានសន្លឹកឆ្នោតច្រើនយ៉ាងគួរឲ្យ ចាប់អារម្មណ៍ជាទីបំផុត។ ហើយគេក៏បានត្រូវជ្រើសតាំងជា ប្រធានគណៈបក្សកម្ម

ករថ្មីម្តងទៀត ដោយបានទទួលសន្លឹកឆ្នោតនិយមច្រើនជាង លោក គ្លីន តែបន្តិចបន្តួចប៉ុណ្ណោះ។ តំណែងដែលបានពោលមកនេះ បានធ្វើឲ្យគេជាអ្នកដឹកនាំគណៈបក្ស ទំនាស់ក្នុងសភាសាមញ្ញយ៉ាងអង់អាចក្លាហាន ទាល់តែកេរ្តិ៍ឈ្មោះរបស់គេ បានខ្ចរខ្ចាវយ៉ាងមហស្ចារ្យ។

ក្នុងការបោះឆ្នោតជ្រើសតាំងសមជិករដ្ឋសភាឆ្នាំ ១៩២២ នេះគណៈបក្សកម្មករបានត្រូវជាប់ឆ្នោតច្រើន (បាន កៅអីច្រើន) ហើយតមកដល់ក្នុងឆ្នាំ ១៩២៤ រដ្ឋបាលរបស់គណៈបក្សខនស៊ីវេទីហ្វ (Conservative Party) របស់លោក បល្ដុវិន ក៏បានពើបប្រទះនូវវិក្រិត្តិកាលដោយបានចាញ់ឆ្នោតនិយមក្នុងញាត្តិ ដោយមិនមានការទុកចិត្ត ។ លោកបល្ដុវិន នាយករដ្ឋមន្ត្រីក៏បានលាលែងចាកតំណែងភ្លាម ហើយតមកពីរបីម៉ោង ក៏បានទទួលការស្នើរសុំឲ្យលោកម៉ែកដូណ័ល ដ៏ចាត់តាំងរដ្ឋាភិបាល។ លោក ម៉ែកដូណ័លដ៏ ក៏ព្រមទទួលការចាត់តាំងភ្លាម។ លុះមកដល់ថ្ងៃទី ២៥ ខែ មករា១៩២៤ យ៉ៃមរៃមសេយ៍ ម៉ែកដូណ័លដ៏ ក៏ចូលទទួលតំណែងនាយករដ្ឋមន្ត្រី ដូចគោលបំណងរបស់គេគ្រប់យ៉ាង ។ ភាសិតអង់គ្លេសមួយប្រយោគមួយថា (Where there is a will there is a way) សេចក្ដីតាំងចិត្តមាននៅទីណា ក៏មានសេចក្ដី សម្រេចនៅទីនោះ។

**( កើតជាខ្មែរ ចិត្តជាខ្មែរ បានចំជាខ្មែរ )**

# បទទី៣
# ជំនឿខ្ជាប់ក្នុងខ្លួនឯង

## ១. ជំនឿខ្ជាប់គឺអ្វី?

បុគ្គលសំខាន់ៗ ក្នុងពិភពលោកដែលបានពើបប្រទះនូវសេចក្ដីសម្រេចដ៏វិសេសក្នុងឆាកជីវិតព្រមទាំងមានអំណាចវាសនាយ៉ាងបរិបូណ៌ រាប់ថាជាបុគ្គលអ្នកមានគុណសម្បត្តិដ៏លើសលប់គឺ "ជំនឿខ្ជាប់ក្នុងខ្លួនឯង"។

ព្រោះសេចក្ដីជឿមាំក្នុងខ្លួនឯង ចាត់ជាឋាមពលមួយដ៏សំខាន់បំផុតសំរាប់បណ្ដុះបណ្ដាលផ្សាំនូវសមិទ្ធិភាព និង ប្រសិទ្ធិភាពគ្រប់យ៉ាងរបស់មនុស្ស។ សេចក្ដីជឿមាំ ឬ ស៊ប់ក្នុងខ្លួនឯងនេះជាវត្ថុធាតុមួយវិសេសបំផុត ក្នុងការស្ថិតស្ថាងនៃជីវិតក្នុងការតស៊ូនៃជីវិត ដើម្បីឧត្ដម ប្រយោជន៍របស់ខ្លួន។ សេចក្ដីជឿស៊ប់មាំពិតប្រាកដទៀងទាត់ មិនថានឹងកើតដល់នរណា នរនោះទោះជាមានបញ្ញា ឬ ល្ងង់ខ្លៅយ៉ាងណាក៏ដោយ សេចក្ដីជឿមាំនោះដូចជាមន្តដ៏វិសេស ជាឱសថដ៏សក្ដិសិទ្ធិ ដែលអាចនឹងស្ថិតស្ថាងឲ្យគេថា "អច្ឆរិយៈ" ដើរ្បងមកទាល់តែបាន។ យើងនឹងប្រកបការងារយ៉ាងណា ទោះជាការងារនោះនឹងពិបាកសែនពិបាកយ៉ាងណាក៏ដោយ តែបើយើងមានសេចក្ដីជឿយ៉ាងមាំហើយ ការងារដ៏ពិបាកទាំងនោះ ក៏អាចនឹងសំរេចទៅបានយ៉ាងពិតប្រាកដ។ តែបើបុគ្គលនោះ មិនជឿខ្ជាប់ក្នុងសមត្ថភាពរបស់ខ្លួនឯង មិនជឿក្នុងសមិត្តិរបស់ខ្លួនឯង ដែលនឹងត្រូវមានឡើងតាមគ្រោងការណ៍ដែលខ្លួនបានគិតទុកមកហើយ។ កិច្ចការទាំងនោះក៏នឹងត្រូវរលុំរលាយជាបន្ទាន់ ព្រះជាម្ចាស់ ព្រះអាទិទេព ឬ ព្រហ្មលិខិត នឹងមិនជួយទ្រទ្រង់មនុស្សទាំងនោះ ឲ្យមានសុវត្ថិភាពជាដាច់ខាត។

## ២. សេចក្តីជឿមាំ និង សេចក្តីសម្រេច

បើសិនអ្នកណាមានសេចក្តីជឿស៊ប់មាំយ៉ាងខ្លាំងក្លាក្នុងខ្លួនឯងហើយ ជំនឿទាំងនោះតែងតែបង្កើតគុណលក្ខណៈ ច្រើនយ៉ាងច្រើនប្រការក្នុងផ្លូវចិត្ត។ ពាក្យថាគុណលក្ខណៈច្រើនប្រការដែលបដិសន្ធិឡើងក្នុងផ្លូវចិត្តនោះ ខ្ញុំបាទសូមកំណត់សំដៅដល់ចិត្ត ដែលកើតសេចក្តីព្យាយាម សេចក្តីអត់ធន់ គោលដៅនៃជីវិត សេចក្តីក្លាហាន សេចក្តីសង្កេត ការតស៊ូ សមាធិ ចិត្តានុភាព មនោភាព។ល។ គុណសម្បត្តិទាំងនេះហើយ ដែលនឹងត្រូវឧប្បត្តិឡើងដល់បុគ្គលអ្នកមានជំនឿយ៉ាងខ្ជាប់ក្នុងខ្លួនឯង។ ជំនឿខ្ជាប់នៅក្នុងខ្លួនឯងច្រើនយ៉ាង ខ្ញុំជឿថាមានប្រយោជន៍ច្រើនជាងឲ្យទោស។ ជំនឿខ្ជាប់មាំជាថាមពល ជាសារៈប្រយោជន៍សំខាន់បំផុតក្នុងការដែលនឹងបោះជំហានទៅកាន់សេចក្តីចំរើន រុងរឿងថ្កុំថ្កើង ជាអតិបរិមា។ តែជំនឿខ្ជាប់ដែលមិនដល់កម្រិតនោះខ្ញុំយល់ថា មិនមានឥទ្ធិពលដែលនឹងអានបណ្តុះបណ្តាល ឲ្យសំរេចប្រយោជន៍អ្វីបានទេ។ ដូចជំនឿដែលផ្អៀងផ្អង ទ្រេតទ្រោត ស្ទើរស្ទាក់ ជាសញ្ញាលក្ខណ៍របស់សេចក្តីទន់ខ្សោយ ជាសញ្ញាលក្ខណ៍របស់សេចក្តីចុះចាញ់ ជាសញ្ញាលក្ខណ៍នៃការប្រាសចាកសេចក្តីអត់ធន់ជំនឿបែបនេះមិនមានសារៈប្រយោជន៍អ្វីសោះក្នុង "សិល្បៈនៃការតស៊ូក្នុងយុគបច្ចុប្បន្ន" នេះឡើយ។ សិល្បៈនៃការតស៊ូក្នុងយុគបច្ចុប្បន្ននេះ ត្រូវតែមានជំនឿយ៉ាង ខ្ជាប់ខ្លួនស្ថិតស្ថាញត្រូវតែមានជំនឿយ៉ាងរឹងប៉ឹងមុតមាំជានិច្ច។ សូម្បីនឹងមានឧបសគ្គរាំងរាឃាត់ឃាំង មកពីគ្រប់ទិសទីយ៉ាងណាក៏ដោយ ក៏មិនអាចនឹងទំលុះទំលាយនូវជំនឿដ៏ខ្ជាប់ខ្ជួន មុតមាំ យ៉ាងនេះទៅបានឡើយ។ ព្រោះជំនឿបែបនេះ វាបានចាក់ឫសយ៉ាងជ្រៅ និងទ្រទ្រង់គុណតំលៃរបស់ខ្លួនវាយ៉ាងរឹងប៉ឹងមុតមាំបំផុត ដូចពោលមកហើយខាងដើម។

បុគ្គលដែលអស់សង្ឃឹមមិនអាចនឹងប្រែប្រួលគន្លងនៃជីវិត ឲ្យល្អឡើងបានក៏ព្រោះមិនមានជំនឿខ្ជាប់ខ្លួនអ្វីក្នុងខ្លួនឯងសោះឡើយ។ គេមិនដឹងថាខ្លួនរបស់គេនោះ នឹងមានអ្វីល្អពិសេសដូចជាអ្នកដទៃគេមានដែរ។ ធម្មជាតិ ឬ ព្រះជាម្ចាស់ មិនបានស្អិតស្អាងឲ្យមនុស្សណាមួយមានសភាព ខ្ពស់ទាប ឬ មានឋានៈខុសគ្នាក្នុងវិថីជីវិតទេ។ តែខ្លួនរបស់ខ្លួនឯងទេតើដែលជាអ្នកស្អិតស្អាង

សេចក្ដីផ្សេងគ្នាឲ្យបង្កើតដល់ខ្លួនឯង។

លោកជ្រាបឬទេថា អ្នកដែលមានកេរ្តិ៍ឈ្មោះខ្ទរខ្ទារ អ្នកដែលធ្វើការធំដុំសំរេចលទ្ធផលច្រើនណាស់មកហើយ នោះគេតែងតែមានការខុសភ្លាត់មកហើយរាប់មិនអស់ ខ្លះក៏ត្រូវរលុំរលាយទ្រព្យសម្បត្តិគ្មានសល់អ្វីសោះ ខ្លះក៏ត្រូវជាប់ពន្ធនាគារ ខ្លះក៏ត្រូវនិរទេស ខ្លះទៀតក៏ត្រូវគេមើលងាយមើលថោក ខ្លះក៏ត្រូវគេដាក់បណ្តាសា និង ផ្តន្ទាទោសគ្រប់ទិសទី។ តែអ្នកទាំងនោះមិនមានការញាប់ញ័រ រាថយ ធុញទ្រាន់ ព្រោះតែការខុសភ្លាត់នោះៗឡើយ តែផ្ទុយទៅវិញវាជាមេរៀនដ៏ថ្លៃថ្លាបំផុត ដែលបង្រៀនឲ្យគេត្រូវកើតជំនឿយ៉ាងមុតមាំក្នុងខ្លួនឯង គោរពរាប់អានខ្លួនឯង ដោយស្មោះស្ម័គ្រ។

ដូច្នោះលទ្ធផលនៃការងារ ដែលគេខំធ្វើក៏បានបង្កើតជាផលសំរេចដូចពោលមកហើយ។

លោកអ្នកសង្ឃឹមសេចក្តីចំរើនលើផ្ទៃរាបនៃពិភពលោកនេះ មេត្តាយល់ថា សេចក្តីចំរើនមិនបានឋិតនៅក្រោមអាណត្តិរបស់កម្មពៀរ ព្រហ្មលិខិត ព្រះអាទិទេព ឬ ព្រះជាម្ចាស់អ្វីទាំងអស់។ តែវាឋិតនៅនឹងខ្លួនរបស់លោកអ្នកតែម្នាក់នោះទេតើ ដែលលោកត្រូវតែមាណ សេចក្តីរឹងប៉ឹង សេចក្តីព្យាយាម ការតស៊ូយ៉ាងប្តូរស្លាប់ប្តូររស់ មានជំនឿយ៉ាងដាច់ខាត និងមុតមាំ ដូចព្រះពុទ្ធម្ចាស់ ព្រះយេស៊ូ ព្រះមហាមាត់ លិនខល័ន ហិត្លែ មុស្សូលិនី ណាប៉ូឡេអុង-ប៉ូណាប៉ាត៍ ។ល។ បុគ្គលទាំងនោះ សុទ្ធតែបានទទួលសេចក្តីខុសបំណងមកហើយក្នុងការតស៊ូលើកដំបូង។ ទើបគេបានក្លាយទៅជាបុគ្គលមានជោគជ័យ និង មានកេរ្តិ៍ឈ្មោះខ្ទរខ្ទាយ ដូចប្រាកដក្នុងប្រវត្តិសាស្រ្តទល់សព្វថ្ងៃនេះ។

មុស្សូលិនី ជាបុគ្គលសំខាន់ក្នុងលោកម្នាក់ គេអាចនាំខ្លួនគេឡើងមកពីឋានៈមនុស្សក្រីក្រទុរគ៌តកំសត់រហាមជាទីបំផុត។ តែជាមនុស្សដែលមានជំនឿមុតមាំក្នុងខ្លួនឯង ។ កាល មុស្សូលិនីបានជាមេផ្តាច់ការក្នុងអ៊ីតាលី ហើយគេក៏បានឲ្យពាក្យស្លោក១ដល់គណៈបក្ស ហ្វាលិស្តរបស់គេថា "បើខ្ញុំឈានទៅមុខចូរអ្នកឈានតាមខ្ញុំទៅ តែបើខ្ញុំឈប់ដើរ ឬ ថយក្រោយចូរអ្នកសម្លាប់ខ្ញុំចោលចុះ" ។

ការដែល មុស្សូលិនី ហ៊ានពោលដូច្នេះ ជាការគូសបញ្ជាក់ឲ្យឃើញច្បាស់ថា មុស្សូលិនីជាមនុស្សដែលមាន ជំនឿជាប់មាំបំផុតក្នុងខ្លួនឯង។ ដោយជំនឿខ្ជាប់នូវខ្លួនឯងយ៉ាងនេះហើយទើបជាជណ្តើមមួយជួយឲ្យ មុស្សូលិនី ឈានឡើងទៅកាន់ភាពជាមនុស្សរុងរឿង ថ្កុំថ្កើងបំផុតក្នុងឆាកជីវិតរបស់គេ។

លោក លិនខល័ន ប្រធានាធិបតី នៃសបរដ្ឋអាមេរិក ដើមឡើងជាមនុស្សក្រីក្រកំសត់ទុរគ៌ត។ តែគេជាអ្នក មានសេចក្តីព្យាយាម រកនរណាស្មើដូចពុំបានឡើយ ។ គេបានកសាងខ្លួនរបស់គេឡើងមកពីសេចក្តីក្រីក្រខ្សត់ទុរគ៌ត ពីជីវិតរសាត់អណ្តែតរកទីពុំនាក់គ្មានជីវិតរបស់លិខលន៍ ក្នុងគ្រាដំបូងនោះពោរពេញទៅដោយសេចក្តីទុក្ខវេទនា។ សូម្បីតែការសិក្សារៀនសូត្ររបស់លិនខលន៍ នឹងតិចតួចស្តួចស្តើងជាទីបំផុតយ៉ាងណាក៏ដោយ សូម្បីតែលិនខលន៍ តោងស៊ីឈ្នួលគេធ្វើការយ៉ាងនឿយហត់ធ្ងន់ធ្ងរ និង លំបាកលំបិនបំផុតក៏ដោយ។ លិនខលន៍ក៏មិនដែលរើសកិច្ចការងារ ដែលស្រួល ដែលសប្បាយធ្វើសោះឡើយ។ ក្នុងរវាងដែលគេកំពុងតែធ្វើការនេះសោត គេក៏ខំសិក្សារៀនសូត្រគណិតសាស្ត្រ ប្រវត្តិសាស្ត្រ និងក្បួនពន្ធផ្សេងៗជានិច្ច។ លិនខលន៍មានជំនឿយ៉ាងមុតមាំខ្ជាប់ខ្ជួនជានិច្ចថា ខ្លួនរបស់គេតោតែនឹងបានជាប្រធានាធិបតីនៃប្រទេស សហរដ្ឋអាមេរិកជាដាច់ខាត ពាក្យពោររបស់ លិនខលន៍ធ្លាប់បានពោលមកដូច្នេះ។ បានក្លាយទៅជារឿងគួរឲ្យអស់សំណើច ដល់អ្នកបានឮបានស្តាប់ជាខ្លាំង។ ព្រោះមិនមាននរណាម្នាក់ បានគិតទុកថា លិនខលន៍ដែលជាមនុស្សខ្វះការសិក្សាហើយទាំងធ្លាប់នូវក្នុងសភាពទីទ័លក្ររហាមដូច្នេះតើនឹងបានធ្វើប្រធានាធិបតី យ៉ាងម៉េច។ ខ្លះក៏ថា លិនខលន៍ ជាមនុស្សឆ្កួតយសសក្តិ ទាំងជាអ្នកពោលពាក្យដែលព្រហើនហួសមាឌពេកទៅ តែគេទាំងនោះមិនអាចយល់បានថា នោះហើយគឺជាជំនឿយ៉ាងមាំ យ៉ាងខ្ជាប់ យ៉ាងខ្លាំងបំផុតរបស់លោក លិនខលន៍។

មនុស្សគ្រប់គ្នា ដែលកើតមកតែងតែមានការព្រហើនហួសទៅខ្លះ តែក៏មិនមាននរណាអាចដឹងថា នោះហើយគឺ "ជាជំនឿយ៉ាងមុខមាំ ខ្ជាប់ខ្ជួន អង់អាចរបស់ លិនខលន៍" ។

មនុស្សរាល់រូបដែលកើតមកក្នុងលោកនេះ តែងតែមានការខុសភ្លាត់ជាធម្មតាតែសេចក្ដីខុសភ្លាត់ទាំងនោះមិន មែនជាឧបសគ្គដ៏កំណាចសាហាវអ្វីទេ។ វាគ្រាន់តែធ្វើចិត្តរបស់គេឲ្យទន់ខ្សោយ ឬ ក៏ធ្វើឲ្យតោងបោះបង់ចោល នូវគោលដៅនៃជីវិតរបស់គេប៉ុណ្ណោះសេចក្ដីខុសភ្លាត់នោះនឹងមានតិចច្រើនយ៉ាងណាក៏ដោយ តែសេចក្ដីភ្លាត់នោះតោង មិនជាការទំលាយនូវជំនឿយ៉ាងមុតមាំខ្ជាប់ខ្ជួនក្នុងខ្លួនរបស់គេបានឡើយ ។ ដូច្នោះសេចក្ដីខុសភ្លាត់ទើបជាមេរៀនជាគំរូដ៏សំខាន់ បំផុតដែលយើងត្រូវតែព្យាយាមកែខៃ ដើម្បីឲ្យខ្លួនឯងបានមានប្រសិទ្ធិភាពល្អ ត្រឹមត្រូវល្អឡើង។

## ៣. ជំនឿខ្ជាប់របស់ អេជិស័ន

ធោមស៍ អេជិស័ន អ្នកប្រឌិតល្បីឈ្មោះនៃអាមេរិក ដើមឡើយគេធ្លាប់ជាមនុស្សក្រីក្រតោកយ៉ាក ទុរគត៌ កំសត់រកព្រឹកខ្វះល្ងាច មានល្ងាខ្វះព្រឹក។ គេក៏បានធ្លាប់ខុសភ្លាត់ក្នុងឆាកជីវិតក្នុងការប្រឌិតរបស់ខ្លួនគេ ច្រើនលើកច្រើនគ្រារាប់មិនអស់។

មានគ្រាមួយ អេជិស័ន បានតាំងគោលគំនិតគិត និងស្រាវជ្រាវរែកញែកមាសស្រួយបែបថ្មី។ អេជិស័ន ជឿ ខ្ជាប់មាំក្នុងចិត្តថា តោងតែបានជួបប្រទះនូវសេចក្ដីសម្រេច យ៉ាងពិតប្រាកដ ដោយជំនឿយ៉ាងមុតមាំក្នុងផលសំរេចនេះឯង ទើបគេចុះដើមទុនយ៉ាងមហាសាលហើយធ្វើយ៉ាងសង្វាតខ្នះខ្នែងបំផុតអស់វេលាដល់ទៅ៣ឆ្នាំ គេបានខំចំណាយ ទាំងប្រាក់កាសនិងវេលាជាច្រើនបំផុត តែក៏មិនបានសំរេចផលដូចសេចក្ដីប្រាថ្នាឡើយ។ សេចក្ដីខុសភ្លាត់របស់អេជីស័ន ក្នុងគ្រានោះ មិនបានធ្វើឲ្យគេអស់សេចក្ដីសង្ឃឹម ឬ ថយជំនឿយ៉ាងខ្ជាប់ខ្ជួនក្នុងខ្លួនគេសោះឡើយ។ គេប្រកាន់ថា សេចក្ដីខុសភ្លាត់របស់គេនោះជាមេរៀនដ៏សំខាន់បំផុតដែលធ្វើឲ្យគេត្រូវអប់រំខ្លួនឯង ឲ្យមានសមត្ថភាពរឹតតែច្រើនឡើង លុះតមកគេក៏ចាប់ផ្ដើមការសាកល្បងម្ដងទៀត ក៏បានសំរេចដូចសេចក្ដីបំណង គ្រប់ប្រការ។ រូប៉ឺតខេនេគ្គីយ៍ខ័នខៃនអ្នកឧស្សាហកម្មល្បីឈ្មោះម្នាក់ពោលថា "គេតោខូចពេលវេលាទៅយ៉ាងយូរ ក្នុងការស្រាវជ្រាវរឿងផ្សិត

តែគ្មានបានលទ្ធផលអ្វីសោះ ក្នុងការស្រាវជ្រាវនោះ។ តែវាមិនបានទំលាយជំនឿដ៏ខ្ជាប់ខ្ជួន រឹងប៉ឹង របស់គេទេ វាត្រឡប់ជាធ្វើឲ្យគេមានចិត្តរឹងរឹតតែ ខ្លាំងក្លាឡើងទៅទៀត។ អាឡិកសាន់ដឺរក្រេហែម អ្នកជំនាញក្នុងការប្រឌិតគ្រឿងទូរស័ព្ទ ក៏បានខូចពេលវេលាជាច្រើនឆ្នាំក្នុងការព្យាយាមធ្វើឲ្យសត្វចៀមមានកូនច្រើន។ ខាទរ៉ៃទ៍ អ្នកប្រឌិតគ្រឿងចក្រតំបាញ ក៏តោងខូចវេលាទៅជាច្រើនឆ្នាំ ដោយឥតប្រយោជន៍ ក្នុងការព្យាយាមធ្វើម៉ាស៊ីនកប៉ាល់ដោយចំហាយផ្ទះនៃរំសេវ ដោយប្រាសចាកសេចក្តីសម្រេច។ រូប៊ឺត ហ្វុលត័ន មានអាជីវកម្មក្នុងការគូររូបភាពផ្សេងៗលក់ បុគ្គលនេះឯងដែលគិតសាងកប៉ាល់មុចទឹក សំរេចបានមួយគ្រឿង ឲ្យឈ្មោះថា "ណាទិ្ធលុស" ។ ដុកទ័រស៊ុនយ៉ាតសេន អ្នកបដិវត្តនៃជនជាតិចិនទំរាំនឹងធ្វើការបដិវត្តន៍រាជវង្សម៉ែនចូបានសំរេច គេតោងធ្វើការបដិវត្តន៍ដល់ទៅ ១១ដងទើបបានសំរេចផលឡើង គេមានការខុសភ្លាត់ក្នុងការបដិវត្តន៍នេះ ដល់ទៅ១០ដង។ សេចក្តីខុសភ្លាត់របស់មនុស្សដែលយកចិត្តទុកដាក់ក្នុងជំហានរបស់ខ្លួននោះ រមែងមាននៅជានិច្ច (ជំហានជីវិតដោយ អ.ធីរាវុធ) សេចក្តីខុសភ្លាត់មានច្រើនប៉ុន្មាន ក៏នឹងបង្កើត សេចក្តីស្ទាត់ជំនាញឲ្យដល់យើងច្រើនប៉ុណ្ណោះ។ តែសំខាន់ដែលយើងតោងតែចាំទុកឲ្យ ខ្ជាប់មាំក្នុងចិត្តនោះ គឺសេចក្តីខុសភ្លាត់ទាំងនោះ មិនបានធ្វើឲ្យយើងត្រូវទន់ខ្សោយ មិនបានធ្វើឲ្យយើងត្រូវរាថយ ឬ ក៏មិនបានធ្វើឲ្យយើង តោងអស់សេចក្តីព្យាយាម និងសេចក្តីសង្ឃឹមសោះឡើយ។ សេចក្តីខុសភ្លាត់ ទើបជាសិល្បៈ ឬ មេរៀនមួយដ៏វិសេស ដែលនឹងជួយឲ្យយើងមានជំហានទៅកាន់សេចក្តី រុងរឿងថ្កុំថ្កើងបាន តែយើងត្រូវតែមានជំនឿ យ៉ាងមុតមាំបំផុតក្នុងខ្លួនឯងជានិច្ច។ បើសិនសេចក្តីខុសភ្លាត់ បានទំលាយជំនឿយ៉ាងមុតមាំរបស់យើងហើយជំហានទៅមុខរបស់យើងក៏ត្រូវឈប់ភ្លាម។ ដូច្នោះ យើងមិនត្រូវបោះបង់ចោលនូវគោលដៅនៃជីវិតរបស់យើងជាដាច់ខាត។ យើងតោងគិតជានិច្ចថាសេចក្តីខុសភ្លាំងភ្លាត់ជារបស់ធម្មតា ណាប៉ូឡេអុង ឡេនីន ស្តាលីន។ល។ មុននឹងគេរុងរោចន៍ឡើងមកបាននោះ គេតោងមានការខុសភ្លាំងភ្លាត់រាប់មិនអស់។ តែសេចក្តីខុសភ្លាំងភ្លាត់ទាំងនោះ មិនមែនជាឧបសគ្គអ្វីដែលនឹងធ្វើឲ្យកើតទម្ងន់ដល់ខ្លួនគេឡើយ ។ គេ

ត្រឡប់ជាមានកម្លាំងចិត្ត និង សេចក្តីព្យាយាមកាន់តែខ្លាំងក្លាឡើង កាលបើគេមានជំនឿយ៉ាងខ្ជាប់ខ្ជួនមុនមាំរឹងប៉ឹងដូច្នោះ ទើបធ្វើឲ្យគេបានឈានចាកបុគ្គលធម្មតាសាមញ្ញ ក្លាយទៅជាមនុស្សមានកេរ្តិ៍ឈ្មោះល្បីល្បាញ ពេញទាំងផ្ទៃពិភពលោកទល់សព្វថ្ងៃនេះ។

អ្នកចិត្តវិទ្យាក្នុងយុគបច្ចុប្បន្ន បានមូលមតិយល់ស្របគ្នាថា "ជំនឿខ្ជាប់ក្នុងខ្លួនឯង" ជាព្រហ្មលិខិត ជាអាទិទេព នៃជំហានទៅមុខរបស់មនុស្ស ជាលិខិតកំនត់ឲ្យមនុស្សមានឋានៈទាបខ្ពស់ ក្រមាន ក្នុងវិថីនៃជីវិតខុសគ្នា។ យើងតោងគិតជានិច្ចថា មិនមានអ្វីក្នុងពិភពលោកនេះដែលយើងនឹងធ្វើមិនបាន មិនមានអ្វីក្នុងលោកនេះដែលយើងនឹងអនុវត្តន៍ទៅមិនកើតបើសិនវត្ថុទាំងនោះមិនហួសលើសធម្មជាតិ។

មនុស្សយើងគ្រប់រូប រមែងមានជំនឿក្នុងខ្លួនមិនច្រើនក៏តិច ខ្លះមានជំនឿក្នុងខ្លួនឯងតិចហួសពេកទៅលែងទុកចិត្តខ្លួនឯង តោងធ្វើជោគវាសនានឹងអ្នកដទៃអស់មួយជីវិត ខ្លះក៏មានជំនឿក្នុងខ្លួនឯងច្រើនហួសពេកទៅ ទាំងពីរប្រការនេះ មិនអាចនាំផលល្អមកកាន់ខ្លួនឯងណាស់ណាទេ ព្រោះជំនឿមិនបរិបូរណ៍គ្រប់គ្រាន់ ឬ ល្មមដូចពោលមកហើយខាងដើម។ កាលបើលោកមនុស្ស ជាលោកដែលពោរពេញទៅដោយការតស៊ូ ហើយក៏ការតស៊ូរបស់មនុស្សនោះសោតជួនកាលក៏មានជ័យជំនះ មានកេរ្តិ៍ឈ្មោះ ជួនកាលក៏តោងចាញ់យ៉ាងត្រដាបត្រដួសយ៉ាប់យ៉ឺន។ ការបានជ័យជំនះក៏មិន គួរជាសាហេតុបង្កការត្រេកត្រអាលហួសហេតុ ឬ ក៏ធ្វើឲ្យកើតសេចក្តីធ្វេសប្រហែស ដល់ទៅមានជំនឿក្នុងខ្លួនឯងពេកទៅ។ ព្រោះនោះ ជាសាហេតុនៃសេចក្តីធ្វេសប្រហែស ដល់ទៅមានជំនឿក្នុងខ្លួនឯងពេកទៅ។ ព្រោះនោះ ជាសាហេតុនៃសេចក្តីប្រមាទ ដែលអាចបង្កឲ្យកើតសេចក្តីភ្លាំងភ្លាត់បានងាយៗ កាលបើត្រឡប់ចាញ់គេទៅវិញក៏នឹងមានចិត្តពោរពេញទៅដោយសេចក្តីសោក ទុក្ខទោមនស្ស ស្ទើរតែនឹងសម្លាប់ខ្លួនឯង។ ការខូចចិត្តនឹងច្រើន ឬ តិចមានមូលដ្ឋានមកពីផលនៃការចាញ់ជាសំខាន់។

មនុស្សដែលមានជំនឿយ៉ាងខ្ជាប់មុតមាំក្នុងខ្លួនឯង ចាត់ជាមនុស្សមាន

សតិសម្បជញ្ញៈទាំងមានសេចក្តីសំរេចិត្តយ៉ាងដាច់ខាត មនុស្សបែបនេះរមែងតែងតែជួបប្រទះនូវសេចក្តីចំរើនរុងរឿងក្នុងឆាកជីវិតជាដរាប។

## ៤. ជំនឿខ្ជាប់របស់ហ្វូប៉មន់ខេ

កាលកើតសង្គ្រាមរវាងបារាំងសេស និង អាល្លឺម៉ង់ ព.ស ២៤១៣ ខណៈដែលការតស៊ូគ្នាដណ្តើមយកជ័យជំនះផ្តាច់ព្រត្រ័នោះ។ លោក បិសម៉ាន៍គ បានតាមស្តេចព្រះចៅប្រុស្សី ដើម្បីទៅសួរសុខទុក្ខមេទ័ព និង ពលទាហាន។ មេទ័ពអាល្លឺម៉ង់ក្នុងខណៈនោះ ជាមេទ័ពដែលមានសមត្ថភាពខ្លាំងក្លាបំផុតឈ្មោះ ហ្វូប់មន់ខេ។ ខណៈដែលលោក ម៉ន់ខេ កំពុងរាយការណ៍ពីសភាពសង្គ្រាម និង យុទ្ធវិធីទុលថ្វាយព្រះចៅប្រុសស្រីថា ខ្លួនឯងបានស្មានហេតុការណ៍ទុកទៅយ៉ាងម្តេចខ្លះ ហើយទាំងត្រូវធ្វើយ៉ាងផ្តាច់ព្រត្រ័ដោយវិធីណា ទើបយកជ័យជំនះលើកងទ័ពបារាំងសេសបាននោះ ។ លោក ប៊ិសម៉ារ័គ (អ្នកតាមស្តេច) គិតនឹងសាកល្បងសតិសម្បជញ្ញៈរបស់ មន់ខេ មើលដោយបើកប្រអប់បារីហើយឲ្យ មន់ខេ រើសយកជក់ដោយខ្លួនឯង។ ក្នុងប្រអប់បារីនោះមានបារីពីរធុន គឺធុនល្អពិសេស និងធុនល្អធម្មតាចម្រុះលាយឡំគ្នា ។ មន់ខេ ក៏រើសយកតែបារីធុនល្អពិសេសអុជជក់។ ប៊ិសម៉ារ័គ ទើបក្រាបទូលព្រះចៅប្រុស្សីថា ការចំបាំងម្តងនេះ អាល្លឺ ម៉ង់ ត្រូវតែមានជ័យជំនះជាដាច់ខាត ព្រោះមេទ័ពរបស់ព្រះអង្គនៅមានសតិសម្បជញ្ញៈល្អដែលរើសយកតែបារីធុន ល្អពិសេសពីប្រអប់មកអុជជក់ បើសិនសតិសម្បជញ្ញៈខូច ក៏គង់រើសយកបារីពីប្រអប់ជក់ដោយលក្ខណៈតាមយថាកម្ម។ ហើយក៏ការចំបាំងក្នុងគ្រានេះបានប្រព្រឹត្តទៅដូច ប៊ិសម៉ារ័គ ស្មានហេតុការណ៍ទុកគ្រប់យ៉ាង។ នេះជាគ្រឿងពិសោធន៍ ឲ្យឃើញថា "សតិសម្បជញ្ញៈរបស់ មន់ខេ នៅល្អ"។ ហើយសតិសម្បជញ្ញៈនឹងល្អ ឬ អាក្រក់ ក៏ដោយសារជំនឿយ៉ាងមុតមាំក្នុងខ្លួនឯងជាសារៈដ៏សំខាន់ដូចបានពោលខាងលើនេះ។

# ៥. ជំនឿខ្ជាប់របស់នាងកញ្ញា ម៉ែរី ម៉េកខឺរ

នាងកញ្ញា ម៉ែរី ម៉េកខឺរ៍ ស្ត្រីជាតិអាមេរិក ដែលល្ងង់ខ្លៅមានបញ្ញាអាប់ជាទីបំផុតជាស្ត្រីស្មូមទានគេដែលបាន បានពោលមកហើយពីខាងដើម។ ក្នុងទីនេះសូមពោលបន្ថែមបន្តិចបន្តួច ដើម្បីជាឧទាហរណ៍ដល់លោក អ្នកអានជាទីគោរពនាងមានជំនឿ យ៉ាងមុតមាំខ្ជាប់នៅក្នុងខ្លួនឯងជាពិតប្រាកដ គឺនាងបានកើតជំនឿថា នាងអាចធ្វើយ៉ាងពិតប្រាកដ កាលបើនាងកើតជំនឿខ្ជាប់ក្នុងខ្លួនរបស់នាងដូច្នេះហើយ។ អានុភាពនៃចិត្តរបស់នាង ក៏ត្រូវដាស់ឲ្យភ្ញាក់ឡើងនូវមនោភាព សមាធិ ចិន្តានុភាព បានផុសព្រោងព្រាតក្នុងខួរក្បាលរបស់នាងក្នុងគ្រាដំបូងនាងបានសាកល្បងធ្វើហើយ និងបដិបត្តិសាកល្បងមើល តែក៏នៅរកផ្លូវសំរេចមិនទាន់បាន។ នាងក៏បានព្យាយាមធ្វើតទៅ ដោយសេចក្តីជឿខ្ជាប់ក្នុង ចិត្តថាត្រូវតែសំរេចមិនទាន់បាន។ នាងក៏បានព្យាយាមធ្វើតទៅ ដោយសេចក្តីជឿខ្ជាប់ក្នុង ចិត្តថាត្រូវតែសំរេចឲ្យបាន។ សេចក្តីព្យាយាមនិងជំនឿរបស់នាងជាដើមទុន ទៅដុសប្ញសចាក់ស្រែះក្នុងបេះដូងរបស់នាង គ្មានអ្វីក្នុងលោកនេះដែលនាងនឹងធ្វើមិនបាននោះទេ។ ដោយជំនឿខ្ជាប់យ៉ាងមុតមាំដល់អាយុរបស់នាងបាន ៤៥ឆ្នាំ។ នៅទីបំផុត សេចក្តិសំរេចដូចគោលបំណងរបស់នាងយ៉ាងបរិបូរណ៍ក៏បង្កើតដល់នាង ហើយកេរ្តិ៍ឈ្មោះរបស់ស្ត្រីសុំទាន ដែលធ្លាប់តែត្រូវគេមើលងាយ ក៏កក្រើកទូទៅទាំងផ្ទៃនៃពិភពលោក។ នាងមានកូនសិស្សកូនគណច្រើនជាអតិបរមា នាងក៏ក្លាយជាមនុស្សមានធនធានស្តុកស្តម្ភជាសេដ្ឋីឡើង។ ជំនឿខ្ជាប់ ទើបធ្វើឲ្យមនុស្សសុំទានក្លាយជាសេដ្ឋី ព្រមទាំងមានប្រាជ្ញាបានយ៉ាងអស្ចារ្យបំផុត។

យើងឃើញបានហើយ ជំនឿខ្ជាប់របស់មនុស្សជាមូលដ្ឋានដ៏សំខាន់បំផុតក្នុងការសាងជីវិតក្នុងការតស៊ូលើវេទិកានៃឆាកជីវិត ។ ជំនឿយ៉ាងមុតមាំខ្ជាប់ខ្លួនពិតប្រាកដ ទោះបីនឹងកើតដល់នរណា ជំនឿដ៏ខ្ជាប់មុតមាំនឹងជួយបណ្តុះបណ្តាល ស្អិតស្អាងអនុភាពនៃចិត្តគំនិតនរនោះឲ្យឈានទៅកាន់សេចក្តីសំរេចបាន យ៉ាងមិនបាច់សង្ស័យឡើយ។ សូមលោកអ្នកអានពិចារណា ម៉ែរី ម៉េកខឺរ៍ មើលចុះក៏ឃើញថា នាងមានអាជីពជាអ្នកសុំទាន ក្រខ្សត់បញ្ញាអាប់។

កាលបើនាងបានឮពាក្យស្វាធ្យាយន៍ពីរឿងចិត្តវិទ្យា របស់លោកសាស្ត្រាចារ្យជាតិបារាំងសេស។ អំណាចចិត្តានុភាព សមាធិភាព មនោភាព ជំនឿភ្ជាប់មុតមាំក៏បន្ទាន់ប្រែសភាព ហើយក៏កើតឡើងភ្លាម។ ដួងចិត្តរបស់នាងក្លាយភាពជាអច្ឆរិយៈឡើងក្នុងខណៈនោះ អំណាចចោកទាបបានត្រូវទំលាយទៅអស់រលីង។ នេះហើយដែលជាហេតុរុញច្រានឲ្យ នាងកញ្ញាអ្នកស្នូមគួរឲ្យវេទនាបានសម្រេចគោលដៅរបស់នាងបាន។ រង្វាន់នៃភាពជាអច្ឆរិយៈ ដែលហុចជូននាងនោះ គឺជាសេដ្ឋីដ៏ស្តុកស្តម្ភ។

# យើងខ្មែរ ត្រូវដើរតាម សម្តេចឪជានិច្ច

# មេរៀនទី ៤
# សម្ពន្ធភាពនៅនឹងការងារ

## ១. ទស្សនៈវិជ្ជានៃជីវិតនិងនៃពិភពលោក

សេចក្តីត្រូវការរបស់មនុស្សសព្វថ្ងៃនេះគ្រប់ៗគ្នា ចង់មានកេរ្តិ៍ឈ្មោះ ចង់មានអំណាចចង់ជាអ្នកស្តុកស្តម្ភដោយធនធាន និងទ្រព្យសម្បត្តិ។ តែសេចក្តីត្រូវការរបស់បុគ្គលទាំងនេះខ្លះក៏សំរេចក្នុងការងារយ៉ាងមានកិត្តិយស និងទ្រព្យសម្បត្តិដូច រត្តីហ្វេល្លីរ ហេនរីហ្វរត៍ ខានេគីយ៍-វ៉ាណាមេគ្គីរ ណាប៉ូឡេអុង-ប៉ូណាប៉ាត៍ មុស្សូលិនី ហិត្លែ លិនខល៍ន។ល។ ការដែលបុគ្គលទាំងនេះ អាចឈានទៅកាន់សេចក្តីរុងរោចន៍ និងសេចក្តីសំរេចបាននោះ ក៏ព្រោះបុគ្គលទាំងនោះមានចំណុចអាថ៌កំបាំងដ៏សំខាន់នៅក្នុងខួរក្បាលរបស់គេ។ បុគ្គលទាំងនេះតែងតែមានសេចក្តីឆ្លាតគ្រប់គ្រាន់ដែលអាចនឹងយល់ថា ពិភពលោកដែលយើងអាស្រ័យនៅសព្វថ្ងៃនេះ មានបឋមការណ៍យ៉ាងម៉េច? លោកដែលយើងអាស្រ័យនៅសព្វថ្ងៃ នេះកើតចាកអ្វី? ពិភពលោកដែលយើងអាស្រ័យនេះវិវឌ្ឍនាការមកបានយ៉ាងម៉េច? ការប្រែប្រួល នៃពិភពលោកកើតមកបានយ៉ាងម៉េច? ហេតុអ្វីលោកមនុស្សយើងនេះទើបមាន ការខ្វល់ខ្វាយប្រទុស្សរាយបៀតបៀនគ្នា មានការចំបាំងរាំងជល់គ្នាមិនចេះអស់មិនចេះហើយ ហេតុអ្វីប្រទេសធំៗ ដែលថាមហាអំណាចមានការខ្វែងគំនិតគ្នា ទំនាស់គ្នាមិនចេះស្រាកស្រាន្តសោះ។ កាលបើបុគ្គលទាំងនោះយល់ ចូលចិត្តក្នុងទស្សនៈនៃជីវិត ទស្សនៈនៃលោក និង ទស្សនៈនៃលទ្ធិផ្សេងៗដែលគ្របសង្កត់ចិត្តមនុស្សនៅដូច្នោះ។ គេក៏អាចដឹងជាក់ថា សេចក្តីប្រែប្រួលសព្វថ្ងៃនេះរមែងប្រព្រឹត្តទៅតាម ឧត្តមគតិ និងលទ្ធិគ្រប់គ្រង ហើយទាំងលទ្ធិជំនឿ រហូតដល់ការទាក់ទងក្នុងវឌ្ឍនធម៌ ភូមិប្រទេស សភាពប្រទេស សាសនា ហើយក៏ប្រការសំខាន់បំផុតក៏គឺបញ្ហានយោបាយក្នុងប្រទេសនោះ មានប្រសិទ្ធីភាពនឹងវឌ្ឍនភាព

អាក្រក់ល្អយ៉ាងម្តេចទៀតផង។ បុគ្គលដែលមានឈ្មោះបោះសំឡេង ក្នុងពិភពលោកនោះ ចាត់ជាមនុស្សមានវិរិយភាព និងចិត្តានុភព ខ្លាំងក្លាជាទីបំផុត។ ភាសិតបូរាណមួយដែលយើងធ្លាប់បានឮជាញឹកញយថា "ប្រណាំងទូក ប្រណាំងក្តារយើងអាចនឹងប្រណាំងបាន តែប្រណាំងអំណាចវាសនា យើងប្រណាំងមិនបានទេ"។ ការពោលដូច្នេះ ជាការពោលត្រូវម្យ៉ាងដែរ តែគ្មានខ្លឹមសារអ្វីសោះព្រោះជាការពោលដែលធ្វើឲ្យបន្ធូរបន្ថយកំលាំងចិត្ត ឬ អច្ឆរិយៈផ្លូវចិត្តទៅវិញ។ ការពិត គួរតែប្រើពាក្យពេចន៍ទាំងនេះជំនួសគឺ៖ ប្រណាំងទូក ប្រណាំងក្តារក៏ប្រណាំងបាន ប្រណាំងអំណាចវាសនា ក៏អាចប្រណាំងបានដូចគ្នាដែរ" ក្នុងពិភពលោកនេះ គ្មានអ្វីដែលមនុស្សយើងនឹងធ្វើមិនបាន ធ្វើមិនកើតនោះទេ។ ណាប៉ូឡេអុង ប៉ូណាប៉ាត៍ ក៏អាចកសាងខ្លួនឯងចាកបុគ្គលធម្មតាសាមញ្ញ ឡើងមកគ្រងអំណាចដល់ទៅចក្រពត្រាធិរាជ មានកេរ្តិ៍ឈ្មោះកក្រើក សាកលលោកបាន។ ពលបាលឯកបាទិស្តា នៃប្រទេសគុយបា ក៏បានសាងខ្លួនឯងឡើងទៅមេពល។ ពលបាលទោហិត្លែ កម្មករលាបពណ៌ជញ្ជាំងផ្ទះ ក៏អាចសាងបារមីប្រណាំងនឹងប្រវត្តិសាស្ត្ររបស់អាល្លឺម៉ង់ទាល់តែបានឈ្មោះថា គេមានសមត្ថភាពសាងជាតិអាល្លឺម៉ង់ឲ្យថ្កុំថ្កើង មហាសាលជាងយុគប៊ិលម៉ារ៍គ ឬព្រះចៅកៃសឺរមហារាជទៅទៀត។ អិជិស័ន ក្មេងមហាសែនល្ងង់ម្នាក់ទៀត សូម្បីតែគ្រូរបស់ខ្លួនក៏អស់សង្ឃឹម នឹងប្រៀនប្រដៅទៅទៀតបានតោងបញ្ជូនអិជិស័ន ឬ សេចក្តីព្យាយាមពិសោធន៍ខ្លួនឯងថា មិនមែនជាក្មេងល្ងង់ ឬ អាប់ឱនទេ។ ដោយហេតុនេះហើយ ទើបគេព្យាយាមអប់រំខ្លួនឯងដោយខ្លួនឯង ដោយយកចិត្តទុកដាក់ក្នុងការចង់ចេះ ចង់ដឹងបានព្យាយាមអប់រំខ្លួនឯង ដោយពិតប្រាកដអស់ពីដួងចិត្ត។ កាលបើព្រឹត្តិការណ៍ទាំងនេះមាននៅយ៉ាងគ្រប់គ្រាន់បរិបូរណ៍ហើយ សេចក្តីល្ងង់ខ្លៅអាប់ឱនរបស់អជិស័ន ក៏វិនាសបាត់អស់រលីងទៅ។ បញ្ញាភ្លឺថ្លាព្រោងព្រាតក៏ផុសឡើងជំនួស នៅទីបំផុត អិជិស័នក៏មានកេរ្តិ៍ឈ្មោះកងរំពងឡើងល្បីល្បាញ លាន់ឮពេញទាំងផ្ទៃនៃសាកលលោក ដូចយើងរាល់គ្នាបានជ្រាបស្រាប់ហើយ។

កាលដែលខ្ញុំបាទបានពោលមកយ៉ាងវែងហួរហែរនេះ ដើម្បីនឹងដៅ

បញ្ជាក់ឲ្យអ្នកអានបានយល់ដោយជាក់ថា ការប្រែប្រួលនៃលោកមនុស្ស ដែលយើងអាស្រ័យនៅសព្វថ្ងៃនេះ តែងឋិតនៅក្រោមអំណាចនៃមនុស្សច្រើនជាងធម្មជាតិនិងព្រហ្មលិខិត ប្រទេសនឹងចំរើនឬអន់ថយរមែងឋិតនៅគំនិតរបស់មនុស្សតែប៉ុណ្ណោះ។ កាលបើមនុស្សយើង ចេះស្គាល់ទិចនិចដ៏សំខាន់សំរាប់ធ្វើឲ្យកើតវិវឌ្ឍន៍ភាពដល់ជំនុំជនហើយៗ តទៅនេះខ្ញុំបាទនឹងពិសោធន៍រឿងដែល ថាសេចក្តីសំរេចរបស់មនុស្ស ដែលបានពោលមកហើយខាងដើមនោះតោងអាស្រ័យ "ការធ្វើការងារ" យ៉ាងម៉េចខ្លះ?។

## ២. ជីវិត និង ការតស៊ូ

ទស្សនៈនៃសេចក្តីពិតមានន័យថា "ជីវិតគឺការតស៊ូ" ។ បុគ្គលដែលអាចនឹងឈានទៅកាន់ដំណែងធំកំពូល នៃមនុស្សបាននោះ គេក៏តោងតស៊ូគ្រប់កម្មវិធី និង គ្រប់មធ្យោបាយមកយ៉ាងជោគជាំ គេតោងឆ្លងកាត់ការងារជីវិតយ៉ាងមហាពិបាកបំផុត គេតោងតស៊ូនឹងឧបសគ្គនានាគ្រប់ប្រការយ៉ាង្វិតស្វាញ គេតោងព្យាយាមអត់ធន់តស៊ូក្នុងឆាក ជីវិតយ៉ាងសែនវេទនា គេតោពើបប្រទះនូវការស្រេចឃ្លានយ៉ាងទារុណសាហាវ ជាទីបំផុត។ សូម្បីតែហេតុការណ៍ទាំងនោះនឹងផ្ទាញ់ផ្ទាល ធ្វើទុក្ខបុកម្នេញ ដល់គេតិចច្រើនគ្រប់កម្មវិធី និងគ្រប់មធ្យោបាយដើម្បីតស៊ូនូវសង្គ្រាមនៃជីវិត។ គេមានការអត់ទ្រាំដូចគោក្របីបុគ្គលទាំងនេះហើយដែលមានជីវិតរុងរោចន៍ថ្កុំថ្កើង ទាល់តែក្លាយទៅជាបុគ្គលសំខាន់ ឬជាអច្ឆរិយៈបុគ្គលបាននោះ ក៏ព្រោះគេមានវិញ្ញាណជាអ្នកតស៊ូ ហើយចូលចិត្តធ្វើការ ធ្វើការ ធ្វើការទាល់តែចប់ជីវិត។

ជាការពិតណាស់ លើផ្ទៃពិភពនៃជីវិតសព្វថ្ងៃនេះ គេរមែងធ្វើសង្គ្រាមជីវិតគ្រប់ច្រកល្ហកតែគ្រប់ៗគ្នា ដូចសង្គ្រាមខាងផ្លូវទាហាន សង្គ្រាមនយោបាយ សង្គ្រាមរវាងលទ្ធិសង្គ្រាមផ្លូវសេដ្ឋកិច្ច សង្គ្រាមផ្លូវវឌ្ឍនធម៌ សង្គ្រាមចិត្តវិទ្យា សង្គ្រាមឃោសនាបញ្ចុះបញ្ចូល។ល។ អ្នកខ្លះតោងធ្វើសង្គ្រាមជីវិត ទាល់តែខ្លួនឯងត្រូវចប់ជីវិតកណ្តាលថ្នល់ដូចមហាត្មៈគន្ធី មូស្សូលិនី លិនលន៍។ល។ អ្នកខ្លះធ្វើសង្គ្រាមជីវិតបានជ័យជំនះ មានទាំងអំណាចវាសនា ព្រមទាំងទ្រព្យ

សម្បត្តិយ៉ាងមហាសាល។ យើងអាចយល់ឃើញបានហើយថាសង្គ្រាមនៃជីវិតរបស់មនុស្សនោះ។ មនុស្សតែរាល់រូបតោងធ្វើសង្គ្រាមនៃជីវិតទាល់តែចប់ជីវិត។ កាលបើយើងមានកំណើតមកជាមនុស្សហើយ ក៏ត្រូវតែតស៊ូនូវឧបសគ្គ និងវត្ថុធម្មជាតិគ្រប់យ៉ាងដោយជៀសវាងមិនបានដាច់ខាត។ ហើយយើងក៏តោងដឹងថា លើផ្ទៃពិភពនៃជីវិតរបស់មនុស្ស គ្រប់រូបតែងតែមានសង្គ្រាមគ្របសង្កត់នៅទាល់តែអស់ជីវិត ដោយយើងនឹងជៀសវាងមិនផុតជាដាច់ខាត។ ដូច្នេះយើងមានតែវិធីមួយប៉ុណ្ណោះគឺ ត្រូវតែប្រឈមមុខតស៊ូនឹងសត្រូវ ឬឧបសគ្គនោះដោយមិនមានការរំភើប ញាប់ញ័រអ្វីបន្តិច បន្តួចឡើយ។

តែមុនពេលដែលយើង នឹងតស៊ូនូវឧបសគ្គនៃជីវិត យើងក៏តោងដឹងចំណុចអាថ៌កំបាំងទុកខ្លះមិនច្រើនក៏តិច ដើម្បីបណ្តុះផ្សាំវត្ថុខ្វះខាត ដែលអាចនឹងឧប្បត្តិឡើងដោយខ្លួនឯងដឹងមិនឱតដល់។

ឲ្យកត់សំគាល់ទុកជានិច្ចថា មិនមាននរណាក្នុងលោកនេះ នឹងបណ្តុះបណ្តាលខ្លួនឯងឲ្យមានកេរ្តិ៍ឈ្មោះ ឡើងមកបានដោយអ្នកនោះប្រាសចាកការតស៊ូនូវឧបសគ្គនានានោះទេ។ មិនមានអ្នកណា នឹងសំរេចកិច្ចការផ្សេងៗដោយអ្នកនោះមិនបានធ្វើការងារ ឬ តស៊ូនូវឧបសគ្គឃាត់ឃាំង រារាំង នៃឆាកជីវិតនោះទេ។ សង្គ្រាមជីវិតជាយុទ្ធបរិ វេណដ៏ទូលំទូលាយ រកទីបំផុតគ្មាន។ សិល្បៈនៃសង្គ្រាមជីវិត តោងប្រកបដោយគុណសម្បត្តិច្រើនប្រការរួមគ្នា ទើបនឹងអាចបណ្តុះបណ្តាលឲ្យមានជ័យជំនះបាន។ គុណសម្បត្តិដែលខ្ញុំបាទបានពោលមកនេះគឺផែនការណ៍តស៊ូនៃជីវិត។ ចំណែកសង្គ្រាមផ្លូវទាហាននោះតោងតែមានផែនការណ៍ល្អិតល្អន់ហ្មត់ចត់ និងមនោគតិប្រាជ្ញព្រោកក្នុងប្រទេស ក្រៅប្រទេស តោងមានរោងឧស្សាហកម្មទាំងប្រភេទសង្គ្រាម និងប្រភេទដែលទាក់ទងដល់បញ្ហាជីវភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងតោងមានបរិមាណ និង គុណភាពគ្រប់គ្រាន់ ។ ការវិទ្យាសាស្រ្ត និងការឧស្សាហកម្មប្រតិស្នកម្មតោងមានសមត្ថភាពជាអតិបរមា។ ប្រជាពលរដ្ឋក្នុងជាតិ តោងមានគំនិតលះបង់ និង ប្ដូរផ្ដាច់ដើម្បីជាតិរបស់ខ្លួនជានិច្ច ទាំងមានសាមគ្គីជាផ្លុងមួយ ហើយជាការសំខាន់ចុងបំផុតនោះគឺត្រូវតែមានសេចក្តីអំណត់ស៊ិតស្វាញ

ក្នុងការតស៊ូ យ៉ាងវិសេសវិសាលបំផុត។

សង្គ្រាមជីវិតរបស់មនុស្សនោះ និង ដំណើរទៅដោយមិនមានផែនការណ៍ មិនមានគោលដៅ មិនមានដំណើរទៀងទាត់ ចាក់ជាសង្គ្រាមជីវិតដែលប្រើការមិនបានជាដាច់ខាត។ សង្គ្រាមជីវិតរបស់មនុស្ស ដែលពោរពេញទៅដោយបែបផែនពិតៗ នោះជាសង្គ្រាមដែលត្រូវតែមានឱកាសវេលា សេចក្ដីគាប់គួរ និងតុល្យពិនិត្យយ៉ាងល្អិតល្អ គ្រប់គ្រាន់ ច្រើនជាងសង្គ្រាមរវាងប្រទេសនឹងប្រទេសជាអតិបរមា។

កាលបើសង្គ្រាមជីវិត ជាសង្គ្រាមដែលត្រូវតែមានគ្រោងការណ៍ មានលក្ខណ៍ទ្រឹស្ដីមានសិល្បៈដូច្នេះ។ ក៏ជាការពិតណាស់ ដែលសង្គ្រាមជីវិតត្រូវតែដំណើរទៅ ដោយមានរបៀបបែបផែន។ ហើយលើសជាងនោះទៅទៀត សង្គ្រាមជីវិត តោងតែមានទ្រឹស្ដី ឬ សិល្បៈគ្រប់គ្រាន់ទៀតផង។ ដើម្បីបដិរូបចិត្តគំនិតឲ្យមានសេចក្ដីស្រវាស្រទេញ ចិត្តានុភាព សមាធិ មនោភាព គោលដៅនៃជីវិត ជំនឿមាំស៊ុបក្នុងខ្លួនឯង សេចក្ដីអត់ធន់ សេចក្ដីមានៈ ការបង្ហាប់ខ្លួនឯង សេចក្ដីក្លាហាន ការទូលំទូលាយក្នុងសង្គម ទាំងត្រូវមានសុខភាពបរិបូណ៌ម្យ៉ាងទៀតផង។

បើយើងបានព្យាយាមសិក្សាស្រាវជ្រាវ ជីវប្រវត្តិនៃបុគ្គលសំខាន់ក្នុងពិភពលោកមើលហើយ យើងក៏អាចឃើញបុគ្គលទាំងនោះមានគុណសម្បត្តិដូចពោលមកនេះមិនច្រើនក៏តិច។ គេជាមនុស្ស ដែលពោរពេញទៅដោយសេចក្ដីស្រវាស្រទេញយ៉ាងខ្លាំង ទាំងមានគំនិតថ្មីៗប្លែកៗជានិច្ច មានសេចក្ដីអត់ធន់យ៉ាងគួរអស្ចារ្យ មានគោលដៅនៃជីវិត មិនប្រែប្រួលមានសេចក្ដីព្យាយាមយ៉ាងខ្លាំងក្លា សំរេចចិត្តយ៉ាងឆាប់រហ័ស មានសេចក្ដីក្លាហានយ៉ាងកំពូលហើយប្រការសំខាន់បំផុត ក៏គឺជាកម្មករក្នុងគោលដៅរបស់ខ្លួនឯង ដោយមិនរាថយនិងធុញទ្រាន់សោះឡើយ។

ដូចលោក ហាឌិង ប្រធាធិបតីហរដ្ឋអាមេរិក ពោលជាឧត្តមគតិទុកថា "ចូរព្យាយាមហើយក៏ព្យាយាមឲ្យ រិតតែខ្លាំងឡើង ហើយក៏តោងឲ្យរិតតែខ្លាំងឡើងទៅទៀត"។

នេះជាចំណុចអាថ៌កំបាំងរបស់លោក ហាឱង ដែលធ្វើឲ្យលោកបានសម្រេចជាធំជាមហាបុរសឡើងបាន។

វត្ថុធាតុដែលអាចបណ្តុះបណ្តាលឲ្យមនុស្សយើងពើបប្រទះនូវ វឌ្ឍភាពថ្កុំថ្កើនរុងរឿង ទៅមុខបាននោះមិនមែនបិតនៅនឹងព្រហ្មលិខិត ព្រះអាទិទេពព្រះជាម្ចាស់ឬជោគវាសនាតែម្យ៉ាងនោះទេ តោអាស្រ័យគោលគំនិត និង ការធ្វើការងារជាគោលសំខាន់បំផុត។ អំណាចរបស់ដួងតារាឬព្រហ្មលិខិត ច្រើនតែបិតនៅនឹងមនុស្សទន់ខ្សោយមនុស្សដែលមិនជំនឿស៊ប់ក្នុងខ្លួនឯង មនុស្សដែលប្រាសចាកគោលគំនិត មនុស្សដែលប្រាសចាកមនោភាព និង សមាធិមនុស្សដែលប្រាសចាកសេចក្តីក្លាហាន អង់អាច ។ល។

តែមនុស្សដែលចេះសង្កេតការណ៍នូវចលនាក្នុងលោកជាដរាបហើយ គេអាចនឹងយល់ឃើញច្បាស់ថា គ្រប់បែបយ៉ាងក្នុងលោកសព្វថ្ងៃនេះ រមែងប្រែប្រួលផ្លាស់ប្តូរក្នុងលោក បង្កឲ្យកើត "សង្គ្រាមជីវិត" សង្គ្រាមជីវិតត្រូវតែមានគ្រោងការណ៍ ក្នុងការដំណើរនៃ ជីវិតដូចមានគោលដៅនៃជីវិត ការផ្គត់ផ្គង់អប់រំខ្លួនឯង គឺមិនព្រមដេកចាំតែជោគវេសនា ឬព្រះអាទិទេពជួយនោះទេ។ មនុស្សសំខាន់ៗក្នុងលោក រមែងតែប្រើមនោភាពរបស់គេប្រកបការងារ ព្រោះសមិទ្ធិចុងបំផុតរបស់មនុស្ស បិតនៅនឹងការងារ បើមិនធ្វើការងារក៏មិនកើតសេចក្តីសំរេចដូច្នេះជាដើម។

ជាការពិតបំផុត មនុស្សដែលប្រកបទៅដោយជោគវាសនា និងយលស័ក្តិ ព្រមទាំងមានទ្រព្យសម្បត្តិ ធនធាន ស្តុកស្តម្ភថ្នាក់សេដ្ឋី មហាសេដ្ឋីក៏ព្រោះមនុស្សនោះធ្វើការងារយ៉ាងប្តូរផ្តាច់រហូតជីវិត បើសិនគេប្រាសចាកការងារហើយ មនុស្សនោះនិងបោះជំហានទៅកាន់វឌ្ឍនភាពដ៏រុងរឿង ថ្កុំថ្កើងមិនបានជាដាច់ខាត។ ព្រោះការធ្វើការងារ ជាការស្តែងបញ្ជាក់ដល់បុគ្គលិកលក្ខណៈ និង សមត្ថភាពដ៏អង់អាចក្លាហានរបស់គេ។

## ៣. ឧត្តមគតិរបស់បុគ្គលសំខាន់ៗ

បុគ្គលសំខាន់ៗ ក្នុងលោកដូចជាណាប៉ូឡេអុង-ប៉ូណាប៉ារត៍ ក៏បានធ្វើ

ការតស៊ូក្នុងឆាកជីវិតទាល់តែអស់ជីវិត ។ ម៉ាទិនឡូធី ប្រើវេលាក្នុងឆាកជីវិតនិពន្ធសៀវភៅដល់ទៅ ៤៤៦ រឿងហើយទាំងជាអ្នកផ្តើមតាំងលទ្ធិនិកាយ ប្រូតែស្តាំង ទៀតផង។ តូក អហ្វ វេល្លិងតិន បុគ្គលសំខាន់របស់អង់គ្លេស ដែលធ្លាប់ច្បាំងឈ្នះណាប៉ូឡេអុង ប៉ូណាប៉ារត៍ នូវ វទីរលូ ក៏ប្រចក្សថាលោកនេះមានសេចក្តីព្យាយាមខ្នះខ្នែងធ្វើការងារជាអតិបរមាមានសៀវភៅផ្សេងៗ ដែលលោកនេះនិពន្ធទុកទាំងតែអាយុ១៣ឆ្នាំ ក៏ត្រូវបានរក្សាទុកក្នុងសារៈមន្ទីរនៃជាតិ ទាល់តែសព្វថ្ងៃនេះ។

កាលដែលខ្ញុំបាទបានរៀបរាប់ពោលមកទាំងនេះក៏ជាការគូសបញ្ជាក់ឲ្យឃើញច្បាស់ថា បុគ្គលដែលមានសេចក្តីសំរេចយ៉ាងមហាសាលក្នុងឆាកជីវិតរបស់ខ្លួននោះ សុទ្ធតែជាបុគ្គលធ្វើការងារយ៉ាងជោគជាំប្លូរផ្តាច់ទាំងអស់ សុទ្ធតែ ជាបុគ្គលល្មោភធ្វើការងារ ជាអតិបរមាទាំងអស់។ លោកស៊ីវ៉ែលទ័រស្កត់និពន្ធករជាតិអង់គ្លេសកាន់សុភាសិតប្រចាំ ចិត្តថា "កុំនៅស្ងៀមដោយមិនបានធ្វើអ្វី"។ រូប៊ឹតស័នអ្នកប្រាជ្ញមេធី ជាតិបារាំងសេសក៏មានសុភាសិតសម្រាប់ខ្លួនគេថា "តោងនូវនឹងការងារជាដរាប"។

មានគ្រាមួយ កាលព្រះចៅចក្រព័ត្រណាប៉ូឡេអុង បានស្តេចយាងទៅជួបនឹងកូតេអ្នកទស្សនវិទូជាតិ អាល្លឺម៉ង់ បានទតឃើញកិច្ចការងារផ្សេងៗរបសកូតេ ក៏ទ្រង់មានព្រះបន្ទូលនឹងកូតេថា "មនុស្សយ៉ាងលោកនេះ បានចំជាមនុស្ស"។

ការដែលបុគ្គលសំខាន់ៗ បានឲ្យទស្សនៈទាំងនិតិន័យ និងព្រឹត្តិន័យក្នុងផ្លូវទ្រឹស្តីនៃការធ្វើការងារទុក ដូច្នេះរមែងជាការគូសបញ្ជាក់ឲ្យយើងឃើញច្បាស់ថា "សេចក្តីសម្រេចរបស់មនុស្សតែងឋិតនៅនឹងការធ្វើការងារទាំងអស់" ការងារប៉ុណ្ណោះឯងដែល ធ្វើឲ្យមនុស្សយើងស្គាល់ចំណុចអាថ៌កំបាំងនៃវឌ្ឍនភាពដោយច្បាស់លាស់បាន។ ការងារប៉ុណ្ណោះឯង ដែលអាចជួយបណ្តុះបណ្តាលពលានុភាពគ្រប់ផ្លូវ ទាំងផ្លូវចិត្ត និង ពលានុភាពនៃរាងកាយ ។ ការងារប៉ុណ្ណោះឯងដែលនឹងធ្វើឲ្យស្គាល់ច្បាស់នូវការពិតនៃវឌ្ឍនភាព ទាំងអាចកំចាត់ឧសបសគ្គនានាឲ្យវិនាសបាត់បង់ទៅបាន។

នឹងកើតមកជាមនុស្សប្រភេទណាក៏ដោយ នឹងមានសមត្ថភាពយ៉ាងណា ឬ គ្មានក៏ដោយនឹងមានសេចក្តីក្លាហាន តិចច្រើនយ៉ាងណាក៏ដោយ នឹងមានបុគ្គលិកលក្ខណៈវិសេសវិសាលយ៉ាងណាក៏ដោយ តែបើគេទាំងនោះមិនធ្លាប់បានធ្វើការងារយ៉ាងណាមួយមកសោះ ក្នុងគំនិតរបស់គេ មនុស្សនោះនឹងជាអ្វីមិនបានជាដាច់ខាត។ តែគេក៏អាចជាមហា សេដ្ឋី ឬ មេចក្រពត្តិក៏តែក្នុងអាណាចក្រនៃមនោភាពរបស់គេប៉ុណ្ណោះ។

"ជំហានទៅមុខរបស់មនុស្សក្នុងអតីត បច្ចុប្បន្ន និង អនាគត ទើបធ្លាក់ជាសម្បត្តិរបស់អ្នកធ្វើការងារតែមួយពួកប៉ុណ្ណោះ"។

ចំណុចអាថ៌កំបាំងនៃជំហានទៅមុខរបស់មនុស្ស រមែងបិតនៅនឹងការងារ។ តែការធ្វើការងារ ដូចពោលមកនេះ តោងមានសតិសម្បជញ្ញៈចិត្តហើយក៏បង្គាប់ចិត្តមាន សម្បជញ្ញៈនេះឲ្យប្រព្រឹត្តទៅដោយត្រឹមត្រូវ ព្រោះចិត្តមានសម្បជញ្ញៈ ជាវត្ថុចាំបាច់សំរាប់ការធ្វើការងារដែលត្រូវប្រព្រឹត្តទៅដោយត្រឹមត្រូវគាប់គួរជាដរាប។ ហើយក៏ចិត្ត មានសម្បជញ្ញៈនេះឯងរមែងមានប្រសិទ្ធិភាពបរិបូណ៌ អាចពិចារណាបានថា អ្វីខុស អ្វីត្រូវ អ្វីល្អ អ្វីអាក្រក់ ។ ទាំងត្រូវធ្វើយ៉ាងម្តេច ទើបបានជួបប្រទះនូវសេចក្តីសំរេចប្រយោជន៍ក្នុងការងារនោះ។

ជាការពិតណាស់ ដែលសេចក្តីសំរេចរបស់ពួកមនុស្សនោះ តោងអាស្រ័យគោលការណ៍ច្រើនយ៉ាងជួយផង តែដែលសំខាន់បំផុត ក៏គឺការធ្វើការយ៉ាងស្វិតស្វាញអត់ធន់ ហើយទាំងមិនព្រមរួញរាសោះឡើយ។

អ្នកណាក៏ដោយ បើសិនជាអ្នកចូលចិត្តធ្វើការហើយក៏ការធ្វើការនោះបរិបូណ៌ដោយចិត្តមានសម្បជញ្ញៈផង។ ការងាររបស់គេទាំងនោះ ក៏រមែងជួបប្រទះតែសេចក្តីសំរេចជាដាច់ខាត ដោយមិនបាច់សង្ស័យឡើយ។

អ្នកដែលជួបប្រទះនូវសេចក្តីសំរេចនោះ មិនមែនព្រោះព្រះអាទិទេព ឬ ព្រហ្មសិខិតបណ្តាលឲ្យមកទេ តែ ជាការធ្វើការងារយ៉ាងស្វិតស្វាញ អត់ធន់របស់គេដោយឡែកទេតើ។

ដូច្នោះ សមិទ្ធិគ្រប់យ៉ាង រមែងបិតនៅនឹងមនុស្សធ្វើការងារ មនុស្សធ្វើ

ការងារតែប៉ុណ្ណោះឯងទើបជាមនុស្សធំដុំក្នុងសង្គម។ មនុស្សធ្វើការងារតែប៉ុណ្ណោះឯង ដែលត្រូវបានទទួលកេរ្តិ៍ឈ្មោះគួរឲ្យអភិរម្យ ដូចអិដិស័ន បានត្រូវលើកតំកើងថា ជាបុគ្គលសំខាន់របស់អាមេរិក ហ្គ្លយប៉ាស្ទ័រ ជាបុគ្គលសំខាន់របស់បារាំងសេស។ បុគ្គលទាំងពីរនេះ រុងរោចន៍ ចំរុំថ្កើន មកបានក៏ព្រោះគេខំធ្វើការងារដោយខ្នះខ្នែង និង ប្តូរផ្តាច់បំផុតទាំងអស់។

**យើងតស៊ូ គ្រប់មធ្យោបាយ ដើម្បី ជាតិ សាសនា រាជបល្ល័ង្ក**

# បទទី៥
# រឿងសមាធិ

## ១. សមាធិគឺជាអ្វី?

យើងនាំគ្នាមកគិតដល់ពាក្យថា សមាធិ (Concentration) ជាមុខសិន តើពាក្យថា "សមាធិ" នេះសំដៅដល់អ្វី? មានការចាំបាច់ដល់ការកសាងអច្ឆរិយភាពយ៉ាងម៉េច? ទាំងមានការចាំបាច់ដល់ជីវិតមនុស្សយ៉ាងម៉េចខ្លះ?

ពាក្យថា "សមាធិ" ខ្ញុំបាទបានសំដៅយកសេចក្តី "ការធ្វើការងារយ៉ាងណានីមួយក៏ដោយតែតោងធ្វើទៅដោយចិត្តហ្នឹងហ្នពិតប្រាកដ មិនមានការប្រែប្រួល មិនមានអារម្មណ៍ដទៃចូលមកលាយឡំ មានតែចិត្តមួយក្នុងការងារនោះៗ ហៅថា "សមធិ"។

## ២. សមាធិក្នុងទស្សនៈនៃពុទ្ធសាសនា

ពាក្យថា សមាធិ ក្នុងទស្សនៈនៃពុទ្ធសាសនា បានវិគ្រោះសព្ទ និងប្រយោជន៍នៃ "សមាធិ" ទុកដូចតទៅនេះ

"សមាធិ ភិក្ខវេ ភាវេថ សមាហិតោ យថាភូតំ បជានាតិ" ប្រែថា គួរធ្វើសមាធិឲ្យកើត បុគ្គលដែលមានដួងចិត្តជាសមាធិ រមែងធ្វើកិច្ចការគ្រប់យ៉ាងបានសំរេចទាំងអស់។

"មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា" ធម៌ទាំងឡាយមានចិត្តជាធំ មានចិត្តជាអ្នកដឹកនាំនិង ធ្វើអ្វីបានសំរេចក៏ដោយចិត្តទាំងអស់។

"ចិត្តេន នីយតិ លោកោ" លោកដែលចិត្តរមែងនាំទៅ ដូច្នេះជាដើម។ យើងមកពិនិត្យពិចារណាតទៅទៀត តើសមាធិមានប្រយោជន៍យ៉ាងម៉េច? ក្នុងការកសាងអាណាចក្រនៃសេចក្តីគិតនឹកនិងមនោភាព។ សមាធិមាន

ប្រយោជន៍យ៉ាងម៉េច? ក្នុងការសាងសតិសម្បជញ្ញៈចិត្ត និងបរិវាចិត្ត។ ទាំងជាកំលាំងដ៏មុតមាំយ៉ាងម៉េច ក្នុងការសាងអច្ឆរិយៈនៃបុគ្គលសំខាន់ៗ ក្នុងពិភពលោក។ សូមលោកអ្នកអាន មេត្តាចាំឲ្យជាក់ថា សមាធិជាដើមកំណើតនៃសមត្ថភាព ក្នុងការកំណត់ផែនការណ៍។ សេចក្តីគិតល្អ ឬ មិនល្អ សេចក្តីសង្កេតល្អ ឬ មិនល្អ រមែងឋិតនៅនឹងសមាធិជាសំខាន់។ សមាធិជាព្រហ្មលិខិតនៃជីវិត ក្នុងការធ្វើការងារ មនុស្សប្រភេទណាក៏ដោយបើមានសមាធិទៀងទាត់ជាឯកច្ឆន្ទមូលតែមួយហើយៗបុគ្គលនោះក៏ចាត់ថា ជាអ្នកមានសមត្ថភាព ល្អឆើតឆាយក្នុងកិច្ចការរបស់គេ ព្រោះថា កាលបើសមាធិបានកើតឡើងយ៉ាងទៀងទាត់ពិតប្រាកដហើយ ក៏រមែងជាផ្លូវឲ្យបង្កើតបញ្ញា កាលបើកើតបញ្ញាហើយក៏រមែងជាផ្លូវឲ្យកើតសេចក្តីយល់ច្បាស់ ឃើញពិតក្នុងសភាពនៃការងារនោះៗ គ្រប់បែបយ៉ាង។

## ៣. សមាធិនិងវិវឌ្ឍនៈភាព

សមាធិ ទើបជាសារត្ថៈដ៏សំខាន់បំផុត សំរាប់អ្នកត្រូវការបោះជំហានក្នុងកិច្ចការទាំងពួង។ ព្រោះសមាធិ ជាមាត្រដ្ឋានទ្រទ្រង់បុគ្គលិកផាពដទៃៗ ឲ្យមានសមត្ថភាពឡើងបានដូចសេចក្តីគិត សេចក្តីស្រវាស្រទេសញ មនោភាពចិត្តានុភាព សេចក្តីគាប់ចិត្ត សេចក្តីសង្កេត។ល។ សមាធិ ទើបជាដើមកំណើតនៃសេចក្តីគិត និងគ្រោងការណ៍រហូតដល់សិល្បៈផ្សេងៗ។ នរណាមានសមាធិច្រឹមច្រំ មិនទៀតទាត់ មិនពិតប្រាកដ មិនមាំមួន មិនមូលតែមួយនរនោះក៏មិនអាចនឹងធ្វើអ្វីឲ្យសំរេចឡើងមកបានជាដាច់ខាត។ ទោះបី ឱកាសជោគវាសនាឬព្រះអាទិទេពបានជួយឧបត្ថមជននោះៗ ឲ្យបានជាអ្នកដឹកនាំក្នុងវង់ការងារដ៏ធំដុំរបស់ខ្លួនឯង ឬ បានជាប្រធានចាត់ការបរិស័ទធំៗយ៉ាងណាក៏ដោយ។ ខ្ញុំបាទជឿជាក់ថា វង់ការងារដ៏ធំដុំដែលគេទទួលខុសត្រូវទាំងអស់នោះ នឹងមិនមានសេចក្តីចំរើនវឌ្ឍនៈភាពរុងរោចន៍ ទៅមុខបានឡើយ។

បុគ្គលដែលមានសមាធិយ៉ាងគួរអស្ចារ្យ ដូចព្រះសម្មាសម្ពុទ្ធជាម្ចាស់ មហាត្មៈគន្ធី មេពលយ៉ហ្វ ណាប៉ូឡេអុង ប៉ូណាប៉ារត៍ ។ល។ ក្នុងវេលាដែល

លោកទាំងនេះកសាងឋាមពលនៃសេចក្តីគិត។ ចិត្តថ្លើមរបស់លោក កំណត់ហ្នឹងជាឯកច្ឆន្ទ នៅតែក្នុងរឿងដែលលោកគិតតែប៉ុណ្ណោះ។ សោតប្រសាទរបស់លោក ស្ទើរតែមិនបានឮសូរសព្ទសំឡេងអ្វីសោះឡើយ។

ពេលវេលានឹងកន្លងទៅប៉ុន្មានក៏មិនត្រូវការដឹងអន្តរាយនឹងមក ពីទិសទីណាខ្លះ ក៏មិនមានសេចក្តីញាប់ញ័រព្រួយបារម្ភវិតក្ក។ សេចក្តីវិតក្កវិចារៈ មិនបានធ្វើឲ្យលោកទាំងនោះ មានចិត្តជាប់ជំពាក់អ្វីបានឡើយ។ មនុស្សដែលមានសមាធិហ្នឹងហ្នដ៏អស្ចារ្យដូច្នេះ ទើបធ្វើឲ្យលោកទាំងនោះ បានបោះជំហានឡើងទៅកាន់តំណែងនាទីខ្ពស់ មានកេរ្តិ៍ឈ្មោះកងរំពងក្លាយជាអ្នកប្រាជ្ញរាជបណ្ឌិតបាន។ ក្លាយជាអ្នកប្រឌិត មានកេរ្តិ៍ឈ្មោះល្បីពេញទាំងពិភពលោក។ ក្លាយជាអ្នកនយោបាយ ដែលមានវាទសិល្បៈគួរស្តាប់ គួរឲ្យចាប់អារម្មណ៍យ៉ាងក្រៃលែង។ បុគ្គលដែលមានសមាធិដ៏មហាអស្ចារ្យដូច្នេះនេះហើយ ដែលជាអ្នកកសាងគ្រឿងចក្រ គ្រឿងយន្ត គ្រឿងវិទ្យុ និងគ្រឿងវិទ្យាសាស្ត្រ ឲ្យកើតឡើងក្នុងពិភពលោកនាសព្វថ្ងៃនេះដូច អ៊ិដិស័ន ហេនរិហ្វត យ៉ជស្ទិវេនស័ន ។ល។ សមាធិទើបជាវត្ថុធាតុមួយដ៏សំខាន់បំផុតសំរាប់ជាដៃគូក្នុងការតស៊ូលើវេទិកា នៃជីវិតក្នុងលោកយុគបច្ចុប្បន្ននេះ។

ប្រជាជាតិក្នុងសង្គមណា មានសមាធិល្អទៀងទាត់ អត់ធន់ មូលជាឯកច្ឆន្ទតែមួយសេចក្តីចំរើនជឿនលឿន ទៅមុខក្នុងសង្គម ជននោះត្រូវតែសំរេចផលជាដាច់ខាតដោយ មិនបាច់សង្ស័យឡើយ។ ផ្ទុយទៅវិញបើសិនជនណាប្រាស ចាកសមាធិដូចបានពោលមកហើយខ្ញុំបាទជឿជាក់ថា សេចក្តីជ្រួលច្របល់ ប្រែប្រួល ខ្វល់ខ្វាយ ក្នុងបញ្ហាផ្សេងៗរមែង តែងតែមានឡើងដោយមិនតោងសង្ស័យ។ ខ្ញុំបាទពោលមកនេះ គឺពោលដល់សមាធិក្នុងទស្សនៈលោកីយ៍ប៉ុណ្ណោះ។

មនុស្សដែលមានសមត្ថភាពទន់ខ្សោយភាគច្រើនសុទ្ធតែមានសមាធិមិនទៀងទាត់ មានចិត្តរវើរវាយមានសេចក្តីវិតក្កកង្វល់ច្រើន មានសេចក្តីព្រួយបារម្ភជានិច្ច គ្មានជំនឿខ្ជាប់ក្នុងខ្លួនឯងសោះ។ ទោះបីនឹងប្រើសមាធិ ដើម្បីជាប្រយោជន៍ក្នុងការងារមួយថ្ងៃ ត្រឹមតែមួយម៉ោងក៏មិនអាចនឹងធ្វើទៅបានឡើយ

មនុស្សទាំងនេះគ្មានសង្ឃឹមអ្វីសោះ ដរាបអស់ជីវិតរបស់គេ។ ជីវិតរបស់គេពោរពេញទៅដោយសេចក្តីសៅហ្មង ការងាររបស់គេដំណើរទៅយ៉ាងត្រដាបត្រដួសយ៉ាប់យឺនបំផុត។ ឧត្តមគតិនិងគំនិតរបស់គេ តែងតែខ្វះបរិញ្ញាញាណគ្រប់យ៉ាងមនោភាពរបស់គេតែងរវើរវាយជានិច្ច សេចក្តីកត់សំគាល់របស់គេប្រាសចាកសមត្ថភាពសេចក្តីគិតនឹងរបស់គេមិនធួនបរិបូរណ៍ សេចក្តីអត់ធន់ក្នុងការងារ របស់គេវិនាសសាបសូន្យអស់វិនាទីនៃសេចក្តីងងឹតងងល់អន្ធការបានក្លាយមកជាសម្បត្តិដ៏មហាសាលរបស់គេ ដោយជៀសវាងមិនបានឡើយ។

ការដែលព្រះសម្មាសម្ពុទ្ធបានសំរេចសម្ពោធិញាណ ក៏ព្រោះព្រះអង្គមានសមាធិដ៏ប្រសើរមានសមាធិជាឯកច្ឆន្ទតែមួយ ហើយទាំងពេញទៅដោយសេចក្តីតស៊ូ អត់ទ្រាំយ៉ាងស្វិតស្វាញបំផុត។

ណាប៉ូឡេអុង ប៉ូណាប៉ារត៍ មេចក្រពត្តិនៃបារាំងសេស ដែលបានឈានឡើងមកពីមនុស្សធម្មតាសាមញ្ញ ក៏ព្រោះអំណាចសមាធិ បណ្តុះបណ្តាលរុញច្រានស្អិតស្អាងឲ្យ ណាប៉ូឡេអុង ប៉ូណាប៉ារត៍ឈានឡើងកាន់សេចក្តីរុងរោចន៍បាន។ អ្នកប្រវត្តិសាស្ត្រនៃពិភពលោក បានលើកដំកើងណាប៉ូឡេងអុង ជាអនេកប្បការក្នុងការដែល ណាប៉ូឡេអុង មានសមាធិយ៉ាងគួរអស្ចារ្យណាស់ វេលាណាដែលណាប៉ូឡេអុងនឹងគិតរឿងអ្វី ដូចវេលាណាប៉ូឡេអុងកំណត់ផែនការណ៍ចម្បាំងមួយ ណាប៉ូឡេអុងនឹងគិតរឿងអ្វី ដូចវេលាណាប៉ូឡេអុងកំណត់ផែនការណ៍ចម្បាំងមួយ ណាប៉ូឡេអុងក៏បិទសមាធិថតដទៃៗទាំងអស់ គង់នៅសល់តែថតដាក់គំនិតក្នុងរឿងកំណត់ផែកការណ៍ចម្បាំងតែមួយប៉ុណ្ណោះ។ ណាប៉ូឡេអុងនឹកចង់លក់ (ដេកលក់) ឬ អង្គុយលក់ពេលណាក៏លក់បានងាយស្រួលភ្លាមៗ ។ ក្នុងយុទ្ធបរិវេណដែលមានសូរសព្ទសំឡេងកាំភ្លើងតូចធំកងរំពង ដែលកំពុងតែមានការប្រយុទ្ធគ្នាយ៉ាងឃោរឃៅបំផុត នោះ ណាប៉ូឡេអុងក៏អាចប្រើសមាធិបាន មិនរើសពេលណា វេលាណា ឬក៏ស្ថានការណ៍យ៉ាងណា។

## ៤. អាថ៌កំបាំងនៃសមាធិណាប៉ូឡេអុង

នេះគឺជាការគូសបញ្ជាក់ឲ្យយើងរាល់គ្នាជាក់ច្បាស់ថា ណាប៉ូឡេអុង ប៉ូណាប៉ាត៍ ស្គាល់វិធីប្រើសមាធិ បណ្ដុះបណ្ដាលឲ្យកើតប្រយោជន៍ដល់ខ្លួនឯង ក្នុងការសាងបុគ្គលិកភាពយ៉ាងណា។ ដោយហេតុតែ ណាប៉ូឡេអុង ស្គាល់វិធីប្រើសមាធិឲ្យកើតប្រយោជន៍ក្នុងការសាងខ្លួនឯងនេះហើយ ណាប៉ូឡេអុង ក្នុងឋានៈជាកូនអ្នកទីទ័លក្រខ្សត់ទូរគត់ ទើបក្លាយទៅជាមេចំបាំងដ៏ឆ្នើមជាអ្នកនយោបាយដ៏វិសេស ជាអ្នកមានខួរក្បាលដ៏ថ្លៃថ្លា ជាអ្នកធ្វើការយ៉ាងអត់ធន់ដូចប្រាកដក្នុងប្រវត្តិសាស្ត្រស្រាប់ហើយ។

មានគ្រាមួយ ចក្រពត្តិ ណាប៉ូឡេអុង ហៀបនឹងអស់ដង្ហើមនាកោះសៃង៉ីអេលេន។ គ្រូពេទ្យដែលធ្វើការរក្សាព្យាបាយ ណាប៉ូឡេអុង ប្រាថ្នាចង់ដឹងថា ណាប៉ូឡេអុង ដែលបានកសាងខ្លួនឯងឡើងមកចាកមនុស្សសាមញ្ញទាល់តែបានជាចក្រពត្តិបារាំងសេសនោះ តើណាប៉ូឡេអុងមានចំណុចអាថ៌កំបាំងល្អវិសេសយ៉ាងណាខ្លះ?។ ណាប៉ូឡេអុង ទ្រង់មានព្រះបន្ទូលតបពេទ្យថា លោកពេទ្យក្នុងខួរក្បាលរបស់ខ្ញុំនេះ មានថតដែលអាចទាញចេញមកជាថតៗ ថតណាដែលខ្ញុំមិនត្រូវការប្រើ ខ្ញុំក៏បិទវាទុកសិន។ វេលាដែលខ្ញុំធ្វើការផ្នែកខាងគ្រប់គ្រង ខ្ញុំក៏ទាញថតផ្នែកខាងគ្រប់គ្រងចេញមកប្រើហើយខ្ញុំក៏បិទថតដទៃៗទុកសិន ទាំងអស់។ វេលាដែលខ្ញុំកំពុងកំណត់ផែនការណ៍យុទ្ធវិធី ខ្ញុំក៏បិទថតដទៃៗទុកទាំងអស់ បើប្រើចំពោះតែថតចម្បាំងមួយប៉ុណ្ណោះ។ វេលាដែលខ្ញុំនឹករលឹកដល់ យូសេហ្វីន មហេសីរបស់ខ្ញុំ ខ្ញុំក៏បិតថតដទៃៗទាំងអស់ ហើយ បើកចំពោះតែថតស្នេហាសំរាប់ យូសេហ្វីន តែមួយប៉ុណ្ណោះ។ល។

នេះគឺចំណុចអាថ៌កំបាំងរបស់ចក្រពត្តិ ណាប៉ូឡេអុង ប៉ូណាប៉ារត៍ ដែលមានសមត្ថភាពកសាងខ្លួនឯងឡើងមកពីមនុស្សសាមញ្ញក្រទុរគត់ ទាល់តែបានជាចក្រពត្តិ ល្បីល្បាញពេញទាំងផ្ទៃនៃពិភពលោកទល់សព្វថ្ងៃនេះ។

ក្រៅអំពីចក្រពត្តិ ណាប៉ូឡេអុង ជាអ្នកស្គាល់គុណប្រយោជន៍របស់សមាធិពិតប្រាកដនោះនៅមានលោកចម ពលយ៉ហ្វនៃបារាំងសេស ក៏ជាមនុស្សម្នាក់ទៀត ដែលមានសមាធិមិនខុសពីចក្រពត្តិ ណាប៉ូឡេអុង

ណាស់ដែរ។ ក្នុងប្រទេសបារាំងសេស គេតែងតែពោលលើកដំកើងលោក ចមពលយ៉ហ្វ ដែលលោកមានសមត្ថភាពយ៉ាងក្លៀវក្លា អាចការពារក្រុងបារីសមិនឲ្យខូចខាតដោយអាល្លឺម៉ង់ក្នុងសង្គ្រាមលោក គ.ស ១៩១៤ បាន (សង្គ្រាមលោកលើកទី១) ។ លោក ចមពលយ៉ហ្វ មានសមត្ថភាពអាចរុញច្រានកងទ័ពអាល្លឺម៉ង់ ឲ្យថយផុតពីស្ទឹងម៉ារនទៅបាន ទាល់ជាហេតុឲ្យអាល្លឺម៉ង់តោងចាញ់សង្គ្រាមនៅទីបំផុត ទាំងនេះក៏ព្រោះអំណាចសមាធិដែលលោក ចមពលយ៉ហ្វ មានគ្រប់គ្រាន់ បរិបូណ៌ ដូចចក្រពត្តិ ណាប៉ូឡេអុង នោះឯង។

ក្នុងរឿងដែលទាក់ទងនឹងសមាធិរបស់លោក ចមពលយ៉ហ្វ នោះប្រចក្សថាបើសិនលោក ចមពលអង្គុយគិតរឿងអ្វី ក្នុងពេលដែលកំពុងតែមានការតយុទ្ធគ្នានោះ លោក ចមពលស្ទើរតែមិនបានឮសូរសព្ទសម្លេងកាំភ្លើងអ៊ឹងកងនោះឡើយ។ លោក ចមពល នឹងចង់ដេកលក់ក៏អាចលក់បានភ្លាមមិនថាពេលណា វេលាណា ក្នុងការដែលក្រុងបារីស ត្រូវអាល្លឺម៉ង់រុកចូលជិតដល់ជាយក្រុង (សង្គ្រាមលោកលើកទី១) ស្ទើរតែនឹងបាត់បង់ឯករាជ ទៅហើយនោះ។ ប្រជាជន ក្នុងក្រុងបារីសព្រួយបារម្ភភិត័យជ្រួលច្របល់គ្រប់ៗគ្នា ហើយបុគ្គលទាំងនោះបានទូរស័ព្ទទៅកាន់សមរភូមិសួរថា វេលានេះលោក ចមពលមេទ័ពកំពុងធ្វើអ្វីខ្លះ បានទទួលតបថា "លោក ចមពលកំពុងតែដេកលក់"។

ប្រជាជនក្រុងបារីសនាំគ្នាតក់ស្លុត ភិតភ័យរឹតតែខ្លាំងឡើង។ ព្រោះជោគវាសនារបស់ប្រទេសបារាំង និង ជនជាតិបារាំងសេសក្នុងវេលានោះពេញទៅដោយស្ថានការណ៍តឹងតែងជាទីបំផុតហើយ។ តើហេតុម្តេចបានជាលោកមេទ័ព ដេកលក់យ៉ាងសប្បាយដូច្នេះ?។

ការពិត ប្រជាជនក្រុងប៉ារីសមិនដឹងថា ការដែលលោកមេទ័ពដេកលក់ដើម្បីសម្រាកនោះលោកមេទ័ពបាន ប្រើសមាធិគូសកំណត់ផែនការណ៍នៃយុទ្ធវិធី ឬ ភាពនៃហេតុការណ៍ផ្សេងៗនៃយុទ្ធវិធីទុកស្រេច រៀបរយអស់ហើយឃើញថាមិនជាការតឹងតែមានអន្តរាយកាចសាហាវដល់អ្នកក្រុងប៉ារីសអ្វីទេ ។ ទើបលោកមេទ័ព ចូលដេកដើម្បីសំរាកផ្សេងៗ ដូចប្រជាជន ក្រុងប៉ារីស នាំគ្នាចូលចិត្តគិតខុសក្នុងរឿងមេទ័ពរបស់គេដេកលក់ដូច្នេះជាដើម។

"អ្នកណាក៏ដោយ បើសិនមិនអាចធ្វើចិត្តឲ្យហ្នឹងហ្ន មូលជាឯច្ឆន្ទក្នុងការងារបានយ៉ាងតិចត្រឹមមួយថ្ងៃ មួយម៉ោងទេ ក៏មានសង្ឃឹមតិចតួចស្តួចស្តើងបំផុត ដែលនឹងមានជំហានទៅមុខដើម្បីសេចក្តីរុងរោចន៍ក្នុងជីវភាពខ្លួនបានឡើយ។"

សេចក្តីគិតរបស់លោកអ្នក នឹងត្រឹមត្រូវល្អិតល្អគ្រប់បែបយ៉ាងបាន ក៏ព្រោះមានសមាធិជាគោលសំខាន់គឺសមាធិជាឫសគល់នៃអារម្មណ៍គ្រប់ បែបយ៉ាង។ កាលបើសមាធិជាតួអង្គសំរាប់ការសាងអនាគត និងសាងបុគ្គលភាពដូច្នេះ។ ការកសាងសមាធិឲ្យបដិសន្ធិឡើងនោះទើបជាការសាងសមត្ថភាព និង ប្រសិទ្ធិភាពឲ្យដល់ខ្លួនឯង រួមទាំងការងារគ្រប់បែបយ៉ាងផង។

ជនណាក៏ដោយ ដែលប្រកបដោយសមាធិពិតប្រាកដដាច់ខាត អត់ធន់ស្វិតស្វាញ ជននោះទោះបីនៅក្នុងប្រភេទណាក៏ដោយ គឺជាកម្មករ ស្មូម វណិព្វក ក្រខ្សត់ តោកយ៉ាកឬក៏ជាមនុស្សអាប់ជោគ អាប់វាសនាយ៉ាងណាក៏ដោយ គេក៏អាចអប់រំសាងជីវិតរបស់គេឲ្យរុងរោចន៍ចុំថ្កើងឡើងមកបាន យ៉ាងគួរឲ្យអភិរម្យណាស់ដែរ។ បើសិនគេជា មេទ័ពក៏ជាមេទ័ពដែលមានសមត្ថភាព និងប្រសិទ្ធិភាពដ៏ខ្លាំងក្លា មានគោលគំនិតជ្រៅជ្រះ មានសតិអារម្មណ៍ល្អិតល្អពិសេសមានមនោភាពទូលំទូលាយ មើលឃើញហេតុការណ៍វែងឆ្ងាយក្នុងសាកលលោក។ បើសិនជានយោបាយ ក៏ជាអ្នកនយោបាយដែលពោរពេញដោយគោលគំនិតដ៏ធ្ងន់ធ្ងរ ដាច់ខាត មានឧត្តមគតិពិតប្រាកដមិនប្រែប្រួលមានជំនឿក្នុង ខ្លួនឯងយ៉ាងខ្ជាប់ខ្លួនមានគោលបំណងមិនរួញរា គេមើលឃើញហេតុការណ៍ក្នុងសាកលលោក បានយ៉ាងទូលំទូលាយហើយទាំងអាចគ្រប់គ្រងប្រទេសបានល្អត្រឹមត្រូវទាំងក្នុង និងក្រៅប្រទេស ការសេដ្ឋកិច្ចនៃជាតិ ហិរញ្ញវត្ថុរបស់ប្រទេស រហូតដល់ការបដិរូបកិច្ចការផ្សេងៗ ដើម្បីស្ថេរភាព និង សេចក្តីរុងរឿងចុំថ្កើង ក្នុងអនាគតរបស់ប្រទេស។

លោកអ្នកអានជាទីគោរព សមាធិចាត់ជាវត្ថុមួយ ដែលលោកអ្នកអាចធ្វើឲ្យកើតមានឡើងបានដោយមិនបាច់ទិញដូរអ្វីសោះ បើសិនលោកអ្នក ត្រូវការឲ្យខួរក្បាលរបស់លោកមានគុណសម្បត្តិវិសេសវិសាលឡើង។

រឿងដែលលោកត្រូវតែចងចាំជានិច្ចនោះក៏គឺ លោកកុំធ្វើការងារយ៉ាងណាៗ ដោយតាមតែអារម្មណ៍ឲ្យសោះ។ លោកតោងតែធ្វើការយ៉ាងមិនរួញរាថយក្រោយ ជាដាច់ខាត។ ការមារម្មណ៍ក្តី សេចក្តីរវើរវាយក្តី សេចក្តីរុញរាក្តី សេចក្តីមិនជឿខ្ជាប់ក្នុងខ្លួនឯងក្តីសេចក្តីស្ទាក់ស្ទើរក្តី សេចក្តីវិតក្កខ្វល់ក្តី សេចក្តីរុញរាក្តី សេចក្តីមិនជឿខ្ជាប់ក្នុងខ្លួនឯងក្តីសេចក្តីស្ទាក់ស្ទើរក្តី សេចក្តីវិតក្កខ្វល់ក្តី សេចក្តីខ្លាចក្តី។ល។ លោកត្រូវតែកំចាត់វាឲ្យផុតរលត់ពីខ្លួនលោកឲ្យអស់កុំឲ្យសល់។ វត្ថុដែលបានពោលមកនេះ សុទ្ធតែជាឧបសគ្គនៃជំហានទៅមុខរបស់លោក ជាឧបសគ្គក្នុងការកសាងសមាធិរបស់លោក។ លោកនឹងធ្វើការងារយ៉ាងណា ត្រូវតែពិចារណាឲ្យបានម៉ត់ចត់ កុំធ្វើត្រួសៗ ឬ ធ្វើឲ្យតែរួចពីដៃដូចអានសៀវភៅយ៉ាងឆាប់រហ័សដើម្បីឲ្យបានឆាប់ចប់ កាលបើចប់ហើយក៏មិនដឹងរឿងអ្វីសោះក្នុងសៀវភៅនោះៗ ឬក៏ធ្វើច្រិមច្រុំៗ ចាប់នេះលែងចាប់នោះចោល មិនឆ្ពោះត្រង់ណាពិតប្រាកដឬក៏ធ្វើ ការទៅបានបន្តិចបន្តួច ជួបប្រទះនៅការលំបាក ក៏រួញរា អស់កំលាំងចិត្តរត់ចោលដូច្នេះជាដើម។ សេចក្តីនឹកគិតដូច្នោះ បញ្ជាក់ឲ្យឃើញថា អ្នកនោះមានសមាធិនៅប្រើការមិនបានសោះឡើយ។ សមាធិពិតប្រាកដ ហើយទាំងមានគុណប្រយោជន៍ផងនោះ តោងជាអប្បនាសមាធិ មិនមែនឧបចារសមាធិទេ ឬក៏សមាធិនោះៗតោងប្រកបដោយចិត្តានុភាពមនោភាព និង កំលាំងសេចក្តីគិត។ គុណសម្បត្តិទាំង៣ ប្រការនោះជាគ្រឿងស្ពិតស្ពាង បណ្តុះបណ្តាលប្រសិទ្ធិភាព ក្នុងផ្លូវខួរក្បាលឲ្យមានសមត្ថភាពល្អវិសេសវិសាលឡើង។

កាលបើលោកធ្វើការងារអ្វី លោកត្រូវតែឲ្យពាក្យប្តេជ្ញាយ៉ាងខ្ជាប់ខ្ជួន មាំទាំនឹងខ្លួនលោកជាមុនថា លោកអាចកំចាត់សេចក្តីខ្លាច សេចក្តីទន់ខ្សោយសេចក្តីរវើរវាយ ការអាណិត អាសូរខ្លួនឯង កាមអារម្មណ៍ សេចក្តីខ្ជិលច្រអូសសេចក្តីវិតក្កកង្វល់ សេចក្តីស្អប់ខ្ពើម សេចក្តីរុញរា សេចក្តីក្តៅក្រហាយ សេចក្តីគុំគួន សេចក្តីស្ទើរស្ទាក់ សេចក្តីសៅហ្មង សេចក្តីអស្មិមានះ សេចក្តីខ្លាចក្រែងអន្តរាយ សេចក្តីមិនជឿខ្ជាប់ក្នុងខ្លួនឯង សេចក្តីអស់សង្ឃឹមនិងការអស់កំលាំងចិត្ត។ល។ ទាំងនេះជាដើម ឲ្យវិនាសសាបសូន្យ អស់ពីដួងចិត្តរបស់លោក។

កាលបើលោកបានកំចាត់ឧបសគ្គនៃសមាធិដូច្នេះទៅហើយ ក៏គួរតែសាងចិត្តគំនិតជាថ្មីដោយគុណសម្បត្តិដូច តទៅនេះ ៖

សេចក្តីស្ងប់សុខ សេចក្តីអត់ធន់រឹងប៉ឹង ការយល់ឃើញតែក្នុងចំណុចល្អ សេចក្តីប្រាថ្នាយ៉ាងខ្លាំងក្លា ក្នុងការសាង សេចក្តីល្អ សេចក្តីក្លាហានដែលត្រូវតស៊ូនៅឧបសគ្គ សេចក្តីស្ងប់ចិត្តនិង ចិត្តត្រជាក់មិនក្តៅក្រហាយ ទោះបីនឹងពើបប្រទះនៅស្ថានការណ៍យ៉ាងណាក៏ដោយ សេចក្តីស្នេហា សេចក្តីត្រេកត្រអាល ភាពជាអ្នកមានមនុស្សធម៌ និង មេត្តាចិត្ត ដល់ពពួកមនុស្ស និងសត្វទាំងឡាយ ការអភ័យទោសឲ្យ សេចក្តីតាំងចិត្តភ្ជាប់ សេចក្តីជឿខ្ជាប់ក្នុងខ្លួនឯង សេចក្តីប៉ុនប៉ងនៃជីវិត កាន់អារម្មណ៍ជាឧបេក្ខា សេចក្តីជំរុញចិត្ត សេចក្តីព្យាយាមមានះសេចក្តីតាំងចិត្តមាំមួនពិតប្រាកដ។

ដើម្បីឲ្យសេចក្តីប្រាថ្នារបស់លោក មានអំណាចយ៉ាងមហាស្ចារ្យ ដែលនឹងបណ្តុះបណ្តាលចិត្តឲ្យកើតចិត្តានុភាព សមាធិ មនោភាពដ៏ខ្លាំងក្លាឡើងទៀត។ លោកត្រូវតែនឹកដល់បុគ្គលសំខាន់ៗ ក្នុងពិភពលោកដែលគេបានបោះជំហានមកយ៉ាង អត់ធន់ មុតមាំ ដោយការតស៊ូ និងព្យាយាមយ៉ាងពិតប្រាកដ ដូចព្រះសម្មាសម្ពុទ្ធម្ចាស់ ប្រធានាធិបតី លិនខលន៍ ចេហ្វឺស័ន ហិត្លែ មុស្សូលិនី អិដិស័ន មហាត្មៈគន្ធីល។ល។ បុគ្គលទាំងនេះ បានតស៊ូក្នុងឆាកជីវិតរបស់គេមកដោយជោគជាំ និង សេចក្តីពិបាកវេទនាយ៉ាងណា។ នោះហើយ គឺជាមេរៀនដ៏វិសេសបំផុតក្នុងការសាងគោលដៅនៃជីវិត របស់លោកឲ្យបរិបូរណ៍ឡើង។

លោកអ្នកអានជាទីគោរព លោកអាចឃើញជាញឹកញយដែលមានបុគ្គលខ្លះធ្វើអ្វីមិនសម្រេច មិនហ៊ានតស៊ូនឹងជោគវាសនានៃជីវិត ក្នុងពាណិជ្ជកម្មនិងឧស្សាហកម្ម ឬពោលឲ្យងាយស្តាប់ គឺគេធ្វើការច្រិមច្រុំ ចាប់នេះលែងចាប់នោះចោល មិនពិតប្រាកដត្រង់ណា។ បុគ្គលដូចពោលមកនេះ ទោះបីនឹងមានចំណេះវិជ្ជា ចេះដឹងជ្រៅជ្រះ ព្រោកប្រាជ្ញយ៉ាងណាក៏ដោយ ក៏មិនបានជាការអ្វីទេ ស៊ូតែមនុស្សមានចំណេះវិជ្ជាតិចតួចស្តួចស្តើង តែគេមានសមាធិចិត្តពិតប្រាកដ មានសេចក្តីប្រាថ្នាទៀងទាត់ មានគោលដៅនៃជីវិតមុតមាំពិតៗក៏

មិនបាន។ ព្រោះបុគ្គលទាំងនេះ មានសេចក្តីអត់ធន់ ក្នុងសមាធិ មានសេចក្តីអំណត់ ក្នុងការប្រើគោលគំនិតមានសេចក្តីអំណត់ក្នុងការងារ។ គឺគេមានគតិប្រចាំចិត្តថាធ្វើទៅ ធ្វើទៅ ធ្វើទាល់តែបានសម្រេចតាមឧត្តមគតិ ដែលគេបានគិតទុកជាមុន ដែលគេតាំងគោលដៅទុកនោះ។ គេព្យាយាមធ្វើយ៉ាងស្វិតស្វាញបំផុត គឺធ្វើហើយ ធ្វើទៀត ធ្វើទាល់ តែសម្រេចដូចគោលបំណងនៃជីវិតរបស់គេ។

ដើម្បីជាការអប់រំហ្វឹកហ្វឺនសមាធិ របស់លោកឲ្យកើតជាទំលាប់ លោកគួរតែកំណត់ការងារឲ្យពិតប្រាកដថា ថ្ងៃណា វេលាណា លោកត្រូវធ្វើអ្វី។ លោកនឹងអាន ឬនឹងសរសេរអ្វីក្នុងរាយការណ៍ប្រចាំថ្ងៃនោះៗ គួរតែមានឲ្យគ្រប់គ្រាន់ ទាំងការសម្រាកកាយ សម្រាកចិត្តការលេងកីឡា ការហាត់ប្រាណ ហើយនឹងការសេពគប់ក្នុងសង្គមមនុស្សទូទៅ។

តាមទស្សនៈ នៃការធ្វើការងាររបស់បុគ្គលសំខាន់ៗនោះ គ្មានកំណត់ពិតប្រាកដតែយ៉ាងណាទេ ដូចអិតវិនម៉ារ៍គ ហែម តែងកាព្យឃ្លោង មុនពេលទទួលទានអាហារព្រឹក។ ឡូតនទគ្លិហ្វកំណត់កិច្ចការសេនាធិការរបស់លោករួមទាំងឲ្យបញ្ជាការផ្សេងៗ មុនអាហារព្រឹក។

តែលោកខ្លះចូលចិត្តការក្នុងពេលឈប់ដូច ហាហ្វម័ន និពន្ធរឿងប្រលោមលោកតែក្នុងពេលយប់ ធោម៉ាស ម៉ា រគធ្វេន និងរូប៊ីតហ្លួយស្ទីហ្វេនស័ន ចូលចិត្តនិពន្ធរឿងតែក្នុងកន្លែងដេក។

បុគ្គលសំខាន់ខ្លះ នឹងធ្វើការងារបានល្អបំផុត ក៏តោងនៅក្នុងទីស្ងាត់តែម្នាក់ឯងដោយគ្មានឮសូរសព្ទសំឡេងអ្វី មកធ្វើឲ្យខួរក្បាលខ្វល់ដូច ហ្គារលីននឹងធ្វើអ្វីបានទាល់តែសោះបើសិនមានសូរសព្ទសំឡេងតែបន្តិចបន្តួច។ តែក៏មានលោកខ្លះ ផ្ទុយគ្នាទៅវិញដូច ណាប៉ូឡេអុង ប៉ូណាប៉ាត៍ ឡរតខេនវិន ចមពលយ៉ហ្វ មេទ័ពបារាំងសេស ជំនះសង្គ្រាមអាល្លឺម៉ង់ក្នុងសង្គ្រាម១៩១៤។ មហាត្មៈគន្ធី ប្រើខួរក្បាលធ្វើការ ដែលលំបាកបំផុតក្នុងបន្ទប់ទទួលភ្ញៀវ ក្នុងចំណោមសូរសព្ទសំឡេងអឺងកងរំពង។

បុគ្គលដែលមានសមាធិយ៉ាងអស្ចារ្យ រមែងប្រើសមាធិធ្វើការងារ បាន

ដោយមិនរើសពេលវេលា និងទីកន្លែង បុគ្គលប្រភេទនេះ តោងចាត់ថា ជាបុគ្គលមហស្ចារ្យ ឬ នឹងហៅថាជាអច្ឆរិយៈ (Genius) ក៏មិនខុស។ គេអាចប្រើសមាធិរបស់គេ ឲ្យកើតប្រយោជន៍បាន គ្រប់បែបយ៉ាង តាមទស្សនៈ នៃលោកីយ៍សុខ និង លោកុត្តរសុខ ព្រោះសមាធិជាអារម្មណ៍ទទេស្អាតដូចទឹកដែលថ្លាស្អាត បរិសុទ្ធនោះឯង។ បុគ្គលដែលមានសមាធិយ៉ាងមហស្ចារ្យ ទោះបីក្នុងវេលាវិបយោគសោកសៅ ឬ បានទទួលទុកទោមនស្សធ្ងន់ធ្ងរយ៉ាងណាក៏ដោយ គេក៏តែងមានចិត្តធ្ងន់ធ្ងរ ត្រជាក់ ទាំងប្រកបដោយសតិសម្បជញ្ញៈចិត្តមិនមានការញាប់ញ័រព្រួយបារម្ភឬតក់ស្លុតនឹងអន្តរាយយ៉ាងណាឡើយ។ ព្រោះគេប្រកាន់ថាជាវត្ថុ ធម្មតាសាមញ្ញដែលមនុស្សមានជីវិតរស់នៅតែងតែពើបប្រទះ (ជំហានជីវិតដោយ អ.ធីរាវុធ) ។ ហើយគេត្រូវតែតស៊ូដើម្បីជ័យជំនះជាទីបំផុត ទោះបីនឹងត្រូវប្រើពេលវេលាច្រើនយ៉ាងណា ប្រើកំលាំងកាយនិងកំលាំងចិត្តធ្ងន់ធ្ងរយ៉ាងណាដ៏ដោយ។

ដុកទ័រ សែមមួយ ខំធ្វើវចនានុក្រមអស់ពេលដល់ទៅ ៨ឆ្នាំទើបសម្រេច ។ កិប្បនខំនិពន្ធរឿង "សេចក្តីអន់ថយ និងសេចក្តិលិចលង់នៃអាណាចក្ររូម៉ាំង" ទំរាំនឹងសំរេចដល់ទៅ១៤ឆ្នាំ។ ការដែលបុគ្គលទាំងនោះមានសេចក្តីតស៊ូ អត់ធន់យ៉ាងស្វិតស្វាញ ក្នុងការធ្វើការងារទាល់តែសម្រេចដូចគោលបំណងដូច្នោះ ក៏ជាការគូសបញ្ជាក់ឲ្យឃើញថាសមាធិបានសាងសេចក្តីអត់ធន់ស្វិតស្វាញឲ្យដល់បុគ្គលទាំងនោះ ត្រឹមណា យ៉ាងណា?។

អ្នកខ្លះទៀត ប្រើខួរក្បាល ធ្វើការងារបានយ៉ាងគួរអស្ចារ្យណាស់ ទាំងអត់ធន់ តស៊ូយ៉ាងស្វិតស្វាញ ជាពិសេស ក៏ព្រោះបុគ្គលទាំងនោះ មានសមាធិរឹងប៉ឹងមុតមាំពិតប្រាកដ។ គេអាចធ្វើការងារបាន ក្នុងពេលជាមួយគ្នា ច្រើនយ៉ាង ច្រើនប្រការ ឲ្យសម្រេចបានយ៉ាងវិសេសដូច ណាប៉ូឡេអុង ប៉ូណាប៉ាត៌ និង ចមពលយ៉ហ្វ នៃបារាំងសេសជាដើម។ យើងអាចនឹងកត់សំគាល់បានថាសមាធិជាមេស្ងួត្រនៃជំហានទៅមុខ ជាអំណាចដ៏ថ្លៃកអស្ចារ្យហើយទាំងជាផ្លូវបណ្តុះបណ្តាលផ្សាំឲ្យកើតវឌ្ឍនភាពនៃវិថិជីវិត។ មនុស្សសំខាន់ៗ មានកេរ្តិ៍ឈ្មោះខ្ទរខ្ទារ ក្នុងផ្ទៃនៃពិភពលោកនេះ ភាគច្រើន ជាមនុស្សមានសមាធិ

វិសេសវិសាលបំផុត ក្នុងភាពជាអ្នកតស៊ូក្នុងឆាកជីវិតរបស់គេរហូតមក។

មនុស្សដែលមានសមាធិហ្នឹងហ្ន ពិតប្រាកដ តែងតែជាបុគ្គលមានការសម្រេចិត្តយ៉ាងដាច់ខាត មុះមុត រឹងប៉ឹង ជាទីបំផុត។ សេចក្ដីស្ទើរស្ទាក់សង្ស័យ ឬសេចក្ដីមិនពិតប្រាកដក្នុងចិត្តរមែងមិនមាននៅនឹងបុគ្គលទាំងនោះ សោះឡើយ ដូចព្រះសម្មាសម្ពុទ្ធជាម្ចាស់របស់យើងកាលព្រះអង្គធ្វើទុក្ករកិរិយា តាមក្បួនលទ្ធិព្រាហ្មណ៍ ទាល់តែព្រះវរកាយ ស្គាំងស្គមនៅសល់តែឆ្អឹង ហ៊ុមដោយស្បែក ក៏នៅតែមិនបានសំរេចផលក្នុងលោកុត្តរៈធម៌ ព្រះអង្គបានធ្វើការតស៊ូព្រមទាំង សាកល្បងដល់ថ្នាក់នេះហើយ ក៏នៅមិនបានផលអ្វី មានតែធ្វើឲ្យរាងកាយទ្រុឌទ្រោម ព្រមទាំងទទួលទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរបំផុត។ កាលបើហេតុការណ៍ត្រឡប់ជាដូច្នេះ ព្រះអង្គក៏ទ្រង់ឈ្វេងយល់ថា ផ្លូវដែលព្រះអង្គបានបដិបត្តិ មកហើយនេះ ពិតជាផ្លូវខុសមិនមែនផ្លូវដើរទៅដើម្បីសំរេចលោកុត្តរៈធម៌ឡើយ ។ ព្រះអង្គទើបឈប់បដិបត្តិតាមលទ្ធិរបស់ព្រាហ្មណ៍ ដែលជាលទ្ធិមួយត្រូវគេរាប់អាន បូជាលើកតំកើង ក្នុងសម័យនោះយ៉ាងទូលំទូលាយបំផុត។ ទាល់តែធ្វើឲ្យបញ្ចវគ្គី ដែលមកសុំចុះជាសិស្សគណអស់ជំនឿក្នុងព្រះនាំគ្នារត់ចោលអស់ទៅ។ កាលបើបញ្ចវគ្គី នាំគ្នារត់ចោលព្រះអង្គទៅហើយ ព្រះអង្គក៏ទ្រង់ប្ដេជ្ញាយ៉ាងដាច់ខាតថា "អាត្មានឹងអង្គុយសមាធិយ៉ាងនេះ ទាល់តែបានសម្រេច លោកុត្តរធម៌បើសិនអាត្មាមិនបានសំរេចលោកុត្តរធម៌ទេ អាត្មានឹងមិនក្រោកជាដាច់ខាត " ។ នៅទីបំផុតព្រះអង្គក៏បាន ត្រាស់ដូចគោលបំណង។

នេះជាការបញ្ជាក់ឲ្យលោកអ្នកអានឃើញច្បាស់ថា សមាធិមានសេចក្ដីសំខាន់បំផុតដែលអាចសាងសិទ្ធត្ថៈ ឲ្យសម្រេចជាព្រះពុទ្ធម្ចាស់ឡើងមកបានយ៉ាងម្ដេច?។

បុគ្គលសំខាន់បំផុតរបស់ឥណ្ឌាម្នាក់ទៀត ដែលជាជនជាតិឥណ្ឌាទាំងមូល នាំគ្នាសម្រក់ទឹកភ្នែកឲ្យ ក្នុងការដែលគេគោងឃ្លាតទៅដោយសេចក្ដីប្ដូរផ្ដាច់ដើម្បីជនជាតិឥណ្ឌា ទាំងមូលបុគ្គលនេះគឺ លោកមហាត្មៈគន្ធី។ លោកមហាត្មៈគន្ធី ជាមនុស្សម្នាក់ ដែលមានសមាធិ ចិត្តពិតប្រាកដគួរឲ្យអស្ចារ្យណាស់។ មានគ្រាមួយ លោកមហាត្មៈគន្ធីកំពុងធ្វើកិច្ច គឺអង្គុយសូត្រមន្ត

ភាវនា។ មានមនុស្សចិត្តឃោរឃៅ បានចោលគ្រាប់បែកមកធ្លាក់ជិតៗ ខ្លួនលោក គ្រាប់បែកក៏បានផ្ទុះឡើងយ៉ាងគឹងកងរំពង ញាប់ញ័រទាំងបរិវេណនោះ។ តែលោក មហាត្មៈគន្ធី មិនបានភ្ញាក់ផ្អើលញាប់ញ័រយ៉ាងណាសោះឡើង។ លោកនៅតែធ្វើកិច្ចសូត្រ មន្តភាវនាព្រងើយដូចជាគ្មានអ្វីកើតឡើងសោះ ហើយនៅទីបំផុត ក្នុងគ្រាដែលលោកត្រូវគេ លួចលបបាញ់ទាល់តែស្លាប់នោះសោត។ សមាធិរបស់លោកក៏នៅតែហ្នឹងហ្នទៀងទាត់ពិត ប្រាកដ ទាល់តែអស់ដង្ហើមជាទីបំផុត។

នេះជាការដៅបញ្ជាក់ឲ្យយើងឃើញច្បាស់ថា មនុស្សដែលជាបុគ្គលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាបុគ្គលសំខាន់ក្នុងសាកលលោកនោះ តោងជាមនុស្សមានសមាធិទៀងទាត់ពិតប្រាកដ។

## ៥. ការសាងសមាធិតាមបែបដុកទ័រគ្លាហ្វម័ន្ទ

លោកដុកទ័រ ឃីត គ្លាហ្វម័ន្ទ និង លោកសាស្ត្រាចារ្យ អ៊ូហ្វ យ៉េនគ្រុស ជាតិអាល្លឺម៉ង់បានឲ្យពាក្យណែនាំ ក្នុងការសាងសមាធិ ក្នុងតម្រារបស់លោកថា ៖

១. ចូរហ្វឹកហាត់សរសេរអក្សរដោយដៃឆ្វេង

២. ចូរអានសៀវភៅដោយយកក្បាលសៀវភៅសំយុងចុះ

ទាំង២ យ៉ាងនេះ នឹងបានផលយ៉ាងណា ខ្ញុំបាទអ្នករៀបរៀង មិនទាន់បានសាកល្បងធ្វើលមើលទេ។ តែបើពិចារណាទៅហើយឃើញថា ត្រូវតែបង្ហាត់ចិត្តឲ្យជាសមាធិសិនទើបអាចធ្វើទៅបាន នេះក៏ជាវិធិសាងសមាធិឲ្យកើត ឡើងបានមួយបែបដែរ។

វិធីទី១ : តាមការយល់នៃខ្ញុំបាទ ការសាងសមាធិនោះ ក្នុងគ្រាដំបូងៗ គួរតែសាងសមាធិក្នុងការអានសៀវភៅឲ្យត្រឹមត្រូវតាមពេលវេលា ដែលខ្លួនបានកំណត់ទុក។ គឺស្រេចតែយើងនឹងយល់ឃើញថា វេលាណា ជាវេលា ដែលសមរម្យល្អ ព្រោះការអាចសៀវភៅក៏ជាការសាងសមាធិ និងជាការបណ្តុះបណ្តាលវិជ្ជាការផ្សេងៗ ឲ្យមានក្នុងខ្លួន។ តអំពីនោះលោកគួរហាត់កត់ហេតុ

ការណ៍ ឬនឹងតែងអ្វីៗ ក៏បានតាមតែថ្នឹករបស់យើង ដូចលោកគួរសរសេររឿងជីវប្រវត្តិរបស់ខ្លួនឯងជាដើម។

វិធីទី២ : ជាការហ្វឹកហាត់ ទាំងសមាធិ មនោភាព សេចក្តីគិត រួមជាមួយគ្នាទាំង ៣ យ៉ាងពោលគឺ លោក អាចតាំងជាមាតិកាអ្វីមួយក៏បាន។ ដូចមាតិកាថា " ព្រះពុទ្ធសាសនាមានប្រយោជន៍យ៉ាងម៉េច? ឬសង្គមរាស្រ្តនិយម បានបដិរូបឲ្យព្រះរាជអាណាចក្រកម្ពុជា មានល្បឿនយ៉ាងម្តេចខ្លះ? ឬជាមាតិការអ្វីក៏ដោយតាមតែខ្លួនថ្នឹក។ ហើយលោកគួររកកន្លែងណាមួយ ដែលស្ងប់ស្ងាត់សមគួរនឹងឈរក៏បានអង្គុយក៏បាន ធ្វើចិត្តឲ្យកើតសមាធិ ហើយប្រើទាំងមនោភាព សេចក្តីចេះដឹង សេចក្តីគិត ពណ៌នាស្វាធ្យាយតែក្នុងមនោគតិ។ វិធីនេះហ្សារល៍ឌីកកេន បានធ្លាប់ធ្វើសំរេចប្រយោជន៍ មកហើយយ៉ាងវិសេសបំផុត។

វិធីទី៣ : ឬនឹងធ្វើតាមបែបគំរូរបស់ព្រះពុទ្ធម្ចាស់ក៏បាន តែតោងដឹងគោលបំណងជាមុខសិនថាយើងត្រូវការយកសមធិទៅប្រើក្នុងផ្លូវលោកីយសុខតែប៉ុណ្ណោះ មិនមែនលោកុត្តរៈទេ តោងយល់ឲ្យច្បាស់ក្នុង រឿងនេះ។

លោកអ្នកស្នេហាវិវឌ្ឍនភាពក្នុងឆាកជីវិត លោកអាចដុតពីសេចក្តីទន់ខ្សោយទាំងស្រុងបានក៏ព្រោះលោកបាន សាងសមាធិឲ្យមានឡើង ។ ហើយទាំងចេះប្រើសមាធិ ដែលខ្លួនមាននៅទីនោះៗឲ្យកើតប្រយោជន៍បានពិតៗ ដូចចក្រព័ត្ត ណាប៉ូឡេអុង ប៉ូណាប៉ាត៍ ចមពលយ៉ហ្វ នៃបារាំងសេស ឬ លោកមហាត្មៈគន្ធី នៃឥណ្ឌា។ល។ នោះហើយគឺគោលដៅនៃឋាមពលដ៏វិសេសវិសាល ក្នុងការដែលនឹងអូសទាញលោកឲ្យផុតចាកសេចក្តីងងឹតងងុល អន្ធការនិងសេចក្តីទន់ខ្សោយរលំរលាយគ្រប់បែបយ៉ាង ដែលតែងតែសង្កត់យើងគ្រប់រូបនាសព្វថ្ងៃនេះ។

# បទទី៦

# រឿងចិត្តានុភាព

## ១. ចិត្តានុភាពគឺអ្វី?

សារៈសំខាន់របស់ចិត្តានុភាព ខ្ញុំបាទសូមហៅថា ចិត្តានុភាព ឬ អំណាចចិត្ត។ តាមលក្ខណ៍ចិត្តវិទសា (Psychology) ពោលថា ចិត្តានុភាព ជាអំណាចដ៏ប្លែកពិសេសបំផុតក្នុងចិត្តរបស់មនុស្សជាគ្រឿងចក្រដ៏សំខាន់សំរាប់ សេចក្តីចំរើនរុងរឿងរបស់មនុស្សគ្រប់រូបគ្រប់នាម។ ព្រោះអំណាចចិត្ត (ចិត្តានុភាព) ជាអំណាចដ៏អាស្ចារ្យបំផុត ដែលពួនសម្ងំ នៅនឹងមនុស្សទូទៅ។ ធម្មជាតិក៏បានស្ថិតស្ថាងអំណាចដ៏វិសេសនេះ (ចិត្តានុភាព) ផ្តល់ឲ្យមនុស្សគ្រប់ៗគ្នាទាំងអស់ សូម្បីតែស្មូម យាចក វណិព្វក ក៏ដោយ ក៏មិនរើសមុខ។

តែបុគ្គលគ្រប់គ្នា មិនបានព្យាយាមប្រើអំណាចទាំងនោះឲ្យកើតប្រយោជន៍ ក្នុងការលើកតំកើងជីវភាពរបស់ខ្លួនឯងសោះឡើយ អំណាចចិត្តានុភាពទើបដេកលក់សម្ងំស្ងៀមនៅនឹងបុគ្គលទូទៅ ដោយមិនចេះភ្ញាក់សោះ។ កាលបើ យើងបានដឹងជាក់ច្បាស់ថា ចិត្តានុភាពជាវត្ថុធាតុមួយដែលឋិតនៅនឹងមនុស្ស ហើយក៏ចាំតែឲ្យទាំងគុណនិងទោស។ គឺជូនកាលចិត្តានុភាពជាប្រយោជន៍ត្រូវតែនាំយកទៅប្រើក្នុងផ្លូវស្ថិតស្ថាងជីវិត ស្ថិតស្ថាងបុគ្គលិកភាពត្រូវតែនាំយកទៅប្រើក្នុងការធ្វើសង្គ្រាមជីវិតក្នុងការប្រកបការងារ និង ក្នុងការសិក្សា។ ព្រោះអំណាច "ចិត្តានុភាព" ជាមាត្រាដ្ឋានដ៏សំខាន់បំផុតសម្រាប់ស្ថិតស្ថាងអច្ឆរិយភាពឲ្យកើតឡើង។

មុនដែលយើងនឹងចូលចិត្តច្បាស់លាស់ក្នុងអំណាចដ៏អាថ៌កំបាំង របស់ចិត្តានុភាព យើងតោងតែយល់ឲ្យជាក់ច្បាស់ថា ចិត្តានុភាពគឺអ្វីពិត? មានសេចក្តីសំខាន់យ៉ាង ម្តេចខ្លះក្នុងការសាងបុគ្គលិកភាព ហើយនឹងធ្វើឲ្យជីវិតមានវិវឌ្ឍនាការយ៉ាងម្តេចទៅទៀត។ បើសិនប្រាសចាកអំណាចចិត្តានុភាពហើយ តើ

នឹងបណ្តាលឲ្យកើតសេចក្តីខូចខាតយ៉ាងម្តេចខ្លះក្នុងការដំណើរជីវិត និង ក្នុងការកសាងអំណាចឲ្យខ្លួនឯង?។

ពាក្យថា ចិត្តានុភាព (Will power) សំដៅយកអំណាចមួយដែលផុសឡើងក្នុងដួងចិត្ត ហើយដែលកើត ប្រតិកិរិយាស្តែងដល់សេចក្តីរឹងប៉ឹង ក្លាហាន ឬ សេចក្តីអត់ធន់ ឬ ក៏សេចក្តីក្លាហានដែលលើសលើសេចក្តីក្លាហានធម្មតារបស់មនុស្ស។

## ២. ចិត្តានុភាពក្នុងការតស៊ូសំខាន់យ៉ាងដូច?

កាលបើបានពន្យល់ពាក្យថា ចិត្តានុភាព គ្រាន់តែឲ្យឃើញផ្លូវអនុវត្តន៍ទៅប៉ុណ្ណោះ យើងក៏អាចគិតបានថា ចិត្តានុភាព មានសេចក្តីសំខាន់ជាអតិបរមាក្នុងការសាងបុគ្គលិកលក្ខណៈ និងការតស៊ូក្នុងឆាកជីវិតនាពេលបច្ចុប្បន្ន និងអានគត។ ចិត្តានុភាព ទើបដូចភាជនៈមួយសម្រាប់ទទួលនូវសេចក្តីចំរើនថ្កុំថ្កើងរបស់មនុស្សគ្រប់ភេទ និង គ្រប់វ័យ។ សេចក្តីតាំងចិត្តដ៏មុតមាំក្លាហានរបស់បច្ចេកជន រមែងឧបត្ថម្ភគាំទ្រ ឲ្យចិត្តគំនិតមានសេចក្តីស្រវាស្រទេញ (Ambition) ធ្វើឲ្យបុគ្គលមានប្រសិទ្ធក្នុងការងារដោយសមរម្យ ទាំងធ្វើឲ្យមានសមត្ថភាពក្នុងការងារទ្វេរឹតតែខ្លាំងក្លាឡើង។ សេចក្តីសម្រេចផលរបស់ពួកមនុស្ស ដែលនឹងដំណើរទៅកាន់គោលបំណងចុងចប់បាននោះ ក៏ដោយសេចក្តីខ្លាំងក្លាមុតមាំនៃសេចក្តីតាំងចិត្តរបស់ខ្លួននោះឯង។

បើសិនបានសិក្សាជីវប្រវត្តិរបស់បុគ្គលសំខាន់ៗនៃប្រទេស នីមួយៗ ហើយក៏នឹងដឹងបានភ្លាមៗ ថាបុគ្គលដែល សំរេចផលក្នុងកិច្ចការផ្សេងៗបាននោះ ក៏ព្រោះគេមានសេចក្តីប្រាថ្នា និងសេចក្តីតាំងចិត្តយ៉ាងមុតមាំរឹងប៉ឹងបំផុត ដើម្បី សមិទ្ធិភាពនិងប្រសិទ្ធិភាពក្នុងការងារនោះៗ។ សេចក្តីគិតនឹកដែលគេមាននៅគ្រប់វិនាទីនោះ គឺត្រូវតែធ្វើឲ្យសំរេចផលទាល់តែបាន។ គឺគេមិនព្រមបោះបង់ចោល ឬ បណ្តែតបណ្តោយខ្លួនឲ្យកើតសេចក្តីធុញទ្រាន់ រារែក ឬរាថយជាដាច់ខាតគេត្រូវតែមានសេចក្តីក្លាហាន អង់អាចជានិច្ច។ គេមិនព្រមផ្លាស់ប្តូរ ឬ ប្រែប្រួលគោលបំណងឬគោលដៅរបស់គេទាល់តែសោះ គេមាន

ជំនឿខ្ជាប់មាំបំផុតក្នុងខ្លួនឯង គេអាចបង្ហាប់បញ្ហារខ្លួនឯងតាមហេតុផលនៃតក្កវិទ្យា (Logic) ឬ ចិត្តវិទ្យារបៀបថ្មី (New Psychology) ។ បុគ្គលដែលមានបុគ្គលិកលក្ខណៈ ដូចបានពោលមកហើយនេះ ខ្ញុំហៅថាជាមនុស្សមាន "ចិត្តានុភាព" ដែលជាថាមពលដ៏សំខាន់បំផុត សម្រាប់មនុស្សយើងនាសព្វថ្ងៃនេះ ព្រមទាំងអាចស្អិតស្អាង ស្ថាបនសមិទ្ធិគ្រប់បែបយ៉ាង ឲ្យដល់មនុស្សលោកគ្រប់ច្រកល្ហក ទាំងក្នុងផ្លូវនយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ តារាសាស្ត្រ អក្សរសាស្ត្រ សាសនា ពេទ្យសាស្ត្រចំណែកបុគ្គលដែលធ្វើការនឿយហត់ដូចគេឯងដែរ តែគ្មានបានសម្រេចប្រយោជន៍អ្វី ឲ្យដល់ខ្លួនឯងសោះនោះ គឺបុគ្គលដែលធ្វើការច្រិមច្រំុ ចាប់នេះលែង ចាប់នោះចោល មិនឆ្ពោះត្រង់ណាធ្វើការទៅដោយគ្មានសេចក្តីព្យាយាម គ្មានសេចក្តីអត់ធន់ ប្រាសចាកគោលបំណងប្រាសចាកផែនការណ៍ ប្រាសចាកសមាធិ ប្រាសចាកសេចក្តីតាំងចិត្តយ៉ាងក្លៀវក្លា (ចិត្តានុភាព) មានតែសេចក្តីខ្លាចនូវអន្តរាយផ្សេងៗ ឥតគណនា។

"គេសាងសេចក្តីប៉ងប្រាថ្នារបស់គេដោយ" ខួរក្បាលដ៏ក្រខ្វក់ រវើរវាយ មានតែចិត្តគំនិតដ៏ទន់ខ្សោយ ធុញទ្រាន់ រួញរា។ បុគ្គលដែលមានព្រឹត្តិការណ៍ដូចពោលមកនេះ នឹង រកសេចក្តីចំរើនទៅមុខមិនបានដាច់ខាត់។ ជីវភាពរបស់គេវែងតែនឹងទ្រុឌទ្រោម រួមទាំងការងារដែលគេកំពុងធ្វើដោយសមត្ថភាពផ្ទាល់របស់គេទៀតផង។

កាលបើបុគ្គលដូចពោលមកនេះ មិនមានសមត្ថភាព នឹងសាងខ្លួនឯងឲ្យដុះដាលលេចឡើងមកក្នុងសង្គមមនុស្សបានទេ។ គេក៏នឹងក្លាយទៅជាបុគ្គលដែល ចាំតែទិទៀនតេះដៀលគេយ៉ាងនេះ យ៉ាងនោះ មិនចេះអស់ មិនចេះហើយ។ ខ្លះទៀត បន្ទោសជោគវាសនាបន្ទោសភ័ព្វសំណាង បន្ទោសផលកម្មបន្ទោសដល់ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះអាទិទេព បន់ហើយ សូកហើយនៅតែមិនឃើញមកជួយទៀត។ បុគ្គលដែលប្រាសចាក "ចិត្តានុភាព" ទោះបីនឹងមានការសិក្សាល្អ មានបរិញ្ញាប័ត្រគរដូចភ្នំ មានការសង្គមល្អ ចូលណាចូលបានមានរាងកាយរឹងប៉ឹងមាំទាំខែងវែង។ តែគេមិនអាចនាំសេចក្តីរុងរឿង ថ្កុំថ្កើង មកឲ្យខ្លួនឯងបានឡើយ។ ក្នុងវង់នៃការងាររបស់គេ ទោះបីជាអ្នកមានឧត្តមគតិ

ដ៏វិសេសវិសាលដ៏លើសលប់មានសមាធិ (Concentration) ដ៏ប្រសើរមាន មនោគតិដ៏វិសេស មានចំណេះវិជ្ជាដ៏ជ្រៅជ្រះយ៉ាងណាក៏ដោយ តែបើសិនគេ ប្រាសចាក "ចិត្តានុភាព" ដែលជាវត្ថុធាតុមួយដ៏សំខាន់បំផុតដូចបានពោលមក ហើយ ក៏មិនអាចកើតប្រយោជន៍យ៉ាងបរិបូរណ៌ គ្រប់គ្រាន់បានឡើយ។ សេចក្តី ទាំងចិត្តយ៉ាងមុតមាំ (Will power) តែមួយ ប៉ុណ្ណោះ ដែលអាចនឹងជួយបណ្តុះ បណ្តាលឲ្យបានពើតប្រទះផ្លូវដំណើររបស់ជីវិត ដ៏មានកេរ្តិ៍ឈ្មោះ និង ថ្កុំថ្កើង ក្នុង សង្គមមនុស្សបាន។ បុគ្គលដែលមានកម្លាំងចិត្តទន់ខ្សោយ ខ្លាចតែត្រូវពើប ប្រទះនូវឧបសគ្គនានាប្រការនោះ បុគ្គលបែបនេះ មិនមានសង្ឃឹមនឹងបានជួប ប្រសព្វនូវសេចក្តីសម្រេចក្នុងកិច្ចការងារ សេចក្តីរុងរឿងថ្កុំថ្កើង និង សេចក្តីសុក ស្តុម្ភនៃទ្រព្យសម្បត្តិជាដាច់ខាត។ ព្រោះក្នុងសម័យបច្ចុប្បន្ននេះយើងតែងតែ យល់គ្រប់គ្នាហើយថា ចិត្តានុភាពជាថាមពលដ៏សំខាន់បំផុតសំរាប់ជួយជ្រោម ជ្រែង តស៊ូដើម្បីវិវឌ្ឍនភាពនៃជីវិតក្នុងកិច្ចការគ្រប់យ៉ាង។ ហើយក៏កម្លាំងនៃ "ចិត្តានុភាព" នេះឯងជាអំណាចមួយដ៏ប្លែកវិសេស ដែលចាំជួយរុញច្រាន បុគ្គលទាំងនេះឲ្យខ្ពស់ត្រដែតឡើងបាន។ អំណាចដ៏មហស្ចារ្យដូចពោលមក នេះ ជាមន្តដ៏វិសេសជួយឧបត្ថម្ភបណ្តុះបណ្តាលសមត្ថភព និង បុគ្គលិក លក្ខណៈរបស់ មនុស្សឲ្យមានប្រសិទ្ធិភាពបរិបូរណ៌ ហើយនៅជួយឧបត្ថម្ភគាំ ទ្រកម្លាំង និង អំណាចដទៃៗឲ្យរឹងតែមានអំណាចខ្លាំង ក្លាឡើងទៀតដូច អំណាច សមាធិ មនោភាព សេចក្តីស្រវាំស្រទេញ សេចក្តីសង្កេត សេចក្តី សម្រេចចិត្តដោយដាច់ខាត សេចក្តីគិត សេចក្តីចាំ។ ចិត្តានុភាព ទើបដូច ភាជនៈពិសេស ចាំតែទ្រទ្រង់ឲ្យជាអច្ឆរិយៈតែម្តង។

សូមឲ្យកំណត់កត់ចាំជានិច្ចថា "ចិត្តានុភាព" មិនចាំបាច់តោងមានឡើង ព្រោះតែការសិក្សាក្នុងគោល ចារិកនៃចិត្តវិទ្យារបស់ ដុកទ័រ កិតគិន ឬ របស់ ដុកទ័រ សិកម៉ន័ហ្វ្រយ៍ដ ឬ របស់កុសតាហ្វ លីបង់ ឬ ក៏របស់លោកគ្រូ អាចារ្យ ណាៗទេ។ តែអំណាច "ចិត្តានុភាព" បានកើតមានហើយដោយធម្មជាតិ ហើយ ក៏ប្រចាំជាប់នៅនឹងមនុស្ស តែគ្រប់រូប គ្រប់នាម។ ជួនកាល "ចិត្តានុភាព" កើត ឡើងឯងៗ ដោយហេតុបច្ចុប្បន្នភ្លាមៗក៏មានដែរ ដូចបុគ្គលធ្វើដំណើរក្នុងព្រៃ

ជ្រៅ អស់កម្លាំងនឿយហត់ស្ទើរតែស្លាប់ និង ធ្វើដំណើរតទៅទៀតមិនរួចហើយ តែគាប់ជួនក្នុងខណៈដែលដើរទៅមិនរួចនេះឯង គេបានជួបសត្វសាហាវ ដូច ខ្លា ដំរី ដើរតម្រង់មករក គេអាចនឹងរត់ទៅបានលឿនដូចខ្យល់ព្យុះតែម្តង នេះ ហើយហៅថាអំណាច "ចិត្តានុភាព" កើតឡើងដោយបច្ចុប្បន្នភ្លាមៗ ជួនកាល អំណាច "ចិត្តានុភាព" កើតដោយអំណាចនៃការសិក្សាអប់រំតាមទ្រឹស្តីនៃចិត្ត វិទ្យារបៀបថ្មី ឬ អំណាចនៃដួងចិត្ត ដែលកើតពីសភាពព័ទ្ធឡោមនៃ ការសង្គម ក៏បានដែរជាអាទិ៍គឺ សេចក្តីមេត្តាអាសូរ ឧត្តមគតិក្នុងផ្លូវនយោបាយ សេចក្តីទី ទ័លក្រការត្រូវប្រមាថមើលងាយ សេចក្តីព្យាបាទ ការស្រាវជ្រាវរកទ្រឹស្តីផ្សេង ៗ ជំនឿស៊ប់ក្នុងលិទ្ធិណាមួយ ឧបាទាន។ល។ អំណាច "ចិត្តានុភាព" នឹងកើត ឡើងដោយវិធីណាក៏ដោយវាក៏តែងតែស្ទើស្ទងឲ្យចំពោះតែបុគ្គលណា ដែល មានជំនឿខ្ជាប់យ៉ាងមុតមាំ ខ្លាំងក្លា មានសមាធិហ្នឹងហ្ន ឬ ក៏មានសេចក្តីខ្លាច យ៉ាងហួសកម្រិត មានសេចក្តីក្លាហានខុសសាមញ្ញជនធម្មតាមានមនោភាព យ៉ាងខ្លាំក្លា មានមេត្តាអាសូរយ៉ាងទូលំទូលាយ។ល។ តែប៉ុណ្ណោះ។ អំណាច ដួងចិត្ត ត្រូវតែមានឥទ្ធិពល ឬអំណាចលើរាងកាយ អំណាចដួងចិត្ត ត្រូវតែរឹង ប៊ឹងដូចដែកថែប មាំមួនដូចសសរតុងអារមេ។ ថាមពល និង អំណាចដូចពោល មកនេះហើយដែលមានប្រយោជន៍ច្រើនបំផុត សំរាប់ស្អិតស្អាងវិវឌ្ឍនាការហុច ផ្តល់ឲ្យខ្លួនឯង រួមទាំងការរក្សារោគ ដោយអំណាចដួងចិត្តទៀតផង។ ព្រោះ បុគ្គលដែលក្លាយទៅជាមនុស្សសំខាន់ៗក្នុងពិភពលោកនោះ សុទ្ធតែមាន ថាមពលក្នុងផ្លូវដួងចិត្តដ៏រឹងប៊ឹង មុតមាំ ដូចគ្នាទាំងអស់។

មិនជាការប្លែក អស្ចារ្យអ្វីទេដែលនឹងឃើញក្មេងតូចមួយបានចេះធ្វើការ ព្យាបាលរោគដោយអំណាចដួងចិត្តហើយក៏បានសម្រេចប្រយោជន៍ល្អ ជាង ថ្នាំផ្សេងៗ ដែលអ្នកវិទ្យាសាស្ត្រផ្នែកពេទ្យបានស្រាវជ្រាវសំរេចទៀតផង។ ទាំងនេះក៏ព្រោះអំណាចដួងចិត្តរបស់ក្មេងតូចមួយដែលមាន "មហាថាមពល" ដល់ថ្នាក់ដែលនឹងជួយទ្រទ្រង់អំណាចឲ្យអ្នកជម្ងឺបាន ព្រមទាំងអ្នកជម្ងឺក៏មាន ជំនឿស៊ប់ផងថាខ្លួនត្រូវតែជារោគដោយវិធីការបែបនេះ ជាពិតប្រាកដហើយ ទាំងត្រូវមានជំនឿស៊ប់ទៀតថា ក្មេងតូចនេះជាតួតំណាងព្រះអាទិទេព ឬ ជា

អ្នកវិសេសពិតៗផ្ទុយទៅវិញបើសិនជាគេទាំងនោះយល់ឃើញថា ក្មេងតូចនេះជាមនុស្សធម្មតា កំពុងតែស្តែងត្លុកកំប្លែង ឬ លេងសៀកឲ្យយើងមើលហើយ។ អំណាចដួងចិត្តរបស់ក្មេងតូចនោះក៏គ្មានប្រយោជន៍អ្វីសោះឡើយ។ ក្នុងការរក្សារោគដោយអភិនិហារ ឬ ឥទ្ធិឫទ្ធិ នៃអំណាច នៃចិត្តានុភាពក៏បាន។

បើសិនយើងបានពិចារណា វិធីរក្សារោគរបស់ ម៉ូសេសហើយ ក៏អាចដឹងជាក់ថាវិធីការរបស់ ម៉ូសេស មិនខុសអ្វី និងវិធីរបស់ក្មេងតូច ដែលបានពោលមកនេះសោះឡើយ។ អំណាចដួងចិត្ត ឬ "អំណាចចិត្តានុភាព" ដែលឧប្បត្តិឡើងនឹងក្មេងតូច ដែលឧបម៉ាឲ្យស្តាប់អំបាលមិញនេះ នឹងកើតឡើងដោយវិធីណា តាមដែលពោលមកហើយក៏ដោយ រមែងជាថាមពលដ៏សំខាន់បំផុតក្នុងការរក្សារោគដោយអំណាចដួងចិត្ត ។ ខ្ញុំបាទជឿជាក់ថា "អំណាចដួងចិត្ត" តោងមានថាមពលលើសលើកម្លាំងអ្វីទាំងអស់ ជាកម្លាំងអំណាចមួយវិសេសបំផុត ដែលអាចបណ្តុះបណ្តាលឲ្យមនុស្ស ទៅជាអ្វីក៏បានដូចកាំជ្រួចហោះ ដែលហោះឡើងទៅដល់លោកព្រះច័ន្ទ ព្រះអង្គារ ក្នុងអវកាសដ៏សូន្យឈឹងព្រមទាំង សត្វ និង មនុស្សឡើងទៅហើយចុះមកបានជាធម្មតា មិនព្រោះអំណាចចិត្តានុភាព ក្នុងការចង់ដឹង ចង់យល់ទេឬ? រួមទាំងអ្នកដែលអង់អាចហ៊ានរួមទៅក្នុងយាននោះផងក៏តោបាន (ចិត្តានុភាព) យ៉ាងគ្រប់គ្រាន់ដែរ។ ហេតុដូច្នេះអំណាចនៃកំលាំងចិត្ត (Will power) អាចធ្វើឲ្យមនុស្សក្លាយទៅជារដ្ឋបុរស អ្នកទស្សនវិទូ អ្នកវិទ្យាសាស្ត្រ អ្នកតារាសាស្ត្រ អ្នកស្តូតនិក អ្នកបរមាណូ ឬ ក្លាយទៅជាមហាចោរ ដែលមានចិត្តកាចសាហាវ ឃោរឃៅបំផុត ជាអ្នកប្រឌិតដែលប្រឌិតគ្រាប់បែកប្រល័យលោក អាចធ្វើឲ្យមនុស្សវិនាសអន្តរាយទាំងជីវិត និងទ្រព្យសម្បត្តិ យ៉ាងវេទនាបំផុតក៏បាន (គឺរូបបរមាណូ ដែលអាមេរិកាំងទំលាក់នៅកោះ ហិរុសិម៉ានៃប្រទេសជប៉ុនជាដើម)។

## ៣. ចិត្តានុភាពក្នុងការទំលាយ

អំណាច (ចិត្តានុភាព) មានទាំងជួយបណ្តុះបណ្តាល និង ការទំលាយ។ អំណាចចិត្តានុភាព ក្នុងការទំលាយនេះមានអ្នកចិត្តវិទ្យាបារាំងសេសម្នាក់ ចង់

ធ្វើការសាកល្បងមើលថាជំនឿស៊ប់ស្លុង ទាល់តែចិត្តជាផ្លុងមួយលើចិត្ត ធម្មតាសាមញ្ញនោះ តើនឹងឲ្យទោសយ៉ាងកាចសាហាវដល់មនុស្សយ៉ាងណាខ្លះឬទេ? អ្នកចិត្តវិទ្យាដូចពោលមកនេះ ទើបធ្វើចុតហ្មាយមួយស្នើដល់រដ្ឋាភិបាលបារាំងសេស ដើម្បីសូមអ្នកទោសម្នាក់ ដែលសាលាជំនុំជំរះកាត់ទោសឲ្យប្រហារជីវិតមកធ្វើការសាកល្បង។ កាលបើរដ្ឋាភិបាលបានអនុមតិយល់ព្រមហើយអ្នកទោសដែលមានគ្រោះថ្នាក់នោះក៏ត្រូវហៅខ្លួនឲ្យចូលមករកអ្នកចិត្តវិទ្យាភ្លាម។ អ្នកចិត្តវិទ្យាបានពោលប្រាប់អ្នកទោសនោះថា អ្នកឯងឃើញពស់នោះទេ? ពស់នេះមានពិសកាចខ្លាំងណាស់វាចឹកអ្នកឯងតែបន្តិចប៉ុណ្ណោះ ពិសដ៏កំណាចសាហាវនោះ នឹងធ្វើឲ្យអ្នក ឯងដាច់ខ្យល់ស្លាប់ភ្លាម។

កាលបើអ្នកទោសនោះ បានត្រូវឃោសនបញ្ចុះបញ្ចូល ឲ្យជឿដូច្នោះ ក៏បង្កើតជំនឿស៊ប់យ៉ាងខ្ជាប់ខ្ជួនឡើង ទាល់តែជាសាហេតុធ្វើឲ្យកើតអំណាចចិត្តានុភាព (ចិត្តានុភាព ក្នុងផ្លូវទំលាយ) ហើយគេក៏នាំអ្នកទោសនោះ ទៅធ្វើការសាកល្បង តែអ្នកចិត្តវិទ្យានោះ មិនបានឲ្យពស់ចឹកយ៉ាងដែលគេឃោសនានោះទេ។ គេត្រឡប់ជាយកកម្ទុលចាក់កណ្តាលខ្នងព្រមទាំង យកក្រដាសផ្ចិតជ្រលក់ទឹកក្តៅឧណ្ហៗ សម្រក់ដាក់កណ្តាលខ្នងធ្វើ ហាក់ដូចជាឈាមបានហូរចេញមកដូច្នោះ។ អ្នកទោសនោះ ជាអ្នកមានជំនឿស្លុងស៊ប់នៅជាមុនហើយក៏ចូលចិត្តថាមុខជាពស់ចឹកមែនពិតហើយក៏ដាច់ខ្យល់ស្លាប់ភ្លាមទៅ។

នេះជាការស្តែងបញ្ជាក់ឲ្យលោកអ្នកអានឃើញច្បាស់ថា ចិត្តជាតួសំខាន់បំផុតសមតាមពុទ្ធភាសិតថា "មនោ បុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា" ចិត្តជាធំចិត្តជាមេដឹកនាំធ្វើអ្វីតោងសម្រេចដោយចិត្តទាំងអស់។

## ៤. ចិត្តានុភាពក្នុងការសាង

តទៅនេះ ខ្ញុំបាទនឹងបានពោលដល់អំណាចចិត្តានុភាពក្នុងការសាង ឬបណ្តុះបណ្តាលខ្លះ។ ក្នុងកម្មវិធីមួយដែលទាក់ទង និងការព្យាបាលរោគរបេងនោះ។ អំណាច (ចិត្តានុភាព) ផ្នែកបណ្តុះបណ្តាលរមែងតែងតែរក្សារោគនោះ

ជាបានយ៉ាងដាច់ខាត ជាងថ្នាំដទៃៗក្នុងវិធីការនៃពេទ្យសាស្ត្រផែនបច្ចុប្បន្ន ដែលបានស្រាវជ្រាវយ៉ាងវិសេសវិសាលនោះ ទៅទៀត។

រឿងដែលនឹងពោលតទៅនេះ អ្នករៀបរៀងបានពើបប្រទះផ្ទាល់នឹងខ្លួនឯងតែម្តង។ បុគ្គលនោះខ្ញុំបាទបាន ស្គាល់គេយ៉ាងជិតដិត។ តាមធម្មតាគេជាមនុស្សមាននិស្ស័យ និង ចិត្តគំនិតរឹងប៉ឹងក្លាហានមកពីកំណើត ចិត្តានុភាពដោយធម្មជាតិ គឺគេជាមនុស្សមិនចេះខ្លាចអ្វីសោះ។ ខ្មោចលង ឬ? ដែលគេល្បីថា មានខ្មោកាចណាស់លងខ្លាំងនៅទីណា? យប់ស្មើណា? គេក៏ទៅទីនោះទុកជាយប់ស្មើណាក៏ដោយ មិនត្រឹមតែមិនខ្លាចខ្មោចប៉ុណ្ណោះទេ ទោះបីតែមនុស្សគេក៏មិនខ្លាចដែរ។ នេះជាការបញ្ជាក់ឲ្យយើងឃើញថា បុគ្គលនោះមានអំណាច (ចិត្តានុភាព) ដោយធម្មជាតិដោយមិនបាច់អប់រំហ្វឹកហ្វឺន។ តែជាគ្រោះថ្នាក់របស់គេ គេត្រូវមានជម្ងឺដោយរោគរបេងយ៉ាងទម្ងន់។ ក្នុងរវាងដែលគេមានការឈឺចាប់ជាទម្ងន់នោះ គេក៏មិនមានតក់ស្លុត ភិតភ័យ ឬ ភ្ញាក់ផ្អើលអ្វីឡើយ គេមានចិត្តគំនិត និង កិរិយាដូចមនុស្សធម្មតា។ តាមប្រក្រតី គេអាចក្រោកដើរទៅណាមកណាបាន ថ្វីបើអាការរោគក្នុងខ្លួនរបស់គេរឹតតែទ្រុឌទ្រោមឡើងជាអតិបរមា។ កាលបើរោគរឹតតែមានអាការខ្លាំងណាស់ទៅដូច្នេះ។ គេក៏តោងដេកស្តិកនៅនឹងទីដំណេក រាងកាយរបស់គេ ក៏ទ្រុឌទ្រោមស្គាំងស្គមនៅសល់តែស្បែក និង ឆ្អឹង។ នៅទីបំផុត មាតាក៏តោងនាំគេទៅរក្សាព្យាបាលឯបន្ទីរពេទ្យឈ្នួល ជាតិអឺរ៉ុបមួយ។ ដោយអាស្រ័យវិជ្ជាការពេទ្យ ដែលមានវិវឌ្ឍនាការលូតលាស់ដូច្នោះក៏ដោយ។ តែអាការរោគរបស់គេក៏មិនបានធូរស្រាលឡើងសោះ។ ទោះបីរាងកាយរបស់គេ នឹងត្រូវមេរោគចង្រៃកំទិចឲ្យវិនាសអន្តរាយយ៉ាងណាក៏ដោយ តែអំណាចចិត្តរបស់គេក៏នៅតែគ្រប់គ្រង សេចក្តីបរិបូរណ៍របស់(ចិត្តានុភាព) យ៉ាងពេញលេញជានិច្ច។

ថ្ងៃមួយ គ្រូពេទ្យបានត្រួតមើលអាការរោគរបស់សព្វគ្រប់ ហើយយល់ឃើញថាអ្នកជម្ងឺត្រូវតែអស់ជីវិតក្នុងកំឡុង២៤ម៉ោង។ ព្រោះប្រចក្សថាសួតរបស់គេត្រូវខូចខាតសឹងតែប្រើការអ្វីពុំបានសោះឡើយ គ្រូពេទ្យប្រាប់ដល់មាតាអ្នកជម្ងឺថា "នេះនៃលោកអ៊ុំ កូនប្រុសលោកអ៊ុំគង់មិនរួចជីវិតទៅបានក្នុង

កំឡុង២៤ម៉ោងនេះទេ ខ្ញុំយល់ឃើញថា គួរតែយកអ្នកជម្ងឺធ្ងន់នេះដាក់ក្នុងបន្ទប់ "មរណាសន្ន" (បន្ទប់ធ្វើឲ្យស្លាប់) ដើម្បីកុំឲ្យរវើរវាយអន្ទះអន្ទែងលោកអ៊ុំយល់ឃើញយ៉ាងម៉េចទៅ?។

ស្រាប់តែអ្នកជម្ងឺបានឮគ្រូពេទ្យនិយាយដូច្នេះ ដោយកំហឹងហួសកម្រិតគេស្ទុះក្រោកឡើងយ៉ាងក្តៅក្រហាយ (ដោយអំណាចចិត្តានុភាព) តែតាមធម្មតា គេនឹងទៅបន្ទោលាមកក៏តោគ្រាហ៍ទៅយ៉ាងពិបាកវេទនាបំផុត។ គេស្ទុះចាប់កាំបិទស្នៀត ដែលលាក់នៅក្រោមខ្នើយរបស់គេ ហើយស្ទុះលោតទៅប្រុងនឹងចាកគ្រូពេទ្យនោះយ៉ាងពេញទំហឹង។ តែជាជោគល្អដែលគ្រូពេទ្យនោះបានគេចទាន់ ហើយប្រញាប់រត់ចេញទៅដោយឆាប់រហ័ស អ្នកជម្ងឺបានតែស្រែកឡើងយ៉ាងកំហឹងថា មនុស្សនៅមិនទាន់ស្លាប់ ចង់ឲ្យស្លាប់ ឬ? គ្មានមនុស្សធម៌អ្វីសោះ នេះឬគ្រូពេទ្យ ? ក្នុងថ្ងៃជាមួយគ្នានេះឯង មាតាក៏តោងនាំកូនប្រុសដែលកំពុងមានអាការធ្ងន់ធ្ងរនោះត្រឡប់មកផ្ទះខ្លួនវិញ។ អំណើះមក គេក៏មិនបាន ធ្វើការរក្សាព្យាបាលយ៉ាងណាសោះឡើយ គង់បណ្តោយទៅតាមយថាកម្ម។ តែនឹងដោយហេតុយ៉ាងណាក៏ដោយ ថៅរោគរបេងនោះក៏សន្សើមៗ បាត់ទៅឯងៗ ហើយវេលានេះក៏ប្រចក្សថា ថៅរោគកំណាចសាហាវនេះគង់មាននៅក្នុងខ្លួនរបស់គេជាដរាប។ តែវាក៏មិនអាចធ្វើអ្វីឲ្យគេបាន គេគង់តែមានជីវិតរស់នៅទាល់តែសព្វថ្ងៃនេះ។

លោក "ដេម៉សធេចន្និស" អ្នកបាឋកថាសំខាន់របស់ក្រិច។ បុគ្គលនោះក្នុងគ្រាដំបូងបានទៅធ្វើបាឋកថាក្នុងសមាគមធំមួយ តែមិនមានរណាយកចិត្តទុកដាក់ចង់ស្តាប់គេសោះ។ ព្រោះការនិយាយរបស់លោក ដេម៉សធេថ្និស មិនសូវក្បោះក្បាយគួរឲ្យស្តាប់ ទាំងប្រាសចាកវាទសិល្បៈ ក្នុងការនិយាយទៀតផង។ លោក ដេម៉សធេន្និស គួរតែអស់សេចក្តីមានៈ ឬ ក៏អស់សេចក្តីសង្ឃឹមខ្វះកម្លាំងចិត្ត។ តែលោកនេះ ត្រឡប់ជាមានសេចក្តីតាំងចិត្ត និង ឲ្យសមាគមនោះនិយមខ្លួនឲ្យទាល់តែបាន។ ដោយសេចក្តីប្រាថ្នាយ៉ាងខ្លាំងក្លា និង មុតមាំ (ចិត្តានុភាព) ដូច្នេះលោកក៏ធ្វើដំណើរចាកចេញពីក្រុងអេធេន្ស ទៅជាច្រើនឆ្នាំទៅអាស្រ័យនៅជាយសមុទ្រដោយមិនត្រូវការជួបនឹងនរណាទាំងអស់។

លោកបានព្យាយាមអានសៀវភៅល្អៗ ផ្សេងៗរបស់អ្នកប្រាជ្ញជាច្រើន ព្រមទាំងបានព្យាយាមហាត់ប្រាណឲ្យមានសុខភាព រឹងប៉ឹង មាំមួនទៀតផង។ ក្នុងការអប់រំហាត់និយាយនេះ ដេម៉ូសថេននិស បានយកក្រួសដាក់ក្នុងមាត់ ហើយក៏បានទៅឈរនៅតែម្នាក់ឯងក្បែរច្រាំងសមុទ្រមួយ ដើម្បីហ្វឹកហ្វឺន និង ហាត់កិរិយារបស់គេ ឲ្យសំឡេងស្របទៅតាមសំឡេងនៃរលកទឹកក្នុងសមុទ្រ។ គេបានហ្វឹកហាត់កិរិយាមាយាទរបស់ខ្លួនឲ្យមានសេចក្តីស្ងប់ស្ងៀមសមរម្យ មិនឲ្យផ្អៀងផ្អង ឃ្លីងឃ្លោងក្នុងវេលានោះ ដេម៉ូសថេននិស បានប្រើវិធីផ្សេងៗជាច្រើន ទាល់តែដល់ថ្នាក់យកចុងដាវស្រួចមុតផ្ទុងជុំវិញខ្លួនឯង ដើម្បីថា បើសិនខ្លួនឯងឃ្លោងទៅទោះបីបន្តិចសោះ ក៏តោងត្រូវចុងដាវជាហេតុឲ្យឈឺចាប់។ ហើយទាំងដើម្បីនឹងកាត់ មិនឲ្យមានការសេវនាសមាគមទៀតផង។ លោកដេម៉ូថេននិស ក៏បានស្រាវជ្រាវ រកពាក្យពេចន៍របស់ខ្លួនឯងខ្លះ យកតាមបែបរបស់អ្នកដែលធ្លាប់មានវាទសិល្បៈដ៏ល្បីល្បាញខ្លះ ព្យាយាមសិក្សាទន្ទេញតម្រាផ្សេងៗខ្លះ។ ដេម៉ូសថេននិស បានព្យាយាមហ្វឹកហ្វឺន អប់រំខ្លួនឯងដូច្នេះអស់វេលាដ៏យូរឆ្នាំ ដោយការប្រឹងប្រែងជាទីបំផុតទាល់តែដល់អាយុ ២៧ឆ្នាំ ទើបគេបានត្រឡប់មក ក្រុងអេថេនស្ស ម្តងទៀត។

តែការត្រឡប់មកក្រុង អេថេនស្ស ម្តងនេះ លោក ដេម៉ូសថេននិស បានក្លាយទៅជាអ្នកមានវាទសិល្បៈ ដ៏ពីរោះ ក្បោះក្បាយ ជាទីនិយមរាប់អាន របស់មហាជនទូទៅក្នុងក្រុង អេថេនស្ស។ ដោយហេតុនេះឯង មិនយូរប៉ុន្មាន គេក៏បានទទួលដំណែងដ៏សំខាន់ក្នុងវង់ការងាររបស់រដ្ឋ។

នេះគឺ អំណាចចិត្តានុភាព បានជាកម្លាំងរុញច្រាន អូសទាញចិត្តគំនិតរបស់ ដេម៉ូសថេននិសឲ្យទៅកាន់ភាព ជាអ្នករុងរឿងថ្កុំថ្កើងបាន។

នាងកញ្ញា មែរីមេកខឺរ ស្ត្រីជាតិអាមេរិកកាំងម្នាក់ទៀត ជាស្ត្រីដែលល្ងង់ខ្លៅមានបញ្ញាអាប់ជាទីបំផុត។ អាជីវកម្មរបស់នាង គឺដើរសុំទានគេចិញ្ចឹមជីវិតគ្រាន់តែឲ្យរស់នៅមួយពេលៗប៉ុណ្ណោះ គ្មានឧត្តមគតិ គ្មានមនោគតិ គ្មានគោលដៅនៃជីវិតអ្វីទាំងអស់ រស់នៅដោយសេចក្តីពិបាកវេទនាជាទីបំផុត។ ទាល់តែនាងមានអាយុ ៤០ឆ្នាំ ៤០ឆ្នាំក្នុងសេចក្តីវេទនា និង ថោកទាបបំផុត។

មានថ្ងៃមួយដែលនាំឲ្យជីវិត ម៉ែរីមេកខីរ តោងប្រែប្រួលទៅ គឺ នាងកញ្ញា ម៉ែរីមេកខីរ បានស្ដាប់ការស្វាធ្យាយន៍វិជ្ជាសង្កត់ចិត្ត របស់លោកសាស្ត្រាចារ្យជាតិបារាំងសេសម្នាក់។ នាងក៏មានសេចក្ដីជ្រះថ្លា ព្រមដោយជំនឿខ្ជាប់ស៊ប់ក្នុងបេះដូងរបស់នាងថា "វាអាចកើតមានបានយ៉ាងនេះពិតប្រាកដ នាងបានប្ដេជ្ញាថា នាងត្រូវតែធ្វើឲ្យបាន ដូចលោកសាស្ត្រាចារ្យពេលនេះជាដាច់ខាត"។ កាលបើនាងមានជំនឿស៊ប់ខ្ជាប់ក្នុងខ្លួន រួមទាំងកើត សេចក្ដីប្រាថ្នាយ៉ាងខ្លាំងក្លាដាច់ខាតដូច្នោះ។ ពលានុភាពក្នុងផ្លូវចិត្តរបស់នាង ក៏ត្រូវដាស់ឲ្យភ្ញាក់ឡើងភ្លាមក្នុងគ្រាដំបូងនាងបានសាកល្បងធ្វើដោយខ្លួនឯងលមើល តែក៏មិនបានឃើញមានផ្លូវសម្រេចអ្វីសោះ។ នៅទីបំផុតនាងក៏តោង ទៅរួមនឹងលោកសាស្ត្រាចារ្យម្នាក់ ទាល់តែលោកសាស្ត្រចារ្យនោះ យកកម្មវិធីរបស់នាង ទៅធ្វើបានសម្រេចផល ក្នុងការរក្សាព្យាបាលរោគដោយអំណាចកម្លាំងចិត្ត (ចិត្តានុភាព) ។

ចំណែកលោកសាស្ត្រាចារ្យនោះប្រចក្សថា មានទ្រព្យសម្បត្តិយ៉ាងស្ដុកស្ដម្ភ ព្រោះតែការរក្សាព្យាបាលអ្នកជម្ងឺជាច្រើន ។ ចំណែក ម៉ែរីមេកខីរ ក៏បែកគំនិតចេញពីលោកសាស្ត្រាចារ្យនោះទៅ។ ទោះបីនាងនឹងខុសបំណងយ៉ាងណាក៏ដោយ។ នាងក៏មិនមានការរុញរាធុញថប់យ៉ាងណាសោះ។ នាងមានសេចក្ដីតាំងចិត្តមុតមាំដាច់ខាតថា នាងត្រូវតែ ធ្វើឲ្យសម្រេចទាល់តែបាន។ "ក្រោមមេឃ លើដីនេះ មិនមានអ្វីដែលមនុស្សធ្វើមិនបាន ធ្វើមិនកើតនោះទេ" ដោយជំនឿស៊ប់ស្លុងខ្លាំងក្លាដូច្នេះ ទើបជាហេតុឲ្យនាងបានធ្វើការសាកល្បងសាកល្បងម្ដងហើយម្ដងទៀតទាល់តែនាង មានអាយុកន្លងចូល៤៥ឆ្នាំ។ ក្នុងទីបំផុតនាងក៏បានសំរេចផលក្នុងការរក្សាព្យាបាលរោគដោយ ឋាមពលនៃអំណាចចិត្ត។ ដោយសេចក្ដីសំរេចផលក្នុងផ្លូវចិត្តនេះឯង ធ្វើឲ្យ ម៉ែរី មេកខីរ បានក្លាយទៅជាមនុស្សមានមុខមាត់ និង កេរ្តិ៍ឈ្មោះ ល្បីល្បាញមានទ្រព្យសម្បត្តិហូរចូលមកមិនឈប់ឈរ។

នាងកញ្ញា ដែលធ្លាប់តែសុំទានគេយ៉ាងរហាម គ្មានខួរក្បាល គ្មានមនោគតិ គ្មានឧត្តមគតិ គ្មានគោលដៅនៃជីវិត ក៏ក្លាយទៅជាសេចក្ដី គួរឲ្យអស្ចារ្យ

ណាស់។

លោក លិត ទ័រ អ្នកភាសាសាស្ត្រជាតិបារាំងសេស ក៏ជាមនុស្សម្នាក់ទៀត ដែលមានអាយុដល់ទៅ៦៣ឆ្នាំហើយនៅតែមិនព្រមរួញរា ថយក្រោយ នៅតែមិនព្រមដេកសមកុក រួញដៃ រួញជើង នៅតែមិនព្រមអស់សង្ឃឹមក្នុងឆាកជីវិត នៅតែមានការតស៊ូ តស៊ូ តស៊ូជានិច្ចគេមានសេចក្តីប្រាថ្នាយ៉ាងខ្លាំងក្លាបំផុត "ក្នុងការសរសេរវចនានុក្រមបារាំងសេស" ឲ្យសំរេចទាល់តែបាន។ ទោះបី អាយុរបស់គេច្រើនណាស់ទៅហើយក៏ដោយ តែគេមានសេចក្តីប្រាថ្នាយ៉ាងខ្លាំងក្លាម៉ឺងម៉ាត់បំផុតដែលត្រូវតែធ្វើឲ្យសំរេច។ គេប្រកាន់ថា ចាស់តែរាងកាយប៉ុណ្ណោះទ តែខួរក្បាលរបស់គេនោះវានៅតែតស៊ូ នៅតែមុតមាំ នៅតែរឹងប៉ឹង ដូចបន្ទះនៃដែកថែបដូច្នោះ។ លោក លិត ទ័រ បានចាប់ផ្តើមសរសេរ វចនានុក្រមរបស់គេ ដោយការយកចិត្តទុកដាក់ជាអតិបរិមា។ គេប្រញាប់ ហើយខំប្រឹងធ្វើការដោយប្រុងប្រយ័ត្នបំផុតមួយថ្ងៃដល់ទៅ ១៦ម៉ោង គឺគេចាប់ផ្តើមតាំងតែអាយុ ៦៣ឆ្នាំ ប្រើពេលវេលាសរសេរ និងស្រាវជ្រាវដល់ទៅ ១០ឆ្នាំទើបបានសំរេច។

លោក លិត ទ័រ ភ្ញាក់ពីដំណេកម៉ោង៨ព្រឹក ចាប់ផ្តើមត្រួតវិញ្ញាសារតាំងតែម៉ោង ៩ដល់ម៉ោង ១២ ទើបឈប់សំរាក និង ទទួលទានអាហារ។ ហើយក៏ចាប់ផ្តើមត្រួតពីម៉ោង ១៣ដល់ម៉ោង ១៥ គេខ្វល់តែរឿងវចនានុក្រមរបស់គេប៉ុណ្ណោះ ទោះបីគេមានអាយុច្រើនហើយចូលក្នុងវ័យជរាភាពផងក៏ដោយ គេដេកត្រឹមតែ ៥ម៉ោងប៉ុណ្ណោះ។ គេធ្វើការដូច្នេះរហូតវេលា ១០ឆ្នាំគឺ ១០ឆ្នាំដែលពោរពេញទៅដោយប្រយោជន៍សាធារណៈ។ លិត ទ័រ តោងអត់ទ្រាំ តស៊ូធ្វើការដ៏ធ្ងន់ធ្ងរនេះ រហូតវេលាគ្មានស្រាកស្រាន្តសោះ តែទោះបីដូច្នេះក៏ដោយគេក៏គង់មានអាយុដល់ទៅ ៨០ឆ្នាំ ។ នេះជាការដៅបញ្ជាក់ឲ្យយើងរាល់គ្នាឃើញច្បាស់ថា ចិត្តានុភាព (អំណាចនៃចិត្ត) អាចសាងសេចក្តីរឹងប៉ឹង និងឋិតថេរ ឲ្យដល់ជីវិត និង រាងកាយយ៉ាងមហស្ចារ្យណាស់។

ធោម៉ស័ ម៉ាហ្សារីគ ប្រធានាធិបតីនៃ ឆេកូស្លូវ៉ាគី ក្នុងគ្រាដំបូងដែលកំពុងសិក្សាក្នុងមហាវិទ្យាល័យនោះ គេក៏បានតាំងបនោបណិធានថា ក្នុងរយៈ

ពេល ៥០ឆ្នាំ ប្រទេស ឆេកូស្លូវាគី ត្រូវតែមានឥស្សរៈភាពពេញលេញ ហើយក៏ក្នុងរយៈពេល ៥០ឆ្នាំនោះឯងសេចក្តីយល់សប្តិ ដែលពោរពេញទៅដោយសេចក្តីអត់ធន់ តស៊ូ ស៊ូទ្រាំ យ៉ាងរឹងប៉ឹង មុតមាំបំផុតរបស់លោក ម៉ាហ្សារីគ នោះក៏បានសំរេចដូចសេចក្តីប្រាថ្នាគ្រប់យ៉ាង។

ម៉ាហ្សារីគ កើតក្នុងខ្ទមកញ្ជាស ដែលស្ទើរតែបាក់បែកខូចខាតអស់ទៅហើយ ក្នុងខ្ទមនោះសោតក៏រកអ្វីជាខ្លឹមសារមិនបានសោះ គេមានពូជពង្សវង្សត្រកូលជាអ្នកជនបទ ដែលក្រខ្សត់ជាទីបំផុត។ ការសិក្សារៀនសូត្ររបស់គេក៏មិនប្រាថ្នាថាបានចូលរៀនពិតប្រាកដនៅកន្លែងណា តែម៉ាហ្សារីគអាចអានបានខ្លះបន្តិចបន្តួច ចំណែកការសរសេរនោះគេសរសេរមិនបានសោះឡើយ។ បិតារបស់ម៉ាហ្សារីគ បានព្យាយាមដាស់តឿនព្រានប្រដៅកូនប្រុសរបស់គេជានិច្ចថា កុំចង់ធ្វើជាខ្ញុំកញ្ជះបាតជើងអ្នកដទៃ ឬ កុំចង់ធ្វើជាបាវបំរើបាតជើងគេឲ្យសោះត្រូវតែជួយខ្លួនឯង។ វិជ្ជារកចិញ្ចឹមជីវិតមានច្រើនណាស់ ត្រូវតែប្រើវិចារណញ្ញាណឲ្យគាប់គួរនឹងនិស្ស័យដែលខ្លួនស្រឡាញ់ចូលចិត្ត។ ចំណែកមាតារបស់គេវិញ ប្រដៅឲ្យគេចេះស្រឡាញ់ការសិក្សា ព្រោះការសិក្សាជាដួងប្រទីបដ៏ភ្លឺថ្លា ក្នុងការស្វែងរកវិវឌ្ឍនភាពឲ្យដល់ខ្លួនឯងក្នុងឆាកជីវិត។

កាល ម៉ាហ្សារីគ អាយុបាន ១៤ឆ្នាំ ក៏បានចូលធ្វើការងារក្នុងរោងស្លដែកទ្រនាប់ស្បែកជើង ហើយក៏ក្នុងពេលជាមួយគ្នានោះឯង គេក៏ខំសិក្សាជានិច្ចទាល់តែមិត្តភក្តិចំអន់គេថាជាកណ្តៀរស៊ីសៀវភៅ តែ ម៉ាហ្សារីគ មិនខ្វីយកចិត្តទុកដាក់នឹងពាក្យចំអកឡកឡឺយនោះឡើយគេប្រាថ្នាតែម្យ៉ាងគឺសេចក្តីសំរេចក្នុងវិជ្ជាការនោះប៉ុណ្ណោះ ។ ដោយសេចក្តី ព្យាយាមដ៏មុឹងម៉ាត់និងប្តូរផ្តាច់ដោយសេចក្តីស្រវាស្រទេញយ៉ាងខ្លាំងក្លារបស់គេ ព្រោះតែហេតុនោះឯង ទើបធ្វើឲ្យមិត្តម្នាក់និយមនៃសេចក្តីខ្នះខ្នែងរបស់គេ ជួយជាការៈឲ្យគេបានចូលសិក្សាក្នុងមហាវិទ្យាល័យនៅក្រុងវៀណ្ណា។ ព្រោះតែសេចក្តីយកចិត្តទុកដាក់ក្នុងការរៀនសូត្រយ៉ាងកំពូលនិង ប្តូរផ្តាច់របស់គេនេះហើយ គេក៏បានសំរេចលទ្ធផល ក្នុងការប្រឡងចេញដោយងាយហើយគេក៨បានធ្វើជាសាស្ត្រាចារ្យក្នុងទស្សនវិជ្ជាសាស្ត្រ។ អំណើះតមក គេក៏ព្យាយាមស្រាវជ្រាវរកទ្រឹស្តីក្នុងវិជ្ជា

ការផ្សេងៗ ដោយមិនចេះឆ្អែតឆ្អន់សោះ ព្រមទាំងព្យាយាម ប្រៀនប្រដៅមិត្ត មនុស្សទូទៅឲ្យ ស្គាល់ច្បាស់នូវគុណតម្លៃនៃវិទ្យាសាស្ត្រ និង សមភាពនៃការរស់នៅរហូតដល់គោលការណ៍នៃភាពជាមនុស្សមានសេរីភាព ឥស្សរៈភាព សមភាព។ល។ ឈ្មោះសំឡេងរបស់ ម៉ាហ្សារីគ ក៏ចាប់ផ្តើមខ្ទរខ្ទារកងរំពងឡើង ទាល់តែបានជាប់ជាសមាជិករដ្ឋសភាតែក្នុងសម័យនោះ ឬអាយុកាលនៃគេនោះ រដ្ឋសភាតាំងនៅឯងក្រុង វៀណ្ណា នៅឡើយទេ។ ដោយហេតុតែ ឆេកូស្លូវ៉ាគី នៅក្នុងក្រញាំនៃអាណានិគមរបស់អូស្ត្រាលី គេទើបរកមធ្យោបាយតស៊ូដើម្បីឥស្សរៈភាពរបស់ប្រទេស ម៉ាហ្សារីគ ទើបពេញទៅដោយសត្រូវគ្រប់ទិសទីចាំតែធ្វើអន្តរាយនិងធ្វើឃាតចំពោះគេជានិច្ច ហើយគេក៏ត្រូវចាប់ដល់ពីរដងទុកជាដូច្នោះក៏ដោយវិញ្ញាណនៃការតស៊ូរបស់គេនៅតែប្រុងប្រៀបដើម្បី រំដោះនឹងមដែកនៃចក្រពត្តិនិយម ដោយមិនរួញរាជាដរាប ឬ លះបង់ចោលនូវគោលដៅនៃឆាកជីវិតរបស់គេឡើយ។ កាលមហាសង្គ្រាមបានឧប្បត្តិឡើង ម៉ាហ្សារីគ ក៏បានប្តេជ្ញាតស៊ូប្តូរផ្តាច់គ្រប់មធ្យោបាយ និងគ្រប់យ៉ាង ដើម្បីឥស្សរៈភាពរបស់ប្រទេស ។ ទ្រព្យសម្បត្តិរបស់គេ ក៏ត្រូវរដ្ឋរិបអូសអស់ខ្លួនរបស់គេក៏ត្រូវចោទជា "ក្បត់" ។ ទាល់តែមហាសង្គ្រាមបានផុតរលត់ហើយ ទើបមានឱកាសបានប្រកាសឥស្សរៈភាព ហើយគេក៏បានទទួលតំណែងជាប្រធានាធិបតី ជាដំបូងបង្អស់របស់ជាតិឆេកូស្លូវ៉ាគី ក្នុងអាយុ ៦៩ឆ្នាំ។ នេះជាការដៅបញ្ជាក់ឲ្យឃើញថា បើសិន ម៉ាហ្សារីគ មិនមានកំលាំងចិត្ត ឬ ចិត្តានុភាពគ្រប់គ្រាន់ហើយសេចក្តីសំរេចផ្សេងៗក្នុងឆាកជីវិតរបស់គេនឹងមានឡើងមិនបាន ដាច់ខាត់។

មេចក្រពត្តិ ណាប៉ូឡេងអុង ប៉ូណាប៉ារត៍ នៃបារាំងសេស ក្រោយដែលសម្ព័ន្ធមិនបានចាប់បញ្ជូនឲ្យទៅនៅនា កោះ អេលបា តែណាប៉ូឡេអុង ក៏អាចរត់ត្រឡប់មកវិញបានទៀត។ ព្រះចៅហ្លួយទី ១៤ នៃបារាំងសេស បានបញ្ជូនទាហានមួយកងវរសេនាធំ ដើម្បីចាប់ណាប៉ូឡេអុង គួរណាស់តែណាប៉ូឡេអុងនឹងគេចរត់ឲ្យផុតដោយសេចក្តីខាច។ តែដោយអំណាចចិត្តានុភាពដ៏ខ្លាំងក្លាបំផុត ប្រត្យក្សថា ណាប៉ូឡេអុង ត្រឡប់មកឈមស៊ូចំពោះមុខទាហានទាំង

នោះដោយ ដោយណាប៉ូឡេអុង មិនមានអាវុធអ្វីជាប់ដៃមកសោះ ហើយទីបំផុត ណាប៉ូឡេអុង ក៏ស្រែកប្រកាសថា "ទាហាន ទាំងឡាយ លោកហ៊ានបាញ់ចក្រពត្តិរបស់លោកដែលមិនមានអាវុធអ្វីសោះឬ? ទាហានទាំងនោះក៏ភាំងស្មារតីទៅអស់ ព្រោះទាហានទាំងនោះមិនធ្លាប់គិតមកមុនសោះថា ណាប៉ូឡេអុង នឹងមានសេចក្ដីក្លាហានអង់អាចដល់ថ្នាក់នេះឡើយនេះជាការដៅបញ្ជាក់ឲ្យឃើញថា អំណាចចិត្តានុភាពអាចសង្កត់ចិត្តបុគ្គល ឬគណៈបុគ្គលបានដោយអង្គ ណាប៉ូឡេអុងឯង មិនបានទទួលគ្រោះថ្នាក់អន្តរាយអ្វីសោះឡើយក្នុងគ្រានោះ។

តួយ៉ាងមួយទៀតគឺ ក្សត្រ នីរូ នៃរាម ដែលមានចិត្តានុភាពក្នុងផ្លូវទំលាយខ្លាំងក្លាណាស់។ មានរឿងពោលទុកក្នុងប្រវិត្តិសាស្ត្រថា ក្នុងរវាងដែលព្រះអង្គកំពុងគ្រងរាជសម្បត្តិនោះ មានគ្រាមួយ ព្រះអង្គត្រូវការចង់ទតព្រះនេត្រការតស៊ូរវាង មនុស្ស និង សិង្ហតោ។ ទើបព្រះអង្គឲ្យចាប់យកមនុស្សទៅដាក់ក្នុងទ្រុងសិង្ហតោ ដើម្បីទតសិង្ហតោ និង មនុស្សតស៊ូគ្នាដូច្នេះជាដើម។

ទាំងនេះបញ្ជាក់ឲ្យឃើញទៀតថា ចិត្តានុភាពមានទាំងការកសាង និងការទំលាយដូចពោលមកហើយ ខាង លើនោះ។

ខ្ញុំបាទបានពោលដល់អំណាចដួងចិត្ត (ចិត្តានុភាព) ក្នុងផ្លូវបណ្ដុះបណ្ដាល និងក្នុងផ្លូវទំលាយមកហើយ។ ជាការគូសបញ្ជាក់ឲ្យលោកអ្នកអានបានឃើញច្បាស់ថា អំណាចចិត្តានុភាពមានទាំងគុណនិងទោស។ ចិត្តានុភាពដែលកើត ឡើងដោយប្រាសចាកការសិក្សា ឬតាមទ្រឹស្ដី ចាត់ជាចិត្តានុភាពមិនត្រឹមត្រូវតាមគោលចារិក នៃចិត្តវិទ្យារបៀបថ្មីឡើយ អំណាចដួងចិត្តបែបនេះ អាចប្រែប្រួលចក្រវាលនៃចិត្តានុភាពឲ្យត្រឡប់ជាចិត្តានុភាពក្នុងផ្លូវទំលាយទៅវិញក៏បាន។ មនុស្សសំខាន់ៗ ក្នុងពិភពលោកជួនកាលត្រូវវិនាសអន្តរាយយ៉ាងខ្លោចផ្សាជាទីបំផុត។ ព្រោះតែអំណាចចិត្តានុភាព ដែលកើតឡើងឯងៗ គឺមិនមែនដោយអាស្រ័យការអប់រំសិក្សា ឬ ទ្រឹស្ដីនៃចិត្តវិទ្យាដ៏ត្រឹមត្រង់។

## ៥. ចិន្តានុភាពកើតឡើងយ៉ាងម៉េច?

អំណាចនៃចិត្តានុភាព អាចកើតដល់មនុស្សដូចតទៅនេះ ៖

១. កើតតាមយុគៈគឺយុគដែលពេញដោយវិក្រិត្តិកាលនៃការនយោបាយ យុគដែលពេញទៅដោយសង្គ្រាម យុគដែលពេញទៅដោយ ការវិវត្តន៍ក្នុងផ្លូវសេដ្ឋកិច្ច ការក្បត់ រដ្ឋប្រហារការចលាចល ឬ ពោលម្យ៉ាងទៀតគឺ ស្រុកទេសដែលមានភាពមិនប្រកតី រៀបរយស្ថានការណ៍តឹងតែងដូច្នេះ រមែងធ្វើឲ្យកើតចិន្តានុភាព។ ហើយគេក៏ក្លាយជាអច្ឆរិយៈឡើងមកបានដូច ត្បុកអហ្វរ៉ឺឡិងត័នហ្សានដាគ វីរស្ត្រីជាតិបារាំងសេស ហិត្លែរ មុស្សូលិនី ខេម៉ាល ឡេនិនជាដើម។

២. កើតដោយហេតុអាសន្ន ៖ គឺហេតុដែលកើតដោយអាសន្នភ្លាមៗ ដូចវេលាកើតភ្លើងចេះផ្ទះ មានមនុស្សលីទូដែកយ៉ាងធំទៅបានយ៉ាងសប្បាយ (តែតាមធម្មតា៤អ្នកក៏សែងស្ទើរតែមិនរួច) ឬ ដូចមនុស្សដើរក្នុងព្រៃជ្រៅ អស់កំលាំងល្ហិតល្ហៃស្ទើរតែដាច់ខ្យល់ ដើរតទៅមុខទៀតមិនរួចហើយស្រាប់តែមានខ្លាធំមួយដើរតំរង់មករក។ គេឃើញដូច្នេះ ក៏រត់លឿនទៅបានដូចខ្យល់ព្យុះ ដូច្នេះជាដើម។ ខ្ញុំបានសូមហៅថា ចិត្តានុភាព កើតឡើងដោយហេតុបច្ចុប្បន្នអាសន្ន។ គ្រាន់តែផុតហួសពីហេតុការណ៍ទាំងនេះទៅហើយ ចិត្តក៏ប្រព្រឹត្តទៅធម្មតា។

៣. កើតពីជំនឿ ៖ គឺ (ចិត្តជឿស៊ប់ខ្ជាប់)

៤. កើតដោយឧបាទាន (សេចក្តីប្រកាន់ខ្ជាប់)

៥. កើតពីវត្ថុព័ទ្ធឡោម ៖ គឺសេចក្តីមេត្តាអាណិតអាសូរ ដូចសេចក្តីមេត្តាអាណិតអាសូររបស់សម្តេចឪកាលព្រះអង្គប្តេជ្ញាទាមទារឯករាជ្យជូន មាតុប្រទេសទាល់តែបានឯករាជ្យបរិបូណ៌ ហើយព្រះអង្គសំរេចព្រះទ័យដាក់រាជ្យ មកប្តូរផ្តាច់តស៊ូរួមនឹងកូនចៅក៏ដោយព្រះមេត្តាធម៌របស់ព្រះអង្គ។ល។ សេចក្តីស្នេហា សេចក្តីព្យាបាទ ការប្រមាថ មើលងាយ ការតមន្ត្រីសិល្បកម្ម លទ្ធិឧត្តមគតិ លទ្ធិនយោបាយ សាសនា ការគ្រប់គ្រង សេដ្ឋភ័យ។ល។

៦. កើតដោយទ្រឹស្តីនៃចិត្តវិទ្យា ៖ គឺការអប់រំហ្វឹកហ្វឺនតាមទ្រឹស្តីនៃចិត្ត

វិទ្យាបែបថ្មី ។

ខ្ញុំបាទសូមលើកយកគំរូចិត្តានុភាព ឬ "អច្ឆរិយៈនៃយុគ" មកជូនលោកអ្នកអានដូចតទៅនេះ សូមឲ្យលោក សង្កេតមើលតើចិត្តានុភាព "អច្ឆរិយៈនៃយុគ" កើតឡើងយ៉ាងម៉េច?

អច្ឆរិយៈនៃយុគ ៖ អច្ឆរិយៈនៃយុគ ជាអច្ឆរិយៈ ដែលសំខាន់បំផុតរបស់មនុស្ស ព្រោះជាអច្ឆរិយៈ ដែលជាប្រយោជន៍ដល់ពួងមនុស្សយ៉ាងច្រើនបំផុត ហើយក៏ជាទោសដល់ពួងមនុស្សយ៉ាងមហន្តដូចគ្នា។ អច្ឆរិយៈប្រភេទនេះជាអច្ឆរិយៈដែលអុជឈ្នួនផ្ទុះនៃអំណាចចិត្តយ៉ាងខ្លាំងក្លា ជាកំលាំងពលំនៃអំណាចចិត្ត ដែលពេញទៅដោយឧបាទាន និង សេចក្ដីប្រកាន់ខ្ជាប់យ៉ាងអាស្ចារ្យណាស់។ បុគ្គលិកភាពនៃសមាធិក្តី បុគ្គលិកភាពនៃចិត្តានុភាពក្តី ឬ នឹងនិយាយយ៉ាងរួមក៏គឺបុគ្គលិកភាពនៃចិត្តវិទ្យា បានសំដែងដល់សញ្ញាលក្ខណ៍ ដ៏រឹងប៉ឹងដាច់ខាត អត់ធន់ហើយក៏មានប្រសិទ្ធិភាពដ៏បរិបូរណ៍ ជាងអច្ឆរិយៈគ្រប់ប្រភេទ ។ បើសិនបានសិក្សា អច្ឆរិយៈប្រភេទនេះឲ្យល្អិតល្អន់បន្តិចហើយ យើងក៏អាចមើលឃើញបានថា អច្ឆរិយៈ ប្រភេទនេះជាមូលហេតុឲ្យកើតកាលីយុគ សង្គ្រាម មហាសង្គ្រាម ការបដិវត្តិ ការក្បត់ ការចលាចល ការរដ្ឋប្រហារ ។ល។ ដល់សុវត្ថិភាពនៃលោក និង ប្រទេសជាតិផ្សេងៗ រហូតមកដូចលោកអ្នកបានដឹងឮ ដោយវិទ្យុខ្លះ កាសែតខ្លះ ដោយហូរហែមកហើយ តាំងពីអតីតរហូតដល់បច្ចុប្បន្ន នេះ ។ ពាក្យថា "អច្ឆរិយៈនៃយុគ" នោះ គឺកំលាំងនៃអច្ឆរិយៈ បានកើតឡើយក្នុងយុគ ឬ ខណៈដែលស្ថានការណ៍នៃលោកកើតការណ៍ជ្រួលច្របល់ ឬ កើតសង្គ្រាមឡើង កើតបដិ វត្តិន៍ រដ្ឋប្រហារ ឬ កើតស្ថានការណ៍តឹងតែងក្នុងបញ្ហានយោបាយ សេដ្ឋកិច្ច វឌ្ឍនធម៌ សីលធម៌ សាសនា។ល។ បើសិន កំលាំងពលំនៃ "អច្ឆរិយៈ" របស់នរណាបានកើតឡើងក្នុងស្ថានការណ៍ដូចពោលមកនេះ កំលាំងពលំនៃ "អច្ឆរិយៈ" របស់អ្នកនោះហៅថា "អច្ឆរិយៈនៃយុគ"។

កាលបើបានធ្វើការវិគ្រោះសព្ទថា "អច្ឆរិយៈនៃយុគ" តាមទស្សនៈនៃចិត្តវិទ្យារបៀបថ្មី (New Psychology) ដូចបានពោលមកដូច្នេះ ទើបជាការដៅ

បញ្ជាក់ឲ្យឃើញថាបុគ្គលណាក៏ដោយដែលបានអាស្រ័យហេតុការណ៍ ដូចខាងលើនេះ ជាកំលាំងពលំ អុជផ្ទុះនូវអំណាចចិត្តឲ្យមានប្រសិទ្ធិភាពបរិបូរណ៍ ព្រមទាំងមានអំណាចយ៉ាងខ្លាំងក្លាបំផុត ក៏គឺបុគ្គលនោះឯងជា "អច្ឆរិយៈនៃយុគ"។

អច្ឆរិយៈបែបនេះ ក៏មិនសូវនឹងឧប្បត្តិឡើងបានងាយៗ ណាស់ទេ ព្រោះថាបើសិនមិនមានហេតុការណ៍ដ៏អំណាចសាហាវ ឬ អាក្រក់យ៉ាងណាមួយកើតឡើយហើយ "អច្ឆរិយៈ" បែបនេះ ក៏តែងតែគិចពួកសម្ងំនៅស្ងៀមៗ ក្នុងខ្លួននៃបុគ្គលនោះ ឬ បើសិនមិនមានហេតុការណ៍ធ្ងន់ធ្ងរដល់ជីវិត និង ជាតារបស់ប្រទេស ហើយបុគ្គលនោះ ក៏មិនមាន ក្លាយទៅជាមនុស្សសំខាន់ដូចពោលមកនេះបានឡើយ។ កំលាំងពលំនៃសេចក្តីគិត កំលាំងពលំនៃចិត្តានុភាពរបស់អច្ឆរិយៈប្រភេទនេះ នឹងផ្ទុះឡើងមកបាន នោះតោងតែអាស្រ័យហេតុភេទខ្លាំងក្លាបំផុត ឬ ក៏អាក្រក់បំផុត។ ហើយក៏ហេតុការណ៍អាក្រក់ទាំងនោះ អាចជាសាហេតុយ៉ាងណាមួយ ដូចបានពោលមកហើយខាងលើនោះឯង។ បើសិនមិនមានហេតុការណ៍ដូច្នេះកើតឡើងទេ បុគ្គលទាំងនោះនឹងឈានឡើងកាន់ភាពជាមនុស្សសំខាន់ៗ ក្រណាស់។

ដោយអាស្រ័យហេតុការណ៍ដូច បានពោលមកហើយនេះឯង ទើបបានធ្វើឲ្យ "អច្ឆរិយៈ" កើតឡើងពេញទូទៅក្នុងពិភពលោក។ ក្រោយសង្គ្រាមលោកលើកទី១ និង ទី២ ដូចក្នុងប្រទេសអាល្លឺម៉ង់ ក្នុងយុគហិត្លែរ ក្នុងប្រទេស ទួរគី ក្នុងសម័យ ខេម៉ាល ឡេនិន ស្តាឡិន ក្នុងសម័យព្រះចៅហ្សារ ក្សត្រដ៏ទារណរបស់រុស្សី ម៉ៅសេទុង ប្រមុខរដ្ឋចិនកម្មុនីស្តក្នុងសម័យបច្ចុប្បន្ន ហូជីមិញប្រមុខយួនវៀតមិញ ក៏បានព្យាយាមរំដោះឯករាជ្យ និង ឥស្សរភាពរបស់ប្រទេសយ៉ាងក្លាហានអង់អាចបំផុត ដឺហ្គោលនៃបារាំងសេស ជាមនុស្សសំខាន់ឡើងមកបាន ក៏ព្រោះការលិចលង់អាប់អោននៃប្រទេសបារាំងសេស ក្នុងសង្គ្រាមបារាំងសេស អាល្លឺម៉ង់ គ.ស ១៩៤០ ។ ហ្សានដារ៍គ វីរស្ត្រីជនជាតិបារាំងសេសជា មនុស្សសំខាន់ឡើង មកបានក៏ព្រោះវិក្រិត្តិកាលនៃយុគព្រះចៅហ្សាលទី៧ នៃបារាំងសេស។

បើសិនយើងបានពិចារណាព្រឹត្តិការណ៍ផ្សេងៗ របស់មនុស្សសំខាន់ៗក្នុងលោកហើយ យើងអាចនឹងឃើញបានងាយថា កាលបើជាតាកម្មរបស់ប្រទេសកើតវិបត្តិ ដោយហេតុការណ៍យ៉ាងណាហើយឬ ស្រុកទេសកើតការចលាចល មិនថានឹងចលាចលដោយផ្លូវសេដ្ឋកិច្ច សង្គ្រាម ដូចប្រទេសអាល្លឺម៉ង់ក្នុងសម័យហិត្លែរ អ៊ីតាលីក្នុងសម័យមុស្សូលិនី ទួរគីក្នុងសម័យខេម៉ាលហើយក៏រុស្សីក្នុងសម័យព្រះចៅ ហ្សារ ឬ ក៏ក្នុងសម័យអាមេរិកដណ្តើមឯងរាជ្យចាកអង់គ្លេស ជាដើម។ កាលបើសភាពការណ៍របស់ប្រទេសកើតឡើងដើម្បីដូច្នេះ ក៏ជាសញ្ញាលក្ខ័ណ្ឌបញ្ជាក់ឲ្យដឹងបានថាអច្ឆរិយៈនៃយុគ មុខតែនឹងឧប្បត្តិឡើងដើម្បីកែខៃឧបសគ្គនោះ។ ហើយជាកំលាំងដ៏សំខាន់របស់ប្រទេសជាតិ។ បុគ្គលពួកនេះតែមួយពួកប៉ុណ្ណោះ ដែលជាអ្នកមានសមត្ថភាព អាចប្រមូលផ្តុំសាមគ្គីជាឯកច្ឆន្ទ ជាផ្លូងមួយក្នុងជាតិបាន ឬ ជាអ្នកមានសមត្ថភាពអាចរួមកំលាំងចិត្តកំលាំងសាមគ្គីរបស់ប្រជាជននៃជាតិ ឲ្យរួមគ្នាបានយ៉ាងឆាប់រហ័សបំផុត គេអាចចាត់ស្ថេរភាពរបស់ប្រទេសឲ្យបានត្រឹមត្រូវដោយងាយទោះបីក្នុងវេលានោះ ស្ថានការណ៍ក្នុងប្រទេសកំពុងតែធ្លាក់ក្នុងភាពដុនដាបហើយជ្រួលច្របល់យ៉ាងណាដ៏ដោយ។ គេជាមនុស្សមិនមានធាតុនៃសេចក្តីកោតខ្លាច មិនមានវិញ្ញាណនៃសេចក្តីទន់ខ្សោយ មិនមានចិត្តញញើតញញប់ញ័រអ្វីឡើយ តែគេមានជំនឿខ្ជាប់មាំក្នុងខ្លួនឯងជានិច្ច គេមានចិត្តរឹងប៉ឹងមុត មាំដាច់ខាតគេជាមនុស្សមានកំលាំងចិត្តមុះមុតសម្បើមណាស់ គេមិនស្តាយជីវិតរបស់គេទាល់តែសោះគេយល់ឃើញ ចំពោះប្រយោជន៍របស់ជាតិ និង ប្រជាជននៃជាតិជាធំជាងជីវិតរបស់គេ។ អច្ឆរិយៈប្រភេទនេះ ទើបជាអច្ឆរិយៈ ដែលព្រះអាទិទេពបានប្រទានមកសំរាប់កែខៃហេតុការណ៍នៃយុគ។ គឺយុគដែលពេញទៅដោយសង្គ្រាម យុគដែលពេញទៅដោយសេដ្ឋភ័យ យុគដែលពេញទៅដោយការជ្រួលច្របល់។ល។ បុគ្គលដូចពោលមកនេះ គេអាចកែខៃបញ្ហាគ្រប់យ៉ាងបានដូច ហិត្លែរ អាចសាងអាណាចក្រអាល្លឺម៉ង់បាន យ៉ាងប៉ិនប្រសប់បំផុតក្រោយសង្គ្រាមលោក ១៩១៤ ដែលហៀប នឹងលិចលង់តែហោងអស់តាំងជាតិទៅហើយនោះឲ្យត្រឡប់មានភាពធំដុំឡើងក្នុងពេលដ៏ខ្លីបំផុតហើយក៏

អាចមានសំភារៈ និង កំលាំងធ្វើសង្គ្រាមលើកទី២បានទៀត។

នេះជាការបញ្ជាក់ឲ្យយើងឃើញបានថា អច្ឆរិយៈនៃយុគ មានសេចក្តីសំខាន់បំផុតដល់ជោគជាតារបស់ប្រទេសនិងប្រជាពលករ ដែលធ្លាប់នៅក្នុងស្ថានការណ៍ដ៏ទារុណ ហើយក៏អច្ឆរិយៈទៀតនោះឯង ដែលជាអ្នកអាចបង្កឲ្យកើតសង្គ្រាមលោក ការបដិវត្តន៍ រដ្ឋប្រហារចលាចលក្បត់។ល។ ដូចហិត្លែរនៃអាល្លឺម៉ង់ មុស្សូលិនីនៃអ៊ីតាលី គ្រម វ៉េល នៃអង់គ្លេស។ល។ អច្ឆរិយៈ បែបនេះជាអច្ឆរិយៈគាប់គួរសមរម្យនឹងស្ថានការណ៍របស់ប្រទេសដែលពោរពេញ ទៅដោយសភាពនៃវិក្រិត្តិកាល។ ហើយក៏វិក្រិត្តិកាលនោះសោត នឹងជាវិក្រិត្តិកាលនៃនយោបាយសេដ្ឋកិច្ច ឬ ក៏វិក្រិត្តិកាលក្នុងរូបការណ៍ បែបណា យ៉ាងណាក៏ដោយ។ លោកអ្នកអានជាទីគោរពសូមឲ្យលោកមេត្តាសង្កេតមើលថា បុគ្គលិកភាពដែលសំខាន់បំផុតរបស់អច្ឆរិយៈប្រភេទនេះគឺបើសិនមានហេតុការណ៍អ្វីៗចង្អៀតចង្អល់ហួសហេតុ មានសេចក្តីទ្រុឌទ្រោមច្រើនហួសកំរិត មានភាពធ្ងន់ធ្ងរដុនដាបណាស់ បុគ្គលដែលមានអច្ឆរិយៈគេចពួននៅក្នុងខ្លួននោះក៏នឹងសំដែងបញ្ជាក់ឲ្យឃើញភ្លាម គេនឹងក្លាយជាមនុស្សមានសេចក្តីអង់អាចក្លាហានយ៉ាងគួរឲ្យអស្ចារ្យណាស់។ ខួរក្បាលរបស់គេ មានសមត្ថភាពមើលឃើញយ៉ាងរហ័សរហួនបំផុតជំនឿខ្ជាប់របស់គេ មានសមត្ថភាពមើលឃើញហេតុការណ៍វែងឆ្ងាយបានយ៉ាងវិសេសវិសាលបំផុតសមាធិរបស់គេទៀងទាត់ពិតប្រាកដដ៏មាំមួនជាស្ថាពរឡើងមក ជាពិសេស ចិត្តានុភាពរបស់គេ រឹងប៉ឹងក្លៀវក្លាយ៉ាងមិនចេះចុះចាញ់សោះឡើង។ សេចក្តីក្លាហានខុសមនុស្សធម្មតារបស់គេ កើតឡើងដើម្បីកែខៃស្ថានការណ៍យ៉ាងនោះ។ ហើយក៏ស្ថានការណ៍នៃវិក្រិត្តិកាលនោះឯង ជាការផ្ទុះកំលាំពលំនៃខួរក្បាលរបស់គេឲ្យរុងរឿងថ្កុំថ្កើងឡើង។ បើសិនប្រាសចាកហេតុការណ៍នៃវិក្រិត្តិកាលដូចពោលមកហើយនេះក៏ប្រត្យក្សថា សមត្ថភាព និងប្រសិទ្ធិភាពរបស់គេ ក៏គង់ឋិតនៅក្នុងសភាពស្ងប់ស្ងៀមធម្មតាតែប៉ុណ្ណោះ។ បុគ្គលដែលមានបុគ្គលិកភាពយ៉ាងនេះហើយដែលខ្ញុំបាទហៅថា "អច្ឆរិយៈបុគ្គលនៃយុគ"។

បើសិនយើងបានសិក្សាជីវប្រវត្តិអច្ឆរិយៈនៃយុគរបស់ហ្សានដារ៍គវីរស្ត្រី

សំខាន់ របស់បារាំងសេសដែលនាងមានសមត្ថភាពអាចរុញច្រានកងទ័ពអង់គ្លេសឲ្យថយក្រោយ ហើយក៏ចុះចាញ់បានជាច្រើនគ្រានោះ យើងក៏អាចជ្រាបបានថា ការដែលនាងបានក្លាយជា វីរស្ត្រីសំខាន់ទៅបាននោះក៏ព្រោះនាងបានអាស្រ័យស្ថានការណ៍ដ៏អាក្រក់ របស់ប្រទេសបារាំងសេសក្នុងខណៈនោះជាមូលហេតុ។ សភាពនៃវិក្រិត្តិកាលរបស់ប្រទេសបារាំងសេសក្នុងគ្រានោះ បានកើតឡើងក្នុរយៈ ១០០ឆ្នាំ គេនាំគ្នាតាំងឈ្មោះឲ្យថាសង្គ្រាម ១០០ឆ្នាំ។ កងទ័ពនៃចក្រភពអង់គ្លេស មានសមត្ថភាពអាចគ្រប់គ្រងដែនដីភាគខាងជើងរបស់បារាំងសេសក៏ជ្រួលជ្រើមជាទីបំផុត ។ បណ្តាបុគ្គលសំខាន់ៗ ក្នុងផ្លូវទាហាន និង អ្នកនយោបាយបានយល់ស្របគ្នាថាយើងគួរតែចុះចាញ់អង់គ្លេសទើបទៅរួច។ ក្នុងវេលាដែលអ្នកការទាហាននិងអ្នកនយោបាយកំពុងតែប្រឹក្សាគ្នានោះ កងទ័ព អង់គ្លេស ក៏ចូលគ្រប់គ្រងខេត្ត អរទ្បេអង្ស បានទៀតក្នុងគ្រានេះឯងដែលជាសាហេតុធ្វើឲ្យកើត "អច្ឆរិយៈនៃយុគ" ដើម្បីកែខៃ និង រំដោះឯងរាជ្យរបស់បារាំងសេស គឺ វីរស្ត្រី ហ្សានដាវ៌គ នោះឯង។

មុនដែលនាងកញ្ញា ហ្សានដាគ នឹងក្លាយជាអច្ឆរិយបុគ្គល ឬ ក្លាយជាវិរស្ត្រីនោះបានកើតបុព្វនិមិត្តដ៏អស្ចារ្យមួយដល់នាង ក្នុងនិមិត្តរបស់នាងនោះនាងបានយល់សប្តិថា "ទេវតាបានមកប្រាប់ឲ្យនាងទៅរំដោះឯករាជ្យ នៃប្រទេសបារាំងសេស ដែលកំពុងតែធ្លាក់នៅក្រោមការបរាជ័យនៃកងទ័ពអង់គ្លេស"។ ហ្សានដាគ បានយល់សប្តិដូច្នេះ ដល់ទៅ ៣ ដងក្នុងរយៈបន្តបន្ទាប់គ្នា បុព្វនិមិត្តនេះឯងដែលជាឋាមពលដ៏សំខាន់ដុតឈ្នួនផ្ទុះនៃអំណាចចិត្ត (ចិត្តានុភាព) របស់នាងឲ្យកើតឡើង។ នាងមាន ឧបាទានយ៉ាងខ្ជាប់ខ្ជួនថាទេវតាបានបញ្ជាឲ្យនាងមករំដោះឯករាជ្យរបស់បារាំងសេសពិតប្រាកដហើយ។ ឧបាទាននេះឯងដែលធ្វើឲ្យនាងកើតជំនឿស៊ប់មាំក្នុងចិត្តថា ការយល់សប្តិរបស់នាងជាការពិតណាស់។ កាលបើនាងកើតជំនឿស៊ប់ដូច្នេះ កំលាំងពលំនៃជំនឿខ្ជាប់កំលាំងពលំនៃមនោភាព កំលាំងនៃសមាធិកំលាំងពលំនៃចិត្តានុភាព ក៏បង្កើតឡើងដល់នាងយ៉ាងមហាសាល។ អច្ឆរិយៈភាពដែលពួនសម្ងំនៅក្នុងខ្លួនរបស់នាង ក៏ត្រូវដាស់ឲ្យភ្ញាក់ឡើងភ្លាម ហេតុនេះឯង ហ្សានដាគ ទើបបានចូលទៅ

គាល់ព្រះចៅហ្សា ហើយក៏ក្រាបទូលដំណាលរឿងដែលខ្លួនឯងបានយល់សប្តិ ថ្វាយព្រះចៅហ្សាល ឲ្យព្រះអង្គទ្រង់ជ្រាបដោយល្អិតល្អន់។ ព្រះចៅ ហ្សាល និងរាជបរិពារ ព្រះទាំងអាមាត្យមុខមន្ត្រីទាំងឡាយបានឮ ហ្សានដាគ ដំណាលហេតុការណ៍ឲ្យស្តាប់ដូច្នោះ ក៏នឹកអស់សំណើច ហើយក៏នាំគ្នាសើចចំអកឡកឡឺយ ហ្សានដាគ ជាច្រើនខ្លះចូលចិត្តថា ហ្សានដាគកំពុងតែក្រឡុកខួរ កំពុងតែវិកលចរិក កំពុងតែឆ្កួត ច្រើនជាងដែលគិតនឹងរំដោះឯករាជ្យរបស់បារាំងសេស។

ទោះជាយ៉ាងណាក៏ដោយ ហ្សាដាគ ក៏នៅតែព្យាយាមអធិប្បាយដល់សេចក្តីខូចខាតផ្សេងៗដែលត្រូវកងទ័ព អង់គ្លេស ចូលមកជិះជាន់លុកលុយអធិប្បតេយ្យរបស់បារាំងសេស។ បើសិនបារាំងសេសសុខចិត្តញ៉ម នៅក្រោមកញ្ជះបាទជើង ឬ នៅក្រោមអធិប្បតេយ្យរបស់អង់គ្លេស ហើយអង់គ្លេសក៏អាចធ្វើអ្វីៗ បានតាមអំពើចិត្ត អង់គ្លេសអាចបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដ៏មានតម្លៃរបស់រដ្ឋ និងរបស់ប្រជាជនដោយអយុត្តិធម៌ ហើយនឹងកើតសេចក្តីវិនាសអន្តរាយចាក អំពើរបស់កងទ័ពអង់គ្លេសយ៉ាងមហាប្រល័យបំផុត។ បណ្តាអាមាត្យមុខមន្ត្រីនានា នៃបារាំងសេស ក៏នឹងត្រូវចាប់ជា ឈ្លើយសង្គ្រាមហើយនឹងអាចត្រូវភ្នួរកប្រហារជីវិតទាំងអស់។ ម្យ៉ាងទៀត ឯករាជ្យភាពដែលជាទីគោរពបូជាយ៉ាងកំពូលស្មើ ដោយជីវិត របស់ជនជាតិបារាំងសេសនោះ ក៏នឹងត្រូវធ្លាក់ទៅជាខ្ញុំកញ្ជះបាតជើងរបស់អង់គ្លេសជាដាច់ខាត។ ព្រះចៅ ហ្សាល និងមន្ត្រីធំតូចទាំងឡាយ ទោះបីនឹងបានយល់រឿងការខូចខាតអធិប្បតេយ្យភាព ហើយនឹងត្រូវបានទទួលផលយ៉ាងម៉េចខ្លះ ដោយជាក់ច្បាស់ហើយក៏ដោយក៏នៅតែមិនស្មោះចិត្តនឹងជឿថា ហ្សាដាគ មានសមត្ថភាពអាចនឹង ការពារប្រទេសបារាំងសេសឲ្យផុតពីក្រញាំនៃកងទ័ពអង់គ្លេសបានសោះ។ តែដើម្បីជាការសាកល្បងសមត្ថភាព របស់នាងលមើល ព្រះចៅហ្សាល ទើបប្រគល់ទាហានឲ្យនាងមួយកងតូច ដែលមានពលទាហានបន្តិចបន្តួច។ ហ្សានដាគ ក៏មានសេចក្តត្រេកអរណាស់ នាងតែងកាយដូចបុរសភេទមើលទៅសង្ហាស្វាហាប់ណាស់ ព្រមទាំងមានសមត្ថភាពខ្លាំងក្លាបំផុត។ នាងបាននាំកងទាហាននោះសោត កាលបើ

ឃើញមេដឹកនាំរបស់ខ្លួនជាស្ត្រីផង ហើយជាមនុស្សមិនខ្លាចស្លាប់ ជាមនុស្សក្លាហានអង់អាចជាអ្នកស្នេហាជាតិក្លាហានអង់អាច ដូចមេដឹកនាំរបស់ខ្លួនទៅផងដែរ។

ដោយជំនឿស៊ប់ក្នុងខ្លួនឯង ដោយឧបាទានដែលប្រកាន់ខ្ជាប់ថា មុខជាទេវតាមកបញ្ជាឲ្យនាងទៅរំដោះ ឯករាជប្រទេសបារាំងសេស នាងទើបនាំកងទាហានបារាំងសេសដែលឋិតនៅក្រោមបង្គាប់បញ្ជារបស់នាង ចូលធ្វើការប្រយុទ្ធដោយវាយប្រហារកងទាហានអង់គ្លេស ដែលគ្រប់គ្រងនៅខេត្ត អរឡេអង្ស ហើយនាងក៏បានជ័យជំនះជាលើកដំបូងដោយមានសមត្ថភាពបណ្តេញ រុញច្រាន កងទាហានអង់គ្លេស ឲ្យក្រចាត់ក្រចាយបែកទ័ពទៅទាល់តែអស់រលីង។ ក្នុងការដែលនាងបានជ័យជំនះក្នុងគ្រានេះ នាងបានទទួលមេដាយ "ម៉ត់អហ្វអឡេអង្ស" ដែលជាកិត្តិយស នៃសេចក្តីក្លាហាន និង ញាណនៃការតស៊ូ ហើយនិងសមត្ថភាពរបស់នាង។ ដើម្បីការបណ្តុះបណ្តាលស្មារតី និង ព្រលឹងរបស់ប្រជាការបារាំងសេសទាំងមូលឲ្យបរិបូរណ៌ រឹងប៉ឹង មុតមាំឡើង។ ហ្សានដាគក៏បានប្រកបអាពាហ៍ពិពាហ៍ មង្គលថ្វាយព្រះចៅ ហ្សាល នៅខេត្ត រ៉េម ដោយនាងបានកាន់ទង់គូនឹងព្រះចៅ ហ្សាល ធ្វើឲ្យគួរជាទីទស្សនា និងជាទីចាប់អារម្មណ៍ខ្លាំងណាស់។ បណ្តាប្រជាករបារាំងសេស នាំគ្នាមានសេចក្តីត្រេកអរសោមនស្សជាអតិបរមា ស្មារតិ និងព្រលឹងរបស់ប្រជាជាតិបារាំងសេស ក៏បានត្រឡប់មកជាប្រក្រតី។ ព្រោះបុគ្គលទាំងនោះបានជឿជាក់ថាហ្សានដាគ តោងជាអ្នកមានសមត្ថភាពខ្លាំងពូកែ អាចរំដោះប្រទេសបារាំងសេសឲ្យផុតចាកក្រញាំនៃកងទ័ពអង់គ្លេសបានយ៉ាងពិតប្រាកដ។

លុះតមក នាងក៏បាននាំកងទ័ពបារាំងសេស ចូលវាយប្រហារកងទាហានអង់គ្លេសទៀតទាល់តែបានជ័យជំនះ គ្រប់ទីកន្លែង និង គ្រប់វេលា។ ហើយនាងក៏បានទូលណែនាំព្រះចៅហ្សាល ទី៧ ឲ្យធ្វើការរុកវាយប្រហារដណ្តើមយកក្រុងប៉ារីស ត្រឡប់មកវិញឲ្យបាន។ ពួកអាមាត្យ និងរាជបរិពារមានសេចក្តីឫស្យា ឈ្នានីស ចំពោះនាងហ្សាន ដាគ ក៏នាំគ្នាទំនាស់យ៉ាងខ្លាំងទាំងនេះក៏ដោយនឹងខ្លាចក្រែងថា កាលបើនាងបានច្បាំងឈ្នះហើយចូលទៅ

ក្នុងក្រុងប៉ារីសបាន នាងអាចដណ្ដើមយកទ្រព្យសម្បត្តិ ដែលខ្លួនមាននៅក្នុងក្រុង ប៉ារីសនោះទៅ។ តែហ្សានដាគ ក៏បានព្យាយាមយ៉ាងអស់សមត្ថភាព ដើម្បីនាំកងទាហានរុកវាយប្រហារកងទ័ពអង់គ្លេស ទាល់តែដល់ជាយក្រុងប៉ារីស។ ហើយក្នុងខណៈនេះ ក្រុងប៉ារីស ក៏កំពុងតែត្រូវវាយបានមកហើយ ស្រាប់តែព្រះចៅហ្វាល មានព្រះរាជឱង្ការឲ្យចាប់យកខ្លួនហ្សាន ដាគទៅឃុំឃាំងទុកមិនព្រមឲ្យនាង ហ្សានដាគ ធ្វើការប្រយុទ្ធតទៅទៀត។

ក្នុងរវាងដែលហ្សានដាគ់ នៅក្នុងទីឃុំឃាំងនោះ បានឮគេថា កងទ័ពអង់គ្លេសបានចូលគ្រប់គ្រងខេត្ត គប់បៀញ បានទៀត។ ដោយសេចក្ដីស្នេហាជាតិយ៉ាងកំពូល យ៉ាងប្ដូរផ្ដាច់នាងក៏បានព្យាយាមតស៊ូបម្រះទំលុះទំលាយទីឃុំឃាំង ចេញមកទាល់តែបាន។ នាងមានសេចក្ដីសប្បាយចិត្តណាស់ ទើបរហ័សធ្វើដំណើរទៅកាន់ខេត្ត គប់បៀញ នោះភ្លាម។ ពួកអ្នកមានឥទ្ធិពលបារាំងសេស ដែលមានការឫស្យាចំពោះនាងនោះ ក៏នាំគ្នាចាប់នាងចងហើយក៏នាំទៅលក់ឲ្យកងទ័ពអង់គ្លេសដោយតម្លៃថ្លៃបំផុត។ ដោយគេបានធ្វើការឃោសនថា ហ្សានដាគ់ នេះជាតួមេមត់ មានអភិនិហារខុស មនុស្សធម្មតា នាងមានឥទ្ធិពលឫទ្ធិខ្លាំងពូកែណាស់ទោះជាដូច្នោះក៏ដោយ នាងក៏មិនមានចិត្តញាប់ញ័រភិតភ័យឬក៏តក់ស្លុតអ្វីសោះឡើង នាងមានកិរិយាជាប្រក្រតី។ ក្នុងខណៈដែលនាងត្រូវចងភ្ជាប់នឹងសសរដ៏មាំ ហើយត្រូវដុតទាំងអស់ដុតដោយភ្លើងទ្រលោមនោះ នាងបានពោលដល់ព្រះនាមព្រះយេស៊ូជាម្ចាស់ ទាល់តែដាច់ខ្យល់ស្លាប់ទៅ។ នាងត្រូវបាន ស្លាប់ក្នុងសម័យដែលនាងមានអាយុ ១៩ឆ្នាំ។ នេះជាការដោបញ្ជាក់ឲ្យឃើញថា ហ្សាដាគ់ ក្នុងគ្រាដំបូងនោះ នាងក៏មិនបានសំដែងសញ្ញាលក្ខ័ណ្ឌនៃភាពជាអ្នកដឹកនាំ ឬមានអច្ឆរិយៈភាពយ៉ាងណាសោះទេ ឬដែលបញ្ជាក់ឲ្យឃើញថា ជាមនុស្សពូកែវិសេសអ្វីក៏ទេដែរ។ ចំពោះចិត្តគំនិតរបស់នាង ក៏ប្រកបទៅដោយមេត្តាធម៌យ៉ាងវិសេសណាស់ ទាំងមានចិត្តបុណ្យជាអតិបរមា ហើយក៏អាជីពដែលនាងប្រកបក្នុងវេលានោះទៀត ក៏គ្រាន់តែជាអ្នកស៊ីឈ្នួលបំរើគេ ក្នុងរោងតៀមលក់ដូរតូចមួយប៉ុណ្ណោះ។ ការដែលនាងបានក្លាយទៅជាមនុស្សសំខាន់ក្នុងប្រវត្តិសាស្ត្រនៃជាតិបារាំងសេស និង នៃពិភព

លោកបានក្លាយទៅជាមេចំបាំងដែលមានកិត្តិយស បានក្លាយទៅជាអ្នកមានមនោភាពក្នុងផ្លូវនយោបាយ និងផ្លូវទាហានយ៉ាងកំពូលនោះ ក៏ដោយហេតុការណ៍នៃយុគ ឬ ដែលអ្នកស្រុកនាំគ្នាហៅថា សង្គ្រាម១០០ឆ្នាំ ដែលបារាំងសេស និង អង់គ្លេសបានធ្វើឡើងនោះឯង មកជួយបណ្ដុះបណ្ដាលស្អិតស្អាងកំលាំងពលំនៃអណាចចិត្តរបស់នាង ឲ្យមានប្រសិទ្ធិភាពខ្លាំងក្លាឡើង។

ខ្ញុំបាទជឿយ៉ាងពិតប្រាកដថា បើសិនហេតុការណ៍នៃវិក្រិត្តិកាល ឬ សង្គ្រាមរវាងបារាំងសេស អង់គ្លេសមិនបានឧប្បត្តិឡើងទេ។ ហ្សានដាគ ក៏គង់មិនក្លាយទៅជាមនុស្សសំខាន់បានជាដាច់ខាត ហើយប្រវត្តិសាស្ត្រក៏មិនបានស្គាល់ ហ្សានដាគ ប្រទេសបារាំងសេសក៏គ្មានវីរស្ត្រីអួតជាតិដទៃដែរ។ ការដែលហ្សានដាគ បានក្លាយខ្លួនទៅជាអច្ឆរិយៈបុគ្គលបាននោះ ក៏ដោយវិក្រិត្តិកាលនៃយុគនោះឯង ជាសាហេតុដុតឈ្នួនផ្ទុះនៃអំណាចចិត្តរបស់នាង ឲ្យមានប្រតិកិរិយាឬ ការប្រែប្រួលឡើង ហើយបើសិនហេតុការណ៍នៃវិក្រិត្តិកាល មិនបានឧប្បត្តិឡើងទេ ហ្សានដាគ ក៏មិនអាចកើតជាបុគ្គលសំខាន់មកបានជាពិតប្រាកដ។

## ៦. ចិត្តានុភាពមានពីរយ៉ាង

ចិត្តានុភាព (Will Power) មានពីរយ៉ាងគឺ ៖

១. (Will Power) ឬ ចិត្តានុភាព ដែលកើតជាស្ថាពរបានសេចក្ដីថា ចិត្តានុភាពដែលត្រឹមត្រូវតាមទ្រឹស្ដីនៃ ចិត្តវិទ្យា និង ឋិតថេរខ្ជាប់ខ្ជួនរហូតមិនប្រែប្រួល ផ្លាស់ប្ដូរសោះ ដូចចិត្តានុភាព របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាដើម។

២. (Will Power) ឬ ចិត្តានុភាព កើតជាបណ្ដោះអាសន្ន ហើយក៏បាត់ទៅវិញក្លាយទៅជាចិត្តធម្មតា ដូចចិត្តានុភាពរបស់ គ្រមវេល នៃអង់គ្លេស រូបេស បីអែរ អ្នកបដិវត្តន៍នៃបារាំងសេសជាដើម។

## ៧. វិធីសាងចិត្តានុភាព

ក្នុងការដែលយើងនឹងបណ្តុះផ្សាំអំណាចចិត្ត (ចិត្តានុភាព) ឲ្យកើតមានឡើង ត្រូវតែធ្វើដូចតទៅនេះ ៖

១. តោងព្យាយាមបំរុងរាងកាយឲ្យមានអានម័យ រឹងប៉ឹង មាំមួនជានិច្ចត្រូវតែមានការបញ្ចេញកំលាំងកាយ ឬ ហាត់ប្រាណ ឬលេងកីឡា ទាំងមានការសំរាកឲ្យគ្រប់គ្រាន់ធូនល្មមសមរម្យ។

២. តោងព្យាយាមរក្សាកំលាំងចិត្ត ឲ្យមានប្រសិទ្ធិភាពលើសចិត្តសាមញ្ញធម្មតា។ ទោះបីនឹងធ្វើការងារយ៉ាងណា ឬ តស៊ូនូវឧបសគ្គនៃជីវិតយ៉ាងណាត្រូវតែថែទាំគ្រប់គ្រងអំណាចចិត្តឲ្យរឹងប៉ឹងមុតមាំនៅជានិច្ច រក្សាឲ្យចិត្តមានអំណាចលើសលើវត្ថុទាំងអស់។

៣. នឹងនិយាយស្តីអ្វី ឬ គិតអ្វីក៏ដោយ ត្រូវតែត្រិះរិះ ពិនិត្យពិចារណាឲ្យសមរម្យជាដរាប។ និងធ្វើការអ្វីៗតទៅ តាំងសំរេចចិត្តដោយដាច់ខាត ក្នុងកិច្ចការនោះ តោងតស៊ូដោយចិត្តមិនរុញរា ឬ ធុញទ្រាន់ជាដាច់ខាត។

៤. តោងប្តេជ្ញាចិត្តរបស់ខ្លួនជាមុនថា ខ្លួនមានគោលដៅយ៉ាងម៉ឺងម៉ាត់ពិតប្រាកដដែល នឹងធ្វើឲ្យមានជំហាននៃជីវិតរបស់ខ្លួន ដូចពាក្យប្តេជ្ញារបស់លោក លិនខល័ន ដែលពោលថា "ខ្ញុំត្រូវតែជាប្រធានាធិបតីដូច វ៉ស៊្សិងត៍នទាល់តែបានបើខ្ញុំបានធ្វើជាប្រធានាធិបតី ហើយខ្ញុំឈប់ឲ្យមានខ្ញុំកញ្ជះបាតជើងគេជាដាច់ខាត" ឬ ពាក្យប្តេជ្ញារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែលពោលថា" បើសិនអាត្មា មិនបានសំរេចក្នុងសម្មាសម្ពោធិញ្ញាណទេ អាត្មានឹងមិនព្រមក្រោកពីការអង្គុយសមាធិជាដាច់ខាត" ពាក្យប្តេជ្ញា ឬ បដិញ្ញា ទើបមានសេចក្តីសំខាន់ណាស់ ដូចបានរៀបរាប់មកហើយនេះ ។ បុគ្គលដែលប្រាថ្នាសេចក្តីសំរេចក្នុងករណីណាក៏ដោយ។ គួរតែតាំងចិត្តប្តេជ្ញាទុកនឹងខ្លួនឯង ដូចព្រះសម្មាសម្ពុទ្ធម្ចាស់ សម្តេចឪ លិនខល័ន ។ ហើយត្រូវតែព្យាយាមធ្វើឲ្យបានយ៉ាងម៉ឺងម៉ាត់ តាមពាក្យប្តេជ្ញានោះយ៉ាងពិតប្រាកដ។ ដូចពាក្យប្តេជ្ញារបស់សម្តេចឪនៃយើង កាលព្រះអង្គប្តេជ្ញាទាមទារឯករាជ្យជូនមាតុប្រទេស និង កូនចៅរបស់ព្រះអង្គ នៅ ថ្ងៃ ទី ១៥ ខែ មិថុនា ១៩៥២ ថាបើសិនព្រះអង្គទាមទារ

ឯករាជ្យជូនមាតុប្រទេសមិនបានហើយ ឬ បារាំងសេសមិនព្រមប្រគល់ឯករាជ្យបរិបូរណ៍ពេញលេញឲ្យមកខ្មែរទេ ព្រះអង្គនឹងមិនព្រមត្រឡប់មកចូលវាំង ឬ ក៏សោយរាជ្យវិញ ជាដាច់ខាត"។ នៅថ្ងៃទី ៩ខែ កុម្ភៈ ឆ្នាំ ១៩៥៣ ព្រះអង្គបានយាងចេញចាកពីប្រទេសទៅបរទេស គឺព្រៃនគរហុកកុង ជប៉ុន ប៉ារីស វ៉ាស៊ិងតោន ញូវយ៉ក ។ល។

ទាំងនេះ ដើម្បីបញ្ចេញសេចក្តីក្លាហាន តស៊ូទាមទារឯករាជ្យព្រះអង្គស្រែកប្រកាសបង្អើលឲ្យពិភពលោកជួយទទួលដឹងថា "ប្រទេសបារាំងសេសក្រាញមិនព្រមប្រគល់ឯករាជ្យបរិបូរណ៍ដល់ប្រទេសកម្ពុជាទេ សូមឲ្យសាកលលោកជួយដឹងឮផងតទៅនេះព្រះអង្គព្រមទាំងកូនចៅរបស់ព្រះអង្គ និងតស៊ូគ្រប់មធ្យោបាយ ដើម្បីឲ្យបានឯករាជ្យបរិបូរណ៍ជូនមាតុប្រទេស។ ហើយព្រះអង្គស្តេចយាងត្រឡប់មកកាន់មាតុប្រទេសវិញ នៅថ្ងៃ ១៤ ខែ ឧសភា ឆ្នាំ ១៩៥៣។ ព្រះអង្គទៅគង់នៅខេត្តបាត់ដំបង និងសៀមរាបដើម្បីបំពេញព្រះសកម្មភាពរួម និងកូនចៅតទៅ។

ក្នុងគ្រានោះឯងធ្វើឲ្យមជ្ឈដ្ឋានទូទៅក្នុងសាកលលោក ជាពិសេសបារាំងសេស ម្ចាស់នឹមដែកដែលធ្លាប់ទឹមខ្មែរយ៉ាងទារុណមក្ខជិតមួយសតវត្សហើយនោះ មានការជ្រួលជ្រើម ឬ ប្រតិកិរិយាខុសប្រក្រតី ចំណែកក្នុងសហរដ្ឋអាមេរិកវិញ សារពត៌មានជាច្រើនបានពិភាក្សាវិចារចំពោះអំពើអាក្រក់ក្បាលរឹង និងអស្មិមានះរបស់បារាំងសេស។

ចំណែកក្នុងរដ្ឋកម្ពុជាវិញ កូនចៅរបស់ព្រះអង្គនាំគ្នាកើតទុក្ខ ព្រួយបារម្ភខ្លាំងព្រោះនឹកក្រែងថា បើសិនចក្រព័ត្ត ម្ចាស់នឹមដែក មិនព្រមដោះនឹងបណ្តោយឲ្យខ្មែរមានឥស្សរៈភាព សេរីភាពទេ មុខជាសម្តចឪរបស់ខ្លួនមិនព្រមយាងមកជាម្លប់វិញជាដាច់ខាត។ ហើយក្រែងម្យ៉ាងទៀត គឺក្រែងបារាំងសេសក្រាញរឹងរូស មិនព្រមប្រគល់ឯករាជ្យពេញលេញ និងប្រតិបត្តិតាម ដែលព្រះអង្គបានតាំងមនោបណិធានមកហើយនោះ។ កូនចៅរបស់ព្រះអង្គទាំងប្រទេសរន្ធត់ញាប់ញ័រ ព្រោះតែសេចក្តីស្នេហា ចំពោះព្រះអង្គលើសជាងជីវិតរបស់ខ្លួនទៅទៀត។ ក្នុងមជ្ឈដ្ឋាននៃកូនចៅរបស់ព្រះអង្គទូទៅពេញទាំងផ្ទៃប្រទេសបាន

កើតប្រតិកិរិយាចំពោះរដ្ឋបារាំង និង ជនជាតិបារាំងសេសយ៉ាងសម្បើមណាស់ ។ ទាល់តែក្នុងខណៈនោះទាហានបារាំងសុទ្ធសាធ និង ទាហានស៊ីឈ្នួលបារាំងសេស (ទាហានបរទេស) ដែលឋិតនៅក្រោមបង្គាប់បញ្ជាររបស់បារាំងសេស តោងនាំគ្នាញរញ្ញើត ភិតភ័យ លែងហ៊ានក្អេងក្អាងដូចកាលមុនៗនោះឡើយ។ នៅទីបំផុតបារាំងសេសក៏ត្រូវចាញ់បារមី (ចិត្តានុភាព) របស់ព្រះអង្គសុខចិត្តដោះនឹងដែកដែលធ្លាប់តែបំពាក់ទឹមក្បាលខ្មែរមកយ៉ាងទារុណ បំផុតជិតមួយសតវត្សនោះទៅហើយព្រមប្រគល់ឯករាជ្យពេញបរិបូរណ៍ថ្វាយព្រះអង្គវិញ ដោយដាច់ខាតនូវ ថ្ងៃទី ២៣ ខែ កុម្ភៈ ១៩៥៥។ សូមឲ្យបងប្អូនរួមឈាមមេត្តាពិចារណាមើលដោយយុត្តិធម៌ចុះ តើក្នុងកាលដែលព្រះអង្គទ្រង់ប្ដេជ្ញាតស៊ូទាមទារឯករាជ្យនោះព្រះអង្គធ្វើទៅដោយអំណាចអ្វី? មិនព្រោះដោយអំណាចមេត្តាអាណិតអាសូរ ចំពោះកូនចៅរបស់ព្រះអង្គទេឬ? ហើយក៏អំណាចមេត្តាអាណិតអាសូរនេះឯងដែល ជាមូលហេតុឲ្យកើតចិត្តានុភាព។ ចិត្តានុភាព ជាដើមកំណើតនៃអច្ឆរិយៈបុគ្គល។ តាមគោលការនៃចិត្តវិទ្យា ខ្ញុំបានសូមទុកសិល្បៈដ៏ឆ្នើមបំផុត ព្រះអង្គមានមហាឋាមពលនៃចិត្តមុះមុតបំផុត ជាមហាបុរសដែលមានសមាធិវិសេសបំផុត ជាមហារដ្ឋបុរសដែលមានចិត្តានុភាពខ្លាំងក្លាបំផុត។ល។ ព្រះអង្គតស៊ូដើម្បីមាតុប្រទេស និង កូនចៅឲ្យរួចផុតពីនឹមដែកនៃចក្រព័ត្តិ។ ហើយព្រះអង្គក៏នៅតែតស៊ូ តស៊ូដើម្បីសន្តិភាពក្នុងលោក ព្រោះព្រះអង្គមានព្រះទ័យបង់ឲ្យលោកទាំងមូល មានតែសន្តិភាព និង សន្តិសុខ គំរូជាក់ស្ដែង គឺការផ្សះផ្សារលាវជាដើម។ នេះហើយ គឺអំណាចមេត្តាអាណិតអាសូររបស់ព្រះអង្គ ដែលទ្រង់យល់ឃើញថារដ្ឋកម្ពុជាក្ដី កូនចៅរបស់ព្រះអង្គក្ដីដែលត្រូវតែធ្វើទារុណកម្មហុតឈាម សង្កត់ក្បាលមកជិត១០០ឆ្នាំហើយនោះគ្មាននរណាគិតគូរអើពើ និងរំដោះសោះ ដោយសារតែព្រះអង្គមានការតស៊ូប្ដូរផ្ដាច់យ៉ាងសម្បើម ក្នុងគ្រានោះឯង មហាជោគជ័យទាំងស្រុងក៏ធ្លាក់ជាសម្បត្តិរបស់ព្រះអង្គ ទាំងនេះក៏ព្រោះ "មហាឋាមពលនៃអំណាចចិត្ត" របស់ព្រះអង្គដែលកើតដោយមេត្តាអាណិតអាសូរចចំពោះកូនចៅ និងមាតុប្រទេសនោះឯង។ មិនត្រឹមតែប៉ុណ្ណោះសោត ព្រះអង្គក៏នៅតែតស៊ូ ប្ដូរផ្ដាច់ រុញច្រានរដ្ឋនាវា

កម្ពុជាអព្យាក្រិត្យទាល់តែមានឈ្មោះល្បីល្បាញក្នុងឆាកអន្តរជាតិ។ ការសែត បរទេសភាគច្រើន ដែលធ្លាប់តែមើលងាយទិទៀនព្រះអង្គ វេលានេះបានត្រឡប់ខួរ (ស្មើយឆ្លួត) យល់ឃើញថា ព្រះអង្គជាឪនៃសន្តិភាពក្នុងអាស៊ីភាគអាគ្នេយ៍ តាំងពីខណៈដែលព្រះអង្គផ្សះផ្សារឿងបងប្អូនសាវ ស៊ីងតែទាស់ទែងដណ្ដើមគ្នាធ្វើធំ (ខ្លះចង់ធ្វើធំខាងលោកសេរី ខ្លះចង់ធ្វើធំខាងលោកគម្មុនីស្ត) ព្រះអង្គក៏ព្យាយាមបញ្ចុះបញ្ចូលឲ្យចាប់ដៃគ្នា ឲ្យរួមគំនិតគ្នា ចងបាច់គ្នា ធ្វើជាអព្យាក្រឹតទៅវិញទៅបានវាបានសុខ។ តែរឿងរ៉ាវទាំងនោះ បានត្រូវប្រទាញប្រទុងគ្នា ធ្លាក់ទៅដល់ ហ្សឺណែវព្រះអង្គក៏តោងហោះទៅធ្វើជាប្រធានបើអង្គប្រជុំទៀត។ ហើយក្នុងពេលជាមួយគ្នានោះប្រទេសខ្លះឈ្នានីសខ្មែរសម្បើមណាស់ គេអន់ចិត្តព្រោះខ្លួនគេក្ដី អ្នកដឹកនាំក្ដី និង ប្រទេសគេក្ដីវាធ្លាប់ធំជាងខ្មែរសម្បើមជាងខ្មែរ ឯករាជ្យមុនខ្មែរ ហេតុម្ដេចបានជាវាមិនលេចក្បាលត្រដែតឡើងក្នុងឆាកអន្តរជាតិ ដូចបងខ្មែរសោះ។ ខ្លះនឹងពេក សុខចិត្តអត់កាហ្វេ អត់ការរ៉េមកែ។ល។ ស៊ូប្ដូរផ្ដាច់យកលុយកាក់ទៅជួលកាសែតផ្កាមាស កាសែតគំនិតថោក កាសែតលក់ខ្លួននៅអឺរ៉ុបខ្លះឲ្យនាំគ្នាហ៊ូមរោងដាក់ព្រះអង្គ ទិទៀនព្រះអង្គ។ល។ ក្នុងអំពើដែល ព្រះអង្គខំតស៊ូដើម្បីសន្តិភាពក្នុងរឿងលាវនោះ។ ចំពោះកាសែតសៀមវិញ សានសេរី ស្យាមរដ្ឋ ភិមថៃ ស្យាមនិកន។ល។ វាចុះថា "ព្រះអង្គម្ចាស់ នរោត្តម សីហនុ ចង់ធ្វើជាអ្នកសម្បើម ចង់មានមុខ មានមាត់ ចង់ធ្វើជាអ្នកដឹកនាំក្នុងភាគអាស៊ីអាគ្នេយ៍ ចង់អូសទាញលាវឲ្យទៅជាខ្ញុំបញ្ជះក្រោមបាតជោះងគម្មុនីស្តចិន។ល។ "ទាំងនេះ ក៏ដោយសេចក្ដី ឈ្នានីសចំពោះព្រះអង្គចំពោះកូនចៅខ្មែរដែលតែងដង្ហែតាមព្រះអង្គ ប្ដូរផ្ដាច់ចំពោះព្រះអង្គ។ ហើយជាពិសេស ឈ្នានីស ដែលពួកវាធ្វើមិនកើត ធ្វើមិនបានដូចព្រះអង្គ ព្រោះព្រះអង្គមាន "មហាឋាមពលនៃអំណាចចិត្តមហាបុគ្គលិក លក្ខណៈដែលពោរពេញដោយព្រះមេត្តាធម៌ ប្រកបដោយអហិង្សាជាប់មាំជានិច្ច"។ ព្រះអង្គមានព្រះទ័យប្ដូរផ្ដាច់ចំពោះជាតិមាតុភូមិ និង ចំពោះសន្តិភាពក្នុងលោកព្រះអង្គឃើញទុក្ខក្ដៅក្រហាយរបស់អ្នកដទៃសំខាន់ជាងទុក្ខរបស់ព្រះអង្គទៅទៀត។ យើងរាល់គ្នាឃើញស្រាប់ហើយ ព្រះអង្គសុខចិត្តដាក់រាជ្យសម្បត្តិ នៅថ្ងៃទី២

មិនា ១៩៥៥ វេលាម៉ោង ១២-៣០ ។ ទាំងនេះដើម្បីព្រះអង្គបានមកប្ដូរផ្ដាច់តស៊ូរួមនឹងកូនចៅដោយជិតស្និទ ដោយព្រះអង្គតែងតែមានព្រះទ័យ ប្រោសប្រណីកូនចៅរបស់ព្រះអង្គជានិច្ច ព្រះអង្គមានព្រះទ័យចង់ឲ្យតែកូនចៅមានសេចក្ដីសុខ សម្បូណ៍សប្បាយ និង មាតុប្រទេសចុំថ្កើងរុងរឿងប៉ុណ្ណោះ។

សូមឲ្យលោកអ្នកអានជាទីគោរព មេត្តាសង្កេតគុណសម្បត្តិនៃអច្ឆរិយបុគ្គល ៣០ ខក្នុងបទទី៨។

លោកនឹងឃើញជាក់ច្បាស់ថា ឱយើងព្រះអង្គមានគុណសម្បត្តិនៃអច្ឆរិយបុគ្គលគ្រប់បរិបូរណ៍ តាមដែលដុកទ័រ ភិគគិន ឬ ហ្សិគម៉នហ្វ្រយដ អ្នកចិត្តវិទ្យាបានពោលទុកក្នុងតម្រា (The psychology of achievement) នោះយ៉ាងគ្រប់គ្រាន់បរិបូរណ៍។

៥. កាលបើពើបប្រទះនូវឧបសគ្គ ឃាត់ឃាំងរារាំងនៅចំពោះមុខ ទោះបីឧបសគ្គនឹងតិចច្រើនយ៉ាងណា ឬ ឧបសគ្គនោះនឹងកើតឡើងដោយវិធីណាក៏ដោយ ក៏ត្រូវតែមានកំលាំងចិត្តយ៉ាងមុតមាំ ដាច់ខាត ដើម្បីតស៊ូពុះពារនូវឧបសគ្គនោះៗ ដោយមិនមានភិតភ័យ ញាប់ញ័រតក់ស្លុតអ្វីសោះឡើយ។ តែរឿងដែលត្រូវពិនិត្យពិចារណានោះ គឺត្រូវប្រើសម្បជញ្ញៈចិត្ត (Conscious mina) ចិត្តមានស្មារតីពិចារណាឲ្យល្អិតល្អសុខុមជាមុនសិនថា តើឧបសគ្គដែលកំពុងកើតដល់យើងនោះ វាមានឥទ្ធិពលខ្លាំងក្លាតិចច្រើនយ៉ាងណា គួរនឹងកំចាត់របៀបណាទើបបានសំរេច។ កាលបើយើងបានពិចារណាឃើញផ្លូវ និង ឧបាយដ៏ត្រឹមត្រូវល្អដូច្នេះហើយ។ វិធីតទៅ គឺប្រុងស្មារតីដើម្បីកំចាត់ឧបសគ្គនោះៗឲ្យវិនាសបាត់បង់ទៅ ហើយជាពិសេសជាងនោះទៅទៀតវិធីដែលត្រឹមត្រង់នោះ គឺកុំប្រើកែវឆ្លុះ (ចិត្ត) ឆ្លុះពង្រីកឧបសគ្គនោះៗឲ្យវាធំហួសហេតុ (កលវិធីរំដោះទុក្ខ អ.ធីរាវិធ) ធ្វើឲ្យពិបាកក្នុងការកំចាត់ណាស់។

៦. បើសិនបានជាត្រឡប់ចាញ់ឧបសគ្គនោះយ៉ាងខ្លោចផ្សាទៅវិញ ក៏សូមឲ្យយើងគប្បីចូលចិត្តថានោះគ្រាន់តែជាហេតុការណ៍បណ្ដោះអាសន្ន ដែលកើតដល់យើងប៉ុណ្ណោះទេ។ ហើយយើងត្រូវតែរួបរួមកំលាំងចិត្តខ្លាំងក្លា ឲ្យមុតមាំតស៊ូនូវឧបសគ្គ របស់យើងនោះបានសេចក្ដីថាយើងគ្មានបានសំរេចអ្វី

ដូចគោលបំណងឡើយ ឬ មិនដូច្នោះទេ យើងក៏បានឈ្មោះថាបាន ដាច់ខ្យល់ស្លាប់ក្រោមបាទជើងនៃឧបសគ្គនោះទៅហើយ។ ទាំងនេះសូមឲ្យពិចារណាការតស៊ូរបស់ព្រះសម្មាសម្ពុទ្ធ ម្ចាស់ សម្ដេចឪ ដុកទ័រស៊ុនយ៉ាត់សេន ឡេនិន ខេម៉ាល ហិត្លែរ មុស្សូលិនី លិនល័ន មហាត្មៈគន្ធី ជាដើម។

៧. កាលបើមានគោលដៅនៃជីវិតពិតប្រាកដដូច្នេះហើយ ក៏គួរព្យាយាមទៅរកទីសំងាត់គ្មានមនុស្សដូចក្នុងព្រៃស្មសានឋានស្ងាត់ ឬ ក្បែរជាយសមុទ្រជាដើម។ ហើយក៏ពេញញសំរែកយ៉ាងខ្លាំងដែលអាចនឹងស្រែកខ្លាំងបានថា "ខ្ញុំត្រូវតែមិនញាប់ញ័រ ខ្លាចក្រែងឧបសគ្គអ្វីទាំងអស់ឧបសគ្គ អន្តរាយ ជំងឺឈឺថ្កាត់ចូលមកតស៊ូ នឹងអញចុះអញមិនខ្លាចញញើតឯងទាំងអស់ឡើង "សេចក្ដីសំរេចដូចពោលមកនេះ លោក ដេម៉ស ធេន្នីស ក៏បានធ្វើ បានផលសំរេចមកហើយ គួរឲ្យអភិរម្យណាស់។

៨. ចូរអ្នកអានសៀវភៅ ដែលទាក់ទងនឹងជីវៈប្រវត្តិរបស់មនុស្សសំខាន់ៗ ក្នុងពិភពលោកឬ អានសៀវភៅប្រភេទកម្លាំងចិត្ត ឬ អប់រំចិត្តផ្សេងៗ ដើម្បីអប់រំហ្វឹកហ្វឺនឲ្យចិត្តមានកំលាំងក្លៀវក្លារឹងប៉ឹងឡើង។

៩. ចូរអានសៀវភៅឲ្យច្រើនបំផុត ដើម្បីបណ្ដុះបណ្ដាលសតិសម្បជញ្ញៈនឹងខួរក្បាលឲ្យមានសមត្ថភាពខ្លាំងក្លាឡើង។

១០. កុំប្រើមនោភាព ឲ្យរវើរវាយ ដោយប្រាសចាកហេតុផល ឬ គិតរឿងផ្ដេសផ្ដាសអ្វីសោះជាដាច់ខាត។

## ៨. ចិត្តានុភាពមានប្រយោជន៍យ៉ាងម៉េច?

តទៅនេះ ខ្ញុំបាទនឹងអធិប្បាយសារៈប្រយោជន៍របស់ចិត្តានុភាព ថាតើមានប្រយោជន៍យ៉ាងម៉េច។ ចិត្តានុភាព ឬ (Will Power) មានប្រយោជន៍ដូចតទៅនេះ។

១. ដើម្បីបង្គាប់អ្នកដទៃឲ្យធ្វើតាមបំណងយើង ឬ ជឿតាមផែនការណ៍របស់យើង។

២. ដើម្បីសាងអច្ឆរិយៈផ្ទាល់ខ្លួនរបស់យើងឲ្យរឹតតែមានអំណាចខ្លាំងក្លា

ឡើង។

៣. ជាកំលាំងពលំ បណ្តុះបណ្តាលផ្សាំការតស៊ូរបស់ជីវិត ឲ្យរឹងប៉ឹងមាំមួនឡើង។

៤. ជាកំលាំងពលំសំរាប់ថែររក្សាសមាធិ មនោភាព ឧត្តមគតិ ជំនឿស៊ប់ សេចក្តីកត់សំគាល់ សេចក្តីក្លាហាន សេចក្តីអត់ធន់ គោលដៅនៃជីវិត សេចក្តីស្រវាស្រទេញឲ្យដំណើរទៅដោយមិនឈប់ឈរ ព្រមទាំងរក្សាថៃទាំចិត្ត នឹងសតិសម្បជញ្ញៈឲ្យប្រព្រឹត្តទៅដោយត្រឹមត្រូវតាមគោលវិវឌ្ឍនាការរបស់មនុស្សលោក។

៥. ជាកំលាំងពលំដ៏សំខាន់ ដែលនឹងស្ថាបនាឲ្យចិត្តគំនិត មានសេចក្តីបរិបូរណ៍មាំមួនរឹតតែច្រើនឡើង តាមគោលចិត្តវិទ្យាសម័យបច្ចុប្បន្ន ។ ហើយទាំងអាចបដិរូបចិត្តដែលខ្វះសមត្ថភាពឲ្យត្រឡប់មានសមត្ថភាព និងប្រសិទ្ធិភាពយ៉ាងម៉ឺងម៉ាត់។ ចិត្តានុភាព ទើបជាកំលាំងពលំដែលអាចកសាងចិត្តគំនិតឲ្យរឹងប៉ឹង មាំមួនក្នុងឧត្តមការណ៍របស់ខ្លួនបាន។

៦. ក្រៅពីមានសមត្ថភាព ស្ថាបនាចិត្តឲ្យមានបុគ្គលិកលក្ខណៈ ឬ ចិត្តជាអច្ឆរិយៈហើយ។ ចិត្តានុភាពអាច មានសមត្ថភាពរក្សាសុភាពរបស់រាងកាយ និងចិត្តគំនិតឲ្យមានអាយុយឺនយូរវែងទៅបានទៀតផង។ សូមឲ្យ សង្កេតមើលមនុស្សដែលមានចិត្តានុភាពប្រាកដថា មានអាយុយឺនយូរវែងឆ្ងាយជាច្រើនដូចព្រះពុទ្ធជាម្ចាស់ លិតទ័រ ប៊ីរ ណាវ៍តស័រ រ៉ូលទែរ ជាដើម។

៧. បុគ្គលដែលមានកំលាំងពលំនៃចិត្តានុភាព ភាគច្រើនយើងតែងតែឃើញបុគ្គលពួកនេះមានសមត្ថភាពអាចកសាងខ្លួនឯងឲ្យមានឋានៈខ្ពស់យ៉ាងត្រដែត លើសលើគេឯង។ ទោះបីបុគ្គលទាំងនោះមានឋានៈនិងវណ្ណៈទាបថោក យ៉ាងម៉េចពីមុនមកក៏ដោយ ដូច លិនខល៍ន ណាប៉ូឡេអុងប៉ូណាបារត៍ អិដិស័ន កាហ្វិល ចេហ្វីរស័ន ហិត្លែរ មូស្សូលិនី ជាដើម។

៨. ជាកំលាំងពលំក្នុងការបណ្តុះផ្សាំចិត្តគំនិត ឲ្យប្រាសចាកសេចក្តីខ្លាចក្រែងអន្តរាយយ៉ាងណាទាំងអស់ក្នុងការតស៊ូនៃឆាកជីវិត។

បន្ទប់ឥតតម្រា ដូចអាត្មា ឥតវិញ្ញាណ

**ចង់ឲ្យជីវិតមានអនាគត់ថ្លៃថ្នូរ តោងអាន "ជំហ៊ានជីវិត"**
**ចង់ឲ្យមានសេចក្តីសុខ តោងអាន "កលវិធី រំដោះទុក្ខ"**
**ចង់ឲ្យដឹងវិធីការពាររោគ និងវិធីរក្សារោគ តោងអាន**
**"គ្រូពេទ្យប្រចាំគ្រួសារ"**

†††

# បទទី៧

# អច្ឆរិយៈ និង ធម្មជាតិ

## ១. អច្ឆរិយៈ និង ធម្មជាតិ គឺជាអ្វី?

អ្នកចិត្តវិទ្យាបានឲ្យទស្សនៈ ព្រះទាំងធានារ៉ាប់រងទុកថា "អច្ឆរិយៈ" មាននៅនឹងមនុស្សជាតិមកយូរអង្វែងណាស់ហើយ។ ធម្មជាតិបានប្រសិទ្ធិប្រសាធ "អច្ឆរិយៈ" ឲ្យដល់មនុស្សគ្រប់រូបដោយមិនរើសមុខ។ តែ ខ សំខាន់ គឺមនុស្សគ្រប់រូបអាចចេះប្រើអច្ឆរិយៈ ដែលគេចពួននៅក្នុងខ្លួនឯងនោះឬទេ។ បុគ្គលដែលស្គាល់ជាក់ច្បាស់នូវចំណុចអាថ៌កំបាំងនៃភាពជាអច្ឆរិយៈ ហើយក៏ចេះនាំយកមកប្រើឲ្យកើតប្រយោជន៍បានផងនោះ។ បុគ្គលនោះក៏ក្លាយទៅជាបុគ្គលដ៏ឆ្នើមនោះយើងហៅ ថាអច្ឆរិយៈបុគ្គល។ ចំណែកបុគ្គលដែលមិនអាចនាំយកអច្ឆរិយៈក្នុងខ្លួនឯងមកធ្វើឲ្យកើតប្រយោជន៍ដល់ខ្លួនឯង បាននោះគេក៏ត្រូវជាបុគ្គលធម្មតាសាមញ្ញចប់ចុងចប់ដើម ទាល់តែរស់មួយជីវិត ឬ ជួនកាលអាចមានហេតុការណ៍ដទៃ ជាពិសេសខាងក្រៅមួយឬ ច្រើនយ៉ាង មកជួយរុញច្រានឲ្យកើត ភាពជាអច្ឆរិយៈក៏បានដែរ។

កាលពើពោលដល់ "អច្ឆរិយៈបុគ្គល" ធ្វើឲ្យយើងចូលចិត្តគោលការណ៍ជញ្ជីងត្រាជូនៃធម្មជាតិបានថា ជញ្ជីងត្រាជូនៃធម្មជាតិមិនបានឲ្យសេចក្តីយុត្តិធម៌ដល់មនុស្សគ្រប់រូបគ្រប់នាមយ៉ាង ណាទេ។ រឿងនេះ យើងអាចសង្កេតបានថា មនុស្សគ្រប់រូបមានសេចក្តីខុសផ្សេងៗពីគ្នាច្រើនណាស់ក្នុងការរស់នៅនៃជីវិត។ សភាពនៃការ

រស់នៅនៃជីវិត មានមិនដូចគ្នាទេខ្លះកើតក្នុងត្រកូលដែលល្អ គឺល្អទាំងពូជពង្សវង្សត្រកូល (Heredity) ល្អទាំងវត្ថុព័ទ្ធទ្បោម (Environment)។ គឺគ្រាន់តែកើតមកឃើញពន្លឺព្រះអាទិត្យភ្លាម ខ្លួនឯងក៏បានទទួលសេចក្ដីសុខ
សម្បូណ៌សប្បាយគ្រប់សព្វទៅដោយសេចក្ដីសុខទាំងផ្លូវកាយ ផ្លូវចិត្ត មានអ្នកបំរើជាបរិវារនៅ ឆ្វេងស្ដាំ មុខក្រោយ ខ្លះក៏មានរាងកាយរឹងប៉ឹង មាំមួន មានសុខភាពពេញលេញ រាងកាយស្អាតស្អមគួរគាប់បី ខ្លះកើតមកផ្ទុយគ្នាស្រឡះដូចមេឃនិងដី គឺកើតមកក្នុងត្រកូលដែលក្រខ្សត់ ខ្វះព្រឹកខ្លះល្ងាច ខ្លះមានរោគភ័យ ជំងឺឈឺថ្កាត់ បន្តមកពីអ្នកឲ្យកំណើតគេបានទទួលទុក្ខវេទនាទារុណកម្មនានា ពីរោគរបស់ខ្លួននោះ។ ខ្លះកើតមកដោយសេចក្ដីឆ្លៀវឆ្លាតឈ្លាសវៃ ខ្លះក៏កើតមកដោយសេចក្ដីល្ងង់ល្ងៅ អាប់ឱនបញ្ញា។

ព្រឹត្តិការណ៍ដែលកើតឡើងដូច្នេះ រមែងបញ្ជាក់ឲ្យយើងគ្រប់គ្នាឃើញបានថា ធម្មជាតិឬ ត្រាជូនៃធម្មជាតិ មិនបានឲ្យសេចក្ដីយុត្តិធម៌ដល់មនុស្សគ្រប់រូបទេ ជាពិសេសលើសជាងនោះតទៅទៀត ធម្មជាតិក៏បានស្ថិតស្ថាងកំលាំង សេចក្ដីគិតសតិបញ្ញា សេចក្ដីសង្កេត សេចក្ដីចាំសេចក្ដីអត់ធន់ សមាធិ ចិត្តានុភាព មនោភាពមកឲ្យមិនស្មើគ្នាដែរ។ យើងអាចបានដឹង និងមើលឃើញទូទៅក្នុងសង្គមមនុស្សនៃពិភពលោកនាសព្វថ្ងៃនេះ គឺខ្លះកើតមកល្ងង់ល្ងៅ រកសតិបញ្ញាអ្វីគ្មានសោះគឺល្ងង់ទាល់តែមែនទែន ទោះបីនឹងបានព្យាយាមអប់រំយ៉ាងណា ប្រៀនប្រដៅយ៉ាងណា ហ្វឹកហ្វឺនយ៉ាងណា គេក៏មិនអាចនឹងកត់ចាំ

ទុកបានឡើយ យ៉ាងគ្រាន់បើណាស់ក៏បានតែអង្គុយញញឹមឬអង្គុយសើច (គឺទាល់គំនិត) តែប៉ុណ្ណោះ តែខ្លះកើតមកក៏មានសតិបញ្ញាល្អ មានសេចក្តីឆ្លៀវឆ្លាត មានបដិភាណឈ្លាសវៃ បានទទួលការអប់រំសិក្សាជា គ្រឿងគាំទ្រតែបន្តិចបន្តួច ក៏មានសេចក្តីប្រាជ្ញប្រៀកឆ្លាតឆ្លៀវ មានសមត្ថភាពឈ្វេងយល់សព្វគ្រប់ក្នុងកិច្ចការសារពើផ្សេងៗ យ៉ាងគួរឲ្យអស្ចារ្យពេកណាស់ បើនឹងធ្វើការយ៉ាងណាមួយ ក៏មានសមត្ថភាពមើលឃើញដោយជាក់ច្បាស់ ហើយក៏យល់ការនោះដោយមនោភាពរបស់ខ្លួន ព្រមទាំងបានសម្រេចផលក្នុងកិច្ចការនោះ។ រហូតដល់មានគេនិយម ស្រឡាញ់ស្នេហារាប់អាន ទាំងជាអ្នកមានសញ្ញាល័ក្ខណ្ឌស្តែងឲ្យឃើញសមត្ថភាព ក្នុងភាពជាមេដឹកនាំ ឬ ជាមេដឹកនាំក្នុងក្រិត្យក្រមនៃវិជ្ជាការផ្សេងៗ ដូចជាការវិទ្យាសាស្ត្រ ការពេទ្យ ការទាហាន ការពាណិជ្ជការតន្ត្រីល។ល។ បុគ្គល ដែលមានភាពជាអច្ឆរិយៈ ដូចពោលមកហើយនេះ ខ្ញុំសូមហៅថា "អច្ឆរិយៈបុគ្គល"។

២. គោលការណ៍នៃគារទ្រទ្រង់គឺជាអ្វី? (Law of Compensation)

គោលការណ៍ក្នុងការទ្រទ្រង់ ឬ គោលការណ៍ក្នុងការតបស្នងបំពេញឲ្យជាគោលការណ៍ដែលអ្នកប្រាជ្ញជន ជាតិបារាំងសេសម្នាក់បានស្រាវជ្រាវជួប។ គោលការណ៍នេះមានសារៈប្រយោជន៍សំខាន់ណាស់ គឺទោះជាធម្មជាតិ នឹង មានជញ្ជីងត្រាជូមិនយុត្តិធម៌ ដូចបានពោលមកហើយខាងលើនោះក៏ដោយ។ តែធម្មជាតិ ក៏បានបំពេញតបស្នងបំណាច់រង្វាំ ជាតម្លៃព្រលឹងឲ្យដល់បុគ្គលដែលកើតមកមិនមានការទ្រទ្រង់ ឬ កើតមកមិននៅ ក្នុងសភាពដ៏សម្បូណ៌សមរម្យ។

គោលការណ៍ដូចនេះហើយដែលយើងសំដៅយកសេចក្ដីថាគ្រប់បែប យ៉ាងក្នុងពិភពលោកនេះ គួរតែមានសេចក្ដីទ្រទ្រង់ ឬ គួរតែមានតុល្យភាពស្មើៗគ្នា។ ធម្មជាតិតែងតែព្យាយាមជួយឲ្យសេចក្ដីយុត្តិធម៌ ឬ ធ្វើការតបស្នងដល់វត្ថុដែលគ្មានការទ្រទ្រង់ ឬ តុល្យភាពឲ្យមានស្ថេរភាពសម្បូណ៌សមរម្យជាដរាប។ ធម្មជាតិរមែងឲ្យតម្លៃព្រលឹងជាបំណាច់រង្វាន់ដល់សង្ខារ និង ផ្លូវចិត្តផង។

ខ្ញុំបាទបានពោលមកហើយថា ធម្មជាតិបានឲ្យសភាពការណ៍រស់នៅទាំង កំលាំងកាយកំលាំងគំនិត កំលាំងសេចក្ដីក្លាហាន រហូតដល់រូបរាងកាយខុសផ្សេងៗពីគ្នា គឺខ្លះកើតមកមានរូបរាងកាយធំធាត់មាំមួនប្រហែលយក្ស ខ្លះកើតមកមានរូបរាងកាយតូច ទាប តឿ យ៉ាងគួរឲ្យអាណិតអាសូរពន់ពេកណាស់ ខ្លះកើតមកមានត្រចៀកថ្លង់ ភ្នែក ខ្វាក់ កំបុតដៃរាងកាយក៏ពេញទៅដោយរោគភ័យ នេះជារឿងពិការក្នុងរូបរាងសង្ខារ។ ចំណែកក្នុងផ្លូវចិត្តវិញនោះ ធម្មជាតិក៏មានជញ្ជីងត្រាជូ មិនដូចគ្នាដែរ គឺខ្លះគ្រាន់តែកើតមកក៏មានសេចក្ដីឆ្លាតប្រាជ្ញព្រោក ចេះដឹងស្គាល់សព្វវត្ថុ ផ្សេងៗបានយ៉ាងឆាប់រហ័ស ខ្លះក៏មានសេចក្ដីល្ងង់ខ្លៅងងឹតងងុលអាប់បញ្ញានិងរកអ្វីប្រៀបពុំ បាន ។ នេះជាគោលការណ៍ជញ្ជីងត្រាជូនៃធម្មជាតិ ដែលបានសាងសេចក្ដីមិនយុត្តិធម៌ ឲ្យដល់មនុស្សលោក។

ដោយហេតុតែធម្មជាតិមិនមានយុត្តិធម៌ ដូចពោលមកនេះហើយ សំរាប់បុគ្គលដែលកើតមកមិនមានការទ្រទ្រង់ គឺរាងកាយមិនសម្បូណ៌តាមប្រក្រតីជននោះ។ ធម្មជាតិក៏បានព្យាយាមឲ្យតម្លៃព្រលឹងទាំងផ្នែករាងកាយ និងផ្នែកចិត្ត។ ក្នុងផ្នែកចិត្តនោះ បានបំពេញតម្លៃព្រលឹងជាបំណាច់រង្វាន់ឲ្យគេមានប្រសិទ្ធិភាព

នៃអំណាចចិត្តខ្លាំងក្លាណាស់ ដូចធ្វើឲ្យគេជាមនុស្សដែលមានសេចក្តីមានះព្យាយាម ខ្លាំងក្លា ធ្វើឲ្យគេជាមនុស្សមានសេចក្តីស្រវាំស្រទេញ មុតមាំក្លៀវក្លា ធ្វើឲ្យគេជាមនុស្សមានចិត្តានុភាពរឹងប៉ឹង មុះមុត ឬ ពោលដោយងាយៗ ក៏គឺឋាមពលនៃអំណាចចិត្តរបស់គេ កើតប្រតិកិរិយាដ៏មានប្រសិទ្ធិភាព និងអានុភាពខ្លាំងក្លាជាអិតបរិមា។

ចំណែកក្នុងផ្នែកសង្ខារនោះទៀត ខ្លះកើតមកមានភ្នែកខ្វាក់ម្ខាងគង់មើលឃើញបានតែម្ខាងប៉ុណ្ណោះ យ៉ាងនេះ ហៅថាមិនមានការទ្រទ្រង់ ឬ តុល្យភាព គឺរាងកាយមានសភាពមិនសមសួន រាងកាយវិកលពិការ រាងកាយមិនសមរម្យ រាងកាយមិនបរិបូរណ៍ ដោយអាការ៣២ប្រការ។ ធម្មជាតិតែងតែប្រសិទ្ធិប្រសាទតម្លៃព្រលឹងឲ្យបុគ្គលដែលមានកំណើតមកគ្មានការ ទ្រទ្រង់ដោយមានតែភ្នែកម្ខាង ឲ្យប្រើការបានប្រយោជន៍ច្រើនជាងមនុស្សដែលគ្មានភ្នែកទាំងពីរទៅទៀត ។ ខ្ញុំបាទអ្នករៀបរៀង បានធ្លាប់ឃើញមនុស្សភ្នែកខ្វាក់ទាំងពីរខាងប្រើរន្ទច្រមុះផ្លុំខ្លុយ ប្រើមម្រាមដៃ ខាងឆ្វេងរាប់រន្ធខ្លុយ ប្រើដៃស្តាំវាយស្គរ ប្រើជើងខវាយឆឹងឆាប់។ គេអាចបន្លេងភ្លេងបានយ៉ាងពីរោះ គ្រាន់បើជាងអ្នក តន្ត្រីដែលមានរាងកាយ បរិបូរណ៍ទៀតផង។ ហើយទាំងធ្លាប់ឃើញមនុស្សបំបុតដៃទាំងពីររហូសកែងនៃមកបន្តិច តែនិងដោយហេតុអ្វីខ្ញុំបាទមិនបានជ្រាប គេអាចមូរបារីស្លឹកចេគឬ ស្លឹកសង្កែជក់បានយ៉ាងប៉ិប្រសប់ ហើយម្រាមជើងក៏អាច គូសឈើគូសអុចបារីស្លឹកចេក ឬស្លឹកសង្កែជក់បានយ៉ាងប៉ិនប្រសប់ ហើយម្រាមជើងក៏អាច គូសឈើគូសអុចបារីបានដោយខ្លួនឯង ដោយមិនបាច់ពឹងពាក់អ្នកណាសោះ។ ក្នុងទស្សនាវិធីអង់គ្លេសមួយដំណាលទុកថាមេផ្នែកគណិតសាស្រ្ត ក្នុងមហាវិទ្យាល័យមួយកាលណានេះទៅរៀនថ្នាក់មធ្យមសិក្សានោះប្រត្យក្សថា គេទន់ខ្សោយយ៉ាងខ្លាំងក្នុងវិជ្ជាលេខ។ បិតារបស់ជាវិស្វករដែលមានសមត្ថភាពខ្លាំងក្លាណាស់ក្នុងវិធីគិតលេខ។ កាលបើឃើញកូនប្រុសរបស់គេមានសមត្ថភាពទន់ខ្សោយណាស់ក្នុងវិជ្ជាគណិត សាស្រ្តដូច្នោះ គេច្រើនតែចូលចិត្តនិយាយា ដៀម ដាម ឡកឡឺយ កូនប្រុសរបស់គេ

ជានិច្ច។ គេពោលថា កូនប្រុសបានត្រូវបិតា ដៀមដាម ឡកឡឺយ ឲ្យដូច្នោះក៏ធ្វើឲ្យកើតការបំពេញស្នងឬ តម្លៃព្រលឹងដល់ចិត្តខ្លួនឡើយ។ ធ្វើឲ្យមេផ្នែកគណិតសាស្ត្រនោះកើតសេចក្តីមានះ កើតសេចក្តីព្យាយាម កើតសេចក្តីតាំងចិត្តប្រាថ្នា ឬ ការអប់រំខ្លួនឯងឡើង។ គេបានពោលចេញមក ដោយសំឡេងដ៏កងរំពងថា "ខ្ញុំត្រូវតែជាអ្នកស្ទាត់ជំនាញ ក្នុងវិជ្ជាគណិតសាស្ត្រឲ្យទាល់តែបាន" ។ តអំពីនោះមកគេក៏ខំប្រឹងរៀន ខំគិត ខំធ្វើ ដោយការប្រឹងប្រែង យ៉ាងមុតមាំដូច្នេះ។ ទីបំផុតគេក៏បានសម្រេចដូចសេចក្តីប្រាថ្នា ទាល់តែនរណាក៏ឃើញគេជាអច្ឆរិយៈបុគ្គល ដែលមាន សមត្ថភាពយ៉ាងកំពូលក្នុងវិជ្ជាគណិតសាស្ត្រ ហើយគេក៏អាចប្រកាន់យកជាអាជីវកម្មបានទាល់តែសព្វថ្ងៃនេះ។

"នេះជាគោលការណ៍នៃការបំពេញស្នងតម្លៃព្រលឹងធម្មជាតិក្នុងផ្លូវចិត្ត"

សំរាប់បុគ្គលដែលមានរាងកាយមិនសមសួន ឬកើតមកមិនមានការទ្រទ្រង់ដូចប្រក្រតីជនគោលការណ៍ធម្មជាតិ ក៏រមែងបំពេញតំលៃព្រលឹង ឲ្យដល់បុគ្គលទាំងនោះ ឲ្យមានការទ្រង់ទ្រង់ខ្លួនកើតឡើង ដូចកុមារម្នាក់មាន រូបរាងតូចខុសក្បួនខ្នាត ទាំងមានរាងកាយទន់ខ្សោយមានរោគផ្សេងៗ ប្រចាំជានិច្ច តែគោលការណ៍ធម្មជាតិក៏បានបំពេញតម្លៃព្រលឹងឲ្យ ដល់កុមារនោះ ដោយឲ្យកុមារនោះបញ្ចេញកំលាំងកាយ និង ទទួលទានអាហារឲ្យត្រូវតាមក្បួនខ្នាតអនាម័យ ឲ្យមានការសម្រាកតាមគោលការណ៍នៃសុខវិទ្យា។ គេក៏ត្រឡប់មានរាងកាយធំធាត់ រឹងប៉ឹងជាងកុមារធម្មតាទៅទៀត។ នេះជាគោលការណ៍ធម្មជាតិបានបំពេញតម្លៃព្រលឹងឲ្យក្នុងផ្នែករាងកាយ ជាតម្លៃព្រលឹងរបស់ធម្មជាតិ គ្រាន់តែឲ្យមានការទ្រទ្រង់ខ្លួនដោយធម្មជាតិប៉ុណ្ណោះ នេះមិនទាន់ដល់កម្រិតដែលហៅ "អច្ឆរិយភាព" ទេ។

តែកុមារជាមួយគ្នាដែលបានពោលមកខាងលើនេះ នៅតែព្យាយាមធ្វើអត្តពលិកម្មហាត់ប្រាណដោយដួងចិត្ត រឹងប៉ឹងមុតមាំ ដើម្បីធ្វើរាងកាយរបស់គេឲ្យក្លាយទៅជាយក្សឲ្យបានដូច្នេះហៅថា ការបំពេញតបស្នង ដែលឈានឡើងកាន់ភាពថា "អច្ឆរិយៈបុគ្គល"។

មនុស្សដែលមានរាងកាយរឹងប៉ឹង មុតមាំ ដោយតែបានសាងខ្លួនឯងឡើងពីរាងកាយទន់ខ្សោយ ពីរាងកាយមានតែរោគ ពីសេចក្តីមិនសម្បូណ៌សចាកធម្មជាតិ ដូចជា យូយីន សងដាវ អ្នកសាច់ដុំសំខាន់ក្នុងលោក ដែលមានរាងកាយរឹងប៉ឹង មាំទាំ ទាំងមានរូបរាងទ្រង់ទ្រាយល្អសមសួនណាស់។ ស្ទេម្បហ្សេ ខាប់ទ័រ និង យីនត័ន្នី អ្នកប្រដាល់ធន់ធ្ងន់ ដែលប្រដាល់ឈ្នះ យែកដេមហ្សេ ជាសែមបៀន (កំពូល) ក្នុងលោកនោះ។ កាលគេនៅជាកុមារតូចនោះ គេមានរោគាព្យាធិបៀតបៀនជានិច្ចថែមទាំងមានរោគរបេងទៀតផង។ កុមារទាំងពីរនេះមានការមិនទ្រទ្រង់ខ្លួនមកពីតូចៗ។ តែបុគ្គលទាំងពីរនេះ បានបំពេញតម្លៃព្រលឹងឲ្យដល់រាងកាយនិង ចិត្តគំនិតរបស់ខ្លួនឯងច្រើនណាស់ គេទើបក្លាយ ទៅជាមនុស្សមានឈ្មោះសំឡេងគឹងកងរំពងពេញទាំងផ្ទៃសាកលលោក។

លោក ស៊ីរសស៊ីល អតីតនាយករដ្ឋមន្ត្រីអង់គ្លេស កាលនៅជាកុមារតូចនោះ លោកនេះក៏មានរាងកាយមិនសមប្រកប ពោលគឺលោកនេះនិយាយមិនច្បាស់ដូចកូនក្មេងតូចៗទូទៅ ថែមទាំងនិយាយដោយជាប់ប្រដិតទៀតផង។ ធម្មជាតិក៏បានបំពេញតម្លៃព្រលឹង ឬ ពូនបំណាច់រង្វាន់ឲ្យលោក ស៊ីរស៊ីល មានសេចក្តីមានះ មានសេចក្តីព្យាយាម មានសេចក្តីអត់ធន់មានះតស៊ូកែប្រែវត្ថុដែលខ្វះខាតមិនសមរម្យរបស់ខ្លួននោះ ឲ្យកើតមានការទ្រទ្រង់ដូចប្រក្រតីជនទូទៅ។ តែលោក វិនស្តុនស៊ីរស៊ីល មិនព្រមឈប់តែត្រឹមការទ្រទ្រង់ប៉ុណ្ណោះទេ គេបានទទួលតម្លៃតបស្នងពីគោលការណ៍នៃការទ្រទ្រង់ ឬ ក្រិត្យក្រមនៃការបំពេញៗថែមឲ្យហួសកំរិត ព្រមទាំងកន្លងចូលក្នុងកំរិតនៃភាពជាអច្ឆរិយៈបុគ្គលទៀតផង។ ដោយហេតុនេះឯងវិនស្តុនស៊ីរស៊ីល ទើបបានក្លាយជាអ្នកមានវាទសិល្បៈសំខាន់ក្នុងលោកទៅ ទាំងនេះក៏ព្រោះស៊ីរស៊ីល មានរាងកាយទុព្វលភាពខុសប្រក្រតីជនមកពីតូចៗ ជាសំខាន់។

ឡតបៃរ៉ន ក៏ជាមនុស្សម្នាក់ទៀតដែលបានចាប់កំណើតមកមិនមានការទ្រទ្រង់គឺលោកនេះ បានកើតមកដោយមានជើងទាំងពីរសំប៉ែតមកពីកំណើតតែម្តង។ តែគោលការណ៍ធម្មជាតិក៏បានបំពេញបន្ថែមតម្លៃព្រលឹងឲ្យគេដោយ

ឲ្យលោកនេះ ជាអ្នកហែលទឹកទាល់តែមានកេរ្តិ៍ឈ្មោះខ្ទរខ្ទារ ល្បីល្បាញពេញទាំងផ្ទៃសាលកលោក គេជាមនុស្ស ដំបូងបង្អស់ដែលអាចហែលទឹកឆ្លងកាត់ទន្លេតូចឈ្មោះ ហេល្លេស្ប៉ុង បានសំរេចជោគជ័យយ៉ាងល្អបំផុត។

ការដែលលោក ឡរត៍ បានក្លាយទៅជាមនុស្សមានឈ្មោះសំឡេងគឹងកងរំពងមកបាននេះ ក៏ព្រោះមានរាងកាយពិការមិនសមសួននោះឯង ធម្មជាតិទើបតមស្នងបំពេញឲ្យ ឬ សំណាងតម្លៃព្រលឹងឲ្យក្នុងផ្លូវចិត្ត គឺធ្វើឲ្យគេពេញទៅដោយសេចក្តីស្រវាស្រទេញ សេចក្តីអត់ធន់ សេចក្តីព្យាយាមសេចក្តីមានះការតស៊ូ ឬ ពោលយ៉ាងងាយៗ គឺ ជាការផ្ទុះហាមពលនៃភាពជាអច្ឆរិយៈឲ្យឧប្បត្តិឡើងនោះឯង។ ជាពិសេសក្រៅអំពីជាអ្នកហែលទឹកខ្លាំងពូកែហើយ គេក៏បានជាអ្នកនិពន្ធដែលមានឈ្មោះ សំឡេងកងរំពងទូទៅទាំងសាកលលោកទៀតផង។

នេះជាការបញ្ជាក់ឲ្យឃើញច្បាស់ថាធម្មជាតិបានបំពេញបន្ថែម តម្លៃព្រលឹង ឲ្យហួសកំរិតនៃការទ្រទ្រង់ កន្លងចូលកំរិតនៃភាពជា "អច្ឆរិយៈបុគ្គល" ទើបធ្វើឲ្យគេក្លាយទៅជាអច្ឆរិយៈយ៉ាងបរិបូរណ៍។

## ៣. គោលការណ៍នៃការទ្រទ្រង់ដោយប្រតិការ

គោលចារិក ឬ គោលការណ៍នៃការទ្រទ្រង់រាប់ថា ជាកំរិតនៃតម្លៃព្រលឹងត្រូវតែផ្តល់ឲ្យបុគ្គលដែលកើតមកហើយមិនមានការទ្រទ្រង់ ជាកម្រិតដែលឲ្យតម្លៃតបស្នងបំពេញក្នុងផ្លូវចិត្ត។ ខ្ញុំបាទបានធ្លាប់ពោលមកហើយថា កំលាំងពលំនៃអំណាចចិត្ត អច្ឆរិយៈគ្រប់ប្រភេទនឹង កើតឡើងបានក៏ព្រោះតែអំណាចកំលាំងចិត្តជាគោលសំខាន់ដូច ពុទ្ធភាសិតដែលថា "ចិត្តេននីយតិ លោកោ" លោកដែលចិត្តតែងតែនាំទៅមានពុទ្ធភា សិតមួយទៀតថា "មានអ្វីខ្លះ ឬដែលធំជាអំណាចចិត្ត? អំណាចចិត្តជាតួប្រធានដ៏សំខាន់ ជាទោចក្រនៃការប្រែប្រួលជាតួធ្វើឲ្យជីវិតមានជំហានទៅមុខបានពិតប្រាកដ (អានជំហានជីវិត អ.ធីរ៉ាវុធ) ។ តាមធម្មតាមនុស្សយើងបើគ្មានហេតុការណ៍អ្វីមករុញច្រានចិត្ត ហើយយើងក៏គង់មានសភាពជាមនុស្សធម្មតា។ ដោយហេតុនេះឯងធម្មជាតិទើបបានឲ្យ

ភាពមិនសមរម្យ សេចក្តីមិនយុត្តិធម៌ផ្សេងៗដល់សង្គម ដល់ប្រទេស និងជាតិផ្សេងៗ បុគ្គលិកលក្ខណៈរបស់បុគ្គលជាតិមួយ និងមួយទៀតតែងតែផ្សេងៗពីគ្នា ដោយធម្មជាតិប្រសាទប្រសិទ្ធិឲ្យ។ តម្លៃព្រលឹងរបស់ធម្មជាតិក៏ឲ្យកំលាំងពលំនៃអំណាចចិត្តមិនដូចគ្នាដែរ។ ដូចប្រទេសរងារ ធម្មជាតិតែងតែឲ្យតម្លៃព្រលឹងដល់សង្ខារ និង ចិត្តគំនិត សមរម្យគាប់គួរនឹងសភាពនៃប្រទេសរបស់គេ សំរាប់ប្រទេសដែលមានរបបគ្រប់គ្រងផ្សេងៗ ដូចការគ្រប់គ្រងក្នុងរបប ប្រជាធិបតេយ្យការគ្រប់គ្រងរបបផ្តាច់ការ និង ជារបបឆ្វេងឬស្តាំក៏ដោយ ។ តម្លៃព្រលឹងនៃអំណាចចិត្ត ដែលធម្មជាតិបានស្មើរស្មងឲ្យនោះក៏ផ្សេងគ្នាទៅផងដែរ។

គោលការណ៍នៃការទ្រទ្រង់ ទើបជាគោលការណ៍ដ៏សំខាន់បំផុតបានបំពេញតម្លៃព្រលឹងក្នុងផ្លូវចិត្ត ដោយរុញច្រានអំណាចចិត្តឲ្យក្លាយទៅជាមនុស្សៗ ក្នុងពិភពលោកច្រើនណាស់មកហើយ។ ដូចលោក យូលីអាស៊ីហ្សារប៊ី ធោហ្វេន អ្នកតែងនាមឱគ្សោស គឹងកងរំពងពេញសាកលលោកក៏ជាមនុស្សថ្លង់។ វិល្លិយាំភិត (បុត្រ) អតីតនា យករដ្ឋមន្ត្រីអង់គ្លេសក្នុងអាយុកាលដែលគេនៅជាក្មេងតូចៗ នោះក៏មានរាងកាយពិការមិនសមប្រកបមកពីកំណើត។ រូសវ៉េសទ៍ ប្រធានាធិបតីនៃសហរដ្ឋអាមេរិកគេឈឺ ដោយរោគស្ពឹករាងកាយរបស់គេស្លាប់ទៅពាក់កណ្តាល។ តែមនុស្សអស់ទាំងនេះ បានទទួលតម្លៃព្រលឹងពីគោលការណ៍នៃភាពរបស់ធម្មជាតិយ៉ាងខ្លាំង យ៉ាងថ្លៃបំផុតទើបមានសមត្ថភាព ជាអច្ឆរិយៈបុគ្គលឡើងមកបាន។ តែបើសិនគេមានរូបរាងកាយដោយធម្មតា ហើយគេក៏មិនអាចក្លាយជាអច្ឆរិយៈបុគ្គលឡើងមកបានជាដាច់ខាត។

## ៤. គោលការណ៍នៃការទ្រទ្រង់មានប្រយោជន៍យ៉ាងម៉េច?

(Law of Compensation) គោលការណ៍នៃការទ្រទ្រង់ ឬគោលការណ៍នៃការតបស្នងតែងតែឲ្យតម្លៃ ព្រលឹងដល់រាងកាយ និង ចិត្តគំនិតមាន ៣ ប្រការ គឺ ៖

១-ការតបស្នងបំពេញយ៉ាងធម្មតាសាមញ្ញ។

២-ការតបស្នងបំពេញក្នុងធុនកណ្តាល គឺធុនមជ្ឈិមាបតិបទា។

៣-តបស្នងបំពេញឲ្យយ៉ាងខ្លាំងក្លាបំផុត ទាល់តែចូលក្នុងកំរិតជា អច្ឆរិយៈបុគ្គល។ តែមុនដែលលោក នឹងដឹងដល់គោលការណ៍នៃការទ្រទ្រង់មានប្រយោជន៍យ៉ាងម៉េចនោះ សូមឲ្យលោកចូលចិត្តរឿងរាងកាយមិនមានការទ្រទ្រង់ជាមុនសិន។ ហើយលោកអាចយល់រឿងគោលការណ៍នៃការទ្រទ្រង់មានប្រយោជន៍យ៉ាងម៉េចបានដោយងាយតែម្តង។

ពាក្យថារាងកាយមិនមានការទ្រទ្រង់នោះ ខ្ញុំបាទសូមសំដៅថា បុគ្គលណាមួយមានរាងកាយមិនសមប្រកប ឬ មិនមានការទ្រទ្រង់មកពីកំណើត ឬតាំងពីកុមារតូច ឬ ធំហើយឬជាអ្នកមានរោគាព្យាធិច្រើនមានរាងកាយទន់ខ្សោយ មានជម្ងឺឈឺថ្កាត់ច្រើនជានិច្ច ទោះបីក្នុងវ័យណាក៏ដោយ បុគ្គលដែលមានព្រឹត្តិការណ៍ដូចពោលមកហើយនេះ យើងចាត់ថាជាអ្នកមានរាងកាយមិនបរិបូរណ៍លក្ខណៈដូច្នេះហៅថា មានទុព្វលភាពក្នុងផ្លូវកាយ មានសភាពមិនលើសខ្វះខុសគ្នា នៃការរស់នៅរបស់ជីវិត។ បុគ្គលដែលមានសភាពយ៉ាងណានីមួយ ឬ ច្រើនយ៉ាងក៏ដោយដូចពោលមកហើយនេះ បញ្ជាក់ឲ្យឃើញច្បាស់ថាគេគ្មានការទ្រទ្រង់ខ្លួនឯងដូចបុគ្គលធម្មតាសាមញ្ញទូទៅទេ ព្រោះគេមានរាងកាយវិកលវិការ គេមានសភាពលើសខ្វះខុសគ្នាក្នុងផ្លូវកាយ។ មនុស្សយើងកើតមកក្នុងលោកនេះ រមែងតែងមានការទ្រទ្រង់ខ្លួន ឬ មានកំណើតមកបរិបូណ៌គ្រប់យ៉ាង គឺគេគ្មានអ្វីសោះដែលខុសផ្សេងពីបុគ្គលធម្មតាដទៃទូទៅ។ បុគ្គលដូចពោលមកនេះ យើងអាចហៅបានថាបុគ្គលមានការទ្រទ្រង់ខ្លួនឯង។ បុគ្គលទាំងពីរប្រភេទនេះគេតែងមានភាពជាអច្ឆរិយៈគេចពួន នៅក្នុងចិត្តគំនិតរបស់គេ ដោយធម្មជាតិស្រេចហើយហើយមានសេចក្តីផ្សេងគ្នាជាច្រើន។ បុគ្គលដែលកើតមក មិនសមប្រកប ឬ គ្មានការទ្រទ្រង់ ឬ គ្មានការណ៍ទ្រទ្រង់នោះ ទោះបីមិនមានការណ៍ទ្រទ្រង់ ឬ មិនសមប្រកបដោយហេតុយ៉ាងណាក៏ដោយ។

ធម្មជាតិ ក៏តែងតែព្យាយាមបណ្តុះផ្សាំបំពេញឲ្យបុគ្គលទាំងនោះ អុច

ឈ្នះផ្ទុះនូវអច្ឆរិយៈនៃអំណាចចិត្តឲ្យ កើតមានឡើងដោយរួសរាន់ ឬ ថាមពលនៃអច្ឆរិយៈភាព អាចឧប្បត្តិឡើងយ៉ាងឆាប់រហ័សជាងបុគ្គលដែលកើតមកមិនមានជំងឺឈឺចាប់អ្វីៗនោះទៀត។ ការណ៍អស់ទាំងនេះ រមែងកើតមកពីការខ្វះខាតក្នុងផ្លូវកាយធម្មជាតិ ត្រូវតែឧបត្ថមឲ្យអំណាចនៃចិត្ត ផ្ទុះចេញមក ឬពង្រីកខ្លួនឯងចេញមក។ អំណាចចិត្តជាវត្ថុសំខាន់បំផុត ជាដើមកំណើតនៃអច្ឆរិយៈជាមូលដ្ឋាននៃសមិទ្ធិ ជាប្រសិទ្ធិភាពក្នុងការតស៊ូនៃជោគជាតាជីវិត។ កាលបើថាមពលនៃអំណាចចិត្ត ផ្ទុះចេញមកហើយ ក៏រមែងជាការបណ្តុះបណ្តាលនូវប្រសិទ្ធិភាពនៃអំណាចតក្កញាណ សមាធិ មនោភាព ចិត្តានុភាព សេចក្តីសង្កេត សេចក្តីស្រវាស្រទេញ។ល។ ឲ្យកើតមានឡើងហើយបើសិនអំណាចនៃចិត្តកើតមានឡើងហើយ សេចក្តីសំរេចក៏រមែងតែមានតាមមកដោយមិនបាច់សង្ស័យឡើយ។

សេចក្តីមិនសមប្រកបនឹងកើតឡើងដោយហេតុណាក៏ដោយ ក៏អាចធ្វើឲ្យអ្នកដែលឋិតនៅក្នុងសភាព ដូច្នោះកើតសេចក្តីលើសខ្វះផ្សេងគ្នាក្នុងផ្លូវចិត្តកើតសេចក្តីអាក់អន់ចិត្តក្នុងរឿងដែលខ្លួនឯងខុសពីគេនោះ ឬកើតចំណុចខ្សោយឡើងក្នុងខ្លួនឯងនោះ។ គេរមែងមិនមានសេចក្តីពេញចិត្តក្នុងជីវភាព ដែលខ្លួនមាននៅ គេតែងមានសេចក្តីអាក់អន់ចិត្តក្នុងអារម្មណ៍ទូទៅជានិច្ច។ ព្រឹត្តិការណ៍ទាំងនេះ ធម្មជាតិក៏បានព្យាយាមឲ្យតម្លៃស្មើរស្មងបំពេញឲ្យបុគ្គលទាំងនោះ ទាំងផ្លូវកាយ និង ផ្លូវចិត្ត។

តម្លៃស្មើរស្មងក្នុងផ្លូវកាយ ខ្ញុំបាទសំដៅយកសេចក្តីថា អាចធ្វើឲ្យរាងកាយ របស់អ្នកនោះមានសុខភាពគ្រប់គ្រាន់ល្អឡើងវិញ ដោយការហាត់ប្រាណ ឬ ធ្វើឲ្យរាងកាយផ្នែកណាមួយដែលពិការនោះ ឲ្យត្រឡប់ល្អឡើងវិញ (ឲ្យមានការទ្រទ្រង់)។ ដូចមនុស្សនិយាយប្រដិត គេអាចស្មើរស្មងជំនួសការប្រដិត ឲ្យចេះច្រៀងបានយ៉ាងពិរោះបំផុតដោយការច្រៀងគ្មានជាប់ប្រដិតសោះជាដើម។ ការស្មើរស្មងតម្លៃក្នុងផ្លូវកាយនោះ ជាការស្មើរស្មងដោយ ផ្លូវវៀច ឬ ផ្លូវត្រង់ក៏ដោយ។ តំលៃស្មើរស្មងដោយផ្លូវត្រង់នោះ ខ្ញុំបាទសំដៅថាជាការស្មើរស្មងដោយត្រង់តែម្តង ដូចមនុស្សដែលកើតរោគរបេង និងរក្សា

ព្យាបាលយ៉ាងណាឬដោយវិធីណា ក៏មិនចេះជាដាច់បានសោះឡើយ ព្រោះនៅមិនទាន់មានគ្រូទេព្យណាអាចគិតស្រាវជ្រាវឲ្យបានថ្នាំដ៏ស័ក្តិសិទ្ធិ សំរាប់ទំលុះទំលាយតួបាក់តេរី (Bacteria) មេរោគទាំងនេះ ឲ្យវិនាសអន្តរាយអស់ទៅបានដោយពិតប្រាកដ ។ តែធម្មជាតិក៏បានស្មើរស្មងតម្លៃឲ្យគេចេះតស៊ូដោយវិធីហាត់ប្រាណធ្វើអត្តពលិកម្ម ឲ្យរាងកាយរឹងប៉ឹងមាំមួនឡើងហើយក៏អាចទំលុះទំលាយកំចាត់មេរោគនោះៗឲ្យវិនាសសាបសូន្យទៅបាន។ ចំណែកការស្មើរស្មងដោយផ្លូវវៀចនោះ ខ្ញុំបាទសំដៅថាជាការស្មើរស្មងឲ្យមិនមែនដោយត្រូវ ដូចមនុស្ស និយាយប្រដិតដូតយ៉ាងដែលបានពោលមកហើយ។ គេមិនអាននឹងកំចាត់ការនិយាយប្រដិតនោះបានទេ តែគេក៏អាចបំបាក់អារម្មណ៍ទាំងនោះបាន ដោយការហ្វឹកហាត់ច្រៀងទាល់តែគេមានឈ្មោះសំឡេងជាទីនិយម របស់មនុស្សទូទៅ ហើយទាល់តែធ្វើឲ្យគេបាត់អារម្មណ៍ខូចចិត្តខូចគំនិតនោះទៀតផង។ បញ្ហាកែរបស់ថ្លៃលក្ខ័សេដ្ឋសាស្ត្រ គេមានលក្ខ័ណ្ឌមួយគឺលក្ខ័នៃការផ្លាស់ប្តូរ។ អ្នកខ្លះក៏ហៅថា លក្ខ័តួជំនួស គឺ "ឡ អហ្វ ស័បស្ទិស្ទូតសិន" (Law of substitution) ខ្ញុំបាទសូមហៅក្នុងខេមរភាសាថា លក្ខ័តួជំនួស ។ លក្ខ័តួជំនួសនេះឯង ក្នុងក្បួនសេដ្ឋសាស្ត្រគេថាធ្វើរបស់ថ្លៃឲ្យថោកបាន តែនឹងធ្វើបានយ៉ាងម្តេចនោះ សូមលោកអ្នកអានកុំភ្លេចថា សេដ្ឋសាស្ត្រជាសាស្ត្រប្រជាគមន៍ គឺមិនមែនវិទ្យាសាស្ត្រ ឬ ពេទ្យសាស្ត្រដែលជាវិជ្ជា ២២ មិនជា ៤ ដរានោះទេ វាអាចក្លាយទៅជាអ្វីដទៃទៀតក៏បាន។ ទើបគេហៅក្បួនសេដ្ឋសាស្ត្រថា ជាក្បួននៃគារផ្ទៀងផ្ទង (Tendency) គឺក្បួននៃគារផ្ទៀងផ្ទង ឬ ក្បួននៃការអូនអៀងនោះឯង។

កាលដែលខ្ញុំបាទពោលថា (Law of substitution) អាចកែរបស់ថ្លៃឲ្យថោកបាននោះ មានអ្នកប្រាជ្ញក្នុង ផ្លូវសេដ្ឋសាស្ត្រជាច្រើនគេបានពោលទុកថាសន្មតថា ប៉ិបស៊ីកូលាជាទីនិយមរាប់រកត្រូវការរបស់ប្រជាជនគ្រប់ៗគ្នា។ ព្រោះគេបរិភោគទៅហើយវាឆ្ងាញ់ពិសារ។ តែអ្នកលក់ប៉ិបស៊ីកូលាប្រកាន់យក (Demand) ឬ សេចក្តីត្រូវការរបស់អ្នក បរិភោគជាសារហេតុមួយតំឡើងថ្លៃ។ យើងក៏មិនខ្វីទិញផឹកទៅទិញបៀកឡេយ៍ ឬ អ្វីដទៃដែលមានតម្លៃថោកជាងមក

ផឹកវិញ។ កាលណា ប៊ុបស៊ីកូលា គ្មានមនុស្សផឹក ហើយក៏ចាំបាច់តែត្រូវចុះថ្លៃឲ្យថោកនេះហើយគឺ លក្ខ័តួជំនួស ឬ (Substitution) ។

ការពិតនោះ លក្ខ័តួជំនួសមិនបានទាក់ទងនឹងភាពជាអច្ឆរិយៈសោះទេ។ តែដែលទាញយក (Law of substitution) មកពោលផងនោះ ក៏ព្រោះយល់ឃើញថា ការស្នើរស្នងជំនួសនៃធម្មជាតិដោយផ្លូវរៀច នោះមានឧបមាឧបមៃប្រហាក់ប្រហែលគ្នាបំផុត។ ការស្នើរស្នងជំនួសដោយផ្លូវរៀចនោះ មានសេចក្តីសំខាន់បំផុតជាងការស្នើរស្នងជំនួសដោយត្រង់ច្រើនណាស់។ បុគ្គលដែលជាអច្ឆរិយៈ ច្រើនតែបានទទួលការស្នើរស្នងបំពេញឲ្យដោយផ្លូវរៀចទាំងអស់។ ការស្នើរស្នងបំពេញឲ្យដោយផ្លូវរៀចពីធម្មជាតិ ទើបជាគោលការណ៍មួយដ៏សំខាន់ក្នុងវិវឌ្ឍនភាពរបស់មនុស្សលោក។

ការស្នើរស្នងបំពេញឲ្យក្នុងផ្លូវចិត្តនោះ ចាត់បានជាមានសេចក្តីសំខាន់ជាងការស្នើរស្នងក្នុងកាយច្រើនណាស់។ ព្រោះការស្នើរស្នងក្នុងផ្លូវចិត្តជាការផ្ទុះឋាមពលនៃខួរក្បាលឲ្យមានអំណាចពិសេសឡើង។ តាមការពិត រាងកាយវិការមិនសមប្រកប ឬ មិនមានការទ្រទ្រង់នោះមិនអាចនឹងសាងឲ្យអ្នកជាអច្ឆរិយៈបានទេ។ តែរាងកាយមិនមានការទ្រទ្រង់អាចជាការបណ្តុះផ្សាំឲ្យកើតសន្ទុះផ្ទុះចេញ នៃអំណាចចិត្ត ឆាប់រហ័សណាស់។

លោកអ្នកអានជាទីគោរព លោកអាចជ្រាបបានហើយថា ចិត្តជាតួចក្រនៃការប្រែប្រួលចិត្តជាតួប្រធាននៃគារបោះជំហានទៅមុខ ចិត្តជាអង្គនៃការបដិវត្តន៍ បដិរូប។ គេទើបពោលបានថាកំលាំងនៃអំណាចចិត្តជាកំលាំងនៃសេចក្តីចំរើនទៅមុខ។ អ្នកទស្សនៈវិទូបានពោលទុកថាក្នុងលោកនេះមានរបស់សំខាន់ពីរយ៉ាងគឺ វត្ថុមួយអំណាចចិត្ត ឬ យើងហៅថាសមាធិចិត្ត និងមួយវត្ថុទៀតគឺវត្ថុទាំងឡាយនឹងមានវិវឌ្ឍនភាពក៏ព្រោះចិត្តមានជំហានទៅមុខ។ ចិត្តទើបជាគោលការណ៍ដ៏សំខាន់បំផុតក្នុងភាពជា "អច្ឆរិយបុគ្គលក្នុងលោក"។ ភាពជា "អច្ឆរិយបុគ្គលក្នុងលោក" នឹងកើតឡើងមកឯងៗ មិនបានជាដាច់ខាត ត្រូវតែមានមូលហេតុយ៉ាងណាមួយធ្វើឲ្យកើតឡើង អាចជាវត្ថុព័ទ្ធលោមដូចសេចក្តីទីទ័លក្រការប្រមាថ មើលងាយសេចក្តីមេត្តាអាណិតអាសូរ គោលនៃការ

ស្មើរស្មង ការត្រូវការឈ្មោះសំឡេង។ល។ វត្ថុទាំងនេះអាចនឹងកើតឡើងក្នុងវ័យណាក៏បាន តែនឹងកើតក្នុងវ័យណាក៏បាន តែនឹងកើតក្នុងវ័យទារកមិនបាន ត្រូវតែកើតក្នុងវ័យដែលមានអាយុហួសពី ៧ ឆ្នាំទៅហើយ ឬ ច្រើនជាងនោះ។ ទោះបីអច្ឆរិយៈ ឬ នាមធម៌នឹងមានផ្ទេរបន្តពូជគ្នាបានក្នុងផ្លូវតំណខ្សែលោហិត (Heredity) ក៏ដោយ។ តែក៏មិនអាចនឹងស្តែងសេចក្តីឆ្លៀវឆ្លាត សមត្ថភាពបានដូចបុព្វបុរសសព្វគ្រប់នោះទេ។ ការផ្ទេរបន្តពូជគ្នាក្នុងផ្លូវតំណខ្សែលោហិតនោះ អាចប្រាកដផលជាក់ច្បាស់ ក៏តែក្នុងសភាពផ្លូវកាយប៉ុណ្ណោះ ដូចគោលការរបស់លោក មេណ្ដេន (Law of Menden) ដែលបានសាកល្បងពិសោធន៍ឲ្យឃើញបានពិតៗ ក្នុងរវាងសត្វតិណជាតិរុក្ខជាតិ អាចផ្ទេរផ្លាស់ប្តូរគ្នាបានដោយពិតមែន។ តែក្នុងផ្លូវបញ្ញាកំលាំងចិត្ត កំលាំងសមាធិ ចិត្តានុភាព សេចក្តីនាំ ឃើញថា នៅមិនទាន់មានអ្នកប្រាជ្ញណាបានធ្វើការសាកល្បង ក្នុងរឿងការផ្ទេរបន្តឲ្យគ្នាបានក្នុងផ្លូវខួរក្បាលឲ្យជាក់ច្បាស់ម្តងណាសោះ ព្រោះថាមពលនៃខួរក្បាលនោះ រមែងនៅនឹងអំណាចចិត្តជាតួសំខាន់បំផុត។ ខ្ញុំបាទយល់ឃើញថាមនុស្សគ្រប់រូបចំរើន ឬ អន់ថយ មានជំហានទៅមុខ ឬ ថយក្រោយក៏ព្រោះស្ថាប័ននៃអំណាចចិត្តច្រើនជាង រឿងដទៃ ។ បើសិនជារាងកាយរបស់យើងនឹងទ្រុឌទ្រោមទៅយ៉ាងណាក៏ដោយ ក៏មិនជាការអ្វីប៉ុន្មានទេ កុំឲ្យតែកំលាំងចិត្តរបស់យើងទ្រុឌទ្រោមទៅផងឡើយ ចិត្តរបស់យើងត្រូវតែមានសង្ឃឹម មានការតស៊ូមានសេចក្តីរឹងប៉ឹង មានជំហានទៅមុខ មានការស៊ូទ្រាំ មានសេចក្តីមានះមានគោលដៅនៃជីវិតមានការផ្តួចផ្តើមក្នុងការងារ រួមសេចក្តីទៅក៏គឺ យើងត្រូវតែសន្សំថាមពលនៃអំណាចចិត្តពោលគឺ យើងត្រូវតែហ្វឹកហាត់ អប់រំផ្លូវ បញ្ញាការពិចារណា ការសិក្សា សតិ សម្បជញ្ញៈ របស់យើងឲ្យសំដៅយកតែផលល្អផលវិសេស ទាំងឲ្យជាទម្លាប់ក្នុងការបដិបត្តិការងារនោះ។ តែប៉ុណ្ណោះ ក៏ជាសេចក្តីចំរើនរុងរឿងរបស់ពួងមនុស្សទាំងឡាយ ក្នុងពិភពលោកនេះគ្រប់គ្រាន់ណាស់ទៅហើយ។

អច្ឆរិយៈមិនមានការទ្រទ្រង់ ឬ មិនសមប្រកប មានសារៈប្រយោជន៍ក្នុងការបណ្តុះផ្សាំថាមពលនៃសេចក្តីស្រវាស្រទេញ (Ambition) បណ្តុះផ្សាំឲ្យមាន

ថាមពលនៃគោលគំនិត ថាមពលនៃចិត្តានុភាព ថាមពលនៃមនោភាព ថាមពលនៃសញ្ជាតិញាណនៃការតស៊ូៗលៗ

បើសិនយើងចង់រកខពិសោធន៍ក្នុងរឿងនេះ ហើយយើងក៏អាចរកឃើញបានភ្លាមថាមុនដែលមនុស្សសំខាន់ៗ ក្នុងពិភពលោកនឹងឡើងកាន់ភាពជាអ្នកធំដុំ ជាអ្នកសម្បើម ជាអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ ភាគច្រើនមនុស្សទាំងនេះ ច្រើនតែមានរាងកាយមិនមានការទ្រទ្រង់ ឬ មិនសមប្រកបយ៉ាងណាមួយមកពីមុនហើយ ដូចលោកហ្វ្រែង ក្លិនឌី រ៉ូសវ៉េល ប្រធានាធិបតីទី៣២ របស់អាមេរិកកាំង ក៏បានកើតរោគខ្វិននៃទារក (Infantile paralysis) អ័ង់គ្លាឡវេន្ទឡា រូសីអា អ្នកវិទ្យាសាស្ត្រសំខាន់នៃលោក ក៏កើតរោគក្រពះអាហារពិការរាំរៃ វិល្លិយាំភិត (ឪ) និង វិល្លិយាំភិត (កូន) ក៏មានរាងកាយវិកលវិការ មិនមានការទ្រទ្រង់មិនសមប្រកប យូលីអាស៊ីហ្សារ ចក្រពត្តិនៃអាណាចក្ររ៉ូម៉ែងក្នុងសម័យបុរាណ ក៏មានរាងកាយទន់ខ្សោយ ហើយកើតរោគខ្យល់គប្រកាច់ជាញឹកញយ ។ តែលោក ស៊ីហ្សារ ក៏អាចសាងខ្លួនឯងឡើងមកបាន ទាល់តែក្លាយទៅជាមនុស្សសំខាន់ក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ជាអ្នកចម្បាំងមានាមឧត្តោស មិន ចាញ់មេចម្បាំងណាប៉ូឡេអុងប៉ូណាបារត៍ នៃបារាំងសេសប៉ុន្មាន។

បីធោហ្វេន អ្នកតែងភ្លេងមានឈ្មោះល្បីល្បាញនៃអាល្លឺម៉ង់ ក៏មានរាងកាយមិនមានការទ្រទ្រង់មិនសមប្រកប លោកនេះថ្លង់មិនឮអ្វីសោះ ដោយមូលហេតុតែត្រចៀកថ្លង់នេះឯងបានក្លាយជាមន្តដ៏វិសេស បណ្តុះផ្សាំឲ្យថាមពលនៃអំណាចចិត្ត មានប្រសិទ្ធិភាពដ៏ បរិបូណ៌ឡើង ទាល់តែមានសមត្ថភាពអាចតែងភ្លេងបានយ៉ាងពីរោះ គួរឲ្យចាប់អារម្មណ៍ជាទីបំផុត។

លោក ឡុកអហ្វវេល្លិងត័ន បុគ្គលសំខាន់របស់អង់គ្លេសម្នាក់ទៀតក៏មានរាងកាយវិកលពិការយ៉ាងខ្លាំងក្នុងខណៈដែលមេចក្រពត្រ៍នៃ បារាំងសេស ណាប៉ូឡេអុងប៉ូណាបារត៍ ពង្រីកសៃន្យានុភាពធ្វើការរុករានទន្ទ្រានអឺរុបស្ទើរតែគ្រប់ប្រទេសក្នុងវេលានោះ។ លោកឡុកអហ្វវេល្លិងត័ន ជានាយទាហានថ្នាក់មេទ័ព ហើយលោកមេទ័ពកំពុងតែកើត ជំងឺដោយរោគរបេងយ៉ាងធ្ងន់ធ្ងរទៀតផង។ លោកបានពិចារណាយល់ឃើញថា អនាគតនៃជីវិតរបស់

លោកកំពុងតែតែរង់ចាំសេចក្តីស្លាប់នៅជានិច្ច ព្រោះរោគដែលសង្កត់ជិះជាន់លោកនេះកាចសាហាវណាស់ អស់សង្ឃឹមនឹងរក្សាឲ្យជាដាច់បានឡើយ។ សេចក្តីស្លាប់របស់លោកគ្មានប្រយោជន៍អ្វីដល់កិត្តិយសរបស់ខ្លួនឯង កិត្តិយសរបស់ជាតិ រាជបល្លង្ក និងប្រយោជន៍សាធារណៈជនសោះឡើយ។ ដូច្នោះលោកទើបសូមអាសាបង្ក្រាមេទ័ព ណាប៉ូឡេអុងប៉ូណាបារត៍ ហើយក៏ក្នុងខណៈនោះ ខ្លួនរបស់លោកក៏កំពុងតែមានរោគរបេង សង្កត់សង្កិនលោកយ៉ាងខ្លាំងបំផុត ដូចបានពោលមកហើយ ដូច្នោះសង្គ្រាម វទើរលូ ទើបឧប្បត្តិឡើងយ៉ាងទារុណគួរឲ្យស្ញប់ស្ញែងជាទីបំផុត។ ចុងចប់របស់ ណាប៉ូឡេអុង ប៉ូណាបារត៍ រាជាធិរាជនៃសង្គ្រាមក៏ពើបប្រទះនូវអវសានតែត្រឹមនោះឯង។ នេះគឺជាតម្លៃព្រលឹងពីធម្មជាតិមួយ ដែលមានការស្មើរស្មេងបំពេញឲ្យក្នុងផ្លូវវៀចនិងផ្លូវត្រង់ លោក ឡុត ក៏អាចមានអាយុនៅតមកទៀតជាយូរឆ្នាំ ទើបបានស្លាប់។

ចាកតួយ៉ាងដែលបានពោលមកហើយនេះ ស្តែងឲ្យឃើញយ៉ាងច្បាស់លាស់ថារាងកាយមិនមានការទ្រទ្រង់មិនសមប្រកបជាមូលដ្ឋាន ដ៏សំខាន់សំរាប់ឲ្យឧប្បត្តិនៃអច្ឆរិយៈសម្បត្តិ។ គោលការណ៍នៃការស្មើរស្មេង ឬគោលការណ៍នៃការទ្រទ្រង់ (Law of compensation) ទើបជាតួជួយបណ្តុះផ្សាំសមត្ថភាព និង ប្រសិទ្ធិភាពក្នុងការធ្វើការងារជាការបណ្តុះផ្សាំសមត្ថភាព និងប្រសិទ្ធិភាពក្នុងផ្លូវចិត្ត ជាការបណ្តុះផ្សាំបុគ្គលភាព ឲ្យមានឥទ្ធិពលបរិបូណ៌ឡើង។ បុគ្គលដែលមានរាងកាយមិនមានការទ្រទ្រង់ មិនសមប្រកប ហើយក៏សេចក្តីមិនមានការទ្រទ្រង់នោះ នឹងបានឧប្បត្តិឡើងក្នុងវ័យណាក៏ដោយ។ រាងកាយដែលមិនមានការទ្រទ្រង់ មិនសមប្រកប ទើបផ្ទុះជាថាមពលនៃការផ្តួងផ្តើម (Originality Power) ឲ្យកើតមានឡើង។ កាលបើថាមពលរូបរបៀបនេះបានផ្ទុះឡើងលយើ ថាមពលនៃសមាធិ (Concentration Power) ថាមពលនៃចិត្តានុភាព (Will Power) ថាមពលនៃមនោភាព (Imagination Power) ថាមបឡនៃសេចក្តីសង្កេត (Observation Power) ថាមពលនៃសេចក្តីស្រវាំស្រទេញ (Ambition Power) ថាមពលនៃសេចក្តីសំគាល់ ឬ កត់ចាំ (Memory Power) ក៏កើតតាមកដោយមិនតោងសង្ស័យ។ រួមសេចក្តីមកថា

ថាមពលក្នុងទស្សនៈចិត្តវិទ្យាផ្សេងៗក៏នឹងផ្ទុះចេញ យ៉ាងពេញទំហឹងដោយរួស រាន់។ ថាមពល ដូចបានពោលមកនេះត្រូវតែមានការបដិរូបយ៉ាងសម្បើម ទើប បណ្តុះផ្សាំអច្ឆរិយៈ សម្បត្តិឲ្យមានថាមពលយ៉ាងខ្លាំងក្លាបរិបូណ៌បាន។ ថាមពល នៃធម្មជាតិនេះហើយដែលបានស្ថាបនាឲ្យមនុស្សយើងស្មើគ្នា តែ ភាគច្រើនយើងទេតើ ដែលមិនចេះប្រើវត្ថុដែលស្មើគ្នាដែលធម្មជាតិបានហុច មកឲ្យយើងនោះ ទើបកើតមានសេចក្តីផ្សេងគ្នាក្នុងសេចក្តីសង្កេត សេចក្តីចាំ សេចក្តីគិត សេចក្តីក្លាហាន សមាធិ។ល។ កាលបើសេចក្តីផ្សេងគ្នាមាននៅ ដូច្នេះសភាពនៃការរស់នៅរបស់មនុស្សទូទៅ ទាំងក្នុងផ្លូវ សេដ្ឋកិច្ច នយោ បាយ និង អាជីវកម្ម ទើបមានការបោះជំហានទៅមុខ ឬ ថយក្រោយ ក៏ស្រេច តែសេចក្តីផ្សេងគ្នា ដូចបានពោលមកហើយនោះដែរ។

ដោយហេតុតែមនុស្សយើងមិនសូវស្គាល់គុណតម្លៃ "អច្ឆរិយៈនៃធម្ម ជាតិ" ហើយទាំងមិនចេះចាំមក "អច្ឆរិយៈនៃធម្មជាតិ" មកប្រើឲ្យកើតប្រយោ ជន៍ដល់មនុស្សបាននោះធម្មជាតិទើបដាក់ទោសមនុស្សទាំងនោះហើយ ក៏បាន សាងសញ្ជាតិញាណផ្សេងៗទុកមកឲ្យមនុស្សទាំងនោះទៀត។ សញ្ជាតិញ្ញាណ នៃសេចក្តីត្រូវការទាំងនោះ ក៏អុចផ្ទុះថាមពលនៃអច្ឆរិយៈនៃធម្មជាតិ ឲ្យមានការ ផ្តុងផ្តើមកិច្ចការផ្សេងៗឡើង។

មិនដូច្នោះទេ អច្ឆរិយៈនៃធម្មជាតិ ក៏មិនអាចមានឱកាសបានស្តែងសមត្ថ ភាព និង ប្រសិទ្ធិភាពយ៉ាងណាមួយទាល់តែអស់ជីវិត។

ខ្ញុំបាទបានពោលមកហើយថា ធម្មជាតិរមែងស្មើរស្មង បំពេញតម្លៃ ព្រលឹងឲ្យដល់បុគ្គលដែលមានរាងកាយ មិនមានការទ្រេទ្រង់មិនសមប្រកប។ រឿងនេះខ្ញុំបាទសូមនាំយកវាទៈរបស់ "អេហ្សីរ៉េលស៍" អ្នកនិពន្ធល្បីឈ្មោះរបស់ អង់គ្លេស ដែលមានឈ្មោះសំឡេងខ្ទរខ្ទារពេលទាំងផ្ទៃនៃសាកលលោក មកជា តួយ៉ាងដូចតទៅនេះ។

"ខ្ញុំបាទមិននឹកខូចចិត្តទោះបីបន្តិចបន្តួចសោះឡើយ ក្នុងការដែលខ្ញុំបាទ ត្រូវទទួលគ្រោះថ្នាក់ ដល់ទៅបាក់ជើងរបស់ខ្ញុំបាទ ព្រោះបើសិនខ្ញុំបាទមិនបាន ទទួលគ្រោះថ្នាក់ដល់បាក់ជើងហើយខ្ញុំបាទក៏មិនអាចបានជា អ្នកនិពន្ធល្បី

ឈ្មោះ ក្នុងពិភពលោកដូចសព្វថ្ងៃនេះទេ ខ្ញុំបាទមិនមានសេចក្តីសៅសោក ទោមនស្ស និង ជោគជតាដែលខ្ញុំបាទបានទទួលរហូត មួយជីវិតនោះសោះ ឡើយ។

ថាមពលឬសន្ទុះនៃអច្ឆរិយៈភាពរបស់លោក អេជហ្សីវ៉េលស៍ បានក្លាយ ជាអច្ឆរិយៈភាពនៃការនិពន្ធ។ ក្នុងគ្រាដែលអ្នកនិពន្ធនេះបានជួបប្រទះគ្រោះ កម្មនៃជីវិត ពីមិត្តភក្តិរបស់គេម្នាក់ កាលប្រមាណ ៧០ ឆ្នាំកន្លងមកនោះមាន និស្សិតធំម្នាក់បានចាប់យក អេជហ្សីវ៉េលស៍បោះឡើងទៅតែក្នុងវេលាដែល អេជហ្សីវ៉េលស៍ ធ្លាក់ចុះមកវិញនោះគេទទួលមិនទាន់ជាហេតុឲ្យ អេជហ្សីវ៉េល ស៍ ធ្លាក់មកប៉ះទង្គិចនឹងផ្ទៃថ្មល់ ហើយជើងម្ខាងបានបាក់ឆ្អឹងខ្ទិចសូម្បីតែគ្រូ ពេទ្យនឹងចាត់ការរក្សាព្យាបាលយ៉ាងម៉េចក៏មិនអាចជាបានដូចដើម ទើបក្លាយ ទៅជាមនុស្សពិការអស់មួយជីវិត ដោយឧប្បត្តិហេតុនៃជើងបាក់របស់គេនោះ ឯង ទើបជាមូលហេតុដ៏សំខាន់ដែលធម្មជាតិត្រូវស្នើរស្នងបំពេញឲ្យគេ ពោលគឺ បង្គាប់ឲ្យ អេជហ្សីវ៉េលស៍ ត្រូវបែរកសៀវភៅធ្វើជាមិត្តអានកែអផ្សុក ព្រោះគេ នឹងធ្វើដំណើរទៅណាមកណាមិនបាន។ ដោយការអានសៀវភៅជាច្រើននេះ ឯង ធ្វើឲ្យគេមានគោលគំនិតចេះដឹងជ្រៅជ្រះប្រាជ្ញព្រោកព្រោងព្រាត ឡើង។ សៀវភៅនេះបានជំរុញតឿនឲ្យកើតកំលាំងចិត្ត និងចិន្តនាការដ៏ភ្លឺថ្លាត្រចះត្រ ចង់ឡើង។ គេបានតាំងគោលដៅនៃជីវិតរបស់គេយ៉ាងទៀងទាត់ពិតប្រាកដថា គេនឹងព្យាយាមធ្វើខ្លួនឲ្យជាអ្នកនិពន្ធល្បីឈ្មោះឲ្យទាល់តែបាន។ ឧប្បត្តិហេតុ នៃជើងបាក់របស់គេ បានប្រែប្រួលនូវថាមពលនៃអច្ឆរិយៈភាពនៃធម្មជាតិ ឲ្យ ត្រឡប់ក្លាយជា អច្ឆរិយៈភាពមានជីវិតរស់រវើកឡើងវិញ។

សញ្ញាលក្ខ័ណ្ឌនៃភាពជាអច្ឆរិយៈរបស់ អេជហ្សីវ៉េលស៍ បានកើតឡើង ដោយរាងកាយមិនមានការទ្រទ្រង់ មិនសមប្រកដ ពោលគឺរាងកាយរបស់គេ ពិការនោះឯង។ គោលការណ៍នៃការទ្រទ្រង់ (Law of compensation) បាន ឲ្យតម្លៃព្រលឹងដល់គេយ៉ាងខ្ពស់ត្រដែតទើបធ្វើឲ្យ អេជហ្សីវ៉េលស៍ បានក្លាយ ទៅជាអ្នកនិពន្ធមានឈ្មោះល្បីខ្ចរខ្ចារពេញទាំងសាកលលោក។ អេជហ្សីវ៉េល ស៍ កើតក្នុងត្រកូលនៃសេចក្តីខ្សត់ទីទ័លក្រ។ តែគេបានព្យាយាមសាងឈ្មោះ

សំឡេង ឡើងមក ដោយសេចក្ដីមានៈតស៊ូព្រមទាំងមានសេចក្ដីស្រវាស្រទេញ យ៉ាងខ្ពស់។ តែប្រការសមខាន់បំផុតនោះ បើសិនគេមិនបានជួបប្រទះគ្រោះថ្នាក់ទេដល់បាក់ជើងដើមិនរួចហើយ។ ជួនកាលគេអាចមានតំណែងត្រឹមតែស្មៀនរាយរងតូច តាចមួយក្នុងហាងលក់ទំនិញតូចមួយក៏បាន។ តែព្រោះរាងកាយមិនមានការទ្រទ្រង់មិនសមប្រកប បុគ្គលឡើងមកនេះឯងជាមូលហេតុឧបត្ថម រួញច្រាណឲ្យគេក្លាយទៅជា អច្ឆរិយបុគ្គលឡើងមកបាន។

អេជហ្សិវ៉េលស៍ ជាអ្នកនិពន្ធដែលមានខួរក្បាលភ្លឺថ្លាត្រចះត្រចង់បំផុតជាអ្នកនិពន្ធដែលមានមនុស្សនិយមច្រើនបំផុត។ គេមានប្រាក់ចំណូលចាកការនិពន្ធរបស់គេរាប់ចំនួនលាលិវស្ទីលិង្គក្នុងមួយឆ្នាំៗ។ ទោះបីខ្លួនគេនឹងមានអវៈយវៈ ពិការនិងមានរាងកាយមិនមានការទ្រទ្រង់ដូច្នោះក៏ដោយ។ គោលការណ៍នៃការទ្រទ្រង់ ក៏បានបំពេញតម្លៃព្រលឹងតបស្នើរស្នងឲ្យគេក្នុងផ្លូវចិត្តធ្វើឲ្យគេមានចិត្តានុភាព រឹងប៉ឹងមុតមាំតស៊ូក្នុងឆាកជីវិតទាល់តែមានកេរ្តិ៍ឈ្មោះល្បីល្បាញ ខ្ទរខ្ទារពេញទាំងផ្ទៃនៃពិភពលោកនេះ ហើយដែលហៅថា "អច្ឆរិយបុគ្គល"។

## ‡ សេចក្ដីព្យាយាម មាននៅទីណា ‡
## † សេចក្ដីសំរេច ក៏មាននៅទីនោះ †

‡

†

# បទទី៨

# សមិទ្ធិ នៃ អច្ឆរិយបុគ្គល

## ១. អច្ឆរិយៈ គឺអ្វី?

មុននឹងអធិប្បាយពាក្យថា "អច្ឆរិយៈ" គឺអ្វី? អច្ឆរិយៈ មានសេចក្តីសំខាន់យ៉ាងម៉េច?។ យើងគោងតែស្តាប់ ទស្សនៈរបស់ប្រាជ្ញ ផ្សេងៗក្នុងផ្លូវចិត្តវិទ្យា និងអាជ្ញាវិទ្យាដូចតទៅនេះជាមុនសិន។

## ២. អច្ឆរិយៈក្នុងទស្សនៈ ឡមប្រូសូ

ពាក្យថា អច្ឆរិយៈក្នុងទស្សនៈរបស់លោក ឡមប្រូសូ អ្នកប្រាជ្ញចិត្តវិទ្យា និងអាជ្ញាវិទ្យាជាតិអ៊ីតាលីបានឲ្យ ទស្សនៈក្នុងរឿង អច្ឆរិយៈ ទុកថាអច្ឆរិយៈ និងលក្ខណៈនៃការវិកលចរិកនោះប្រហាក់ប្រហែលគ្នាជាទីបំផុត។

ទស្សនៈរបស់លោក ឡមប្រូសូ ជាទស្សនៈដែលអ្នកប្រាជ្ញផ្លូវចិត្តវិទ្យា (Psychology) ភាគច្រើនបានមូលមតិគ្នារាប់រងថា ជាពាក្យនិយមដែលមានកៅលចារឹកបរិបូណ៌ ហើយទាំងត្រឹមត្រូវជាអតិបរមាក្នុងព្រឹត្តិកម្មគ្រប់យ៉ាង។

អ្នកចិត្តវិទ្យាខ្លះទៀតបានអធិប្បាយពាក្យថា "អច្ឆរិយៈ" ទុកក្នុងទស្សនៈរបស់គេថា "អច្ឆរិយបុគ្គល" គឺបុគ្គល ដែលមានប្រាជ្ញាឈ្លាសវៃ មានសមត្ថភាពប្រសិទ្ធិភាពលើសលើបុគ្គលធម្មតាសាមញ្ញ ព្រមទាំងមានអារម្មណ៍តឹងរឹងខ្លាំងក្លា មុះមុតបំផុត ក្នុងសេចក្តីប្រាថ្នា និងគោលដៅនៃជីវិតរបស់ខ្លួន។

អ្នកចិត្តវិទ្យាខ្លះទៀតបានកំរិតពាក្យថា "អច្ឆរិយៈ" គឺបុគ្គលដែលមានប្រសាទញាណច្រើនជាង ៥ គឺមានញាណប្រសាទី ៦-៧-៨ ដោយបរិបូណ៌។ តែតាមធម្មតា ហើយបុគ្គលដែលជាអច្ឆរិយៈនោះ តោងតែអានព្រឹត្តិកម្ម និងព្រឹត្តិការណ៍ប្រហាក់ប្រហែលនឹងមនុស្សវិកលចរិក។ គឺមនុស្សដែលមានសេចក្តីប្រព្រឹត្តខុសពិធម្មតាសាមញ្ញ មនុស្សមានចិត្តគំនិតប្លែកៗ ថ្មីៗជានិច្ចជា

អ្នកមានសញ្ញាតិញាណក្នុងការលើកតំកើងខ្លួនយ៉ាងខ្ពស់ ជាអ្នកមានប្រសាទទី ៦-៧-៨ ជាញាណប្រសាទអាចកំបាំងស្ថិតនៅក្នុងខួរក្បាល ឬចិត្តគំនិត អាចឈ្វេងយល់ឃើញហេតុការណ៍ផ្សេងៗ បានយ៉ាងទូលំទូលាយ រួមទាំងមានសេចក្តីក្លាហានខុសធម្មតា សាមញ្ញជននេះហើយដែលយើងហៅថា "អច្ឆរិយបុគ្គល"។

## ៣. អច្ឆរិយៈក្នុងទស្សនៈ ភិទគិន

ក្នុងតម្រាចិត្តវិទ្យារបស់ដុកទ័រ ភិទគិន ដែលមានឈ្មោះ (The psychology of achievement) បានវែកញែកបែងចែកអច្ឆរិយៈទុកច្រើនប្រភេទណាស់។ តែផ្នែកសំខាន់ៗ នៃគុណលក្ខណៈរបស់អច្ឆរិយបុគ្គលមានដូចតទៅនេះ ៖

## ៤. គុណសម្បត្តិអច្ឆរិយបុគ្គល

១. អច្ឆរិយបុគ្គលនោះមានប្រាកដការណ៍នៃសេចក្តីស្រវាំស្រទេញ អន្ទះអន្ទែងក្នុងការចង់ចេះ ចង់ដឹង ចង់ឃើញ ចង់ចង់យល់ យ៉ាងខ្លាំងក្លាបំផុត។

២. សិក្សាតាមចំណង់យ៉ាងក្លៀវក្លាបំផុត ក្នុងរឿងណាមួយដោយខ្លួនឯង។

៣. ចេះស្គាល់នៅភាពជាអច្ឆរិយបុគ្គល រួមសំបាច់ក្នុងសង្គមមនុស្សដ៏គួរគាប់នឹងអច្ឆរិយៈគ្រប់យុគ គ្រប់សម័យ ដើម្បីពួតដៃគ្នាលើកតំកើងមនុស្សជាតិក្នុងពិភពលោក។

៤. មានកំលាំងពលំ ក្នុងការរៀនសូត្រខ្លាំពូកែជាអតិបរមា។

៥. មានកំលាំងពលំ ក្នុងការចេះចាំ មុតមាំ ទៀតទាត់ពិប្រាកដណាស់។

៦. មានមនោគតិ ឧត្តមគតិ ល្អិតល្អន់ ជ្រៅជ្រះ ទូលំទូលាយជាទីបំផុត។

៧. មានសុខភាពបរិបូណ៌ អាចទប់ទល់តស៊ូនូវសេចក្តីវិបត្តិផ្សេងៗ ការប្រមាថមើលងាយសេចក្តីកោងកាច និង សេចក្តីអយុត្តិធម៌ ផ្សេងៗបាន

យ៉ាងវិសេសបំផុត។

៨. សំរេចិត្តពិភាក្សាក្នុងបញ្ហាចំពោះមុខ បានយ៉ាងប៉ិនប្រសប់ ឆាប់រហ័ស ដាច់ខាត។

៩. និយមការផ្តួចផ្តើមក្នុងការងាររបសខ្លួន មិនព្រមធ្វើអ្វីតាមបែបអ្នកដទៃទាំងមិនព្រមមាការទុច្ចរិតក្នុង សេចក្តីផ្តួចផ្តើមរបស់ខ្លួន និង របស់អ្នកដទៃទៀតផង។

១០. ចរិយាមារយាទក្នុងផ្លូវចិត្តថ្លៃថ្នូរបំផុត ឃើញទុក្ខអ្នកដទៃដូចទុក្ខរបស់ខ្លួន មានចាគៈចិត្ត និង មេត្តាចិត្ត ជាដរាប មានការពិសោធន៍ និងការស្រាវជ្រាវជានិរន្តន៍។

១១. មានកំលាំងពលាំងក្នុងសមាធិទៀងទាត់ ហ្នឹងហ្ន ស្ទិតស្ទាញពិតប្រាកដ។

១២. មានកំលាំងពលំនៃចិត្តានុភាពមុតមាំ។

១៣. មានកំលាំងពលំនៃមនោគតិ និង គំនិតថ្មីៗ មិនតាមបែបនរណា។

១៤. មានខន្តីធម៌ រឹងប៉ឹង មុតមាំ ជាទីបំផុត។

១៥. មានកំលាំងពលំនៃសេចក្តីមានៈ ព្យាយាមអត់ធន់យ៉ាងស្ទិតស្ទាញជាទីបំផុត។

១៦. មានកំលាំងពលំនៃសេចក្តីក្លាហានដាច់ខាត ជាអតិបរមា។

១៧. មានកំលាំងពលំនៃកាមារម្មណ៍ខ្លាំងក្លា។

១៨. មានកំលាំងពលំក្នុងការអំនួតពូកែណាស់។

១៩. មានកំលាំងពលំនៃជំនឿខ្ជាប់ខ្លួនមុតមាំមិនប្រែប្រួលផ្លាស់ប្តូរងាយៗឡើយ។

២០. មានកំលាំងពលំក្នុងការសាងគោលដៅនៃជីវិតពិតប្រាកដ មិនផ្លាស់ប្តូរប្រែប្រួលទៅតាមអារម្មណ៍ងាយៗ ឡើយ។

២១. មានកំលាំងពលំនៃមនុស្សធម៌ថ្លៃថ្លាជាទីបំផុត។

២២. មានកំលាំងពលំពីការទីទាល់ក្រ។

២៣. មានកំលាំងពលំពីសេចក្តីខ្លាច។

២៤. មានកំលាំងពលំពីតន្ត្រី

២៥. មានកំលាំងពលំពីសេចក្តីមិនសមប្រកប ដែលត្រូវតែតបស្នងដោយក្រិត្យក្រមនៃការទ្រទ្រង់។

២៦. មានកំលាំងពលំពីឧបាទាន ឬ សេចក្តីប្រកាន់ភ្ជាប់យ៉ាងស្វិតស្វាញបំផុត។

២៧. មានកំលាំងពលំពីហេតុការណ៍វិបត្តិកាលផ្សេងៗ។

២៨. មានកំលាំងពលំនៃមេត្តាធម៌ ដល់ពពួកមនុស្ស និង សត្វទូទៅយ៉ាងទូលំទូលាយបំផុត។

២៩. មានកំលាំងពលំនៃការតស៊ូឆ្មើមបំផុត។

៣០. មិនមានអាថ៌កំបាំងអ្វីសោះសំរាប់ខ្លួនឯង និង អ្នកដទៃឡើយ។

បើសិនយើងសង្កេតមើលអាចឃើញងាយថា អច្ឆរិយបុគ្គលក្នុងពិភពលោកនេះ ភាគច្រើនបំផុតច្រើនតែកើត ដោយហេតុផ្សេងៗយ៉ាងណាមួយដូចបានពោលមកហើយខាង លើនោះ។

ខ្ញុំបាទធ្លាប់បានពោលមកហើយថា អច្ឆរិយៈដោយធម្មជាតិនោះគ្មាន។ មានតែអច្ឆរិយៈដែលកើតឡើងបាន ក៏តោងអាស្រ័យអំណាចកំលាំងចិត្ត (ចិត្តានុភាព)។

អំណាចកំលាំងចិត្តដែលពោលមកនេះ អាចប្រសិទ្ធិភាពសេចក្តីបរិបូណ៌បាន ក៏តោងអាស្រ័យថាមពលយ៉ាងណាមួយដូចពោលមកហើយ ជាកំលាំងវុញប្រាន ជាឈ្នួនអុចដុតឲ្យផ្ទុះឡើងគឺឲ្យអំណាចកំលាំងចិត្តឡើង ឬ ឲ្យចិត្តមានកំលាំងខ្លាំងក្លាឡើងៗ កាលបើអំណាចចិត្តខ្លាំងក្លាឡើងកាលណា វេលាណានោះហើយ គឺជាការបញ្ជាក់ឲ្យឃើញច្បាស់ថា "ភាពនៃអច្ឆរិយៈ" បានចាប់បញ្ចាំងរស្មី ឲ្យដល់ជីវិតរបស់គេហើយ។

អច្ឆរិយទើបមិនបានឋិតនៅក្រោមអំណាចធម្មជាតិ មិនបានឋិតនៅក្រោមអំណាចព្រហ្មលិខិត ព្រះអាទិទេព ព្រះជាម្ចាស់ មិនបានឋិតនៅក្រោមអំណាចដួងចិត្ត ដួងចន្ទ ដួងអាទិត្យមិនបានឋិតនៅក្រោមអំណាចជោគជតាវាសនា ឬ ក្រោមអំណាចអារក្សទេវតា ។ល។ ទាំងអស់។ តែវាឋិតនៅក្រោម

អំណាចកំលាំងចិត្ត របស់មនុស្សតែម្នាក់ៗ តែប៉ុណ្ណោះ។ មនុស្សណាក៏ដោយ បើនឹងក្លាយទៅជាអច្ឆរិយបុគ្គលបាន លុះត្រាតែធ្វើគុណតម្លៃអំណាចកំលាំងចិត្តរបស់ខ្លួនឲ្យមានប្រសិទ្ធិភាពត្រដែតឡើង ដោយការអប់រំខ្លួនឯង ហ្វឹកហ្វឺនខ្លួនឯងតោងឈ្នះចិត្តខ្លួនឯង (ចិត្តេន ជិនស ចិត្តំ) តាមគោលការនៃចិត្តវិទ្យា (Psychology) របស់ព្រះពុទ្ធជាម្ចាស់ឬរបស់ ភិតគិន (Pitkin) ឈ្មោះ (The psychology of Achievement) ជាដើម។

អច្ឆរិយៈក្នុងទស្សនៈផ្សេងៗ ដូចបានពោលមកហើយខាងលើនេះ ជាការសំដែងឲ្យដឹងថាអច្ឆរិយភាពរបស់ មនុស្សនោះ រមែងស្តែងដល់ព្រឹត្តិកម្ម ដែលកើតឡើង ដល់មនុស្សនោះ។ វាសរទៅដល់លក្ខណៈ ការដែលខុសប្រក្រតី វិស័យសាមញ្ញជនទូទៅ។ ប្រាកដការណ៍ដែលស្តែងចេញមក ដោយព្រឹត្តិការណ៍ខុសពីសាមញ្ញជននោះ ជាសញ្ញាល័ក្ខណ្ឌនៃបុគ្គលិកភាព អាចប្រាប់ឲ្យយើងដឹងថា អច្ឆរិយភាពបានគេចពួនទៅក្នុងដួងចិត្ត ដូចអាការស្តែងនៃភាពជាអ្នកតស៊ូយ៉ាងក្លៀវក្លា អាការស្តែងនៃភាពជាអ្នកតំកើងខ្លួន អាការស្តែងមេដឹកនាំ អាការស្តែងនៃភាព ជាអ្នកនយោបាយ ជាអ្នកនិពន្ធ ជាអ្នកទស្សនវិទូ ជាអ្នកសាសនា ឬ អាការស្តែងចេញមកដោយលក្ខណៈផ្សេងៗយ៉ាងណាក៏ដោយ ក៏ជាប្រតិកិរិយានៃអំណាចកំលាំងចិត្តក្នុងផ្លូវ ផ្តើមប្រែប្រួលទាំងអស់។

មនុស្សដែលមាននិស្ស័យប្លែកៗមានចិត្តគំនិតប្លែកពិស្តារ ប្រកាន់យកតែគោលគំនិត របស់ខ្លួនជាធំ មានសញ្ញាតិញាណក្នុងការលើកតំកើងខ្លួន មានលក្ខណៈចូលចិត្តធ្វើជាមេដឹកនាំគេជានិច្ចមានសេចក្តីក្លាហាន មានការពិនិត្យពិចារណាត្រឹមត្រូវ ចូលចិត្តសាងមនោភាពផ្សេងៗ លក្ខណៈទាំងនេះហាក់ដូចជាមាននៅនឹងមនុស្សសំខាន់ៗ ក្នុងពិភពលោកសឹងតែគ្រប់រូប ដូច ខេម៉ាលមេផ្តាច់ការទូរគី ក៏មានលក្ខណៈជាមេដឹកនាំមកតាំងតែនៅជាកុមារតូចៗ ចូលចិត្តតស៊ូនិង ផ្សងភ័យ។ លក្ខណៈ និង គុណសម្បត្តិទាំងនេះជាលក្ខណៈនិងគុណសម្បត្តិដ៏ប្រសើរសំរាប់មនុស្សជាលក្ខណៈដែលតែង តែបញ្ជាក់ឲ្យយើងដឹងថាគេត្រូវតែមានអនាគតនៃសេចក្តីរុងរឿងធំុថ្កើងក្នុងឆាកជីវិត ក្នុងផ្លូវណាមួយជាមិនខាន។ បើសិនគេមានការសិក្សានៅមិនទាន់បានជ្រៅជ្រះទេ គេក៏តោងខ្នះ

ខ្មែងស្រវាស្រទេញក្នុងការសិក្សាយ៉ាងពូកែយ៉ាងខ្លាំងក្លា។ តែបើគេមានការសិក្សាគ្រប់គ្រាន់ហើយ អនាគតរបស់គេក៏ត្រូវតែរុងរឿងថ្កុំថ្កើងត្រដែតឡើងក្នុងវង់សង្គមទូទៅ យ៉ាងពិតប្រាកដ។

រុស្សូ អ្នកទស្សនវិទូជាតិបារាំងសេស ជាអ្នកនិពន្ធរឿង សញ្ញាប្រជាគមន៍ "Social Contract" ក៏ជាអ្នកមាននិស្ស័យប្លែកៗ ក្រអឺតក្រទម ព្រហើន ចូលចិត្តធ្វើខ្លួនពិសេស ពិស្ដារប្លែកៗ ប្រហែលនឹងវិល្លិយាំភិត (បុត្រ) អតីតនាយករដ្ឋមន្ត្រីអង់គ្លេស ដែលនៅក្មេងបំផុតនៃបណ្ដាលនាយករដ្ឋមន្ត្រីដូចគ្នា។

(គេបានធ្វើជានាយករដ្ឋមន្ត្រីក្នុងកំឡុងអាយុ ២៤ឆ្នាំ) មាននិស្ស័យចូលចិត្តធ្វើខ្លួនជាអ្នកដឹកនាំគេតាំងតែនៅកុមារតូចៗ។ ជួនកាលគេធ្វើខ្លួនយ៉ាងសង្ហាអស្ចារ្យ ដំណើរស្វាហាប់ ជួនកាលស្ដែងកិរិយាក្រអឺតក្រទម ព្រហើនប្រកាន់ ឬកខ្ពស់។ ទាំងនេះជាសញ្ញាលក្ខ័ណ្ឌបញ្ជាក់ឲ្យឃើញដល់អច្ឆរិយៈក្នុងអនាគតរបស់គេ គឺកាលវិល្លិយាំភិត (បុត្រ) នៅជាកុមារតូចអាយុប្រហែល៧ឆ្នាំនោះ វិល្លិយាំភិត បានស្ដែងចេតនាក្នុងការដំណើរជីវិតជាអ្នកនយោបាយរបស់គេទុកថា "ខ្ញុំត្រូវតែធ្វើជាសមាជិករដ្ឋសភាសាមញ្ញ បែបបិតារបស់ខ្ញុំឲ្យទាល់តែបាន។

នេះជាសន្ទុះ ចិត្តមួយដែលចាំតែដុតភាពជាអច្ឆរិយបុគ្គលរបស់ វិល្លិយាំងភិត ឲ្យផ្ទុះឡើង។

## ៥. ប្រវត្តិសង្ខេបរបស់ វ៉ូលទែរ

លោក វ៉ូលទែរ អ្នកប្រាជ្ញជាតិបារាំងសេស គេក៏មានសញ្ញលក្ខ័ណ្ឌដែលសំដែងដល់សមត្ថភាពក្នុងការនិពន្ធរបស់គេមកតាំងតែនៅជាក្មេងតូចៗ។ វ៉ូលទែរ ច្រើនតែមានមនោភាពកំណត់ផែនគ្រោងការណ៍ផ្សេងៗ យ៉ាងត្រចះត្រចង់។ ខួរក្បាលរបស់គេផ្ទុកទៅដោយផែនការណ៍ផ្សេងៗ ទាំងធំទាំងតូច គេមានសេចក្ដីស្រវាស្រទេញយ៉ាងក្លៀវក្លា មានសេចក្ដីហានយ៉ាងមិនរំភើបញាប់ញ័រនូវហេតុការណ៍ដែលនឹងត្រូវកើតឡើង ដោយហេតុតែមានខួរក្បាលដ៏ត្រចះត្រចង់ទាំងផ្ទុកដោយគ្រោងការណ៍ផ្សេងៗដូច្នេះ។ គេទើបមានគោលគំនិត

មុតមាំក្នុងការនិពន្ធ គេចាប់ផ្តើមនិពន្ធរឿងផ្សេងៗយ៉ាងពិតប្រាកដ។

ក្នុងសម័យដែល វ៉ូលទែរ សំរេចការសិក្សាពីមហាវិទ្យាល័យ សីរក្រុងដ៏ ហើយគេក៏មានគោលដៅក្នុងការនិពន្ធយ៉ាងម៉ឺងម៉ាត់តែម្តង។ តែកិច្ចការនិពន្ធរបស់វ៉ូលទែរជាការផ្ទុយស្រឡះនឹងឧត្តមគតិនៃបិតារបស់គេ។ កាលបើការនិពន្ធ ជាការផ្ទុយនឹងឧត្តមគតិរបស់បិតាដូច្នោះហើយបិតារបស់គេទើបបញ្ជូន វ៉ូលទែរ ឲ្យទៅធ្វើជាបុគ្គលិកក្នុងស្ថានទូតបារាំងសេសនាប្រទេសហុល ឡងដ៏។ តែលោក វ៉ូលទែរ ត្រឡប់ទៅសាងស្នេហាផ្អែមល្ហែមនឹងស្ត្រីជាតិហុលឡងដ៏ម្នាក់ក្នុងប្រទេសហុលឡងដ៏។ បិតាបានឃើញហេតុការណ៍ដូច្នេះហើយកើតឡើង ទើបសូមឲ្យស្ថានទូតបញ្ជូន វ៉ូលទែរ ត្រឡប់មកប្រទេសរបស់ខ្លួនវិញ ហើយបិតាក៏បញ្ជូន វ៉ូលទែរ ឲ្យចូលធ្វើការក្នុងក្រុមអយ្យការនាក្រុងប៉ារីស។ នាក្រុងប៉ារីសនេះឯង មានអនាមិកជនក្លែងក្លាយសរសេរចុតហ្មាយ ថ្កោលទោសលោកប្រធានទីប្រឹក្សាព្រះរាជណាចក្រ សំរាប់ខ្លួន វ៉ូលទែរឯងក៏ត្រូវសង្ស័យថា ជាអ្នករួមគំនិតនឹងគេផង។ ដោយហេតុនេះឯង លោក វ៉ូលទែរ ទើបត្រូវនិរទេសឲ្យទៅនៅស្រុក ស៊ុល្លី ជាបណ្តោះអាសន្ន។ គ្រានេះហើយដែលហេតុការណ៍ផ្សេងៗបានរុញច្រានកំលាំងពលំនៃអំណាចចិត្ត ឬ ថាមពលនៃភាពជាអច្ឆរិយៈសន្សឹមៗបញ្ចាំរស្មីទៅក្នុងដួងចិត្តរបស់ វ៉ូលទែរ។ គេមានកំហឹងគុំគួនយ៉ាងខ្លាំង គេសាងចិន្តនាការយ៉ាងទូលំទូលាយ។ កំលាំងពលំនៃនៃអំណាចចិត្ត កំលាំងពលំនៃអំណាចសមាធិ កំលាំងពលំនៃមនោភាព កំលាំងពលំនៃសេចក្តីក្លាហាន កំលាំងពលំនៃសេចក្តីប្តូរផ្តាច់របស់គេក៏សន្សឹមៗ មានសមត្ថភាពនិងប្រសិទ្ធិភាព រឹតតែខ្លាំងក្លាឡើង។

វ៉ូលទែរ ត្រូវនិរទេសទៅមិនយូរប៉ុន្មាន ក៏បានទទួលអភ័យទោសហើយក៏បានចូលមកធ្វើការនាក្រុងប៉ារីសវិញ។ លុះតមកមិនយូរប៉ុន្មាន ក៏មានអ្នកប្រឌិតរឿងថ្កោលទោសទំនងដូចគ្រាមុនទៀត ជាហេតុឲ្យជាប់ជំពាក់ប្រឡាប់ដល់ ហ្វ្រង់ស័រ ម៉ារីអារុអេ ឬ វ៉ូលទែរ ដូចកាលដែលគេត្រូវនិរទេសនោះទៀត។ គេក៏ត្រូវចាត់ចូលក្នុងពួកអ្នករួមគំនិតក្នុងគ្រានេះហើយ គេក៏បានទទួលតំណែងជានាយកការិយាល័យបុគ្គលិកមន្ទីព្រះបន្ទម របស់ព្រះចៅ ហ្លួយទី១៥។

អំណើះតមកទៀត វ៉ូលទែរ ក៏បានទទួលកិត្តិយសលើកតំកើងជាច្រើន ពោលគឺរាជរដ្ឋាភិបាលក្នុងសម័យនោះ បានតែងតាំង វ៉ូលទែរ ជាកម្មការសមាគមវណ្ណកម្មរបស់ជាតិបារាំងសេសមួយតំណែងទៀត។ ចំណែកព្រះចៅ ហ្វ្រេដឺរីគ មហារាជនៃប្រុស្ស៊ី ក៏បានទ្រង់បបួល វ៉ូលទែរ ឲ្យទៅនៅក្នុងប្រទេសប្រុស្ស៊ីជាមួយព្រះអង្គ ទាំងទ្រង់ព្រះរាជទានតំណែងជានាយការិយាល័យបុគ្គលិក មន្ទីរព្រះបន្ទំរបស់ព្រះអង្គទៀតផង វ៉ូលទែរ ទើបបានទៅប្រុស្ស៊ី តាមព្រះរាជហឫទ័យនៅថ្ងៃទី៣០ កក្កដា គ.ស ១៧៥០។ ទាំងនេះក៏ព្រោះ ហ្វ្រេដឺរីគ មហារាជចង់ឲ្យវ៉ូលទែរ ជាគ្រូក្នុងការនិពន្ធរបស់ព្រះអង្គ ទោះជាយ៉ាងណាក៏ដោយ វ៉ូលទែរ ក៏នៅមិនបានយូរទេព្រោះ វ៉ូទែរ ជាមនុស្សមាននិស្ស័យមិនញញើមនរណាព្រហើនកោងកាច ប្រកាន់ខ្លួន។ ហើយប្រការសំខាន់បំផុតក៏គឺ ជាមនុស្សមានសេចក្តីស្រវាស្រទេញ យ៉ាងខ្លាំងក្លាមានសញ្ជាតិញាណនៃការអំនួត ទើបកើតខ្វែងគំនិតនឹងបុគ្គលសំខាន់ៗ របស់ព្រះចៅ ហ្វ្រេដឺរីគ មហារាជ (ប្រវត្តិហ្វ្រេដឺរីគ មហារាជ)។

វ៉ូលទែរ តោងធ្វើដំណើរត្រឡប់ ហើយការត្រឡប់ពីប្រទេសប្រុស្ស៊ីគ្រានេះ វ៉ូលទែរក៏មានរឿងក្តៅក្រហាយ និង គំនុំគមគួនជាច្រើន ធ្វើឲ្យសមត្ថភាពនៃអំណាចចិត្តរបស់គេរឹងប៉ឹងដូចបន្ទះនៃដែកថែប ធ្វើឲ្យជំនឿស៊ប់ក្នុង ខ្លួនគេរឹតតែមាំមួនឡើង។

ធ្វើឲ្យកំលាំងនៃអំណាចចិត្តរបស់គេ រឹតតែមានការតស៊ូខ្លាំងក្លាឡើង។ វ៉ូលទែរ បានតស៊ូប្រឹងប្រែងក្នុងការនិពន្ធរឿងរ៉ាវរបស់គេខ្លាំងក្លាជាងគ្រាណាៗទាំងអស់។ វិធីនិពន្ធរបស់គេពេញទៅដោយក្រឹត្យក្រមយ៉ាងមុះមុតក្នុងការដៀមដាម ឌឺដង ឆ្កឹសឆ្កៀល អ្នកនយោបាយនិងអ្នកសាសនា។ គេហ៊ានពិភាក្សាបញ្ហាផ្សេងៗ យ៉ាងមិនញញើតដល់ឥទ្ធិពលនរណាយ៉ាងណាទាំងអស់។ ទស្សនវិជ្ជារបស់គេ ពេញទៅដោយវោហារដ៏លែបខាយក្បោះក្បាយខ្លាំងក្លា និងមុះមុតជាទីបំផុត។ គ្រានោះហើយ ដែលកំលាំងពលំនៃអច្ឆរិយៈក្នុងការនិពន្ធរបស់គេបានបោះសន្ទុះដល់កំរិតខ្ពស់ យ៉ាងពេញទំហឹង។

របៀតអាយុ ៨៤ឆ្នាំ របស់ វ៉ូលទែរ វ៉ូលទែរគង់គ្រងអំណាចកំលាំងចិត្ត

ដូច្នេះរហូតដល់អវសាននៃជីវិតរបស់គេគឺក្នុង ថ្ងៃទី ៣០ ឧសភា គ.ស ១៧៧៩។

ជីវប្រវត្តិសង្ខេបៗរបស់វ៉ូលទេរ អ្នកប្រាជ្ញជាតិបារាំងសេស តាមដែលបានជំរាបមកនេះឲ្យ ឃើញច្បាស់ថា វ៉ូលទែរ ជាមនុស្សមាននិស្ស័យ និងបុគ្គលិកភាពប្លែកយ៉ាងម៉េចខ្លះ។ ពិសេសបំផុត គឺជាមនុស្សមានជំនឿស៊ប់ខ្ជាប់ក្នុងខ្លួនឯងយ៉ាងខ្លាំងក្លាបំផុត មានគោលដៅនៃជីវិតក្នុងការនិពន្ធយ៉ាងទៀងទាត់ពិតប្រាកដ រួមទាំងមាន សេចក្តីក្លាហាន អង់អាច មិនខ្លាចឥទ្ធិពលមកពីទិសទីណាទាំងអស់។ មន្តនៃអំណាចដួងចិត្តនេះឯង ជាថាមពលមួយដ៏វិសេសបំផុត ជួយរុញឲ្យភាពជាអច្ឆរិយបុគ្គលក្នុងពិភពលោកនេះ បានកើតមានឡើងដូចបានរៀបរាប់មកហើយខាងដើមនេះ។

## សូស្តី ចប់

**“មានតែសេចក្តីអត់ធន់ និងសេចក្តីព្យាយាម**
**មិនចេះឈប់ឈរតែប៉ុណ្ណោះទើបធ្វើឲ្យអ្នកទទួល**
**បាននូវការសម្រេចទាំងឡាយ គ្មានសត្វភ្នាន់ណា**
**ដែលរត់ចូលមកក្នុងមាត់សីហ្ធតោនោះទេ។”**